

រាជបណ្ឌិត្យសភាកម្ពុជា

ROYAL ACADEMY OF CAMBODIA

វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ផ្នែកគណិតវិទ្យានិងស្ថិតិ

# សិក្សាប្រភេទអាំងតេក្រាលមួយចំនួន ក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ

*(Study of Some Integral Types In Mathematics and Science)*

សិក្សារៀបរៀងដោយ  យឹម អាយុវឌ្ឍនៈវិជ្ជា

ភ្នំពេញ ២០១៦

# សិក្សាប្រភេទអាំងតេក្រាលមួយចំនួន ក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ

*(Study of Some Integral Types In Mathematics and Science)*


**គណៈកម្មការត្រួតពិនិត្យ**

**បណ្ឌិត អ៊ិប បុណ្ណា**

**បណ្ឌិត ហាក់ ធីរោ**

**សិក្សារៀបរៀង**

**យឹម អាយុវឌ្ឍនៈវិជ្ជា**



រក្សាសិទ្ធដោយរាជបណ្ឌិត្យសភាកម្ពុជា



ធ្វើនៅភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

# បុព្វកថា

សៀវភៅស្តីពី « សិក្សាប្រភេទអាំងតេក្រាលមួយចំនួនក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ » នេះ ជាសៀវភៅដែលលោក យឹម អាយុវឌ្ឍនៈវិជ្ជា បានធ្វើការស្រាវជ្រាវ បកប្រែ ដោះស្រាយអាំងតេក្រាលតាមប្រភេទ រៀបរៀងនិងចងក្រងឡើង ដើម្បីទុកជាស្នាដៃថ្មីមួយទៀតសម្រាប់សិស្ស និស្សិតនិងអ្នកស្រាវជ្រាវគណិតវិទ្យានិងវិទ្យាសាស្ត្រ។

កន្លងមកស្នាដៃស្រាវជ្រាវដែលត្រូវបានបោះពុម្ពជាភាសាខ្មែរដែលទាក់ទងទៅនឹងការយល់ដឹងអំពីប្រភេទអាំងតេក្រាលនិងវិធីសាស្ត្រដោះស្រាយវាគឺមានតិចតួចណាស់។

ដូចនេះ សៀវភៅស្តីពី « សិក្សាប្រភេទអាំងតេក្រាលមួយចំនួនក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ » ជាស្នាដៃថ្មីមួយដែលមានសារៈប្រយោជន៍ឆ្លើយតបទៅនឹងតម្រូវការជាចាំបាច់ខាងលើនេះ។ ខ្លឹមសារនៃសៀវភៅនេះបានបង្ហាញជូនលោកអ្នកអាននិងអ្នកស្រាវជ្រាវនូវវិធីសាស្ត្រដោះស្រាយទៅតាមប្រភេទអាំងតេក្រាលមួយចំនួននិងរបៀបប្រើប្រាស់រូបមន្តអាំងតេក្រាល។ ខ្ញុំសង្ឃឹមថា លោកអ្នកអាននិងអ្នកស្រាវជ្រាវចេះគណនាអាំងតេក្រាលមិនកំណត់និងកំណត់ដោយប្រើប្រាស់រូបមន្តអាំងតេក្រាលទាំងនេះទៅជាភាពងាយស្រួល។ ជាងនេះទៅទៀត ខ្ញុំសង្ឃឹមថាលោក យឹម អាយុវឌ្ឍនៈវិជ្ជា ប្រាកដជាខិតខំស្រាវជ្រាវបន្តទៀត ដើម្បីចែករំលែកបទពិសោធន៍និងចំណេះដឹងដល់យើងទាំងអស់គ្នានិងអ្នកស្រាវជ្រាវជំនាន់ក្រោយ។

ជាមួយគ្នានេះ ក្នុងនាមរាជបណ្ឌិត្យសភាកម្ពុជា នាងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ សម្តេចតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលតែងតែគាំទ្រដល់បេសកកម្មរបស់រាជបណ្ឌិត្យសភាកម្ពុជា ចំពោះកិច្ចការស្រាវជ្រាវនិងការបោះពុម្ពផ្សាយ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

បណ្ឌិតសភាចារ្យ ខ្លួត ធីដា

# ចំណាប់អារម្មណ៍
# របស់ឯកឧត្តមបណ្ឌិត អ៊ាប មុណ្ណា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដោយបានឃើញនូវខ្លឹមសារនៃសៀវភៅស្ដីពី « **សិក្សាប្រភេទអាំងតេក្រាលមួយចំនួនក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ** » របស់លោក យឹម អាយុវឌ្ឍនៈវិជ្ជា ដែលជាអ្នកវិទ្យាសាស្ត្រផ្នែកគណិតវិទ្យានិងស្ថិតិនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

សៀវភៅនេះ ជាស្នាដៃថ្មីមួយដែលមានប្រយោជន៍សម្រាប់សិស្ស និស្សិតនិងអ្នកស្រាវជ្រាវក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ។ ខ្លឹមសារនៃសៀវភៅនេះបានបង្ហាញជូនលោកអ្នកអាននិងអ្នកស្រាវជ្រាវនូវវិធីសាស្ត្រដោះស្រាយទៅតាមប្រភេទអាំងតេក្រាលមួយចំនួននិងរបៀបប្រើប្រាស់រូបមន្តអាំងតេក្រាល។ ជាងនេះទៅទៀត ខ្ញុំសង្ឃឹមថាលោក យឹម អាយុវឌ្ឍនៈវិជ្ជា ប្រាកដជាខិតខំស្រាវជ្រាវបន្តទៅទៀត ដើម្បីចែករំលែកបទពិសោធន៍និងចំណេះដឹងដល់យើងទាំងអស់គ្នានិងអ្នកស្រាវជ្រាវជំនាន់ក្រោយបន្ថែមទៀត។

ជាមួយនឹងវិភាគទានដ៏ថ្លៃថ្លាក្នុងវិស័យគណិតវិទ្យារបស់លោក យឹម អាយុវឌ្ឍនៈវិជ្ជា ការសិក្សាស្រាវជ្រាវនេះបានផ្ដល់ចំណេះដឹងខាងទ្រឹស្ដីនិងគណនាក្នុងការអភិវឌ្ឍវិស័យវិទ្យាសាស្ត្របែមទៀត។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦

**ប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា**

បណ្ឌិត.អ៊ាប_មុណ្ណា

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមបណ្ឌិត **អ៊ាប បុណ្ណា** ប្រធានវិទ្យាស្ថានវិទ្យាសាស្រ្តនិងបច្ចេកវិទ្យា និង បណ្ឌិត **ហាក់ ធីរោ** អនុប្រធានវិទ្យាស្ថានវិទ្យាសាស្រ្តនិងបច្ចេកវិទ្យាដែលបានជួយត្រួតពិនិត្យ កែសម្រួលនិងអនុម័តស្នាដៃនេះឱ្យបានចេញជារូបរាងឡើង។

ខ្ញុំសូមថ្លែងអំណរគុណជាពន្លឹកចំពោះបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឯកឧត្តម **លី សុធីរ័ត្ន** អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា និងសហការីទាំងអស់ដែលបានជួយរៀបចំកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ស្នាដៃនេះ។

សូមថ្លែងអំណរគុណចំពោះសាស្រ្តាចារ្យ បណ្ឌិតនិងទស្សនវិទូគណិតវិទ្យាទាំងឡាយដែលបានខិតខំស្រាវជ្រាវទ្រឹស្តីឬរូបមន្តគណិតវិទ្យា ហើយបានចងក្រងជាសៀវភៅយ៉ាងច្រើនទុកឯកសារស្រាវជ្រាវដល់កូនចៅជំនាន់ក្រោយ។

**អ្នកសិក្សារៀបរៀង**

**យឹម អាយុវឌ្ឍនៈវិជ្ជា**

**តំណាងផ្នែកគណិតវិទ្យានិងស្ថិតិ**

# មាតិកា

ទំព័រ


សេចក្តីថ្លែងអំណរគុណ .......... i

មាតិកា .......... ii

អារម្ភកថា .......... viii

សេចក្តីផ្តើម .......... ix

**ជំពូកទី១ ទ្រឹស្តីទាក់ទង .......... ១**

១.១ព្រីមីទីវ .......... ១

១.១.១ និយមន័យ .......... ១

១.១.២ ទ្រឹស្តីបទ .......... ២

១.២ អាំងតេក្រាលមិនកំណត់ .......... ២

១.២.១ និយមន័យ .......... ២

១.២.២ រូបមន្តគ្រឹះនៃអាំងតេក្រាលមិនកំណត់ .......... ២

១.២.៣ រូបមន្តទាយនៃអាំងតេក្រាលមិនកំណត់ .......... ៤

១.៣ អាំងតេក្រាលកំណត់ .......... ៦

១.៣.១ និយមន័យ .......... ៦

១.៣.២ រូបមន្តគ្រឹះនៃអាំងតេក្រាលកំណត់ .......... ៩

១.៣.៣ ទ្រឹស្តីបទ Newton-Leibnitz .......... ១១

១.៤ វិធីប្តូរអថេរ .......... ១៤

១.៥ វិធីអាំងតេក្រាលដោយផ្នែក .......... ១៧

១.៦ អាំងតេក្រាល Improper .......... ១៨

**ជំពូកទី២ ប្រភេទអាំងតេក្រាលនៃអនុគមន៍សនិទាន .......... ២៣**

២.១ ការបំបែកអនុគមន៍សនិទានក្នុង $\mathbb{R}$ .......... ២៣

២.២ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{1}{(ax+b)^n}dx$ ....................២៧
២.៣ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{dx}{x^2 \pm a^2}$ ............................២៨
២.៤ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{dx}{ax^2+bx+c}$ ....................៣០
២.៥ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{(a_1x+b_1)\,dx}{ax^2+bx+c}$ ..................៣៣
២.៦ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{dx}{(x^2+a^2)^m}$ ........................៣៧
២.៧ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{dx}{(x^2-a^2)^m}$ .......................៣៩
២.៨ អនុវត្តន៍នៃការបំបែកអនុគមន៍សនិទាន..........................................៤១
**ជំពូកទី៣ ប្រភេទអាំងតេក្រាលនៃអនុគមន៍អសនិទាន** ....................**៤៤**
៣.១ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt[n]{ax+b}}dx$ ....................៤៤
៣.២ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt[n]{ax+b}\,dx$ ...................៤៥
៣.៣ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt[n]{(ax+b)^m}\,dx$ .............៤៦
៣.៤ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt{k-x^2}}dx$ ....................៤៧
៣.៥ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt{x^2+k}}dx$ ....................៤៨
៣.៦ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt{x^2-k}}dx$ ....................៥០
៣.៧ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt{k-x^2}\,dx$ ....................៥១
៣.៨ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt{x^2+k}\,dx$ .....................៥៣

៣.៩ អាំងតេក្រាលនៃអនុគមន៍អសនិទាននរាង $\int\sqrt{x^2-k}\,dx$ ..................... ៥៥

៣.១០ អាំងតេក្រាលនៃអនុគមន៍អសនិទាននរាង $\int(\alpha x+\beta)\sqrt{ax+b}\,dx$ .. ៥៧

៣.១១ អាំងតេក្រាលនៃអនុគមន៍អសនិទាននរាង $\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}$ ...... ៥៧

៣.១២ អាំងតេក្រាលនៃអនុគមន៍អសនិទាននរាង $\int\frac{dx}{\sqrt{ax^2+bx+c}}$ ........... ៥៩

៣.១៣ អាំងតេក្រាលនៃអនុគមន៍អសនិទាននរាង $\int\sqrt{ax^2+bx+c}\,dx$ ...... ៦៣

៣.១៤ អាំងតេក្រាលនៃអនុគមន៍អសនិទាននរាង $\int\frac{(\alpha x+\beta)dx}{\sqrt{ax^2+bx+c}}$ ............ ៦៦

**ជំពូកទី៤ ប្រភេទអាំងតេក្រាលមានអនុគមន៍អិចស្ប៉ូណង់ស្យែល.៦៩**

៤.១ អាំងតេក្រាលនៃអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int a^{\alpha x+\beta}\,dx$ ........ ៦៩

៤.២ អាំងតេក្រាលមានអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int\frac{dx}{p+a^{\alpha x}}$ ...... ៧៣

៤.៣ អាំងតេក្រាលមានអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int\frac{dx}{(p+a^{\alpha x})^2}$ . ៧៤

៤.៤ អាំងតេក្រាលមានអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int\frac{a^{2\alpha x}\,dx}{p+qa^{\alpha x}}$ .... ៧៧

៤.៥ អាំងតេក្រាលមានអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}$ ៧៩

៤.៦ អាំងតេក្រាលនៃអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int_{-\infty}^{+\infty}e^{-ax^2}dx$ ....... ៨១

៤.៧ អាំងតេក្រាលនៃអនុគមន៍អិចស្ប៉ូណង់ស្យែលរាង $\int_{-\infty}^{+\infty}e^{-(ax^2+bx+c)}dx$ ៨៣

**ជំពូកទី៥ ប្រភេទអាំងតេក្រាលមានអនុគមន៍លោការីត.................... ៨៦**

៥.១ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a(px+q)\,dx$ ..............៨៦

៥.២ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a|px+q|\,dx$ .............៨៩

៥.៣ អាំងតេក្រាលមានអនុគមន៍លោការីតរាង $\int \log_a^2(px+q)\,dx$ ...........៩២

៥.៤ អាំងតេក្រាលមានអនុគមន៍លោការីតរាង $\int \log_a^2|px+q|\,dx$ ...........៩៤

៥.៥ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a(x^2+b^2)\,dx$ ..............៩៦

៥.៦ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a(x^2-b^2)\,dx$ ..............៩៨

**ជំពូកទី៦ ប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ ..............១០៣**
**ស្វៀលនិងអនុគមន៍ស្វ័យគុណ**

៦.១ ប្រភេទអាំងតេក្រាលមានរាង $\int x e^{\alpha x}\,dx$ និង $\int x a^{\alpha x}\,dx$ .................១០៣

៦.២ ប្រភេទអាំងតេក្រាលមានរាង $\int x^2 e^{\alpha x}\,dx$ និង $\int x^2 a^{\alpha x}\,dx$ .............១០៥

៦.៣ ប្រភេទអាំងតេក្រាលមានរាង $\int x^n e^{\alpha x}\,dx$ ..........................................១០៨

៦.៤ ប្រភេទអាំងតេក្រាលមានរាង $\int x^{-1} e^{\alpha x}\,dx$ ..........................................១០៩

៦.៥ ប្រភេទអាំងតេក្រាលមានរាង $\int x e^{\alpha x^2}\,dx$ និង $\int x a^{\alpha x^2}\,dx$ ...............១១២

៦.៦ ប្រភេទអាំងតេក្រាលមានរាង $\int x^{-2} e^{-\alpha x^2}\,dx$ .......................................១១៤

៦.៧ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x e^{-a(x-b)^2}\,dx$ .................................១១៥

៦.៨ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x e^{-ax^2+bx} dx$ ..................................១១៧

៦.៩ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x^2 e^{-ax^2} dx$ ......................................១១៨

៦.១០ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x^2 e^{-ax^2-bx} dx$ .............................១២០

៦.១១ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x^3 e^{-ax^2+bx} dx$ .............................១២២

**ជំពូកទី៧ ប្រភេទអាំងតេក្រាលមានអនុគមន៍លោការីត និងអនុគមន៍ស្វ័យគុណ** ..................**១២៥**

៧.១ ប្រភេទអាំងតេក្រាលមានរាង $\int x^m \ln x\, dx$ ...........................................១២៥

៧.២ ប្រភេទអាំងតេក្រាលមានរាង $\int \frac{(\ln(ax))^n}{x} dx$ ...................................១២៧

៧.៣ ប្រភេទអាំងតេក្រាលមានរាង $\int \frac{\ln(ax)^n}{x} dx$ .......................................១២៩

៧.៤ ប្រភេទអាំងតេក្រាលមានរាង $\int \frac{\ln(ax)}{x^m} dx$ .........................................១៣១

៧.៥ ប្រភេទអាំងតេក្រាលមានរាង $\int \frac{dx}{x[\ln(ax)]^n}$ .....................................១៣៣

៧.៦ ប្រភេទអាំងតេក្រាលមានរាង $\int \frac{dx}{x^m \ln x}$ ..............................................១៣៥

៧.៧ ប្រភេទអាំងតេក្រាលមានរាង $\int x^m (\ln x)^n dx$ ....................................១៣៧

៧.៨ ប្រភេទអាំងតេក្រាលមានរាង $\int \frac{x^m}{(\ln x)^n} dx$ .........................................១៤១

**ជំពូកទី៨ ប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីក** .................**១៤៥**

៨.១ អនុគមន៍អ៊ីពែបូលីក ..................................................................................... ១៤៥
៨.១.១ និយមន័យ ..................................................................................... ១៤៥
៨.១.២ លក្ខណៈ ..................................................................................... ១៤៦
៨.២ ប្រភេទអាំងតេក្រាលមានរាង $\int \sinh(a x)\, dx$ ..................................... ១៤៩
៨.៣ ប្រភេទអាំងតេក្រាលមានរាង $\int \cosh(a x)\, dx$ ..................................... ១៥១
៨.៤ ប្រភេទអាំងតេក្រាលមានរាង $\int \sinh^2(a x)\, dx$ ..................................... ១៥២
៨.៥ ប្រភេទអាំងតេក្រាលមានរាង $\int \cosh^2(a x)\, dx$ ..................................... ១៥៥
៨.៦ ប្រភេទអាំងតេក្រាលមានរាង $\int \tanh(a x)\, dx$ ..................................... ១៥៧
៨.៧ ប្រភេទអាំងតេក្រាលមានរាង $\int \coth(a x)\, dx$ ..................................... ១៥៩
៨.៨ ប្រភេទអាំងតេក្រាលមានរាង $\int \sec h(a x)\, dx$ ..................................... ១៦១
៨.៩ ប្រភេទអាំងតេក្រាលមានរាង $\int \cos ech(a x)\, dx$ ..................................... ១៦៤
៨.១០ ប្រភេទអាំងតេក្រាលមានរាង $\int \frac{dx}{\cosh^2(a x)}$ ..................................... ១៦៧
៨.១១ ប្រភេទអាំងតេក្រាលមានរាង $\int \frac{dx}{\sinh^2(a x)}$ ..................................... ១៦៩
ការសន្និដ្ឋាន ..................................................................................... ១៧៣
ឯកសារយោង ..................................................................................... ១៧៦

# អារម្ភកថា

លោកអ្នកសិក្សាគណិតវិទ្យាអាចដឹងហើយថា អាំងតេក្រាលជាផ្នែកមួយនៃគណិតវិទ្យាដែលមានការស្មុគស្មាញទាំងទ្រឹស្តីនិងគណនាដល់អ្នកសិក្សាវា ប៉ុន្តែផ្នែកមួយនេះគេមិនអាចដកវាចេញបានឡើយសម្រាប់អ្នកសិក្សានិងស្រាវជ្រាវក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ។ ម្យ៉ាងទៀត នៅក្នុងប្រទេសកម្ពុជា ឯកសារឬសៀវភៅដែលត្រូវបានបោះពុម្ពជាភាសាខ្មែរហើយដែលទាក់ទងទៅនឹងការយល់ដឹងអំពីប្រភេទអាំងតេក្រាលនិងវិធីសាស្ត្រដោះស្រាយវាគឺមានតិចតួចបំផុត។

ដោយសារមូលហេតុនេះហើយទើបខ្ញុំបានកំណត់យកប្រធានបទមួយមកបកស្រាយគឺ « **សិក្សាប្រភេទអាំងតេក្រាលមួយចំនួនក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ** »។ សៀវភៅនេះត្រូវបានស្រាវជ្រាវ បកប្រែ ដោះស្រាយអាំងតេក្រាលតាមប្រភេទនិងរៀបរៀងឡើង ដើម្បីទុកជាឯកសារស្រាវជ្រាវនិងជាចំណេះដឹងមួយសម្រាប់សិស្ស និស្សិត និង អ្នកស្រាវជ្រាវគណិតវិទ្យាដែលមានបញ្ហាខ្លះៗទាក់ទងនឹងប្រធានបទនេះ។

សៀវភៅនេះរួមមាន៨ជំពូក។ ជំពូកទី១សិក្សាអំពីទ្រឹស្តីទាក់ទង ជំពូកទី២សិក្សាអំពីប្រភេទអាំងតេក្រាលនៃអនុគមន៍សនិទាន ជំពូកទី៣សិក្សាអំពីប្រភេទអាំងតេក្រាលនៃអនុគមន៍អសនិទាន ជំពូកទី៤សិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល ជំពូកទី៥សិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍លោការីត ជំពូកទី៦សិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ ជំពូកទី៧សិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណ និងជំពូកទី៨សិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីក។

សរុបសេចក្តីមក ខ្ញុំសង្ឃឹមនិងជឿជាក់ថា មិត្តអ្នកអាន និង អ្នកសិក្សាស្រាវជ្រាវគណិតវិទ្យាពិតជាទទួលបាននូវផលប្រយោជន៍និងជោគជ័យក្នុងកិច្ចការសិក្សាជាមិនខានពីសៀវភៅនេះ។

**រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦**

**អ្នកសិក្សារៀបរៀង**

**យឹម អាយុវឌ្ឍនៈវិជ្ជា**

**តំណាងផ្នែកគណិតវិទ្យានិងស្ថិតិ**

# សេចក្តីផ្តើម

បច្ចុប្បន្ននេះ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកាន់តែរីកចម្រើនទៅមុខឥតឈប់ឈរមែនក៏នៅតែពឹងផ្អែកលើរូបមន្តឬវិធីសាស្ត្រនានានៃជំនាញគណិតវិទ្យា។ ក្នុងគណិតវិទ្យាមានប្រភេទនិងវិធីសាស្ត្រជាច្រើន ប៉ុន្តែខ្ញុំលើកយកតែប្រភេទនិងវិធីសាស្ត្រគណនាមួយផ្នែកប៉ុណ្ណោះក្នុងគណិតវិទ្យាគណនាមកសិក្សាស្រាវជ្រាវនិងរៀបរៀង។ ម្យ៉ាងទៀត សិស្សនិងនិស្សិតភាគច្រើននៅក្នុងប្រទេសយើងចូលចិត្តរៀនគណិតវិទ្យាគណនាជាងខាងទ្រឹស្តី ហេតុនេះ ខ្ញុំនឹងលើកយកប្រធានបទមួយស្តីអំពី << **សិក្សាប្រភេទអាំងតេក្រាលមួយចំនួនក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ** >>។ តើគេមានប្រភេទអាំងតេក្រាលអ្វីខ្លះដែលអាចគណនាបាន ? តើគេអាចដោះស្រាយប្រភេទអាំងតេក្រាលទាំងនេះតាមវិធីសាស្ត្រណា ? ដើម្បីឆ្លើយតបនឹងសំណួរទាំងពីរនេះ ខ្ញុំនឹងបង្ហាញនៅក្នុងជំពូកទី២ ទីបីនិងបន្តបន្ទាប់។ ជាដំបូង យើងនឹងសិក្សាទ្រឹស្តីដែលទាក់ទងនឹងប្រធានបទរបស់យើងក្នុងជំពូកទី១មុនសិនស្តីអំពីទ្រឹស្តីទាក់ទង។

# ជំពូកទី១

# ទ្រឹស្ដីទាក់ទង

## ( Related Theories )

នៅក្នុងជំពូកទី១នេះ យើងនឹងសិក្សានូវនិយមន័យនៃព្រីមីទីវនិងអាំងតេក្រាល ហើយបន្ទាប់មក យើងនឹងសិក្សារូបមន្ត លក្ខណៈ និងវិធីខ្លះៗនៃការគណនាអាំងតេក្រាលដូចតទៅៈ

## ១.១ ព្រីមីទីវ

### ១.១.១ និយមន័យ

អនុគមន៍ $H(x)$ ជាព្រីមីទីវនៃអនុគមន៍ $h(x)$ កាលណា $H'(x) = h(x)$ ចំពោះគ្រប់តម្លៃ $x$ ក្នុងដែនកំណត់នៃអនុគមន៍ $h(x)$ ។[១]

**ឧទាហរណ៍ទី១** គេមានអនុគមន៍ $G(x) = 2x^3 - 8e^x$ និង $H(x) = 2x^3 - 8e^x + 2016$ កំណត់លើ $\mathbb{R}$។ តើ $G(x)$ និង $H(x)$ ជាព្រីមីទីវនៃអនុគមន៍ $g(x) = 6x^2 - 8e^x$ ឬទេ?

ដំណោះស្រាយ

យើងមាន $G(x) = 2x^3 - 8e^x$ និង $H(x) = 2x^3 - 8e^x + 2016$ នាំឱ្យ

$G'(x) = 6x^2 - 8e^x = g(x)$ និង $H'(x) = 6x^2 - 8e^x = g(x)$ ។

ដូចនេះ $G(x)$ និង $H(x)$ ជាព្រីមីទីវនៃ $g(x)$ ។

**ឧទាហរណ៍ទី២** គេមាន $F(x) = x^5\left(3e^x + 2\right)$ និង $f(x) = x^4\left(15e^x + 10 + 3xe^x\right)$ កំណត់លើ $\mathbb{R}$ ។ បង្ហាញថា $F(x)$ ជាព្រីមីទីវនៃ $f(x)$។

ដំណោះស្រាយ

យើងមាន $F(x) = x^5\left(3e^x + 2\right),\ \forall x \in \mathbb{R}$ នាំឱ្យ

$$F'(x) = (x^5)'(3e^x + 2) + x^5(3e^x + 2)'$$
$$= 5x^4(3e^x + 2) + x^5(3e^x)$$
$$= 15x^4e^x + 10x^4 + 3x^5e^x = x^4\left(15e^x + 10 + 3xe^x\right) = f(x)$$

---

[១] យឹម អាយុវឌ្ឍនៈវិជ្ជា “ *អាំងតេក្រាលមិនកំណត់* ” ទំព័រទី៨ ឆ្នាំ១៩៩៧

$= x^4\left(15e^x + 10 + 3xe^x\right) = f(x)$ ។

ដោយ $F'(x) = f(x)$ , $\forall x \in \mathbb{R}$ ដូចនេះ $F(x)$ ជាព្រីមីទីវនៃ $f(x)$ ។

**ឧទាហរណ៍ទី៣** គេមាន $G(x) = xe^{-3x^2}$ និង $g(x) = \left(1-6x^2\right)e^{-3x^2}$ កំណត់លើ $\mathbb{R}$ ។ បង្ហាញថា $G(x)$ ជាព្រីមីទីវនៃ $g(x)$ ។

ដំណោះស្រាយ

យើងមាន $G(x) = xe^{-3x^2}$ , $\forall x \in \mathbb{R}$

នាំឱ្យ $G'(x) = (x)'e^{-3x^2} + x(e^{-3x^2})'$

$= (1)e^{-3x^2} + x(-3x^2)'e^{-3x^2}$

$= e^{-3x^2} + x(-6x)e^{-3x^2}$

$= \left(1-6x^2\right)e^{-3x^2} = g(x)$ ។

ដោយ $G'(x) = g(x)$ , $\forall x \in \mathbb{R}$ ដូចនេះ $G(x)$ ជាព្រីមីទីវនៃ $g(x)$ ។

### ១.១.២ ទ្រឹស្តីបទ

គេឱ្យ $H(x)$ ជាព្រីមីទីវមួយនៃអនុគមន៍ $h(x)$ នោះព្រីមីទីវទាំងអស់នៃ $h(x)$ មានទម្រង់ទូទៅ $H(x) + c$ ដែល $c$ ជាចំនួនពិតថេរ។

សម្រាយបញ្ជាក់

យើងមាន $(H(x) + c)' = H'(x) = h(x)$ ពីព្រោះ $c$ ជាចំនួនពិតថេរ និង $H(x)$ ជាព្រីមីទីវនៃ $h(x)$ នាំឱ្យព្រីមីទីវទាំងអស់នៃ $h(x)$ មានទម្រង់ទូទៅ $H(x) + c$ ( ពិត )។

## ១.២ អាំងតេក្រាលមិនកំណត់

### ១.២.១ និយមន័យ

គេមាន $H(x)$ ជាព្រីមីទីវនៃអនុគមន៍ $h(x)$ ។ អាំងតេក្រាលមិនកំណត់នៃ $h(x)$ កំណត់ដោយ $\int h(x)\,dx = H(x) + c$ ដែល $c$ ជាចំនួនពិតថេរ។

### ១.២.២ រូបមន្តគ្រឹះនៃអាំងតេក្រាលមិនកំណត់

យើងមានរូបមន្តគ្រឹះនៃអាំងតេក្រាលមិនកំណត់សំខាន់ពីរគឺ៖[២]

---

[២] យឹម អាយុវឌ្ឍនៈវិជ្ជា “ *អាំងតេក្រាលមិនកំណត់* ” ទំព័រទី១០ ឆ្នាំ១៩៩៧

១. $\int[g(x)\pm h(x)]\,dx=\int g(x)\,dx\pm\int h(x)\,dx$

២. $\int \alpha g(x)\,dx=\alpha\int g(x)\,dx\ ;\ \forall\alpha\in\mathbb{R}$ ។

**ឧទាហរណ៍ទី៤** គណនាអាំងតេក្រាល៖ $\int \lambda\,dx\ ,\ \int x^{\lambda}\,dx\ ,\int e^{x}dx\ ,\int b^{x}dx\ ,$ $\int\frac{dx}{x^2-a^2}$ និង $\int\frac{dx}{x^2+a^2}$ ដែល $\lambda\in\mathbb{R}, b>0, b\neq 1,\ a\neq 0$ ។

ដំណោះស្រាយ

យើងមាន៖

. $(\lambda x+c)'=\lambda$ នាំឱ្យ $\int\lambda\,dx=\lambda x+c$ ។

. $\left(\frac{1}{\lambda+1}x^{\lambda+1}+c\right)'=\frac{\lambda+1}{\lambda+1}x^{(\lambda+1)-1}=x^{\lambda},\ \lambda\neq-1$

និង $\left(\ln|x|+c\right)'=\frac{1}{x}=x^{-1},\ \lambda=-1,\ x\neq 0$

នាំឱ្យ $\int x^{\lambda}\,dx=\frac{1}{\lambda+1}x^{\lambda+1}+c\ ,\ \lambda\neq-1$

និងចំពោះ $\lambda=-1,\ \int x^{-1}\,dx=\int\frac{dx}{x}=\ln|x|+c$ ។

. $(e^x+c)'=e^x$ នាំឱ្យ $\int e^x\,dx=e^x+c$ ។

. $\left(\frac{b^x}{\ln b}+c\right)'=\frac{b^x\ln b}{\ln b}=b^x$ នាំឱ្យ $\int b^x\,dx=\frac{b^x}{\ln b}+c$ ។

. $\left(\frac{1}{2a}\ln\left|\frac{x-a}{x+a}\right|+c\right)'=\left(\frac{1}{2a}\ln|x-a|-\frac{1}{2a}\ln|x+a|+c\right)'$

$$=\frac{1}{2a}\cdot\frac{1}{x-a}-\frac{1}{2a}\cdot\frac{1}{x+a}=\frac{x+a-x+a}{2a(x-a)(x+a)}$$

$$=\frac{2a}{2a(x^2-a^2)}=\frac{1}{x^2-a^2}$$

នាំឱ្យ $\int\frac{dx}{x^2-a^2}=\frac{1}{2a}\ln\left|\frac{x-a}{x+a}\right|+c$ ។

$$.\ \left(\frac{1}{a}\arctan\frac{x}{a}+c\right)' = \frac{\left(\frac{x}{a}\right)'}{a\left(1+\left(\frac{x}{a}\right)^2\right)} = \frac{1}{a^2\left(1+\frac{x^2}{a^2}\right)} = \frac{1}{x^2+a^2}$$

នាំឱ្យ $\int \frac{dx}{x^2+a^2} = \frac{1}{a}\arctan\frac{x}{a}+c$ ។

### ១.២.៣ រូបមន្តងាយនៃអាំងតេក្រាលមិនកំណត់

ពីឧទាហរណ៍ទី៤ យើងបានរូបមន្តងាយៗមួយចំនួននៃអាំងតេក្រាលមិនកំណត់ដូចតទៅ៖

១. $\int \lambda\, dx = \lambda x + c \quad (1.1)$

២. $\int x^{\lambda}\, dx = \frac{1}{\lambda+1}x^{\lambda+1}+c,\ \lambda \neq -1 \quad (1.2)$

៣. $\int x^{-1} dx = \int \frac{dx}{x} = \ln|x| + c \quad (1.3)$

៤. $\int e^x\, dx = e^x + c \quad (1.4)$

៥. $\int b^x\, dx = \frac{b^x}{\ln b}+c\ ,\ b>0\ ,\ b\neq 1 \quad (1.5)$

៦. $\int \frac{dx}{x^2-b^2} = \frac{1}{2b}\ln\left|\frac{x-b}{x+b}\right|+c \quad (1.6)$

៧. $\int \frac{dx}{x^2+a^2} = \frac{1}{a}\arctan\frac{x}{a}+c = \frac{1}{a}\tan^{-1}\frac{x}{a}+c\ ,\ a\neq 0 \quad (1.7)$

យើងក៏អាចកំណត់បាននូវរូបមន្តដទៃទៀតដូចជា៖[៣]

៨. $\int \frac{dx}{x^2} = \int x^{-2}\, dx = -\frac{1}{x}+c \quad (1.8)$

៩. $\int \sin x\, dx = -\cos x + c \quad (1.9)$

---

[៣] ឃឹម អាយុវឌ្ឍនៈវិជ្ជា " *អាំងតេក្រាលមិនកំណត់* " ទំព័រទី១១ ឆ្នាំ១៩៩៧

១០. $\int \cos x\,\mathrm{dx} = \sin x + \mathrm{c}$ (1.10)

១១. $\int \dfrac{\mathrm{dx}}{\cos^2 x} = \tan x + c$ (1.11)

១២. $\int \dfrac{\mathrm{dx}}{\sin^2 x} = -\cot x + c$ (1.12)

**ឧទាហរណ៍ទី៥** គណនាអាំងតេក្រាលមិនកំណត់

$\int(-7x^7 - 4x^4 + 2x^2 - 9)\,\mathrm{dx}$ , $\int\dfrac{3x^2+2x+5}{x}\mathrm{dx}$ និង $\int(7\mathrm{e}^x - 8\cdot 5^x + 2\mathrm{x}^3)\,\mathrm{dx}$ ។

ដំណោះស្រាយ

តាមរូបមន្តក្នុងផ្នែក១.២.៣ យើងបាន៖

$$\int(-7x^7 - 4x^4 + 2x^2 - 9)\,\mathrm{dx} = -7\int x^7\,\mathrm{dx} - 4\int x^4\,\mathrm{dx} + 2\int x^2\,\mathrm{dx} - \int 9\,\mathrm{dx}$$

$$= -7\cdot\frac{x^{7+1}}{7+1} - 4\cdot\frac{x^{4+1}}{4+1} + 2\cdot\frac{x^{2+1}}{2+1} - 9x + c$$

$$= -\frac{7x^8}{8} - \frac{4x^5}{5} + \frac{2x^3}{3} - 9x + c$$

$$\int\frac{3x^2+2x+5}{x}\mathrm{dx} = \int\left(\frac{3x^2}{x} + \frac{2x}{x} + \frac{5}{x}\right)\mathrm{d}x = \int\left(3x + 2 + \frac{5}{x}\right)\mathrm{d}x$$

$$= 3\int x\,\mathrm{d}x + 2\int \mathrm{d}x + 5\int\frac{\mathrm{d}x}{x} = \frac{3x^2}{2} + 2x + 5\ln|x| + c$$

និង $\int(7\mathrm{e}^x - 8\cdot 5^x + 2\mathrm{x}^3)\,\mathrm{dx} = 7\int \mathrm{e}^x\,\mathrm{d}x - 8\int 5^x\,\mathrm{d}x + 2\int x^3\,\mathrm{d}x$

$$= 7e^x - 8\cdot\frac{5^x}{\ln 5} + 2\cdot\frac{x^4}{4} + c$$

$$= 7e^x - \frac{8}{\ln 5}5^x + \frac{x^4}{2} + c$$ ។

**ឧទាហរណ៍ទី៦** គណនាអាំងតេក្រាលមិនកំណត់ $\int\dfrac{\mathrm{dy}}{y^2-25}$ និង $\int\dfrac{\mathrm{dy}}{y^2+2018}$ ។

ដំណោះស្រាយ

តាមរូបមន្តអាំងតេក្រាលមិនកំណត់ក្នុងផ្នែក១.២.៣ យើងបាន៖

$$\int \frac{\mathrm{dy}}{y^2-25}=\int \frac{\mathrm{dy}}{\mathrm{y}^2-5^2}=\frac{1}{2(5)}\ln\left|\frac{y-5}{y+5}\right|+c=\frac{1}{10}\ln\left|\frac{y-5}{y+5}\right|+c$$

និង $\int \frac{\mathrm{dy}}{y^2+2018}=\int \frac{\mathrm{dy}}{y^2+(\sqrt{2018})^2}=\frac{1}{\sqrt{2018}}\tan^{-1}\left(\frac{y}{\sqrt{2018}}\right)+c$ ។

# ១.៣ អាំងតេក្រាលកំណត់

## ១.៣.១ និយមន័យ

គេឱ្យអនុគមន៍ $y=g(x)$ កំណត់លើចន្លោះ $[a, b]$។ ចែកចន្លោះ $[a, b]$ ជា $n$ ចន្លោះដោយចំណុច $a=x_0<x_1<x_2<\cdots<x_{i-1}<x_i<\cdots<x_n=b$ ។ នៅលើចន្លោះនីមួយៗ $[x_{i-1}, x_i]$ គេជ្រើសរើសយកចំណុច $\xi_i$ ហើយគេរកប្រវែងនៃចន្លោះនោះ $\Delta x_i=x_i-x_{i-1}$ ។ នាំឱ្យផលបូកអាំងតេក្រាលនៃ $g(x)$ លើចន្លោះ $[a, b]$ ជាផលបូកមានរាង៖

$$S_n=g(\xi_1)\Delta x_1+g(\xi_2)\Delta x_2+\cdots+g(\xi_n)\Delta x_n=\sum_{i=1}^{n} g(\xi_i)\Delta x_i$$ ។

អាំងតេក្រាលកំណត់នៃអនុគមន៍ $y=g(x)$ លើចន្លោះ $[a, b]$ ជាលីមីតនៃផលបូកអាំងតេក្រាលដោយមានលក្ខខណ្ឌប្រវែងដែលធំបំផុតក្នុងចន្លោះខិតទៅរកសូន្យ គឺថា

$$\int_a^b g(x)\,dx=\lim_{d\to 0}\sum_{i=1}^{n} g(\xi_i)\Delta x_i$$

ដែល $d=\max\limits_{1\le i\le n}\Delta x_i$ ។

បើ $S_n$ មានលីមីតកំណត់ $S$ មិនទាក់ទងនឹងការចែកអង្កត់និងការជ្រើសរើសចំណុច $\xi_i$ នោះគេថា $S$ ជាអាំងតេក្រាលនៃអនុគមន៍ $g(x)$ លើចន្លោះ $[a, b]$ ហើយគេសរសេរជា

$$\int_a^b g(x)\,dx=\lim_{d\to 0}\sum_{i=1}^{n} g(\xi_i)\Delta x_i=\lim_{n\to+\infty} S_n=S \quad (1.13)$$ ។[៤]

គេថា $g(x)$ មានអាំងតេក្រាលលើចន្លោះ $[a, b]$។ អាំងតេក្រាល $\int_a^b g(x)\,dx$ ទាក់ទងតែអនុគមន៍ $g(x)$ និងគោល $a$, $b$ ហើយមិនទាក់ទងនឹងអថេរអាំងតេក្រាលទេគឺ

$$\int_a^b g(x)dx=\int_a^b g(t)dt$$ ។

[៤] យឹម អាយុវឌ្ឍនៈវិជ្ជា " *អាំងតេក្រាលកំណត់* " ទំព័រទី១ ឆ្នាំ១៩៩៧




យើងនឹងគណនាអាំងតេក្រាលកំណត់តាមនិយមន័យដែលបានបង្ហាញនូវឧទាហរណ៍ទី៧ ទី៨និងទី៩ដូចតទៅ៖

**ឧទាហរណ៍ទី៧** គណនា $\int_3^6 25dx$ ។

ដំណោះស្រាយ

អនុគមន៍ $g(x)=25$ ជាប់លើ $[3, 6]$ នាំឱ្យវាមានអាំងតេក្រាលលើចន្លោះនោះ។ ចែកចន្លោះ $[3, 6]$ ជា $n$ ចន្លោះស្មើៗគ្នាដោយចំណុច $x_i = a + i\cdot\frac{b-a}{n} = 3 + i\cdot\frac{6-3}{n} = 3 + i\cdot\frac{3}{n}$ និង $\Delta x_i = x_i - x_{i-1} = \frac{b-a}{n} = \frac{3}{n}$ ហើយជ្រើសរើសចំណុច $\xi_i$ លើចន្លោះ $[x_{i-1}, x_i]$ ដែល $\xi_i = x_i$ នាំឱ្យ $g(\xi_i)=25$ យើងបាន៖

$$S_n = \sum_{i=1}^{n} g(\xi_i)\Delta x_i = 25\sum_{i=1}^{n}\Delta x_i = 25\sum_{i=1}^{n}\frac{3}{n} = 25\cdot\frac{3}{n}\cdot n = 75$$

និង $\int_3^6 25dx = \lim_{n\to+\infty} S_n = 75$ ។

**ឧទាហរណ៍ទី៨** គណនា $\int_0^1 -5x^2dx$ ។

ដំណោះស្រាយ

អនុគមន៍ $g(x) = -5x^2$ ជាប់លើ $[0, 1]$ នាំឱ្យវាមានអាំងតេក្រាលលើ $[0, 1]$។

នាំឱ្យ $\int_0^1 -5x^2dx = \lim_{d\to 0}\sum_{i=1}^{n} g(\xi_i)\Delta x_i$ ដែល $d = \max_{1\le i\le n}\Delta x_i$ ។ ក្នុងនោះលីមីតមានដោយមិនទាក់ទងនឹងការចែកចន្លោះ $[0, 1]$ និងការជ្រើសរើសចំណុច $\xi_i$ ទេ។ គេចែកចន្លោះ $[0, 1]$ ជា $n$ ចន្លោះតូចៗស្មើគ្នានិងជ្រើសរើស $\xi_i = x_i$ , $i\in\{1, 2, ..., n\}$ ។ គេបាន៖

$\Delta x_i = x_i - x_{i-1} = \frac{1}{n}$ ; $i \in \{1, 2, ..., n\}$ ; $\xi_i = x_i = \frac{i}{n} \Rightarrow g(\xi_i) = -5\xi_i^{\,2} = \frac{-5i^2}{n^2}$ និង

$$S_n = \sum_{i=1}^{n} g(\xi_i)\cdot\Delta x_i = \sum_{i=1}^{n}\frac{-5i^2}{n^2}\cdot\frac{1}{n} = -\frac{5}{n^3}\sum_{i=1}^{n} i^2$$

$$= -\frac{5}{n^3}\cdot\frac{n(n+1)(2n+1)}{6} = -\frac{5(n+1)(2n+1)}{6n^2} = -\frac{5}{6}\left(1+\frac{1}{n}\right)\left(2+\frac{1}{n}\right)$$ ។

ដោយចែកជាចន្លោះស្មើៗគ្នា នាំឱ្យ $\Delta x_i \to 0$ នោះ $n \to +\infty$ និង

$$\int_0^1 -5x^2 dx = \lim_{n\to+\infty} S_n = -\frac{5}{6}\lim_{n\to+\infty}\left(1+\frac{1}{n}\right)\left(2+\frac{1}{n}\right)$$

$$= -\frac{5}{6}(1+0)(2+0) = -\frac{5}{3}$$ ។

**ឧទាហរណ៍ទី៩** គណនា $\int_a^b e^x\,dx \quad (0 < a < b)$ ។

ដំណោះស្រាយ

អនុគមន៍ $\text{g(x)} = e^x$ ជាប់លើ $[a, b]$ នាំឱ្យវាមានអាំងតេក្រាលលើ $[a, b]$។

នាំឱ្យ $\int_a^b e^x\,dx = \lim_{d\to 0}\sum_{i=1}^{n} g(\xi_i)\Delta x_i$ ដែល $d = \max_{1\le i\le n}\Delta x_i$ ។ ក្នុងនោះលីមីតមានដោយមិនទាក់ទង នឹងការចែកចន្លោះ $[a, b]$ និងការជ្រើសរើសចំណុច $\xi_i$ ទេ។ គេចែកចន្លោះ $[a, b]$ ជា $n$ ចន្លោះតូចៗស្មើគ្នានិងជ្រើសរើស $\xi_i = x_i$ , $i \in \{1, 2, ..., n\}$ ។

គេបាន៖ $\Delta x_i = x_i - x_{i-1} = \frac{b-a}{n}$ ; $i \in \{1, 2, ..., n\}$ ;

$$\xi_i = x_i = a + i\cdot\frac{b-a}{n} \Rightarrow g(\xi_i) = e^{\xi_i} = e^{a+i\cdot\frac{b-a}{n}}$$

និង $S_n = \sum_{i=1}^{n} g(\xi_i)\cdot\Delta x_i = \sum_{i=1}^{n} e^{a+i\cdot\frac{b-a}{n}}\cdot\frac{b-a}{n}$

$$= \frac{(b-a)e^a}{n}\sum_{i=1}^{n} e^{i\cdot\frac{b-a}{n}} = \frac{(b-a)e^a}{n}\cdot e^{\frac{b-a}{n}}\cdot\frac{1-\left(e^{\frac{b-a}{n}}\right)^n}{1-e^{\frac{b-a}{n}}}$$

$$=\frac{(b-a)\left(e^a-e^b\right)}{n}\cdot\frac{e^{\frac{b-a}{n}}}{1-e^{\frac{b-a}{n}}}=\left(e^b-e^a\right)e^{\frac{b-a}{n}}\cdot\frac{\left(\frac{b-a}{n}\right)}{e^{\frac{b-a}{n}}-1}$$ ។

ដោយចែកជាចន្លោះស្មើៗគ្នា នាំឱ្យ $\Delta x_i \to 0$ នោះ $n\to+\infty$ និង

$$\int_a^b e^x\,dx=\lim_{n\to+\infty}S_n=\left(e^b-e^a\right)\lim_{n\to+\infty}e^{\frac{b-a}{n}}\cdot\frac{\left(\frac{b-a}{n}\right)}{e^{\frac{b-a}{n}}-1}=e^b-e^a$$

ពីព្រោះ $\lim\limits_{n\to+\infty}e^{\frac{b-a}{n}}=e^0=1$ និងតាង $x=\frac{b-a}{n}$ នាំឱ្យ

$$\lim_{n\to+\infty}\frac{\left(\frac{b-a}{n}\right)}{e^{\frac{b-a}{n}}-1}=\lim_{x\to0}\frac{x}{e^x-1}=\lim_{x\to0}\frac{1}{\frac{e^x-1}{x}}=\frac{1}{1}=1$$ ។

ដូចនេះ យើងបាន $\int_a^b e^x\,dx=e^b-e^a$ ។

### ១.៣.២ រូបមន្តគ្រឹះនៃអាំងតេក្រាលកំណត់[៥]

គេឱ្យ $f(x)$ និង $g(x)$ ជាអនុគមន៍ជាប់លើ $[a,b]$ នោះគេបាន៖

១. $\int_a^b[f(x)\pm g(x)]dx=\int_a^b f(x)dx\pm\int_a^b g(x)dx$ (1.14)

២. $\int_a^b\lambda g(x)dx=\lambda\int_a^b g(x)dx\,;\ \forall\lambda\in\mathbb{R}$ (1.15)

៣. $\int_a^b g(x)\,dx=\int_a^c g(x)\,dx+\int_c^b g(x)\,dx\,;\ a<c<b$ (1.16)

៤. $\int_a^a g(x)\,dx=0$ (1.17)

៥. $\int_a^b g(x)dx=-\int_b^a g(x)dx$ (1.18)

៦. បើ $g(x)\ge0$ លើ $[a,b]$ នោះគេបាន $\int_a^b g(x)\,dx\ge0$ (1.19)

---

៥ យឹម អាយុវឌ្ឍនៈវិជ្ជា “ *អាំងតេក្រាលកំណត់* ” ទំព័រទី២និងទី៣ ឆ្នាំ១៩៩៧

## វិបាក

៧. ចំពោះ $\forall x \in [a, b];\ g(x) \le f(x)$ នាំឱ្យ $\int_a^b g(x)\,dx \le \int_a^b f(x)\,dx$ (1.20)

៨. $\left|\int_a^b g(x)\,dx\right| \le \int_a^b |g(x)|\,dx$ (1.21)

**ឧទាហរណ៍ទី១០** ចូរប្រៀបធៀបអាំងតេក្រាល $\int_0^1 x^2 \sin^2 x\,dx$ និង $\int_0^1 x \sin^2 x\,dx$ ។

ដំណោះស្រាយ

ចំពោះ $\forall x \in [0, 1]$ យើងបាន $0 \le x^2 \le x \le 1$ និង $\sin^2 x = (\sin x)^2 \ge 0$

នាំឱ្យ $x^2 \sin^2 x \le x \sin^2 x$ ចំពោះ $\forall x \in [0, 1]$ ។

នោះតាមរូបមន្ត (1.20) ដូចនេះ $\int_0^1 x^2 \sin^2 x\,dx \le \int_0^1 x \sin^2 x\,dx$ ។

**ឧទាហរណ៍ទី១១** ស្រាយបញ្ជាក់ថា $0 < \int_1^{\sqrt{3}} \frac{e^{-x}\sin x}{x^2}\,dx < \frac{1}{e}$ ។

ដំណោះស្រាយ

យើងមាន $0 < 1 \le x \le \sqrt{3} < \pi$

នាំឱ្យ $x^2 > 0,\ 0 < \sin x < 1$ និង $e = e^1 \le e^x$ ។

នាំឱ្យ $\frac{1}{x^2} > 0,\ e^{-x} = \frac{1}{e^x} \le \frac{1}{e}$ និង $0 < \frac{e^{-x}\sin x}{x^2} \le \frac{1}{e x^2}$ ចំពោះគ្រប់ $x \in [1, \sqrt{3}]$ ។

នោះតាមរូបមន្ត (1.20) នាំឱ្យ

$$0 < \int_1^{\sqrt{3}} \frac{e^{-x}\sin x}{x^2}\,dx \le \int_1^{\sqrt{3}} \frac{1}{e x^2}\,dx = \frac{1}{e}\int_1^{\sqrt{3}} x^{-2}\,dx$$

សមមូល $0 < \int_1^{\sqrt{3}} \frac{e^{-x}\sin x}{x^2}\,dx \le \frac{1}{e}\cdot\left.\frac{x^{-1}}{(-1)}\right|_1^{\sqrt{3}}$

នាំឱ្យ $0 < \int_1^{\sqrt{3}} \frac{e^{-x}\sin x}{x^2}\,dx \le \frac{-1}{e}\left(\frac{1}{\sqrt{3}} - 1\right) = \frac{1}{e}\left(1 - \frac{1}{\sqrt{3}}\right) < \frac{1}{e}$ (ពិត)។

ដូចនេះ យើងបាន $0<\int_{1}^{\sqrt{3}}\frac{e^{-x}\sin x}{x^2}dx<\frac{1}{e}$ ។

### **១.៣.៣ ទ្រឹស្តីបទ Newton – Leibnitz**

**ទ្រឹស្តីបទ** បើ $g(x)$ ជាអនុគមន៍ជាប់លើ $[a,b]$ និង $G(x)$ ជាព្រីមីទីវនៃ $g(x)$ លើ $[a,b]$ នោះគេបាន

$$\int_a^b g(x)\,dx = G(x)\Big|_a^b = G(b)-G(a)\ \ (1.22)$$ ។

សម្រាយបញ្ជាក់

ដោយ $g(x)$ ជាអនុគមន៍ជាប់លើ $[a,b]$ នាំឱ្យវាមានអាំងតេក្រាលលើ $[a,b]$ ។

បើគេមានព្រីមីទីវ $G(x)$ នៃ $g(x)$ លើ $[a,b]$ នាំឱ្យ

$$G'(x)=\frac{d}{dx}\left[\int_a^x g(t)\,dt\right]=g(x)$$ ចំពោះគ្រប់ $x\in[a,b]$

នាំឱ្យ $\int_a^x g(t)\,dt = G(x)+c$ ( $c$ ជាចំនួនពិតថេរ)។

បើគេឱ្យ $x=a$ នាំឱ្យ $\int_a^a g(t)\,dt = G(a)+c$

សមមូល $0=G(a)+c$ សមមូល $c=-G(a)$ ; $\forall x\in[a,b]$

នាំឱ្យ $\int_a^x g(t)\,dt = G(x)-G(a)$ ។

បើគេឱ្យ $x=b$ នោះគេបាន $\int_a^b g(x)dx = G(b)-G(a)$ ពិត ។

**ឧទាហរណ៍ទី១២** គណនាអាំងតេក្រាលកំណត់៖ $\int_3^5 4x^4dx$ និង $\int_0^{\pi/4}\sin t\,dt$ ។

ដំណោះស្រាយ

យើងមាន $G(x)=\frac{4}{5}x^5+c$ ជាព្រីមីទីវនៃ $g(x)=4x^4$ លើ $[3,5]$ នាំឱ្យ

$$\int_3^5 4x^4dx = (\frac{4}{5}x^5+c)\Big|_3^5 = \left(\frac{4}{5}\cdot 5^5+c\right)-\left(\frac{4}{5}\cdot 3^5+c\right)$$

$$=\frac{11528}{5}=2305.6$$ ។

ម្យ៉ាងទៀត យើងមាន $H(t)=-\cos t+c$ ជាព្រីមីទីវនៃ $h(t)=\sin t$ លើ $[0,\pi/4]$ នាំឱ្យ

$$\int_0^{\pi/4}\sin t\,dt=(-\cos t+c)\Big|_0^{\pi/4}=\left(-\cos\frac{\pi}{4}+c\right)-\left(-\cos 0+c\right)$$

$$=-\frac{\sqrt{2}}{2}+1=\frac{2-\sqrt{2}}{2}\approx 0.2928$$ ។

**ឧទាហរណ៍ទី១៣** តាមរូបមន្តក្នុងផ្នែក១.២.៣ យើងអាចគណនាអាំងតេក្រាលកំណត់មួយចំនួនដូចតទៅ៖

១. $\int_a^b \lambda\,dx=\lambda x\Big|_a^b=\lambda(b-a)$

២. $\int_a^b x^n\,dx=\frac{x^{n+1}}{n+1}\Big|_a^b=\frac{b^{n+1}-a^{n+1}}{n+1}\ ,\ n\neq -1$

៣. $\int_1^a \frac{dx}{x}=\ln|x|\Big|_1^a=\ln|a|-\ln|1|=\ln|a|$

៤. $\int_0^a e^y\,dy=e^y\Big|_0^a=e^a-e^0=e^a-1$

៥. $\int_a^x 8^y\,dy=\frac{8^y}{\ln 8}\Big|_a^x=\frac{8^x}{\ln 8}-\frac{8^a}{\ln 8}=\frac{8^x-8^a}{\ln 8}$ ។

**ឧទាហរណ៍ទី១៤** គណនា $\int_0^a(-8e^t+6\cos t)\,dt$ ។

ដំណោះស្រាយ

យើងមាន $G(t)=-8e^t+6\sin t$ ជាព្រីមីទីវមួយនៃ $g(t)=-8e^t+6\cos t$ លើ $[0,a]$។

នាំឱ្យ $\int_0^a(-8e^t+6\cos t)\,dt=(-8e^t+6\sin t)\Big|_0^a$

$$=\left(-8e^a+6\sin a\right)-\left(-8e^0+6\sin 0\right)$$

$$=-8e^a+6\sin a+8$$

ឬម្យ៉ាងទៀត យើងក៏អាចគណនាវាតាមរូបមន្តអាំងតេក្រាលគឺ

$$\int_0^a(-8e^t+6\cos t)\,dt=-8\int_0^a e^t\,dt+6\int_0^a\cos t\,dt$$

$$=-8e^a+6\sin a+8$$ ។

**ឧទាហរណ៍ទី១៥** គណនា $\int_2^3 \frac{(3t-4)^2}{t}dt$ ។

ដំណោះស្រាយ

តាមរូបមន្តអាំងតេក្រាល យើងបាន៖

$$\int_2^3 \frac{(3t-4)^2}{t}dt = \int_2^3 \frac{(3t)^2-2(3t)(4)+4^2}{t}dt$$

$$= \int_2^3 \frac{9t^2-24t+16}{t}dt = \int_2^3 \left(9t-24+\frac{16}{t}\right)dt$$

$$= \left(9\cdot\frac{t^2}{2}-24t+16\ln|t|\right)\Big|_2^3$$

$$= \left(9\cdot\frac{3^2}{2}-24\cdot 3+16\ln|3|\right)-\left(9\cdot\frac{2^2}{2}-24\cdot 2+16\ln|2|\right)$$

**ឧទាហរណ៍ទី១៦** គណនា $\int_{-4}^4 |3x+7|\,dx$ ។

ដំណោះស្រាយ

ពីនិយមន័យនៃតម្លៃដាច់ខាត យើងអាចសរសេរ

$$|3x+7| = \begin{cases} -(3x+7), & x < -\frac{7}{3} \\ 3x+7, & x \geq -\frac{7}{3} \end{cases}$$

និងប្រើរូបមន្តអាំងតេក្រាលកំណត់ យើងបាន៖

$$\int_{-4}^4 |3x+7|\,dx = -\int_{-4}^{-7/3}(3x+7)\,dx + \int_{-7/3}^4 (3x+7)\,dx$$

$$= -\left(\frac{3}{2}x^2+7x\right)\Big|_{-4}^{-7/3} + \left(\frac{3}{2}x^2+7x\right)\Big|_{-7/3}^{4}$$

$$= -\left(\frac{3}{2}\left(\frac{-7}{3}\right)^2+7\left(\frac{-7}{3}\right)\right)+\left(\frac{3}{2}(-4)^2+7(-4)\right)$$

$$+\left(\frac{3}{2}(4)^2+7(4)\right)-\left(\frac{3}{2}\left(\frac{-7}{3}\right)^2+7\left(\frac{-7}{3}\right)\right)$$

$$=\frac{49}{3}+48=\frac{193}{3}=64.3333$$ ។

**ឧទាហរណ៍ទី១៧** គណនា $\int_{-2}^{5} t|t-1|\,dt$ និង $\int_{-2}^{5} t^3|t-1|\,dt$ ។

ដំណោះស្រាយ

ពីនិយមន័យនៃតម្លៃដាច់ខាត យើងមាន

$$|t-1| = \begin{cases} -(t-1), & t<1 \\ t-1, & t\geq 1 \end{cases}$$

និងប្រើរូបមន្តអាំងតេក្រាលកំណត់ យើងបាន៖

$$\int_{-2}^{5} t|t-1|\,dt=\int_{-2}^{1} t[-(t-1)]dt+\int_{1}^{5} t(t-1)\,dt$$

$$=-\int_{-2}^{1}(t^2-t)\,dt+\int_{1}^{5}(t^2-t)\,dt$$

$$=-\left(\frac{t^3}{3}-\frac{t^2}{2}\right)\Bigg|_{-2}^{1}+\left(\frac{t^3}{3}-\frac{t^2}{2}\right)\Bigg|_{1}^{5}$$

$$=-\left(\frac{1^3}{3}-\frac{1^2}{2}\right)+\left(\frac{(-2)^3}{3}-\frac{(-2)^2}{2}\right)+\left(\frac{5^3}{3}-\frac{5^2}{2}\right)-\left(\frac{1^3}{3}-\frac{1^2}{2}\right)$$

$$=\frac{149}{6}\approx 24.8333$$

និង $\int_{-2}^{5} t^3|t-1|\,dt=\int_{-2}^{1} t^3[-(t-1)]\,dt+\int_{1}^{5} t^3\,(t-1)\,dt$

$$=-\int_{-2}^{1}(t^4-t^3)\,dt+\int_{1}^{5}(t^4-t^3)\,dt$$

$$=-\left(\frac{t^5}{5}-\frac{t^4}{4}\right)\Bigg|_{-2}^{1}+\left(\frac{t^5}{5}-\frac{t^4}{4}\right)\Bigg|_{1}^{5}$$

$$=-\left(\frac{1^5}{5}-\frac{1^4}{4}\right)+\left(\frac{(-2)^5}{5}-\frac{(-2)^4}{4}\right)+\left(\frac{5^5}{5}-\frac{5^4}{4}\right)-\left(\frac{1^5}{5}-\frac{1^4}{4}\right)$$

$$=\frac{9169}{20}=458.45$$ ។

## ១.៤ វិធីប្តូរអថេរ

ឧបមាថា គេមានអាំងតេក្រាលមិនកំណត់ $\mathrm{J}=\int f[h(x)]\,h'(x)\,\mathrm{dx}$ ។

តាង $\mathrm{v}=h(x)$ នោះ $\mathrm{dv}=h'(x)dx$ ។ យើងបាន៖

$$\mathrm{J}=\int f[h(x)]\,h'(x)\,\mathrm{dx}=\int f(\mathrm{v})\,\mathrm{dv}=F(\mathrm{v})+c_1=F(h(x))+c_1 \quad (1.23)$$

ដែល F(v) ជាព្រីមីទីវនៃ f(v) និង $c_1$ ជាចំនួនពិតថេរ។ ស្រដៀងគ្នាដែរ យើងក៏មានទ្រឹស្តីនៅក្នុងអាំងតេក្រាលកំណត់ដូចខាងក្រោម។

គេមានអនុគមន៍ $f(x)$ ជាប់លើចន្លោះ $[a,b]$។ បើអនុគមន៍ $x=h(t)$ មានដេរីវេ $h'(t)$ ជាប់លើចន្លោះ $[\alpha,\beta]$ ដែល $h([\alpha,\beta])\subseteq[a,b]$ ហើយ $h(\alpha)=a$ និង $h(\beta)=b$ នោះអាំងតេក្រាល

$$\int_a^b f(x)dx=\int_\alpha^\beta f[h(t)]h'(t)dt \qquad (1.24)$$ (រូបមន្តប្តូរអថេរ)[៦]។

សម្រាយបញ្ជាក់

គេដឹងថា $F[h(t)]$ ជាព្រីមីទីវនៃ $f[h(t)]\,h'(t)$។ តាមរូបមន្ត Newton-Leibnitz គេបាន

$$\int_\alpha^\beta f[h(t)]\,h'(t)\,dt=F[h(t)]\Big|_\alpha^\beta=F[h(\beta)]-F[h(\alpha)]$$

$$=F(b)-F(a)=\int_a^b f(x)\,dx$$ (ពិត) ។

**ឧទាហរណ៍ទី១៨** គណនាអាំងតេក្រាល $\int e^{\alpha x}\mathrm{d}x$ និង $\int a^{\alpha x}\mathrm{d}x$ ។

ដំណោះស្រាយ

យើងអាចគណនាអាំងតេក្រាល $\int e^{\alpha x}\mathrm{d}x$ តាមពីរករណីនៃ $\alpha$ គឺ $\alpha=0$ និង $\alpha\neq 0$ ។

- ករណី $\alpha=0$ នាំឱ្យ

$$\int e^{\alpha x}\mathrm{d}x=\int e^{0\cdot x}\mathrm{d}x=\int \mathrm{d}x=x+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $\alpha\neq 0$ យើងប្រើវិធីប្តូរអថេរ គឺតាង $u=\alpha x$ នាំឱ្យ $du=\alpha\,dx \Leftrightarrow dx=\dfrac{du}{\alpha}$ ។ នាំឱ្យ

$$\int e^{\alpha x}\mathrm{d}x=\int e^u\frac{du}{\alpha}=\frac{1}{\alpha}\int e^u\,\mathrm{du}=\frac{1}{\alpha}e^u+c=\frac{1}{\alpha}e^{\alpha x}+c \qquad (1.25)$$

[៦] យឹម អាយុវឌ្ឍនៈវិជ្ជា “ *អាំងតេក្រាលកំណត់* ” ទំព័រទី៤១និងទី៤២ ឆ្នាំ១៩៩៧

ដែល $c$ ជាចំនួនពិតថេរ។

យើងទាញបាន

$$\int a^{\alpha x}\,dx=\int\left(e^{\ln a}\right)^{\alpha x}dx=\int e^{(\alpha\ln a)x}dx=\frac{e^{(\alpha\ln a)x}}{(\alpha\ln a)}+c=\frac{a^{\alpha x}}{\alpha\ln a}+c\quad(1.26)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0\,,a\neq 1$ ។

**ឧទាហរណ៍ទី១៩** គណនាអាំងតេក្រាល $\int\frac{q}{\alpha x+\beta}\,dx\ (\alpha\neq 0)$ និង $\int_0^1\frac{e^x}{4e^x+3}dx$ ។

ដំណោះស្រាយ

តាង $v=\alpha x+\beta$ នោះ $dv=\alpha\,dx\Leftrightarrow dx=\frac{1}{\alpha}\,dv$ ។

យើងបាន

$$\int\frac{q}{\alpha x+\beta}\,dx=\int\frac{q}{v}\cdot\frac{1}{\alpha}dv=\frac{q}{\alpha}\int\frac{dv}{v}$$

$$=\frac{q}{\alpha}\ln|v|+c=\frac{q}{\alpha}\ln|\alpha x+\beta|+c\qquad(1.27)$$

ដែល $c$ ជាចំនួនពិតថេរ

និង $$\int_0^1\frac{e^x}{4e^x+3}dx=\int_0^1\frac{d(e^x)}{4e^x+3}=\frac{1}{4}\ln\left|4e^x+3\right|\Big|_0^1$$

$$=\frac{1}{4}\left(\ln(4e+3)-\ln 7\right)\approx 0.1710$$ ។

**ឧទាហរណ៍ទី២០** គណនាអាំងតេក្រាល $I=\int e^x\sqrt{(3e^x+5)^9}\,dx$ ។

ដំណោះស្រាយ

តាង $v=3e^x+5$ នោះ $dv=3e^x\,dx\ \Leftrightarrow\ e^x\,dx=\frac{1}{3}\,dv$ ។

យើងបាន៖

$$I=\int e^x\sqrt{(3e^x+5)^9}\,dx=\int\sqrt{v^9}\cdot\frac{1}{3}dv=\frac{1}{3}\int v^{\frac{9}{2}}\,dv$$

$$=\frac{1}{3}\cdot\frac{v^{\frac{9}{2}+1}}{(\frac{9}{2}+1)}+c=\frac{1}{3}\cdot\frac{v^{\frac{11}{2}}}{(11/2)}+c=\frac{2}{33}\left(3e^x+5\right)^{\frac{11}{2}}+c$$ ។

## ១.៥ វិធីអាំងតេក្រាលដោយផ្នែក

បើ $u=u(x)$ និង $v=v(x)$ ជាអនុគមន៍មានឌីផេរ៉ង់ស្យែលលើចន្លោះ $[a,b]$ នោះ

គេបានអាំងតេក្រាល $\int_a^b u\,dv=uv\Big|_a^b-\int_a^b v\,du$ (1.28) (រូបមន្តអាំងតេក្រាលដោយផ្នែក)[៧] ។

សម្រាយបញ្ជាក់

ដោយ $u=u(x)$ និង $v=v(x)$ ជាអនុគមន៍មានឌីផេរ៉ង់ស្យែលលើចន្លោះ $[a,b]$ នោះយើងបាន $d(uv)=u\,dv+v\,du$ ។

នាំឱ្យ $\int_a^b d(uv)=\int_a^b u\,dv+\int_a^b v\,du$

តែ $\int_a^b d(uv)=uv\Big|_a^b$

នាំឱ្យ $\int_a^b u\,dv=uv\Big|_a^b-\int_a^b v\,du$ ពិត ។

**ឧទាហរណ៍ទី២១** គណនា $I=\int_0^2 x e^{2x}\,dx$ ។

ដំណោះស្រាយ

យើងយក $u=x$ នាំឱ្យ $du=dx$

និង $dv=e^{2x}\,dx$ នាំឱ្យ $v=\int dv=\int e^{2x}\,dx=\frac{e^{2x}}{2\ln e}=\frac{e^{2x}}{2}$ ។

នាំឱ្យ $I=\int_0^2 x e^{2x}\,dx=\int_0^2 u\,dv=uv\Big|_0^2-\int_0^2 v\,du$

$$=\frac{x e^{2x}}{2}\Big|_0^2-\frac{1}{2}\int_0^2 e^{2x}\,dx=\frac{2e^4}{2}-0-\frac{1}{2}\cdot\frac{e^{2x}}{2}\Big|_0^2$$

**ឧទាហរណ៍ទី២២** គណនា $J=\int\frac{x\ln x\,dx}{(x^2+1)^2}$ ។

[៧] យឹម អាយុវឌ្ឍនៈវិជ្ជា " *អាំងតេក្រាលកំណត់* " ទំព័រទី៤៣ ឆ្នាំ១៩៩៧

ដំណោះស្រាយ

យើងយក $u=\ln x$ នាំឱ្យ $du=\dfrac{dx}{x}$

និង $dv=\dfrac{x\,dx}{(x^2+1)^2}$ នាំឱ្យ $v=\int dv=\int\dfrac{x\,dx}{(x^2+1)^2}=\dfrac{1}{2}\int(x^2+1)^{-2}\,d(x^2+1)$

$$=\frac{1}{2}\cdot\frac{(x^2+1)^{-1}}{(-1)}=-\frac{1}{2(x^2+1)}$$ ។

នាំឱ្យ $\mathrm{J}=\int\dfrac{x\ln x\,dx}{(x^2+1)^2}=\int u\,dv=uv-\int v\,du$

$$=-\frac{\ln x}{2(x^2+1)}+\frac{1}{2}\int\frac{dx}{x(x^2+1)}$$

$$=-\frac{\ln x}{2(x^2+1)}+\frac{1}{2}\int\frac{(x^2+1)-x^2}{x(x^2+1)}\,dx$$

$$=-\frac{\ln x}{2(x^2+1)}+\frac{1}{2}\int\frac{1}{x}dx-\frac{1}{2}\int\frac{x}{(x^2+1)}dx$$

$$=-\frac{\ln x}{2(x^2+1)}+\frac{1}{2}\ln|x|-\frac{1}{4}\int\frac{d(x^2+1)}{(x^2+1)}$$

$$=-\frac{\ln x}{2(x^2+1)}+\frac{1}{2}\ln|x|-\frac{1}{4}\ln(x^2+1)+c$$ ។

## ១.៦ អាំងតេក្រាល Improper [៨]

ក្នុងផ្នែកនេះ យើងនឹងសិក្សាអាំងតេក្រាល Improperមានបីទម្រង់ដូចតទៅ។

**និយមន័យ** គេឱ្យ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,+\infty)$ ។ យើងកំណត់

$$\int_a^{+\infty} f(x)\,dx=\lim_{N\to+\infty}\int_a^{N} f(x)\,dx \quad (1.29)$$ ។

ប្រសិនបើលីមីតនេះមាននិងរាប់អស់ នោះយើងនិយាយថាអាំងតេក្រាល $\int_a^{+\infty} f(x)\,dx$

[៨] http://archives.math.utk.edu/visual.calculus/4/improper.2/

ជាអាំងតេក្រាលរួម ហើយករណីផ្សេងទៀត យើងនិយាយថា វាជាអាំងតេក្រាលរីក។ គេថា $\int_a^{+\infty} f(x)dx$ ជាអាំងតេក្រាល Improper ។

**ឧទាហរណ៍ទី២៣** គណនា $\int_1^{+\infty} \frac{1}{x^2}dx$ និង $\int_0^{+\infty} \frac{dx}{1+x^2}$ ។

ដំណោះស្រាយ

តាមរូបមន្តអាំងតេក្រាល Improper យើងបាន៖

$$\int_1^{+\infty} \frac{1}{x^2}dx = \lim_{N\to+\infty}\int_1^N \frac{1}{x^2}dx = \lim_{N\to+\infty}\int_1^N x^{-2}dx$$

$$= \lim_{N\to+\infty} -\frac{1}{x}\Big|_1^N = \lim_{N\to+\infty}\left(-\frac{1}{N}+1\right) = 1$$

មានន័យថា $\int_1^{+\infty} \frac{1}{x^2}dx$ រួមរក 1

និង $$\int_0^{+\infty} \frac{dx}{1+x^2} = \lim_{t\to+\infty}\int_0^t \frac{dx}{1+x^2} = \lim_{t\to+\infty} \tan^{-1}x\Big|_0^t$$

$$= \lim_{t\to+\infty}\left(\tan^{-1}t - \tan^{-1}0\right) = \frac{\pi}{2} - 0 = \frac{\pi}{2}$$

មានន័យថា $\int_0^{+\infty} \frac{dx}{1+x^2}$ រួមរក $\frac{\pi}{2}$ ។

**សម្គាល់** ក្នុងសៀវភៅខ្លះ គេសរសេរ

$$\int_0^{+\infty} \frac{dx}{1+x^2} = \tan^{-1}x\Big|_0^{+\infty} = \tan^{-1}(+\infty) - \tan^{-1}(0) = \frac{\pi}{2} - 0 = \frac{\pi}{2}$$

ដើម្បីងាយស្រួលក្នុងការសរសេរ និង គណនាអាំងតេក្រាលឱ្យបានរហ័ស។

**និយមន័យ** គេឱ្យ $f$ ជាអនុគមន៍ជាប់លើចន្លោះ $(-\infty, b]$ ។ យើងកំណត់

$$\int_{-\infty}^b f(x)dx = \lim_{N\to-\infty}\int_N^b f(x)dx \quad (1.30)$$ ។

ប្រសិនបើលីមីតនេះមាននិងរាប់អស់ នោះយើងនិយាយថា អាំងតេក្រាល $\int_{-\infty}^{b} f(x)dx$ ជាអាំងតេក្រាលរួម ហើយករណីផ្សេងទៀត យើងនិយាយថា វាជាអាំងតេក្រាលរីក។ គេថា $\int_{-\infty}^{b} f(x)dx$ ជាអាំងតេក្រាល Improper ។

**ឧទាហរណ៍ទី២៤** គណនា $\int_{-\infty}^{2} \frac{1}{(x-5)^{4/3}}dx$ និង $\int_{-\infty}^{0} e^{5x}dx$ ។

ដំណោះស្រាយ

តាមរូបមន្តអាំងតេក្រាល Improper យើងបាន៖

$$\int_{-\infty}^{2} \frac{1}{(x-5)^{4/3}}dx = \lim_{N\to-\infty}\int_{N}^{2} \frac{1}{(x-5)^{4/3}}dx = \lim_{N\to-\infty}\int_{N}^{2}(x-5)^{-4/3}dx$$

$$= \lim_{N\to-\infty}\left.\frac{(x-5)^{-4/3+1}}{(-4/3+1)}\right|_{N}^{2} = \lim_{N\to-\infty}\left(-\frac{3}{\sqrt[3]{-3}}+\frac{3}{\sqrt[3]{N-5}}\right)$$

$$= \frac{3}{\sqrt[3]{3}}+0 = \frac{3}{\sqrt[3]{3}}$$

និង $$\int_{-\infty}^{0} e^{5x}dx = \lim_{N\to-\infty}\int_{N}^{0} e^{5x}dx = \lim_{N\to-\infty}\left.\frac{e^{5x}}{5}\right|_{N}^{0}$$

$$= \lim_{N\to-\infty}\left(\frac{1}{5}-\frac{e^{5N}}{5}\right) = \lim_{N\to-\infty}\left(\frac{1}{5}-\frac{1}{5e^{-5N}}\right)$$

$$= \frac{1}{5}-0 = \frac{1}{5}$$ ។

**និយមន័យ** គេឱ្យ $f$ ជាអនុគមន៍ជាប់លើ $\mathbb{R}$ ។ ប្រសិនបើអាំងតេក្រាល $\int_{-\infty}^{c} f(x)dx$ និង $\int_{c}^{+\infty} f(x)dx$ ទាំងពីររួម ចំពោះចំនួនពិត $c$ មួយចំនួន នោះយើងកំណត់

$$\int_{-\infty}^{+\infty} f(x)dx = \int_{-\infty}^{c} f(x)dx + \int_{c}^{+\infty} f(x)dx \quad (1.31)$$

និងយើងនិយាយថា អាំងតេក្រាល $\int_{-\infty}^{+\infty} f(x)dx$ នេះរួម ហើយករណីផ្សេងទៀត យើងនិយាយថា វាជាអាំងតេក្រាលរីក។ គេថា $\int_{-\infty}^{+\infty} f(x)dx$ ជាអាំងតេក្រាល Improper ។

**ឧទាហរណ៍ទី២៥** គណនា $\int_{-\infty}^{+\infty} \frac{1}{x^2+25}dx$ និង $\int_{-\infty}^{+\infty} x e^{-5x^2} dx$ ។

ដំណោះស្រាយ

តាមរូបមន្តអាំងតេក្រាល Improper យើងបាន៖

$$\int_{-\infty}^{+\infty} \frac{dx}{x^2+25} = \int_{-\infty}^{0} \frac{dx}{x^2+25} + \int_{0}^{+\infty} \frac{dx}{x^2+25}$$

$$= \lim_{N\to-\infty} \int_{N}^{0} \frac{dx}{x^2+25} + \lim_{M\to+\infty} \int_{0}^{M} \frac{dx}{x^2+25}$$

$$= \lim_{N\to-\infty} \int_{N}^{0} \frac{dx}{x^2+5^2} + \lim_{M\to+\infty} \int_{0}^{M} \frac{dx}{x^2+5^2}$$

$$= \frac{1}{5}\cdot \lim_{N\to-\infty} \tan^{-1}\frac{x}{5}\Big|_{N}^{0} + \frac{1}{5}\cdot \lim_{M\to+\infty} \tan^{-1}\frac{x}{5}\Big|_{0}^{M}$$

$$= \frac{1}{5}\cdot \lim_{N\to-\infty}\left(\tan^{-1}\frac{0}{5} - \tan^{-1}\frac{N}{5}\right) + \frac{1}{5}\cdot \lim_{M\to+\infty}\left(\tan^{-1}\frac{M}{5} - \tan^{-1}\frac{0}{5}\right)$$

$$= \frac{1}{5}\left[0 - \left(-\frac{\pi}{2}\right) + \frac{\pi}{2} - 0\right] = \frac{\pi}{5}$$

និង $$\int_{-\infty}^{+\infty} x e^{-5x^2} dx = \int_{-\infty}^{0} x e^{-5x^2} dx + \int_{0}^{+\infty} x e^{-5x^2} dx$$

$$= \lim_{N\to-\infty} \int_{N}^{0} x e^{-5x^2} dx + \lim_{M\to+\infty} \int_{0}^{M} x e^{-5x^2} dx$$

$$= -\frac{1}{10} \lim_{N\to-\infty} \int_{N}^{0} e^{-5x^2} d\left(-5x^2\right) - \frac{1}{10} \lim_{M\to+\infty} \int_{0}^{M} e^{-5x^2} d\left(-5x^2\right)$$

$$= -\frac{1}{10}(1-0) - \frac{1}{10}(0-1) = 0$$ ។

ជាសរុប ជំពូកទី១បានបង្ហាញនូវនិយមន័យនៃព្រីមីទីវ និង អាំងតេក្រាល ទ្រឹស្តីបទរូបមន្តគ្រឹះ ហើយលក្ខណៈជាច្រើននៃអាំងតេក្រាលមិនកំណត់ និង អាំងតេក្រាលកំណត់។ ជាងនេះទៅទៀត ជំពូកទី១នេះបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលមិនកំណត់ អាំងតេក្រាលកំណត់ និង អាំងតេក្រាល Improper តាមនិយមន័យ រូបមន្តងាយ វិធីប្តូរអថេរ និង វិធីអាំងតេក្រាលដោយផ្នែកដោយអនុវត្តន៍លើឧទាហរណ៍មួយចំនួន។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលនៃអនុគមន៍សនិទាននៅក្នុងជំពូកទី២បន្តទៀត។

# ជំពូកទី២

# ប្រភេទអាំងតេក្រាលនៃអនុគមន៍សនិទាន

**( Types of Integrals of Rational Functions )**

នៅក្នុងជំពូកទី២នេះ យើងនឹងសិក្សាអំពីការបំបែកប្រភាគសនិទានក្នុង $\mathbb{R}$ និង ប្រភេទអាំងតេក្រាលនៃអនុគមន៍សនិទានមួយចំនួនដូចតទៅ៖

## ២.១ ការបំបែកអនុគមន៍សនិទានក្នុង $\mathbb{R}$

គេឱ្យ $F(x)=\dfrac{P(x)}{Q(x)}$ ជាអនុគមន៍សនិទានឬប្រភាគមួយដែលមានមេគុណជាចំនួនពិត ក្នុងនោះ $P(x)$ ជាពហុធាភាគយក និង $Q(x)$ ជាពហុធាភាគបែងដែលមានមេគុណជាចំនួនពិត ហើយ $Q(x)\neq 0$ ។

គេឧបមាថាប្រភាគ $F$ ជាតំណាងដោយគូ $(P,Q)$ នៃពហុធាបឋមរវាងគ្នា។ គេថា $F$ ជាប្រភាគមិនអាចបង្រួមបាន។ នោះវាមានប៉ូលនិងជាតុសូន្យផ្សេងៗគ្នា។

**សម្គាល់**

១. $F(x)=\dfrac{P(x)}{Q(x)}$ ជាអនុគមន៍សនិទាន ឬ ប្រភាគសនិទាន ឬ ប្រភាគមួយដែលមានមេគុណ ជាចំនួនពិត។ អនុគមន៍នេះកំណត់បាន កាលណា $Q(x)\neq 0$ ។

២. ប៉ូលនៃប្រភាគ $F$ ជាឫសនៃពហុធាភាគបែង $Q$ និង ជាតុសូន្យនៃប្រភាគ $F$ ជាឫស នៃពហុធាភាគយក $P$ ។

- បើដឺក្រេនៃ $P(x)$ ធំជាងឬស្មើនឹងដឺក្រេនៃ $Q(x)$ គេសរសេរ $\deg P(x)\geq \deg Q(x)$ នោះយើងត្រូវយកពហុធា $P(x)$ ចែកនឹង $Q(x)$ តែម្តង។

- បើដឺក្រេនៃ $P(x)$ តូចជាងដឺក្រេនៃ $Q(x)$ គេសរសេរ $\deg P(x)<\deg Q(x)$ និងតាមទ្រឹស្តីពីជគណិត ពហុធាភាគបែងអាចដាក់ជាកត្តាក្នុង $\mathbb{R}$ ក្រោមទម្រង់ធម្មតាគឺ

$$Q(x)=(x-a_1)^{\alpha_1}\cdots(x-a_k)^{\alpha_k}\left[(x-b_1)^2+c_1{}^2\right]^{\beta_1}\cdots\left[(x-b_l)^2+c_l{}^2\right]^{\beta_l}\ (2.1)\ ។$$

នាំឱ្យ $F(x)$ អាចបំបែកជាផលបូកជាតុងាយឬជាប្រភាគដោយផ្នែកឬជាប្រភាគតូចៗដែលយើងអាចគណនាអាំងតេក្រាលកំណត់តាមរូបមន្តបានគឺ

$$F(x)=\sum_{j=1}^{\alpha_1}\frac{A_{1j}}{(x-a_1)^j}+\cdots+\sum_{j=1}^{\alpha_k}\frac{A_{kj}}{(x-a_k)^j}+\sum_{m=1}^{\beta_1}\frac{B_{1m}x+C_{1m}}{\left[(x-b_1)^2+c_1^{\,2}\right]^m}+\cdots+\sum_{m=1}^{\beta_l}\frac{B_{lm}x+C_{lm}}{\left[(x-b_l)^2+c_l^{\,2}\right]^m}\ (2.2)$$ ។

ក្នុងករណីប៉ូលងាយ (ប៉ូលសាមញ្ញ) ជាចំនួនពិត ឬ ជាចំនួនកុំផ្លិច នោះយើងប្រើវិធីរកមេគុណដូចតទៅ៖

- បើ $F(x)=\dfrac{P(x)}{Q(x)}=\dfrac{P(x)}{(x-a)Q_1(x)}=\dfrac{A}{(x-a)}+\dfrac{P_1(x)}{Q_1(x)}$ នោះ

$A=\dfrac{P(a)}{Q_1(a)}=\dfrac{P(a)}{Q'(a)}=\mathrm{Re}s(F)$ (រ៉េស៊ីឌុយនៃ $F$ ត្រង់ $a$ ) (2.3)។

- បើ $F(x)=\dfrac{P(x)}{Q(x)}=\dfrac{P(x)}{[(x-b)^2+c^2]\,Q_1(x)}=\dfrac{Bx+C}{(x-b)^2+c^2}+\dfrac{P_1(x)}{Q_1(x)}$ នាំឱ្យ

$[(x-b)^2+c^2]F(x)=\dfrac{P(x)}{Q_1(x)}=Bx+C+[(x-b)^2+c^2]\dfrac{P_1(x)}{Q_1(x)}$ ។

ដោយតាង $x=b+ic$ នោះយើងបានសមីការថ្មីគឺ $Bx+C=\dfrac{P(x)}{Q_1(x)}$ (2.4) ដែល $B$ និង $C$ ជាចំនួនដែលអាចកំណត់បាន។ វាអាចប្រើតម្លៃជំនួសនៃ $x$ ដោយជ្រើសរើសស្មើនឹង $0\,,\pm1\,,i\,,\ldots$ ។

ជាពិសេស បើ $F(x)=\sum_i\dfrac{A_i}{x-a_i}$ នាំឱ្យ

$\lim\limits_{x\to+\infty}xF(x)=\lim\limits_{x\to+\infty}\sum_i\dfrac{xA_i}{x-a_i}=\sum_i A_i$ ។

ដូចនេះ យើងបាន $\sum\mathrm{Re}s(F)=\lim\limits_{x\to+\infty}xF(x)$ (2.5)។

**ឧទាហរណ៍ទី១** ចូរបំបែក $F(x)=\dfrac{x^2+x-1}{(x-1)(x+1)(x-2)}$ ក្នុង $\mathbb{R}$ ឬក៏សរសេរ $F$ ជាប្រភាគដោយផ្នែក។

## ដំណោះស្រាយ

**របៀបទី១** យើងមាន $F(x)=\dfrac{x^2+x-1}{(x-1)(x+1)(x-2)}=\dfrac{A}{x-1}+\dfrac{B}{x+1}+\dfrac{C}{x-2}$

ដែល $A, B$ និង $C$ ជាចំនួនដែលត្រូវកំណត់។

នាំឱ្យ $x^2+x-1=A(x+1)(x-2)+B(x-1)(x-2)+C(x-1)(x+1)$

$$=A(x^2-x-2)+B(x^2-3x+2)+C(x^2-1)$$

$$=(A+B+C)x^2+(-A-3B)x+(-2A+2B-C)$$ ។

ដោយផ្ទឹមមេគុណនៃត្រីធា យើងបាន៖

$$(\text{I})\ \begin{cases}A+B+C=1\\ -A-3B=1\\ -2A+2B-C=-1\end{cases}$$

ដោះស្រាយប្រព័ន្ធសមីការ $(\text{I})$ ផ្តល់ឱ្យ $A=-\dfrac{1}{2}, B=-\dfrac{1}{6}$ និង $C=\dfrac{5}{3}$ ។

ដូចនេះ $F(x)=-\dfrac{1}{2}\cdot\dfrac{1}{x-1}-\dfrac{1}{6}\cdot\dfrac{1}{x+1}+\dfrac{5}{3}\cdot\dfrac{1}{x-2}$ ។

**របៀបទី២** យើងមាន $F(x)=\dfrac{x^2+x-1}{(x-1)(x+1)(x-2)}=\dfrac{A}{x-1}+\dfrac{B}{x+1}+\dfrac{C}{x-2}$

ដែល $A, B$ និង $C$ ជាចំនួនដែលត្រូវកំណត់។

នាំឱ្យ $x^2+x-1=A(x+1)(x-2)+B(x-1)(x-2)+C(x-1)(x+1)\quad(*)$ ។

- យើងយក $x=1$ ជំនួសក្នុងសមីការ $(*)$ ផ្តល់ឱ្យ $1=-2A\Rightarrow A=-\dfrac{1}{2}$ ។
- យើងយក $x=-1$ ជំនួសក្នុងសមីការ $(*)$ ផ្តល់ឱ្យ $-1=6B\Rightarrow B=-\dfrac{1}{6}$ ។
- យើងយក $x=2$ ជំនួសក្នុងសមីការ $(*)$ ផ្តល់ឱ្យ $5=3C\Rightarrow C=\dfrac{5}{3}$ ។

ដូចនេះ $F(x)=-\dfrac{1}{2}\cdot\dfrac{1}{x-1}-\dfrac{1}{6}\cdot\dfrac{1}{x+1}+\dfrac{5}{3}\cdot\dfrac{1}{x-2}$ ។

**របៀបទី៣** យើងមាន $F(x)=\dfrac{x^2+x-1}{(x-1)(x+1)(x-2)}=\dfrac{A}{x-1}+\dfrac{B}{x+1}+\dfrac{C}{x-2}$

ដែល $A=\lim\limits_{x\to1}(x-1)F(x)=\lim\limits_{x\to1}\dfrac{x^2+x-1}{(x+1)(x-2)}=-\dfrac{1}{2}$

$$B=\lim_{x\to-1}(x+1)F(x)=\lim_{x\to-1}\dfrac{x^2+x-1}{(x-1)(x-2)}=-\dfrac{1}{6}$$

និង $C=\lim_{x\to 2}(x-2)F(x)=\lim_{x\to 2}\frac{x^2+x-1}{(x-1)(x+1)}=\frac{5}{3}$ ។

ដូចនេះ $F(x)=-\frac{1}{2}\cdot\frac{1}{x-1}-\frac{1}{6}\cdot\frac{1}{x+1}+\frac{5}{3}\cdot\frac{1}{x-2}$ ។

**សម្គាល់** ចំពោះរបៀបទី១ និងទី២ គេច្រើនប្រើប្រាស់វានៅកម្រិតមធ្យមសិក្សា រីឯរបៀបទី៣ វិញ គេប្រើប្រាស់វានៅកម្រិតឧត្តមសិក្សា។

**ឧទាហរណ៍ទី២** ចូរបំបែក $F(x)=\frac{x^4}{(x+1)\left(x^2+1\right)}$ ក្នុង $\mathbb{R}$ ។

ដំណោះស្រាយ

**របៀបទី១** តាមវិធីចែកពហុធា យើងបាន

$$F(x)=\frac{x^4}{(x+1)\left(x^2+1\right)}=x-1+\frac{1}{(x+1)(x^2+1)}$$

និងប្រភាគ $F_1(x)=\frac{1}{(x+1)(x^2+1)}=\frac{A}{x+1}+\frac{Bx+C}{x^2+1}$

ដែល A, B និង C ជាចំនួនដែលត្រូវកំណត់។

នាំឱ្យ $1=A\left(x^2+1\right)+(Bx+C)(x+1)$

$=(A+B)x^2+(B+C)x+(A+C)$ ។

ដោយផ្ទឹមមេគុណនៃត្រីធា យើងបាន៖

$$(\text{II})\begin{cases}A+B=0\\B+C=0\\A+C=1\end{cases}$$

ដោះស្រាយប្រព័ន្ធសមីការ (II) ផ្តល់ឱ្យ $A=\frac{1}{2}, B=-\frac{1}{2}$ និង $C=\frac{1}{2}$ ។

ដូចនេះ $F(x)=x-1+F_1(x)=x-1+\frac{1}{2}\cdot\frac{1}{x+1}+\frac{1}{2}\cdot\frac{-x+1}{x^2+1}$ ។

**របៀបទី២** តាមវិធីចែកពហុធា យើងបាន

$$F(x)=\frac{x^4}{(x+1)\left(x^2+1\right)}=x-1+\frac{1}{(x+1)(x^2+1)}$$

និងប្រភាគ $F_1(x)=\frac{1}{(x+1)(x^2+1)}=\frac{A}{x+1}+\frac{Bx+C}{x^2+1}$

ដែល A, B និង C ជាចំនួនដែលត្រូវកំណត់។

នាំឱ្យ $A=\lim_{x\to -1}(x+1)F_1(x)=\lim_{x\to -1}\frac{1}{(x^2+1)}=\frac{1}{2}$ ។

ដើម្បីកំណត់ B និង C យើងអាចគុណ $F_1(x)$ នឹង $(x^2+1)$ រួចយក $x=i$ ផ្តល់ឱ្យ

$$\frac{1}{x+1}=Bx+C+(x^2+1)\left(\frac{A}{x+1}\right) \text{ និង } \frac{1}{i+1}=Bi+C$$

នាំឱ្យ $B=-\frac{1}{2}$ និង $C=\frac{1}{2}$ ។

ដូចនេះ $F(x)=x-1+F_1(x)=x-1+\frac{1}{2}\cdot\frac{1}{x+1}+\frac{1}{2}\cdot\frac{-x+1}{x^2+1}$ ។

## ២.២ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int\frac{1}{(ax+b)^n}dx$

ដើម្បីគណនាអាំងតេក្រាល $\int\frac{1}{(ax+b)^n}dx$ យើងតាង $u=ax+b$ នាំឱ្យ $du=a\,dx$ សមមូល $dx=\frac{du}{a}$ $(a\neq 0)$ ។

នាំឱ្យ $\int\frac{1}{(ax+b)^n}dx=\int\frac{1}{u^n}\frac{du}{a}=\frac{1}{a}\int u^{-n}du$ ។

បន្ទាប់មក យើងសិក្សាពីរករណីគឺ $n=1$ និង $n\neq 1$។

- បើ $n=1$ នាំឱ្យ

$$\int\frac{1}{(ax+b)^n}dx=\frac{1}{a}\int u^{-1}du=\frac{1}{a}\int\frac{du}{u}$$

$$=\frac{1}{a}\ln|u|+c=\boxed{\frac{1}{a}\ln|ax+b|+c} \qquad (2.6)$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $n\neq 1$ នាំឱ្យ

$$\int\frac{1}{(ax+b)^n}dx=\frac{1}{a}\int u^{-n}du=\frac{u^{-n+1}}{a(-n+1)}+c$$

$$=\frac{-1}{a(n-1)}\cdot\frac{1}{u^{n-1}}+c=\boxed{\frac{-1}{a(n-1)}\cdot\frac{1}{(ax+b)^{n-1}}+c} \qquad (2.7)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៣** គណនា $\int \frac{3}{4x+5}dx$ និង $\int \frac{1}{(2x-1)^7}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (2.6) និង (2.7) យើងបាន៖

$$\int \frac{3}{4x+5}dx = 3\int \frac{1}{4x+5}dx = \frac{3}{4}\ln|4x+5| + c$$

និង $\int \frac{1}{(2x-1)^7}dx = \frac{-1}{2(7-1)}\cdot\frac{1}{(2x-1)^{7-1}} + c = -\frac{1}{12}\cdot\frac{1}{(2x-1)^6} + c$ ។

## ២.៣ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{\mathrm{dx}}{\mathrm{x}^2 \pm a^2}$

ជាមុនដំបូង យើងគណនា $\int \frac{\mathrm{dx}}{\mathrm{x}^2 + a^2}$ ឬ $\int \frac{dx}{a^2 + x^2}$ ដែលជាអាំងតេក្រាលមិនកំណត់។ តាង $x = a\tan t$ នាំឱ្យ $t = \arctan\frac{x}{a} = \tan^{-1}\frac{x}{a}$ $(a \neq 0)$ និង $dx = \frac{a}{\cos^2 t}dt$ ។ តាមរូបមន្តប្តូរអថេរ យើងបាន៖

$$\int \frac{dx}{x^2+a^2} = \int \frac{1}{(a\tan t)^2 + a^2}\cdot\frac{a\,dt}{\cos^2 t} = \frac{1}{a}\int \cos^2 t\cdot\frac{dt}{\cos^2 t}$$

$$= \frac{1}{a}\int dt = \frac{1}{a}t + c = \boxed{\frac{1}{a}\arctan\frac{x}{a} + c} = \boxed{\frac{1}{a}\tan^{-1}\frac{x}{a} + c} \quad (2.8)$$

ដែល $c$ ជាចំនួនពិតថេរ និង $a \neq 0$ ។

**សម្គាល់** គេសរសេរអនុគមន៍ច្រាសនៃអនុគមន៍ $tg\,x$ ឬ $\tan x$ ដោយ $arctg\,x$ ឬ $\arctan x$ ឬ $\tan^{-1}x$ ។

បន្ទាប់មក យើងគណនាអាំងតេក្រាលមិនកំណត់ $\int \frac{\mathrm{dx}}{\mathrm{x}^2 - a^2} = -\int \frac{\mathrm{dx}}{a^2 - \mathrm{x}^2}$ ។

អាំងតេ ក្រាល $\int \frac{\mathrm{dx}}{a^2 - \mathrm{x}^2}$ មានអនុគមន៍អាំងតេក្រាល $\frac{1}{a^2 - x^2}$ $(a \neq 0)$ ដែលយើងអាចសរសេរវាជា ប្រភាគដោយផ្នែកខាងក្រោម៖

យើងមាន $\frac{1}{a^2 - x^2} = \frac{1}{(a-x)(a+x)} = \frac{A}{a-x} + \frac{B}{a+x}$

ក្នុងនោះ $A$ និង $B$ ជាចំនួនដែលត្រូវកំណត់។ យើងអាចកំណត់ចំនួន $A$ និង $B$ តាមពីរបៀប។

*របៀបទី១*

យើងមាន

$$\frac{1}{a^2-x^2}=\frac{A}{a-x}+\frac{B}{a+x}=\frac{A(a+x)+B(a-x)}{(a-x)(a+x)}=\frac{(A-B)x+Aa+Ba}{a^2-x^2}\ ។$$

តាមការផ្ទឹមភាគយក នាំឱ្យ $A-B=0$ និង $Aa+Ba=1$។ នាំឱ្យ $A=B=\frac{1}{2a}$ ។

*របៀបទី២*

យើងមាន $\frac{1}{a^2-x^2}=\frac{A}{a-x}+\frac{B}{a+x}$។

- គុណអង្គទាំងពីរនឹង $(a-x)$ រួចយក $x=a$ នាំឱ្យ $A=\frac{1}{a+a}=\frac{1}{2a}$។

- គុណអង្គទាំងពីរនឹង $(a+x)$ រួចយក $x=-a$ នាំឱ្យ $B=\frac{1}{a-(-a)}=\frac{1}{2a}$។

យើងបាន $\frac{1}{a^2-x^2}=\frac{1}{2a}\cdot\frac{1}{a-x}+\frac{1}{2a}\cdot\frac{1}{a+x}$។

នាំឱ្យ $\int\frac{dx}{a^2-x^2}=\int\left(\frac{1}{2a}\cdot\frac{1}{a-x}+\frac{1}{2a}\cdot\frac{1}{a+x}\right)dx$

$$=-\frac{1}{2a}\ln|a-x|+\frac{1}{2a}\ln|a+x|+c=\boxed{\frac{1}{2a}\ln\left|\frac{a+x}{a-x}\right|+c}\quad(2.9)$$

និង $\int\frac{\mathrm{dx}}{\mathrm{x}^2-a^2}=-\int\frac{\mathrm{dx}}{a^2-\mathrm{x}^2}=-\frac{1}{2a}\ln\left|\frac{a+x}{a-x}\right|+c_1$

$$=\frac{1}{2a}\ln\left|\frac{a-x}{a+x}\right|+c_1=\boxed{\frac{1}{2a}\ln\left|\frac{x-a}{x+a}\right|+c_1}\quad(2.10)$$

ដែល $c$ និង $c_1$ ជាចំនួនពិតថេរ ហើយ $a\neq 0$ ។

**ឧទាហរណ៍ទី៤** គណនាអាំងតេក្រាល $\int_0^1\frac{dt}{1+t^2}$ និង $\int_1^e\frac{dx}{x(1+\ln^2 x)}$ ។

ដំណោះស្រាយ

តាមរូបមន្ត (2.8) យើងបាន៖

$$\int_0^1 \frac{dt}{1+t^2} = \arctan t \Big|_0^1 = \arctan 1 - \arctan 0 = \frac{\pi}{4} \approx 0.7854$$

និងតាង $u = \ln x$ នាំឱ្យ $x = e^u$ និង $du = \frac{dx}{x}$ ។ ពិនិត្យគោល៖ បើ $x=1$ នោះ $u=0$ និង បើ $x=e$ នោះ $u=1$ ។

នាំឱ្យ $\int_1^e \frac{dx}{x(1+\ln^2 x)} = \int_0^1 \frac{du}{1+u^2} = \frac{\pi}{4}$ ។

**ឧទាហរណ៍ទី៥** គណនាអាំងតេក្រាល $\int_2^3 \frac{dt}{1-t^2}$ និង $\int_5^7 \frac{dx}{x^2-16}$ ។

ដំណោះស្រាយ

តាមរូបមន្ត (2.9) និង (2.10) យើងអាចគណនាអាំងតេក្រាលកំណត់ $\int_2^3 \frac{dt}{1-t^2}$ និង $\int_5^7 \frac{dx}{x^2-16}$ ដូចតទៅ៖

$$\int_2^3 \frac{dt}{1-t^2} = \frac{1}{2}\ln\left|\frac{1+t}{1-t}\right|\Bigg|_2^3 = \frac{1}{2}\left[\ln\frac{4}{2} - \ln\frac{3}{1}\right]$$

$$= \frac{1}{2}\ln\frac{2}{3} \approx -0.2027$$

និង $$\int_5^7 \frac{dx}{x^2-16} = \int_5^7 \frac{dx}{x^2-4^2} = \frac{1}{2(4)}\ln\left|\frac{x-4}{x+4}\right|\Bigg|_5^7$$

$$= \frac{1}{8}\left(\ln\frac{3}{11} - \ln\frac{1}{9}\right) = \frac{1}{8}\ln\left(\frac{27}{11}\right) \text{ ។}$$

## ២.៤ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{dx}{ax^2+bx+c}$

អាំងតេក្រាល $\int \frac{dx}{ax^2+bx+c}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{ax^2+bx+c}$ ។ អនុគមន៍នេះមានពហុធាភាគបែងជាត្រីធា $ax^2+bx+c$ $(a \neq 0)$ ។

យើងនឹងសិក្សាតាម $\Delta = b^2 - 4ac$ ដើម្បីស្វែងរកឫសនៃត្រីធានេះ។

១. ប្រសិនបើ $\Delta = 0$ នោះត្រីធាមានឫសឌុបគឺ $x_1 = x_2 = -\dfrac{b}{2a}$ ។

នាំឱ្យ $ax^2 + bx + c = a\left(x + \dfrac{b}{2a}\right)^2$ និង

$$\int \frac{dx}{ax^2+bx+c} = \int \frac{dx}{a\left(x+\frac{b}{2a}\right)^2} = \frac{-1}{a}\cdot\frac{1}{x+\frac{b}{2a}} + c_1$$

$$= \boxed{\frac{-2}{2ax+b} + c_1} = \boxed{\frac{-2}{(ax^2+bx+c)'} + c_1} \quad (2.11)$$

ដែល $c_1$ ជាចំនួនថេរ និង $a \neq 0$ ។

២. ប្រសិនបើ $\Delta > 0$ នោះត្រីធាមានឫសពីរផ្សេងគ្នាគឺ $x_1 = \dfrac{-b+\sqrt{\Delta}}{2a}$ ឬ $x_2 = \dfrac{-b-\sqrt{\Delta}}{2a}$ ។

នាំឱ្យ $ax^2 + bx + c = a(x - x_1)(x - x_2)$ និង

$$\int \frac{dx}{ax^2+bx+c} = \int \frac{dx}{a(x-x_1)(x-x_2)} = \int \frac{[(x-x_2)-(x-x_1)]dx}{a(x_1-x_2)(x-x_1)(x-x_2)}$$

$$= \frac{1}{a(x_1-x_2)}\int \left[\frac{1}{x-x_1} - \frac{1}{x-x_2}\right]dx = \frac{1}{a(x_1-x_2)}\left[\ln|x-x_1| - \ln|x-x_2|\right] + c_1$$

$$= \boxed{\frac{1}{a(x_1-x_2)}\ln\left|\frac{x-x_1}{x-x_2}\right| + c_1} = \boxed{\frac{1}{\sqrt{\Delta}}\ln\left|\frac{x-x_1}{x-x_2}\right| + c_1} \quad (2.12)$$

ដែល $c_1$ ជាចំនួនថេរ និង $a \neq 0$ ។

៣. ប្រសិនបើ $\Delta < 0$ នោះត្រីធាគ្មានឫសចំនួនពិតទេ។ នាំឱ្យត្រីធាអាចសរសេរជា

$$ax^2+bx+c = a\left[\left(x+\frac{b}{2a}\right)^2 + \frac{4ac-b^2}{4a^2}\right] = a\left[\left(x+\frac{b}{2a}\right)^2 + \left(\frac{\sqrt{-\Delta}}{2a}\right)^2\right]$$

និង $$\int \frac{dx}{ax^2+bx+c} = \frac{1}{a}\int \frac{dx}{\left(x+\frac{b}{2a}\right)^2 + \left(\frac{\sqrt{-\Delta}}{2a}\right)^2} = \frac{1}{a\left(\frac{\sqrt{-\Delta}}{2a}\right)}\arctan\left(\frac{x+\frac{b}{2a}}{\frac{\sqrt{-\Delta}}{2a}}\right) + c_1$$

$$=\boxed{\frac{2}{\sqrt{-\Delta}}\arctan\left(\frac{2ax+b}{\sqrt{-\Delta}}\right)+c_1}=\boxed{\frac{2}{\sqrt{-\Delta}}\arctan\left(\frac{(ax^2+bx+c)'}{\sqrt{-\Delta}}\right)+c_1}\quad(2.13)$$

ដែល $c_1$ ជាចំនួនថេរ និង $a\neq 0$ ។

**ឧទាហរណ៍ទី៦** គណនា $\int\frac{dx}{(x-a)(x-b)}$ $(a\neq b, (a,b)\neq(0,0))$, $\int_4^5\frac{dt}{(t-2)(t-3)}$ និង $\int_3^6\frac{dv}{v^2-3v+2}$ ។

ដំណោះស្រាយ

តាមរូបមន្ត (2.12) យើងបាន៖

$$\int\frac{dx}{(x-a)(x-b)}=\boxed{\frac{1}{(a-b)}\ln\left|\frac{x-a}{x-b}\right|+c}\quad(2.14)$$

$$\int_4^5\frac{dt}{(t-2)(t-3)}=\frac{1}{(3-2)}\ln\left|\frac{t-3}{t-2}\right|\Bigg|_4^5$$

$$=\ln\frac{2}{3}-\ln\frac{1}{2}=\ln\left(\frac{2/3}{1/2}\right)=\ln\frac{4}{3}\approx 0.2877$$

និង $$\int_3^6\frac{dv}{v^2-3v+2}=\int_3^6\frac{dv}{(v-1)(v-2)}=\frac{1}{(2-1)}\ln\left|\frac{v-2}{v-1}\right|\Bigg|_3^6$$

$$=\ln\frac{4}{5}-\ln\frac{1}{2}=\ln\left(\frac{4/5}{1/2}\right)=\ln\frac{8}{5}\approx 0.4700$$ ។

**ឧទាហរណ៍ទី៧** គណនា $\int\frac{1}{4x^2-24x+36}dx$ និង $\int\frac{3x}{x^4-2x^2+2}dx$ ។

ដំណោះស្រាយ

យើងមានត្រីធា $4x^2-24x+36$ មាន $\Delta=b^2-4ac=(-24)^2-4(4)(36)=0$ នោះ តាមរូបមន្ត (2.11) យើងបាន៖

$$\int\frac{1}{4x^2-24x+36}dx=\frac{-2}{(4x^2-24x+36)'}+c=\frac{-2}{8x-24}+c=\frac{-1}{4x-12}+c$$ ។

ចំពោះអាំងតេក្រាល $\int \frac{3x}{x^4-2x^2+2}dx$ យើងតាង $y=x^2$ នាំឱ្យ

$dy=2x\,dx \Leftrightarrow x\,dx=\frac{1}{2}dy$ និង $\int \frac{3x}{x^4-2x^2+2}dx=\frac{3}{2}\int \frac{1}{y^2-2y+2}dy$ ។

ប៉ុន្តែត្រីធា $y^2-2y+2$ មាន $\Delta=b^2-4ac=(-2)^2-4(1)(2)=4-8=-4<0$ នោះតាមរូបមន្ត (2.13) យើងបាន៖

$$\int \frac{3x}{x^4-2x^2+2}dx=\frac{3}{2}\int \frac{1}{y^2-2y+2}dy$$

$$=\frac{3}{2}\cdot\frac{2}{\sqrt{4}}\arctan\left(\frac{(y^2-2y+2)'}{\sqrt{4}}\right)+c$$

$$=\frac{3}{2}\arctan\left(\frac{2y-2}{2}\right)+c$$

$$=\frac{3}{2}\arctan(y-1)+c=\frac{3}{2}\arctan\left(x^2-1\right)+c \text{ ។}$$

## ២.៥ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{(a_1x+b_1)\,dx}{ax^2+bx+c}$

អាំងតេក្រាល $\int \frac{(a_1x+b_1)\,dx}{ax^2+bx+c}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $F(x)=\frac{a_1x+b_1}{ax^2+bx+c}$ ។ អនុគមន៍នេះមានពហុធាភាគយកជាទ្វេធា $a_1x+b_1$ $(a_1\neq 0)$ និងពហុធាភាគបែងជាត្រីធា $ax^2+bx+c$ $(a\neq 0)$ ។ យើងនឹងសិក្សាពីរករណីដូចតទៅ៖

- ប្រសិនបើ $a_1x+b_1=k(2ax+b)$ នាំឱ្យ $\frac{a_1x+b_1}{ax^2+bx+c}=\frac{k(2ax+b)}{ax^2+bx+c}$ និង

$$\int \frac{(a_1x+b_1)\,dx}{ax^2+bx+c}=\int \frac{k(2ax+b)\,dx}{ax^2+bx+c}=k\int \frac{(ax^2+bx+c)'\,dx}{ax^2+bx+c}$$

$$=\boxed{k\ln\left|ax^2+bx+c\right|+c_1} \quad (2.15)$$

ដែល $c_1$ ជាចំនួនថេរ។

- ប្រសិនបើ $a_1x+b_1\neq k(2ax+b)$ នាំឱ្យ

$$\frac{a_1x+b_1}{ax^2+bx+c}=\frac{\frac{a_1}{2a}(2ax+b)+b_1-\frac{a_1b}{2a}}{ax^2+bx+c}$$

$$= \frac{a_1}{2a} \cdot \frac{2ax + b}{ax^2 + bx + c} + (b_1 - \frac{a_1 b}{2a}) \cdot \frac{1}{ax^2 + bx + c}$$

និង $\int \frac{(a_1 x + b_1)\, dx}{ax^2 + bx + c} = \frac{a_1}{2a} \int \frac{(2ax + b)\, dx}{ax^2 + bx + c} + (b_1 - \frac{a_1 b}{2a}) \int \frac{dx}{ax^2 + bx + c}$

$$= \boxed{\frac{a_1}{2a} \ln\left|ax^2 + bx + c\right| + (b_1 - \frac{a_1 b}{2a}) \int \frac{dx}{ax^2 + bx + c}} \quad (2.16)$$

ដែលអាំងតេក្រាល $\int \frac{dx}{ax^2 + bx + c}$ អាចកំណត់បាននៅផ្នែក ២.៤ ។

**ឧទាហរណ៍ទី៨** គណនា $\int \frac{(6x-5)}{3x^2 - 5x + 6} dx$ និង $\int \frac{3x+2}{x^2 + x + 1} dx$ ។

ដំណោះស្រាយ

យើងមានត្រីធា $3x^2 - 5x + 6$ និង $(3x^2 - 5x + 6)' = 6x - 5$ នោះតាមរូបមន្ត (2.15) យើងបាន៖

$$\int \frac{(6x-5)}{3x^2 - 5x + 6} dx = \ln\left|3x^2 - 5x + 6\right| + c_1$$

និងតាមរូបមន្ត (2.16) នាំឱ្យ

$$\int \frac{3x+2}{x^2 + x + 1} dx = \frac{3}{2(1)} \ln\left|x^2 + x + 1\right| + \left(2 - \frac{3 \times 1}{2(1)}\right) \int \frac{dx}{x^2 + x + 1}$$

$$= \frac{3}{2} \ln(x^2 + x + 1) + \frac{1}{2} \int \frac{dx}{\left(x + \frac{1}{2}\right)^2 + \left(\frac{\sqrt{3}}{2}\right)^2}$$

$$= \frac{3}{2} \ln(x^2 + x + 1) + \frac{1}{2} \frac{1}{\left(\sqrt{3}/2\right)} \arctan\left(\frac{x + \frac{1}{2}}{\frac{\sqrt{3}}{2}}\right) + c$$

$$= \frac{3}{2} \ln(x^2 + x + 1) + \frac{\sqrt{3}}{3} \arctan\left(\frac{2x+1}{\sqrt{3}}\right) + c \text{ ។}$$

ម្យ៉ាងទៀត អនុគមន៍អាំងតេក្រាល $F(x) = \frac{a_1 x + b_1}{ax^2 + bx + c}$ មានពហុធាភាគបែងជាត្រីធា $ax^2 + bx + c \quad (a \neq 0)$ ដែលមាន $\Delta = b^2 - 4ac$ ។ ឥឡូវនេះ យើងអាចគណនា

អាំងតេក្រាល $\int \frac{(a_1 x+b_1)\,dx}{a x^2+bx+c}$ តាមវិធីផ្សេងទៀតដោយសិក្សាករណី $\Delta \geq 0$ ។ ចំពោះ

ករណី $\Delta < 0$ យើងត្រូវគណនាវាតាមរូបមន្ត (2.16)។

១. ប្រសិនបើ $\Delta = 0$ នោះត្រីធាមានឫសឌុបគឺ $x_1 = x_2 = -\frac{b}{2a}$ ។

នាំឱ្យ $a x^2 + bx + c = a\left(x+\frac{b}{2a}\right)^2$ និង

$$F(x) = \frac{a_1 x + b_1}{a x^2 + bx + c} = \frac{a_1 x + b_1}{a\left(x+\frac{b}{2a}\right)^2} = \frac{A}{x+\frac{b}{2a}} + \frac{B}{\left(x+\frac{b}{2a}\right)^2}$$

ក្នុងនោះ $A$ និង $B$ ជាចំនួនដែលត្រូវកំណត់។

នាំឱ្យយើងបានសមភាពនៃពហុធា $\left(\frac{a_1}{a}\right)x + \frac{b_1}{a} = A\left(x+\frac{b}{2a}\right) + B = Ax + A\frac{b}{2a} + B$

នាំឱ្យ $A = \frac{a_1}{a}$ និង $\frac{bA}{2a} + B = \frac{b_1}{a}$ នាំឱ្យ $A = \frac{a_1}{a}$ និង $B = \frac{b_1}{a} - \frac{bA}{2a} = \frac{2ab_1 - ba_1}{2a^2}$ ។

នាំឱ្យ

$$\int \frac{(a_1 x + b_1)\,dx}{a x^2 + bx + c} = \int \frac{a_1 x + b_1}{a\left(x+\frac{b}{2a}\right)^2}dx = A\int \frac{1}{x+\frac{b}{2a}}dx + B\int \frac{1}{\left(x+\frac{b}{2a}\right)^2}dx$$

$$= A\ln\left|x+\frac{b}{2a}\right| + B\,\frac{\left(x+\frac{b}{2a}\right)^{-1}}{(-1)} + c_1$$

$$= A\ln\left|x+\frac{b}{2a}\right| - \frac{B}{x+\frac{b}{2a}} + c_1$$

$$= A\ln|2ax+b| - \frac{2aB}{2ax+b} + c_2$$

$$= \boxed{\frac{a_1}{a}\ln|2ax+b| - \left(\frac{2ab_1 - ba_1}{a}\right)\frac{1}{2ax+b} + c_2} \qquad (2.17)$$

ដែល $c_2$ ជាចំនួនថេរ និង $a \neq 0$ ។

២. ប្រសិនបើ $\Delta > 0$ នោះត្រីធាមានឫសពីរផ្សេងគ្នាគឺ $x_1 = \dfrac{-b+\sqrt{\Delta}}{2a}$ ឬ

$x_2 = \dfrac{-b-\sqrt{\Delta}}{2a}$ ។

នាំឱ្យ $\mathrm{a}x^2 + bx + c = a(x-x_1)(x-x_2)$ និង

$$F(x) = \frac{\mathrm{a}_1 x + \mathrm{b}_1}{\mathrm{a}x^2 + bx + c} = \frac{\mathrm{a}_1 x + \mathrm{b}_1}{a(x-x_1)(x-x_2)} = \frac{A}{x-x_1} + \frac{B}{x-x_2}$$

ដែល $\mathrm{A} = \lim\limits_{\mathrm{x}\to \mathrm{x}_1} (\mathrm{x}-\mathrm{x}_1)\mathrm{F}(\mathrm{x}) = \lim\limits_{\mathrm{x}\to \mathrm{x}_1} \dfrac{\mathrm{a}_1 \mathrm{x} + \mathrm{b}_1}{\mathrm{a}(\mathrm{x}-\mathrm{x}_2)} = \dfrac{\mathrm{a}_1 \mathrm{x}_1 + \mathrm{b}_1}{\mathrm{a}(\mathrm{x}_1-\mathrm{x}_2)} = \dfrac{\mathrm{a}_1 \mathrm{x}_1 + \mathrm{b}_1}{\sqrt{\Delta}}$

និង $\mathrm{B} = \lim\limits_{\mathrm{x}\to \mathrm{x}_2} (\mathrm{x}-\mathrm{x}_2)\mathrm{F}(\mathrm{x}) = \lim\limits_{\mathrm{x}\to \mathrm{x}_2} \dfrac{\mathrm{a}_1 \mathrm{x} + \mathrm{b}_1}{\mathrm{a}(\mathrm{x}-\mathrm{x}_1)} = \dfrac{\mathrm{a}_1 \mathrm{x}_2 + \mathrm{b}_1}{\mathrm{a}(\mathrm{x}_2-\mathrm{x}_1)} = -\dfrac{\mathrm{a}_1 \mathrm{x}_2 + \mathrm{b}_1}{\sqrt{\Delta}}$ ។

នាំឱ្យ

$$\int \frac{(\mathrm{a}_1 x + \mathrm{b}_1)\mathrm{dx}}{\mathrm{a}x^2 + bx + c} = \int \frac{(\mathrm{a}_1 x + \mathrm{b}_1)\mathrm{dx}}{\mathrm{a}(x-x_1)(x-x_2)} = \int \left(\frac{A}{x-x_1} + \frac{B}{x-x_2}\right)dx$$

$$= \boxed{A\ln|x-x_1| + B\ln|x-x_2| + c_1} \quad (2.18)$$

ដែល $\mathrm{A} = \dfrac{\mathrm{a}_1 \mathrm{x}_1 + \mathrm{b}_1}{\mathrm{a}(\mathrm{x}_1-\mathrm{x}_2)} = \dfrac{\mathrm{a}_1 \mathrm{x}_1 + \mathrm{b}_1}{\sqrt{\Delta}}$ និង $\mathrm{B} = \dfrac{\mathrm{a}_1 \mathrm{x}_2 + \mathrm{b}_1}{\mathrm{a}(\mathrm{x}_2-\mathrm{x}_1)} = -\dfrac{\mathrm{a}_1 \mathrm{x}_2 + \mathrm{b}_1}{\sqrt{\Delta}}$ ហើយ $c_1$ ជាចំនួនថេរ និង $a \neq 0$ ។

**ឧទាហរណ៍ទី៩** គណនា $\displaystyle\int \frac{(8x+5)}{4x^2-12x+9}dx$ និង $\displaystyle\int \frac{3x+11}{x^2-x-6}dx$ ។

ដំណោះស្រាយ

ត្រីធា $4x^2-12x+9$ មាន $\Delta = b^2-4ac = (-12)^2 - 4(4)(9) = 0$ នោះតាមរូបមន្ត (2.17) យើងបាន៖

$$\int \frac{(8x+5)}{4x^2-12x+9}dx = \frac{8}{4}\ln|8x-12| - \left(\frac{2(4)(5)-(-12)(8)}{4}\right)\cdot\frac{1}{8x-12} + c_1$$

$$= 2\ln|8x-12| - \frac{34}{8x-12} + c_1 \text{ ។}$$

ចំពោះត្រីធា $x^2-x-6$ មាន $\Delta = b^2-4ac = (-1)^2 - 4(1)(-6) = 25 > 0$ នោះត្រីធាមានឫសពីរគឺ $x_1 = \dfrac{1+5}{2(1)} = 3,\ x_2 = \dfrac{1-5}{2(1)} = -2$ ។

តាមរូបមន្ត (2.18) យើងបាន៖

$$\int \frac{3x+11}{x^2-x-6}dx = \frac{3(3)+11}{5}\ln|x-3| - \frac{3(-2)+11}{5}\ln|x+2| + c_1$$

$$= 4\ln|x-3| - \ln|x+2| + c_1 \text{ ។}$$

## ២.៦ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{\mathrm{dx}}{(\mathrm{x}^2+a^2)^m}$

អាំងតេក្រាល $\int \frac{\mathrm{dx}}{(\mathrm{x}^2+a^2)^m}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $F(x) = \frac{1}{(\mathrm{x}^2+a^2)^m}$ ។ អនុគមន៍នេះ ជាប្រភាគសនិទាន កាលណា $m \in \mathbb{N}$ ។ យើងនឹងសិក្សាពីរករណី $m=1$ និង $m \neq 1$ ដូចតទៅ៖

- ករណី $m=1$ នោះតាមផ្នែក ២.៣ (រូបមន្ត (2.8) ) យើងបាន៖

$$\int \frac{\mathrm{dx}}{(\mathrm{x}^2+a^2)^m} = \int \frac{\mathrm{dx}}{\mathrm{x}^2+a^2} = \frac{1}{a}\arctan\left(\frac{x}{a}\right) + c$$

ដែល $c$ ជាចំនួនថេរ និង $a \neq 0$ ។

- ករណី $m \neq 1$ យើងតាង $I_m = \int \frac{\mathrm{dx}}{(\mathrm{x}^2+a^2)^m}$ ។ យើងនឹងរកទំនាក់ទំនងរវាង $I_m$ និង $I_{m-1}$ ។

នាំឱ្យ

$$I_{m-1} = \int \frac{\mathrm{dx}}{(\mathrm{x}^2+a^2)^{m-1}} = \int \frac{(\mathrm{x}^2+a^2)\,\mathrm{dx}}{(\mathrm{x}^2+a^2)^m}$$

$$= \int \frac{\mathrm{x}^2\,\mathrm{dx}}{(\mathrm{x}^2+a^2)^m} + \int \frac{a^2\,\mathrm{dx}}{(\mathrm{x}^2+a^2)^m}$$

$$= \int \frac{\mathrm{x}^2\,\mathrm{dx}}{(\mathrm{x}^2+a^2)^m} + a^2 I_m = J_m + a^2 I_m \quad (*)$$

ដែល $J_m = \int \frac{\mathrm{x}^2\,\mathrm{dx}}{(\mathrm{x}^2+a^2)^m}$ ។

យើងប្រើវិធីអាំងតេក្រាលដោយផ្នែក ដោយយក $u = x$ និង $dv = \frac{x\,dx}{\left(x^2+a^2\right)^m}$ នាំឱ្យ

$du = dx$ និង $v = \int \frac{x\,dx}{\left(x^2+a^2\right)^m} = \frac{1}{2}\int \left(x^2+a^2\right)^{-m} d\left(x^2+a^2\right) = \frac{-1}{2(m-1)\left(x^2+a^2\right)^{m-1}}$ ។

នាំឱ្យ $J_m = \int \frac{x^2\,dx}{(x^2+a^2)^m} = \int u\,dv = uv - \int v\,du$

$$= \frac{-x}{2(m-1)\left(x^2+a^2\right)^{m-1}} + \frac{1}{2(m-1)}\int \frac{dx}{(x^2+a^2)^{m-1}}$$

$$= \frac{-x}{2(m-1)\left(x^2+a^2\right)^{m-1}} + \frac{1}{2(m-1)} I_{m-1} \text{ ។}$$

ពីសមីការ $(*)$ យើងបាន៖

$$I_{m-1} = J_m + a^2 I_m = \frac{-x}{2(m-1)\left(x^2+a^2\right)^{m-1}} + \frac{1}{2(m-1)} I_{m-1} + a^2 I_m$$

នាំឱ្យ $a^2 I_m = \frac{x}{2(m-1)\left(x^2+a^2\right)^{m-1}} + \frac{2m-3}{2(m-1)} I_{m-1}$

នាំឱ្យ $I_m = \frac{x}{2(m-1)a^2\left(x^2+a^2\right)^{m-1}} + \frac{2m-3}{2(m-1)a^2} I_{m-1}$ ។

ដូចនេះ $\boxed{\int \frac{dx}{(x^2+a^2)^m} = \frac{x}{2(m-1)a^2\left(x^2+a^2\right)^{m-1}} + \frac{2m-3}{2(m-1)a^2}\int \frac{dx}{(x^2+a^2)^{m-1}}}$ (2.19)

ដែល $a \neq 0$ ។

**ឧទាហរណ៍ទី១០** គណនា $\int \frac{dx}{(x^2+4)^2}$ និង $\int \frac{dx}{(x^2+4)^3}$ ។

ដំណោះស្រាយ

តាមរូបមន្ត (2.19) និង (2.8) យើងបាន៖

$$\int \frac{dx}{(x^2+4)^2} = \frac{x}{2(2-1)(4)\left(x^2+4\right)} + \frac{2(2)-3}{2(2-1)(4)}\int \frac{dx}{x^2+4}$$

$$= \frac{x}{8\left(x^2+4\right)} + \frac{1}{8}\cdot\frac{1}{2}\arctan\frac{x}{2} + c$$

$$= \frac{x}{8\left(x^2+4\right)} + \frac{1}{16}\arctan\frac{x}{2} + c$$

និង $\int \frac{dx}{(x^2+4)^3} = \frac{x}{2(3-1)(4)\left(x^2+4\right)^2} + \frac{2(3)-3}{2(3-1)(4)}\int \frac{dx}{(x^2+4)^2}$

$$= \frac{x}{16\left(x^2+4\right)^2} + \frac{3}{16}\left[\frac{x}{8\left(x^2+4\right)} + \frac{1}{16}\arctan\frac{x}{2}\right] + c_1$$

$$= \frac{x}{16\left(x^2+4\right)^2} + \frac{3x}{128\left(x^2+4\right)} + \frac{3}{256}\arctan\frac{x}{2} + c_1$$ ។

## ២.៧ អាំងតេក្រាលនៃអនុគមន៍សនិទានរាង $\int \frac{dx}{(x^2-a^2)^m}$

អាំងតេក្រាល $\int \frac{dx}{(x^2-a^2)^m}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $F(x) = \frac{1}{(x^2-a^2)^m}$ ។ អនុគមន៍នេះ ជាប្រភាគសនិទាន កាលណា $m \in \mathbb{N}$ ។ យើងនឹងសិក្សាពីរករណី $m=1$ និង $m \neq 1$ ដូចតទៅ៖

- ករណី $m=1$ នោះតាមផ្នែក ២.៣ (រូបមន្ត (2.10) ) យើងបាន៖

$$\int \frac{dx}{(x^2-a^2)^m} = \int \frac{dx}{x^2-a^2} = \frac{1}{2a}\ln\left|\frac{a-x}{a+x}\right| + c_1 = \frac{1}{2a}\ln\left|\frac{x-a}{x+a}\right| + c_1$$

ដែល $c_1$ ជាចំនួនថេរ និង $a \neq 0$ ។

- ករណី $m \neq 1$ យើងតាង $I_m = \int \frac{dx}{(x^2-a^2)^m}$ ។ យើងនឹងរកទំនាក់ទំនងរវាង $I_m$ និង $I_{m-1}$ ។

នាំឱ្យ $I_{m-1} = \int \frac{dx}{(x^2-a^2)^{m-1}} = \int \frac{(x^2-a^2)\,dx}{(x^2-a^2)^m}$

$$= \int \frac{x^2\,dx}{(x^2-a^2)^m} - \int \frac{a^2\,dx}{(x^2-a^2)^m}$$

$$= \int \frac{x^2\,dx}{(x^2-a^2)^m} - a^2 I_m = J_m - a^2 I_m \quad (*_1)$$

ដែល $J_m = \int \frac{x^2\,dx}{(x^2-a^2)^m}$ ។

យើងប្រើវិធីអាំងតេក្រាលដោយផ្នែក ដោយយក $u=x$ និង $dv=\dfrac{x\,dx}{\left(x^2-a^2\right)^m}$ នាំឱ្យ

$du=dx$ និង $v=\displaystyle\int\frac{x\,dx}{\left(x^2-a^2\right)^m}=\frac{1}{2}\int\left(x^2-a^2\right)^{-m}d\left(x^2-a^2\right)=\frac{-1}{2(m-1)\left(x^2-a^2\right)^{m-1}}$ ។

នាំឱ្យ $J_m=\displaystyle\int\frac{x^2\,dx}{(x^2-a^2)^m}=\int u\,dv=uv-\int v\,du$

$$=\frac{-x}{2(m-1)\left(x^2-a^2\right)^{m-1}}+\frac{1}{2(m-1)}\int\frac{dx}{(x^2-a^2)^{m-1}}$$

$$=\frac{-x}{2(m-1)\left(x^2-a^2\right)^{m-1}}+\frac{1}{2(m-1)}I_{m-1}$$ ។

ពីសមីការ $(*_1)$ យើងបាន៖

$$I_{m-1}=J_m-a^2I_m=\frac{-x}{2(m-1)\left(x^2-a^2\right)^{m-1}}+\frac{1}{2(m-1)}I_{m-1}-a^2I_m$$

នាំឱ្យ $a^2I_m=\dfrac{-x}{2(m-1)\left(x^2-a^2\right)^{m-1}}+\dfrac{3-2m}{2(m-1)}I_{m-1}$

នាំឱ្យ $I_m=\dfrac{-x}{2(m-1)a^2\left(x^2-a^2\right)^{m-1}}+\dfrac{3-2m}{2(m-1)a^2}I_{m-1}$ ។

ដូចនេះ $$\boxed{\int\frac{dx}{(x^2-a^2)^m}=\frac{-x}{2(m-1)a^2\left(x^2-a^2\right)^{m-1}}+\frac{3-2m}{2(m-1)a^2}\int\frac{dx}{(x^2-a^2)^{m-1}}}\quad(2.20)$$

ដែល $a\neq 0$ ។

**ឧទាហរណ៍ទី១១** គណនាអាំងតេក្រាលមិនកំណត់ $\displaystyle\int\frac{dx}{(x^2-4)^2}$ ។

ដំណោះស្រាយ

តាមរូបមន្ត (2.20) និង (2.10) យើងបាន៖

$$\int\frac{dx}{(x^2-4)^2}=\frac{-x}{2(2-1)(4)\left(x^2-4\right)}+\frac{3-2(2)}{2(2-1)(4)}\int\frac{dx}{x^2-4}$$

$$=-\frac{x}{8\left(x^2-4\right)}-\frac{1}{8}\int\frac{\mathrm{dx}}{\mathrm{x}^2-4}$$

$$=-\frac{x}{8\left(x^2-4\right)}-\frac{1}{8}\cdot\frac{1}{2(2)}\ln\left|\frac{x-2}{x+2}\right|+c$$

$$=-\frac{x}{8\left(x^2-4\right)}-\frac{1}{32}\ln\left|\frac{x-2}{x+2}\right|+c$$ ។

## ២.៨ អនុវត្តន៍នៃការបំបែកអនុគមន៍សនិទាន

ក្នុងផ្នែកនេះ យើងលើកយកឧទាហរណ៍មួយចំនួនដែលទាក់ទងនឹងការបំបែកប្រភាគសនិទានទៅជាប្រភាគដោយផ្នែក។ បន្ទាប់មក យើងនឹងគណនាអាំងតេក្រាល។

**ឧទាហរណ៍ទី១២** គណនាអាំងតេក្រាល $\int F(x)dx$ ដែល

$$F(x)=\frac{x^2+x-1}{(x-1)(x+1)(x-2)}$$ ។

ដំណោះស្រាយ

តាមឧទាហរណ៍ទី១ យើងមាន៖

$$F(x)=-\frac{1}{2}\cdot\frac{1}{x-1}-\frac{1}{6}\cdot\frac{1}{x+1}+\frac{5}{3}\cdot\frac{1}{x-2}$$ ។

នាំឱ្យ $\int F(x)dx=\int(-\frac{1}{2}\cdot\frac{1}{x-1}-\frac{1}{6}\cdot\frac{1}{x+1}+\frac{5}{3}\cdot\frac{1}{x-2})dx$

$$=-\frac{1}{2}\ln|x-1|-\frac{1}{6}\ln|x+1|+\frac{5}{3}\ln|x-2|+c$$ ។

**ឧទាហរណ៍ទី១៣** គណនា $\int_3^4\frac{dt}{t(t-1)(t-2)^2}$ ។

ដំណោះស្រាយ

យើងមាន $\frac{1}{t(t-1)(t-2)^2}=\frac{A}{t}+\frac{B}{t-1}+\frac{C}{(t-2)^2}+\frac{D}{t-2}$ ។

- គុណអង្គទាំងពីរនឹង $t$ រួចយក $t=0$ នាំឱ្យ $A=-\frac{1}{4}$ ។

- គុណអង្គទាំងពីរនឹង $(t-1)$ រួចយក $t=1$ នាំឱ្យ $B=1$ ។

- គុណអង្គទាំងពីរនឹង $(t-2)^2$ រួចយក $t=2$ នាំឱ្យ $C=\dfrac{1}{2}$ ។

- គុណអង្គទាំងពីរនឹង $t$ រួចយក $t\to+\infty$ នាំឱ្យ $0=A+B+D$ នាំឱ្យ $D=-A-B=\dfrac{1}{4}-1=-\dfrac{3}{4}$ ។

យើងបាន $$\frac{1}{t(t-1)(t-2)^2}=-\frac{1}{4t}+\frac{1}{t-1}+\frac{1}{2(t-2)^2}-\frac{3}{4(t-2)}$$

$$=-\frac{1}{4}\cdot\frac{1}{t}+\frac{1}{t-1}+\frac{1}{2}(t-2)^{-2}-\frac{3}{4}\cdot\frac{1}{(t-2)}\text{ ។}$$

នាំឱ្យ $$\int_3^4\frac{dt}{t(t-1)(t-2)^2}=\int_3^4\left(-\frac{1}{4}\cdot\frac{1}{t}+\frac{1}{t-1}+\frac{1}{2}(t-2)^{-2}-\frac{3}{4}\cdot\frac{1}{(t-2)}\right)dt$$

$$=-\frac{1}{4}\ln|t|+\ln|t-1|+\frac{1}{2}\cdot\frac{(t-2)^{-1}}{(-1)}-\frac{3}{4}\ln|t-2|\Bigg|_3^4$$

$$=\left(-\frac{1}{4}\ln 4+\ln 3+\frac{1}{2}\cdot\frac{2^{-1}}{(-1)}-\frac{3}{4}\ln 2\right)-\left(-\frac{1}{4}\ln 3+\ln 2+\frac{1}{2}\cdot\frac{1}{(-1)}-\frac{3}{4}\ln 1\right)$$

$$=\frac{-\ln 4+5\ln 3+1-7\ln 2}{4}\approx 0.0637\text{ ។}$$

**ឧទាហរណ៍ទី១៤** គណនា $\int_0^1\dfrac{u\,du}{u^3+1}$ ។

ដំណោះស្រាយ

យើងមាន $$\frac{u}{u^3+1}=\frac{u}{(u+1)(u^2-u+1)}=\frac{A}{u+1}+\frac{Bu+C}{u^2-u+1}\text{ ។}$$

- គុណអង្គទាំងពីរនឹង $(u+1)$ រួចយក $u=-1$ នាំឱ្យ $A=\dfrac{-1}{1+1+1}=-\dfrac{1}{3}$ ។

- គុណអង្គទាំងពីរនឹង $u$ រួចយក $u\to+\infty$ នាំឱ្យ $0=A+B$ នាំឱ្យ $B=-A=-\left(-\dfrac{1}{3}\right)=\dfrac{1}{3}$ ។

- យក $u=0$ នាំឱ្យ $A+C=0$ នាំឱ្យ $C=-A=-\left(-\dfrac{1}{3}\right)=\dfrac{1}{3}$ ។

យើងបាន $$\frac{u}{u^3+1}=-\frac{1}{3}\cdot\frac{1}{u+1}+\frac{1}{3}\cdot\frac{u+1}{u^2-u+1}$$

$$=-\frac{1}{3}\cdot\frac{1}{u+1}+\frac{1}{3}\cdot\frac{1}{2}\cdot\frac{(2u-1)+3}{u^2-u+1}$$

$$=-\frac{1}{3}\cdot\frac{1}{u+1}+\frac{1}{6}\cdot\frac{2u-1}{u^2-u+1}+\frac{1}{2}\cdot\frac{1}{\left(u-\frac{1}{2}\right)^2+\left(\frac{\sqrt{3}}{2}\right)^2}$$ ។

នាំឱ្យ $$\int_0^1\frac{u\,du}{u^3+1}=\int_0^1\left(-\frac{1}{3}\cdot\frac{1}{u+1}+\frac{1}{6}\cdot\frac{2u-1}{u^2-u+1}+\frac{1}{2}\cdot\frac{1}{\left(u-\frac{1}{2}\right)^2+\left(\frac{\sqrt{3}}{2}\right)^2}\right)du$$

$$=-\frac{1}{3}\ln|u+1|+\frac{1}{6}\ln|u^2-u+1|+\frac{1}{2}\cdot\frac{1}{\left(\sqrt{3}/2\right)}\arctan\left(\frac{u-\frac{1}{2}}{\frac{\sqrt{3}}{2}}\right)\Bigg|_0^1$$

$$=\left(-\frac{1}{3}\ln 2+\frac{1}{6}\ln 1+\frac{1}{\sqrt{3}}\arctan\frac{1}{\sqrt{3}}\right)-\left(-\frac{1}{3}\ln 1+\frac{1}{6}\ln 1+\frac{1}{\sqrt{3}}\arctan\frac{-1}{\sqrt{3}}\right)$$

$$=-\frac{1}{3}\ln 2+\frac{2}{\sqrt{3}}\arctan\frac{1}{\sqrt{3}}\approx 0.3735$$ ។

ជាសរុប ជំពូកទី២នេះបានផ្តល់នូវវិធីសាស្ត្រនៃការបំបែកអនុគមន៍សនិទានក្នុង $\mathbb{R}$ និងវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍សនិទានមួយចំនួនដូចជា $\int\frac{1}{(ax+b)^n}dx$, $\int\frac{dx}{x^2\pm a^2}$, $\int\frac{dx}{ax^2+bx+c}$, $\int\frac{(a_1x+b_1)\,dx}{ax^2+bx+c}$, $\int\frac{dx}{(x^2+a^2)^m}$ និង $\int\frac{dx}{(x^2-a^2)^m}$ ។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលនៃអនុគមន៍អសនិទាននៅក្នុងជំពូកទី៣បន្តទៀត។

# ជំពូកទី៣

# ប្រភេទអាំងតេក្រាលនៃអនុគមន៍អសនិទាន

# ( Types of Integrals of Irrational Functions )

នៅក្នុងជំពូកទី៣នេះ យើងនឹងសិក្សាតែអំពីប្រភេទអាំងតេក្រាលនៃអនុគមន៍អសនិទានមួយចំនួននិងដំណោះស្រាយរបស់វាដូចតទៅ៖

## ៣.១ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt[n]{ax+b}}dx$

អាំងតេក្រាល $\int \frac{1}{\sqrt[n]{ax+b}}dx\ (a\neq 0, n\in\mathbb{N}, n\geq 2)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\sqrt[n]{ax+b}}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \frac{1}{\sqrt[n]{ax+b}}dx$ យើងតាង $t=\sqrt[n]{ax+b}$ នាំឱ្យ

$t^n = ax+b$ និង $nt^{n-1}dt = a\,dx \Leftrightarrow dx = \frac{n}{a}t^{n-1}dt$ ។

នាំឱ្យ $\int \frac{1}{\sqrt[n]{ax+b}}dx = \int \frac{\frac{n}{a}t^{n-1}dt}{t} = \frac{n}{a}\int t^{n-2}\,dt$ ។

$$= \frac{n}{a}\cdot\frac{t^{n-1}}{(n-1)} + c = \boxed{\frac{n\sqrt[n]{(ax+b)^{n-1}}}{(n-1)a} + c} \quad (3.1)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១** គណនា $\int \frac{1}{\sqrt{3x+4}}dx$ និង $\int_1^2 \frac{1}{\sqrt[3]{5x+3}}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.1) យើងបាន៖

$$\int \frac{1}{\sqrt{3x+4}}dx = \frac{2\sqrt{3x+4}}{3}+c$$

និង $\displaystyle\int_1^2 \frac{1}{\sqrt[3]{5x+3}}dx = \left.\frac{3\sqrt[3]{(5x+3)^2}}{2\cdot 5}\right|_1^2 = \frac{3}{10}\left(\sqrt[3]{13^2}-\sqrt[3]{8^2}\right)$

$$= \frac{3}{10}\left(\sqrt[3]{169}-4\right) \approx 0.4586 \text{ ។}$$

## ៣.២ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt[n]{ax+b}\,dx$

អាំងតេក្រាល $\int \sqrt[n]{ax+b}\,dx$ $(a \neq 0, n \in \mathbb{N}, n \geq 2)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sqrt[n]{ax+b}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \sqrt[n]{ax+b}\,dx$ យើងតាង $t=\sqrt[n]{ax+b}$ នាំឱ្យ

$t^n = ax+b$ និង $nt^{n-1}dt = a\,dx \Leftrightarrow dx = \dfrac{n}{a}t^{n-1}dt$ ។

នាំឱ្យ $\displaystyle\int \sqrt[n]{ax+b}\,dx = \int t\cdot\frac{n}{a}t^{n-1}dt = \frac{n}{a}\int t^n\,dt$

$$= \frac{n}{a}\cdot\frac{t^{n+1}}{(n+1)}+c = \boxed{\frac{n\sqrt[n]{(ax+b)^{n+1}}}{(n+1)a}+c} \qquad (3.2)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី២** គណនា $\int \sqrt{3x+4}\,dx$ និង $\displaystyle\int_1^2 \sqrt[3]{5x+3}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.2) យើងបាន៖

$$\int \sqrt{3x+4}\,dx = \frac{2\sqrt{(3x+4)^{2+1}}}{(2+1)\cdot 3}+c = \frac{2\sqrt{(3x+4)^3}}{9}+c$$

និង $\displaystyle\int_1^2 \sqrt[3]{5x+3}\,dx = \left.\frac{3\sqrt[3]{(5x+3)^4}}{4\cdot 5}\right|_1^2 = \frac{3}{20}\left(\sqrt[3]{13^4}-\sqrt[3]{8^4}\right)$

$$= \frac{3}{20}\left(13\sqrt[3]{13}-16\right) \approx 2.1851 \text{ ។}$$

## ៣.៣ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt[n]{(ax+b)^m}\,dx$

អាំងតេក្រាល $\int \sqrt[n]{(ax+b)^m}\,dx$ $(a \neq 0,\ n \in \mathbb{N},\ n \geq 2,\ m \in \mathbb{Z})$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sqrt[n]{(ax+b)^m}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \sqrt[n]{(ax+b)^m}\,dx$ យើងតាង $t = \sqrt[n]{ax+b}$ នាំឱ្យ

$t^n = ax+b$ និង $nt^{n-1}dt = a\,dx \Leftrightarrow dx = \frac{n}{a}t^{n-1}dt$ ។

នាំឱ្យ $\int \sqrt[n]{(ax+b)^m}\,dx = \int t^m \cdot \frac{n}{a}t^{n-1}dt = \frac{n}{a}\int t^{m+n-1}dt \quad (*)$ ។

បន្ទាប់មក យើងសិក្សាតែករណី $m+n \neq 0$ ។

នាំឱ្យ

$$\int \sqrt[n]{(ax+b)^m}\,dx = \frac{n}{a}\int t^{m+n-1}dt = \frac{n}{a}\cdot\frac{t^{m+n}}{(m+n)} + c$$

$$= \boxed{\frac{n\sqrt[n]{(ax+b)^{m+n}}}{(m+n)a} + c} \qquad (3.3)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៣** គណនា $\int \sqrt{(3x+4)^3}\,dx$ និង $\int_1^2 \sqrt[3]{(5x+3)^4}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.3) យើងបាន៖

$$\int \sqrt{(3x+4)^3}\,dx = \frac{2\sqrt{(3x+4)^{3+2}}}{(3+2)\cdot 3} + c = \frac{2\sqrt{(3x+4)^5}}{15} + c$$

និង $$\int_1^2 \sqrt[3]{(5x+3)^4}\,dx = \left.\frac{3\sqrt[3]{(5x+3)^{4+3}}}{(4+3)\cdot 5}\right|_1^2 = \frac{3}{35}\left(\sqrt[3]{13^7} - \sqrt[3]{8^7}\right)$$

$$= \frac{3}{35}\left(169\sqrt[3]{13} - 128\right) \approx 23.0893$$ ។

## ៣.៤ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt{k-x^2}}dx$

អាំងតេក្រាល $\int \frac{1}{\sqrt{k-x^2}}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\sqrt{k-x^2}}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \frac{1}{\sqrt{k-x^2}}dx$ យើងអាចតាង $\mathrm{x}=\sqrt{\mathrm{k}}\sin \mathrm{t}\ (\mathrm{k}>0)$ ឬ $\mathrm{x}=\sqrt{\mathrm{k}}\cos \mathrm{t}\ (\mathrm{k}>0)$ ។

បើយើងតាង $\mathrm{x}=\sqrt{\mathrm{k}}\sin \mathrm{t}\ (\mathrm{k}>0)$ នាំឱ្យ $\mathrm{t}=\arcsin\frac{\mathrm{x}}{\sqrt{\mathrm{k}}}=\sin^{-1}\frac{\mathrm{x}}{\sqrt{\mathrm{k}}}$ និង $\mathrm{dx}=\sqrt{\mathrm{k}}\cos \mathrm{t}\,\mathrm{dt}$ ។

នាំឱ្យ $$\int \frac{1}{\sqrt{k-x^2}}dx=\int \frac{\sqrt{k}\cos t\,dt}{\sqrt{k-k\sin^2 t}}=\int \frac{\sqrt{k}\cos t\,dt}{\sqrt{k}\cos t}$$

$$=\int dt=t+c=\boxed{\sin^{-1}\frac{x}{\sqrt{k}}+c} \qquad (3.4)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៤** គណនា $\int \frac{1}{\sqrt{5-x^2}}dx$ និង $\int_0^1 \frac{1}{\sqrt{16-9x^2}}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.4) យើងបាន៖

$$\int \frac{1}{\sqrt{5-x^2}}dx=\sin^{-1}\frac{x}{\sqrt{5}}+c$$

និង $$\int_0^1 \frac{1}{\sqrt{16-9x^2}}dx=\int_0^1 \frac{1}{\sqrt{9(\frac{16}{9}-x^2)}}dx=\frac{1}{3}\int_0^1 \frac{1}{\sqrt{\frac{16}{9}-x^2}}dx$$

$$=\frac{1}{3}\sin^{-1}\frac{x}{\sqrt{\frac{16}{9}}}\Bigg|_0^1=\frac{1}{3}\sin^{-1}\frac{3x}{4}\Bigg|_0^1$$

$$=\frac{1}{3}\left(\sin^{-1}\frac{3}{4}-\sin^{-1}0\right)=\frac{1}{3}\sin^{-1}\frac{3}{4}\approx 0.2826$$ ។

## ៣.៥ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt{x^2+k}}dx$

អាំងតេក្រាល $\int \frac{1}{\sqrt{x^2+k}}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\sqrt{x^2+k}}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \frac{1}{\sqrt{x^2+k}}dx$ យើងអាចតាង $x=\sqrt{k}\tan t\ (k>0)$ ឬ $t=x+\sqrt{x^2+k}$ ។

**របៀបទី១** យើងតាង $x=\sqrt{k}\tan t\ (k>0)$ នាំឱ្យ $t=\arctan\frac{x}{\sqrt{k}}=\tan^{-1}\frac{x}{\sqrt{k}}$ ,

$\sec t=\frac{1}{\cos t}=\sqrt{1+\frac{x^2}{k}}=\sqrt{x^2+k}\ /\sqrt{k}$ និង $dx=\sqrt{k}\frac{dt}{\cos^2 t}$ ។

នាំឱ្យ $$\int \frac{1}{\sqrt{x^2+k}}dx=\int \frac{1}{\sqrt{k\tan^2 t+k}}\cdot\frac{\sqrt{k}\,dt}{\cos^2 t}$$

$$=\int \frac{1}{\sqrt{k}\,(1/\cos t)}\cdot\frac{\sqrt{k}\,dt}{\cos^2 t}=\int \frac{\cos t\,dt}{1-\sin^2 t}\ (*)$$ ។

បន្ទាប់មក យើងតាង $u=\sin t$ នាំឱ្យ $du=\cos t\,dt$ និងពីសមីការ $(*)$ ទៅជា៖

$$\int \frac{1}{\sqrt{x^2+k}}dx=\int \frac{\cos t\,dt}{1-\sin^2 t}=\int \frac{du}{1-u^2}$$

$$=\int \frac{(1+u)+(1-u)}{2(1-u)(1+u)}du=\int\left(\frac{1}{2(1-u)}+\frac{1}{2(1+u)}\right)du$$

$$=\frac{1}{2}\ln\left|\frac{1+\sin t}{1-\sin t}\right|+c=\frac{1}{2}\ln\left|\frac{1/\cos t+\tan t}{1/\cos t-\tan t}\right|+c$$

$$=\frac{1}{2}\ln\left|\frac{\sqrt{x^2+k}\,/\sqrt{k}+x/\sqrt{k}}{\sqrt{x^2+k}\,/\sqrt{k}-x/\sqrt{k}}\right|+c=\frac{1}{2}\ln\left|\frac{\sqrt{x^2+k}+x}{\sqrt{x^2+k}-x}\right|+c$$

$$=\frac{1}{2}\ln\left|\frac{(\sqrt{x^2+k}+x)^2}{x^2+k-x^2}\right|+c=\ln\left|x+\sqrt{x^2+k}\right|+c_1$$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ។

**របៀបទី២** យើងតាង $t = x + \sqrt{x^2 + k}$ នាំឱ្យ

$$dt = \left( x + \sqrt{x^2 + k} \right)' dx = \left( 1 + \frac{2x}{2\sqrt{x^2 + k}} \right) dx$$

$$= \left( \frac{x + \sqrt{x^2 + k}}{\sqrt{x^2 + k}} \right) dx = \frac{t}{\sqrt{x^2 + k}} dx$$

និង $\frac{1}{\sqrt{x^2 + k}} dx = \frac{dt}{t}$ ។

នាំឱ្យ $\int \frac{1}{\sqrt{x^2 + k}} dx = \int \frac{dt}{t} = \ln|t| + c = \ln\left| x + \sqrt{x^2 + k} \right| + c$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត $\int \frac{1}{\sqrt{x^2 + k}} dx = \boxed{\ln\left| x + \sqrt{x^2 + k} \right| + c}$ (3.5) ។

**ឧទាហរណ៍ទី៥** គណនា $\int \frac{1}{\sqrt{x^2 + 2}} dx$ និង $\int_0^1 \frac{1}{\sqrt{16 + 9x^2}} dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.5) យើងបាន៖

$$\int \frac{1}{\sqrt{x^2 + 2}} dx = \ln\left| x + \sqrt{x^2 + 2} \right| + c = \ln\left( x + \sqrt{x^2 + 2} \right) + c$$

និង $$\int_0^1 \frac{1}{\sqrt{16 + 9x^2}} dx = \int_0^1 \frac{1}{\sqrt{9(\frac{16}{9} + x^2)}} dx = \frac{1}{3} \int_0^1 \frac{1}{\sqrt{x^2 + \frac{16}{9}}} dx$$

$$= \frac{1}{3} \ln\left| x + \sqrt{x^2 + \frac{16}{9}} \right| \Bigg|_0^1$$

$$= \frac{1}{3} \ln\left| 1 + \sqrt{1 + \frac{16}{9}} \right| - \frac{1}{3} \ln\left| 0 + \sqrt{0 + \frac{16}{9}} \right|$$

$$= \frac{1}{3} \ln 2 \approx 0.2310$$ ។

## ៣.៦ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \frac{1}{\sqrt{x^2-k}}dx$

អាំងតេក្រាល $\int \frac{1}{\sqrt{x^2-k}}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\sqrt{x^2-k}}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \frac{1}{\sqrt{x^2-k}}dx$ យើងអាចតាង $x=\sqrt{k}\sec t=\frac{\sqrt{k}}{\cos t}$ $(k>0)$ ឬ $t=x+\sqrt{x^2-k}$ ។

**របៀបទី១** យើងតាង $x=\sqrt{k}\sec t=\frac{\sqrt{k}}{\cos t}$ $(k>0)$ នាំឱ្យ $\frac{1}{\cos t}=\frac{x}{\sqrt{k}}$ ,

$t=\arccos\frac{\sqrt{k}}{x}=\cos^{-1}\frac{\sqrt{k}}{x}$ , $\tan t=\frac{\sqrt{x^2-k}}{\sqrt{k}}$ និង $dx=\frac{\sqrt{k}\sin t\,dt}{\cos^2 t}$ ។

នាំឱ្យ $\int \frac{1}{\sqrt{x^2-k}}dx=\int \frac{1}{\sqrt{k}\tan t}\cdot\frac{\sqrt{k}\sin t\,dt}{\cos^2 t}=\int\frac{dt}{\cos t}$

$$=\frac{1}{2}\ln\left|\frac{1+\sin t}{1-\sin t}\right|+c=\frac{1}{2}\ln\left|\frac{1/\cos t+\tan t}{1/\cos t-\tan t}\right|+c \text{ (តាមផ្នែក ៣.៥)}$$

$$=\frac{1}{2}\ln\left|\frac{x/\sqrt{k}+\sqrt{x^2-k}/\sqrt{k}}{x/\sqrt{k}-\sqrt{x^2-k}/\sqrt{k}}\right|+c=\frac{1}{2}\ln\left|\frac{x+\sqrt{x^2-k}}{x-\sqrt{x^2-k}}\right|+c$$

$$=\frac{1}{2}\ln\left|\frac{(x+\sqrt{x^2-k})^2}{x^2-x^2+k}\right|+c=\ln\left|x+\sqrt{x^2-k}\right|+c_1$$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ។

**របៀបទី២** យើងតាង $t=x+\sqrt{x^2-k}$ នាំឱ្យ

$$dt=\left(x+\sqrt{x^2-k}\right)'dx=\left(1+\frac{2x}{2\sqrt{x^2-k}}\right)dx=\left(\frac{x+\sqrt{x^2-k}}{\sqrt{x^2-k}}\right)dx=\frac{t}{\sqrt{x^2-k}}dx$$

និង $\frac{1}{\sqrt{x^2-k}}dx=\frac{dt}{t}$ ។

នាំឱ្យ $\int \frac{1}{\sqrt{x^2-k}}dx=\int\frac{dt}{t}=\ln|t|+c=\ln\left|x+\sqrt{x^2-k}\right|+c$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត $\int \frac{1}{\sqrt{x^2-k}}dx = \boxed{\ln\left|x+\sqrt{x^2-k}\right|+c}$ (3.6) ។

**ឧទាហរណ៍ទី៦** គណនា $\int \frac{1}{\sqrt{x^2-5}}dx$ និង $\int_2^4 \frac{1}{\sqrt{9x^2-16}}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.6) យើងបាន៖

$$\int \frac{1}{\sqrt{x^2-5}}dx = \ln\left|x+\sqrt{x^2-5}\right|+c$$

និង $$\int_2^4 \frac{1}{\sqrt{9x^2-16}}dx = \int_2^4 \frac{1}{\sqrt{9(x^2-\frac{16}{9})}}dx = \frac{1}{3}\int_2^4 \frac{1}{\sqrt{x^2-\frac{16}{9}}}dx$$

$$= \frac{1}{3}\ln\left|x+\sqrt{x^2-\frac{16}{9}}\right|\Bigg|_2^4$$

$$= \frac{1}{3}\ln\left|4+\sqrt{4^2-\frac{16}{9}}\right| - \frac{1}{3}\ln\left|2+\sqrt{2^2-\frac{16}{9}}\right|$$

$$= \frac{1}{3}\ln\left(\frac{6+4\sqrt{2}}{3+\sqrt{5}}\right) \approx 0.2667 \text{ ។}$$

## ៣.៧ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int \sqrt{k-x^2}\,dx$

អាំងតេក្រាល $\int \sqrt{k-x^2}\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sqrt{k-x^2}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int \sqrt{k-x^2}\,dx$ យើងអាចតាង $x=\sqrt{k}\sin t$ $(k>0)$ ឬ $x=\sqrt{k}\cos t$ $(k>0)$ ឬក៏យើងអាចប្រើវិធីអាំងតេក្រាលដោយផ្នែក។

**របៀបទី១** យើងតាង $x=\sqrt{k}\sin t$ $(k>0)$ នាំឱ្យ

$\sin t = \frac{x}{\sqrt{k}}$ , $t = \arcsin\frac{x}{\sqrt{k}} = \sin^{-1}\frac{x}{\sqrt{k}}$ និង $dx=\sqrt{k}\cos t\,dt$ ។

នាំឱ្យ $\int \sqrt{k-x^2}\,dx = \int \sqrt{k-k\sin^2 t}\cdot\sqrt{k}\cos t\,dt = k\int \cos^2 t\,dt$

$$=k\int\frac{1+\cos 2t}{2}dt=\frac{k}{2}\left(t+\frac{1}{2}\sin 2t\right)+c$$

$$=\frac{k}{2}\left(t+\frac{1}{2}2\sin t\cos t\right)+c=\frac{k}{2}\left(t+\sin t\sqrt{1-\sin^2 t}\right)+c$$

$$=\frac{k}{2}\left(\sin^{-1}\frac{x}{\sqrt{k}}+\frac{x}{\sqrt{k}}\sqrt{1-\frac{x^2}{k}}\right)+c$$

$$=\frac{k}{2}\sin^{-1}\frac{x}{\sqrt{k}}+\frac{1}{2}x\sqrt{k-x^2}+c$$

ដែល $c$ ជាចំនួនពិតថេរ។

**របៀបទី២** យើងប្រើវិធីអាំងតេក្រាលដោយផ្នែក។

យើងមាន $\int\sqrt{k-x^2}\,dx=\int\frac{k-x^2}{\sqrt{k-x^2}}dx=k\int\frac{dx}{\sqrt{k-x^2}}-\int\frac{x^2}{\sqrt{k-x^2}}dx\quad(*)$ ។

យើងយក $u=x$ នាំឱ្យ $du=dx$

និង $dv=\frac{x}{\sqrt{k-x^2}}dx$ នាំឱ្យ $v=\int dv=\int\frac{x}{\sqrt{k-x^2}}dx=-\frac{1}{2}\int(k-x^2)^{-\frac{1}{2}}d\left(k-x^2\right)$

$$=-\frac{1}{2}\cdot\frac{(k-x^2)^{\frac{1}{2}}}{(1/2)}=-\sqrt{k-x^2}$$ ។

នាំឱ្យ $\int\frac{x^2}{\sqrt{k-x^2}}dx=\int u\,dv=uv-\int v\,du$

$$=-x\sqrt{k-x^2}+\int\sqrt{k-x^2}\,dx$$

និងតាមសមីការ $(*)$ នាំឱ្យ

$$\int\sqrt{k-x^2}\,dx=k\int\frac{dx}{\sqrt{k-x^2}}+x\sqrt{k-x^2}-\int\sqrt{k-x^2}\,dx$$

$$\Leftrightarrow\quad 2\int\sqrt{k-x^2}\,dx=k\int\frac{dx}{\sqrt{k-x^2}}+x\sqrt{k-x^2}$$

$$\Rightarrow\quad\int\sqrt{k-x^2}\,dx=\frac{k}{2}\int\frac{dx}{\sqrt{k-x^2}}+\frac{1}{2}x\sqrt{k-x^2}$$

$$=\frac{k}{2}\sin^{-1}\frac{x}{\sqrt{k}}+\frac{1}{2}x\sqrt{k-x^2}+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត $\int\sqrt{k-x^2}\,dx=\boxed{\frac{1}{2}x\sqrt{k-x^2}+\frac{k}{2}\sin^{-1}\frac{x}{\sqrt{k}}+c}$ (3.7) ។

**ឧទាហរណ៍ទី៧** គណនា $\int\sqrt{5-x^2}\,dx$ និង $\int_0^1\sqrt{16-9x^2}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.7) យើងបាន៖

$$\int\sqrt{5-x^2}\,dx=\frac{1}{2}x\sqrt{5-x^2}+\frac{5}{2}\sin^{-1}\frac{x}{\sqrt{5}}+c$$

និង $$\int_0^1\sqrt{16-9x^2}\,dx=\int_0^1\sqrt{9(\frac{16}{9}-x^2)}\,dx=3\int_0^1\sqrt{\frac{16}{9}-x^2}\,dx$$

$$=\left.\frac{3}{2}x\sqrt{\frac{16}{9}-x^2}+\frac{3}{2}\cdot\frac{16}{9}\sin^{-1}\frac{x}{\sqrt{\frac{16}{9}}}\right|_0^1$$

$$=\left.\frac{3}{2}x\sqrt{\frac{16}{9}-x^2}+\frac{8}{3}\sin^{-1}\frac{3x}{4}\right|_0^1$$

$$=\frac{3}{2}\sqrt{\frac{16}{9}-1}+\frac{8}{3}\left(\sin^{-1}\frac{3}{4}-\sin^{-1}0\right)$$

$$=\frac{\sqrt{7}}{2}+\frac{8}{3}\sin^{-1}\frac{3}{4}\approx 3.5843$$ ។

## ៣.៨ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int\sqrt{x^2+k}\,dx$

អាំងតេក្រាល $\int\sqrt{x^2+k}\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sqrt{x^2+k}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int\sqrt{x^2+k}\,dx$ យើងអាចតាង $\mathrm{x}=\sqrt{\mathrm{k}}\tan \mathrm{t}\ (\mathrm{k}>0)$ ឬក៏យើងអាចប្រើវិធីអាំងតេក្រាលដោយផ្នែក។

ឥឡូវនេះ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក។

យើងមាន $\int\sqrt{x^2+k}\,dx=\int\frac{x^2+k}{\sqrt{x^2+k}}dx=\int\frac{x^2}{\sqrt{x^2+k}}dx+k\int\frac{dx}{\sqrt{x^2+k}}\quad(*)$ ។

យើងយក $u=x$ នាំឱ្យ $du=dx$

និង $dv=\frac{x}{\sqrt{x^2+k}}dx$ នាំឱ្យ $v=\int dv=\int\frac{x}{\sqrt{x^2+k}}dx=\frac{1}{2}\int(x^2+k)^{-\frac{1}{2}}d\left(x^2+k\right)$

$$=\frac{1}{2}\cdot\frac{(x^2+k)^{\frac{1}{2}}}{(1/2)}=\sqrt{x^2+k}\text{ ។}$$

នាំឱ្យ $\int\frac{x^2}{\sqrt{x^2+k}}dx=x\sqrt{x^2+k}-\int\sqrt{x^2+k}\,dx$

និងតាមសមីការ $(*)$ នាំឱ្យ

$$\int\sqrt{x^2+k}\,dx=x\sqrt{x^2+k}-\int\sqrt{x^2+k}\,dx+k\int\frac{dx}{\sqrt{x^2+k}}$$

$$\Leftrightarrow\quad 2\int\sqrt{x^2+k}\,dx=x\sqrt{x^2+k}+k\int\frac{dx}{\sqrt{x^2+k}}$$

$$\Rightarrow\quad \int\sqrt{x^2+k}\,dx=\frac{1}{2}x\sqrt{x^2+k}+\frac{k}{2}\int\frac{dx}{\sqrt{x^2+k}}$$

$$=\frac{1}{2}x\sqrt{x^2+k}+\frac{k}{2}\ln\left|x+\sqrt{x^2+k}\right|+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត $\int\sqrt{x^2+k}\,dx=\boxed{\frac{1}{2}x\sqrt{x^2+k}+\frac{k}{2}\ln\left|x+\sqrt{x^2+k}\right|+c}\quad(3.8)$ ។

**ឧទាហរណ៍ទី៨** គណនា $\int\sqrt{x^2+5}\,dx$ និង $\int_0^1\sqrt{16+9x^2}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.8) យើងបាន៖

$$\int\sqrt{x^2+5}\,dx=\frac{1}{2}x\sqrt{x^2+5}+\frac{5}{2}\ln\left|x+\sqrt{x^2+5}\right|+c$$

និង $$\int_0^1\sqrt{16+9x^2}\,dx=\int_0^1\sqrt{9(\frac{16}{9}+x^2)}\,dx=3\int_0^1\sqrt{x^2+\frac{16}{9}}\,dx$$

$$=\frac{3}{2}x\sqrt{x^2+\frac{16}{9}}+\frac{3}{2}\cdot\frac{16}{9}\ln\left|x+\sqrt{x^2+\frac{16}{9}}\right|\Bigg|_0^1$$

$$=\frac{3}{2}\sqrt{1+\frac{16}{9}}+\frac{8}{3}\ln\left|1+\sqrt{1+\frac{16}{9}}\right|-\frac{8}{3}\ln\left|0+\sqrt{0+\frac{16}{9}}\right|$$

$$=\frac{5}{2}+\frac{8}{3}\ln\frac{8}{3}-\frac{8}{3}\ln\frac{4}{3}=\frac{5}{2}+\frac{8}{3}\ln 2\approx 4.3483$$ ។

## ៣.៩ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int\sqrt{x^2-k}\,dx$

អាំងតេក្រាល $\int\sqrt{x^2-k}\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sqrt{x^2-k}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int\sqrt{x^2-k}\,dx$ យើងអាចតាង $\mathrm{x}=\sqrt{\mathrm{k}}\sec\mathrm{t}=\frac{\sqrt{\mathrm{k}}}{\cos\mathrm{t}}$ $(\mathrm{k}>0)$ ឬក៏យើងអាចប្រើវិធីអាំងតេក្រាលដោយផ្នែក។

ឥឡូវនេះ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក។

យើងមាន $\int\sqrt{x^2-k}\,dx=\int\frac{x^2-k}{\sqrt{x^2-k}}dx=\int\frac{x^2}{\sqrt{x^2-k}}dx-k\int\frac{dx}{\sqrt{x^2-k}}$ $(*)$ ។

យើងយក $u=x$ នាំឱ្យ $du=dx$

និង $dv=\frac{x}{\sqrt{x^2-k}}dx$ នាំឱ្យ $v=\int dv=\int\frac{x}{\sqrt{x^2-k}}dx=\frac{1}{2}\int(x^2-k)^{-\frac{1}{2}}d\left(x^2-k\right)$

$$=\frac{1}{2}\cdot\frac{(x^2-k)^{\frac{1}{2}}}{(1/2)}=\sqrt{x^2-k}$$ ។

នាំឱ្យ $\int\frac{x^2}{\sqrt{x^2-k}}dx=x\sqrt{x^2-k}-\int\sqrt{x^2-k}\,dx$

និងតាមសមីការ $(*)$ នាំឱ្យ

$$\int\sqrt{x^2-k}\,dx = x\sqrt{x^2-k}-\int\sqrt{x^2-k}\,dx-k\int\frac{dx}{\sqrt{x^2-k}}$$

$$\Leftrightarrow\quad 2\int\sqrt{x^2-k}\,dx = x\sqrt{x^2-k}-k\int\frac{dx}{\sqrt{x^2-k}}$$

$$\Rightarrow\quad \int\sqrt{x^2-k}\,dx = \frac{1}{2}x\sqrt{x^2-k}-\frac{k}{2}\int\frac{dx}{\sqrt{x^2-k}}$$

$$=\frac{1}{2}x\sqrt{x^2-k}-\frac{k}{2}\ln\left|x+\sqrt{x^2-k}\right|+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត $\int\sqrt{x^2-k}\,dx = \boxed{\frac{1}{2}x\sqrt{x^2-k}-\frac{k}{2}\ln\left|x+\sqrt{x^2-k}\right|+c}$ (3.9) ។

**ឧទាហរណ៍ទី៩** គណនា $\int\sqrt{x^2-5}\,dx$ និង $\int_2^4\sqrt{9x^2-16}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.9) យើងបាន៖

$$\int\sqrt{x^2-5}\,dx = \frac{1}{2}x\sqrt{x^2-5}-\frac{5}{2}\ln\left|x+\sqrt{x^2-5}\right|+c$$

និង $$\int_2^4\sqrt{9x^2-16}\,dx = \int_2^4\sqrt{9(x^2-\frac{16}{9})}\,dx = 3\int_2^4\sqrt{x^2-\frac{16}{9}}\,dx$$

$$=\frac{3}{2}x\sqrt{x^2-\frac{16}{9}}-\frac{3}{2}\cdot\frac{16}{9}\ln\left|x+\sqrt{x^2-\frac{16}{9}}\right|\Bigg|_2^4$$

$$=\frac{3}{2}\cdot4\cdot\sqrt{4^2-\frac{16}{9}}-\frac{8}{3}\ln\left|4+\sqrt{4^2-\frac{16}{9}}\right|-\frac{3}{2}\cdot2\cdot\sqrt{2^2-\frac{16}{9}}+\frac{8}{3}\ln\left|2+\sqrt{2^2-\frac{16}{9}}\right|$$

$$=16\sqrt{2}-2\sqrt{5}+\frac{8}{3}\ln\frac{3+\sqrt{5}}{6+4\sqrt{2}}\approx 16.0210$$ ។

## ៣.១០ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int(\alpha x+\beta)\sqrt{ax+b}\,dx$

អាំងតេក្រាល $\int(\alpha x+\beta)\sqrt{ax+b}\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមាន អនុគមន៍អាំងតេក្រាល $(\alpha x+\beta)\sqrt{ax+b}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int(\alpha x+\beta)\sqrt{ax+b}\,dx$ យើងតាង $\mathrm{t}=\sqrt{\mathrm{a\,x+b}}$ $(\mathrm{a}\neq 0)$ នាំឱ្យ $t^2=ax+b$ , $x=\dfrac{t^2-b}{a}$ និង $2t\,dt=a\,dx\Leftrightarrow dx=\dfrac{2}{a}t\,dt$ ។

នាំឱ្យ $$\int(\alpha x+\beta)\sqrt{ax+b}\,dx=\int\left[\alpha\left(\frac{t^2-b}{a}\right)+\beta\right]t\cdot\frac{2}{a}t\,dt$$

$$=\frac{2}{a^2}\left[\alpha\frac{t^5}{5}+(a\beta-\alpha b)\frac{t^3}{3}\right]+c$$

$$=\frac{2\alpha}{5a^2}t^5+\frac{2(a\beta-\alpha b)}{3a^2}t^3+c$$

$$=\boxed{\frac{2\alpha}{5a^2}\sqrt{(ax+b)^5}+\frac{2(a\beta-\alpha b)}{3a^2}\sqrt{(ax+b)^3}+c}\quad(3.10)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១០** គណនា $\int(6x+5)\sqrt{3x+4}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (3.10) យើងបាន៖

$$\int(6x+5)\sqrt{3x+4}\,dx=\frac{2\cdot 6}{5\cdot 3^2}\sqrt{(3x+4)^5}+\frac{2(3\cdot 5-6\cdot 4)}{3\cdot 3^2}\sqrt{(3x+4)^3}+c$$

$$=\frac{4}{15}\sqrt{(3x+4)^5}-\frac{2}{3}\sqrt{(3x+4)^3}+c \text{ ។}$$

## ៣.១១ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}$

អាំងតេក្រាល $\int\dfrac{dx}{(\alpha x+\beta)\sqrt{ax+b}}$ $(a\neq 0,\ \alpha\neq 0)$ ជាអាំងតេក្រាលមិនកំណត់

ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{(\alpha x+\beta)\sqrt{ax+b}}$ ជាអនុគមន៍អសនិទាន។

ដើម្បីគណនាអាំងតេក្រាល $\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}$ យើងតាង $t=\sqrt{ax+b}$ នាំឱ្យ

$t^2=ax+b,\ x=\frac{t^2-b}{a}$ និង $2t\,dt=a\,dx\Leftrightarrow dx=\frac{2}{a}t\,dt$ ។

នាំឱ្យ $$\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}=\int\frac{\frac{2t\,dt}{a}}{(\alpha(\frac{t^2-b}{a})+\beta)t}=\frac{2}{a}\int\frac{dt}{\frac{\alpha t^2-\alpha b+a\beta}{a}}$$

- បើ $k=0$ នោះពីសមីការ $(*)$ នាំឱ្យ

$$\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}=\frac{2}{\alpha}\int\frac{dt}{t^2}=\frac{2}{\alpha}\int t^{-2}dt$$

$$=\frac{2}{\alpha}\frac{t^{-1}}{(-1)}+c=-\frac{2}{\alpha t}+c=\boxed{-\frac{2}{\alpha\sqrt{ax+b}}+c}\quad(3.11)$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $k>0$ នោះពីសមីការ $(*)$ និងតាមផ្នែក ១.២.៣ នាំឱ្យ

$$\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}=\frac{2}{\alpha}\int\frac{dt}{t^2+(\sqrt{k})^2}=\frac{2}{\alpha}\cdot\frac{1}{\sqrt{k}}\tan^{-1}\left(\frac{t}{\sqrt{k}}\right)+c$$

$$=\boxed{\frac{2}{\alpha\sqrt{k}}\tan^{-1}\left(\frac{\sqrt{ax+b}}{\sqrt{k}}\right)+c}\quad(3.12)$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $k<0$ នោះពីសមីការ $(*)$ និងតាមផ្នែក ១.២.៣ នាំឱ្យ

$$\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}=\frac{2}{\alpha}\int\frac{dt}{t^2-(\sqrt{-k})^2}=\frac{2}{\alpha}\cdot\frac{1}{2\sqrt{-k}}\ln\left|\frac{t-\sqrt{-k}}{t+\sqrt{-k}}\right|+c$$

$$=\boxed{\frac{1}{\alpha\sqrt{-k}}\ln\left|\frac{\sqrt{ax+b}-\sqrt{-k}}{\sqrt{ax+b}+\sqrt{-k}}\right|+c}\quad(3.13)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១១** គណនា $\int\frac{dx}{(2x+3)\sqrt{2x+3}}$ , $\int\frac{dx}{(2x+5)\sqrt{4x+3}}$ និង $\int\frac{dx}{(4x+3)\sqrt{2x+5}}$ ។

ដំណោះស្រាយ

ចំពោះអាំងតេក្រាល $\int\frac{dx}{(2x+3)\sqrt{2x+3}}$ មាន $k=\frac{a\beta-\alpha b}{\alpha}=\frac{2(3)-2(3)}{2}=0$ ។

នោះតាមរូបមន្ត (3.11) យើងបាន៖

$$\int\frac{dx}{(2x+3)\sqrt{2x+3}}=-\frac{2}{2\sqrt{2x+3}}+c=-\frac{1}{\sqrt{2x+3}}+c$$

ចំពោះអាំងតេក្រាល $\int\frac{dx}{(2x+5)\sqrt{4x+3}}$ មាន $k=\frac{a\beta-\alpha b}{\alpha}=\frac{4(5)-2(3)}{2}=7>0$ ។

នោះតាមរូបមន្ត (3.12) យើងបាន៖

$$\int\frac{dx}{(2x+5)\sqrt{4x+3}}=\frac{2}{2\sqrt{7}}\tan^{-1}\left(\frac{\sqrt{4x+3}}{\sqrt{7}}\right)+c=\frac{1}{\sqrt{7}}\tan^{-1}\left(\frac{\sqrt{4x+3}}{\sqrt{7}}\right)+c$$

និងចំពោះអាំងតេក្រាល $\int\frac{dx}{(4x+3)\sqrt{2x+5}}$ មាន

$$k=\frac{a\beta-\alpha b}{\alpha}=\frac{2(3)-4(5)}{4}=-3.5<0$$ ។

នោះតាមរូបមន្ត (3.13) យើងបាន៖

$$\int\frac{dx}{(4x+3)\sqrt{2x+5}}=\frac{1}{4\sqrt{3.5}}\ln\left|\frac{\sqrt{2x+5}-\sqrt{3.5}}{\sqrt{2x+5}+\sqrt{3.5}}\right|+c$$ ។

## ៣.១២ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int\frac{dx}{\sqrt{ax^2+bx+c}}$

អាំងតេក្រាល $\int\frac{dx}{\sqrt{ax^2+bx+c}}$ $(a\neq 0)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\sqrt{ax^2+bx+c}}$ ជាអនុគមន៍អសនិទាន។ អនុគមន៍នេះមានត្រីធា $ax^2+bx+c$ $(a\neq 0)$ ។

យើងនឹងសិក្សាតាម $\Delta = b^2 - 4ac$ ដើម្បីស្វែងរកឫសនៃត្រីធានេះ។

១. ករណី $\Delta = 0$ នោះត្រីធាមានឫសឌុបគឺ $x_1 = x_2 = -\dfrac{b}{2a}$ ។

នាំឱ្យ $ax^2 + bx + c = a\left(x + \dfrac{b}{2a}\right)^2$ , $\sqrt{ax^2 + bx + c} = \sqrt{a}\left|x + \dfrac{b}{2a}\right|$ $(a > 0)$ និង

$$\int \frac{dx}{\sqrt{ax^2 + bx + c}} = \frac{1}{\sqrt{a}} \int \frac{dx}{\left(x + \frac{b}{2a}\right)} = \frac{1}{\sqrt{a}} \ln\left|x + \frac{b}{2a}\right| + c_1$$

$$= \boxed{\frac{1}{\sqrt{a}} \ln|2ax + b| + c_2} \qquad (3.14)$$

ដែល $c_1, c_2$ ជាចំនួនថេរ និង $a > 0$ ។

២. ករណី $\Delta > 0$ នោះត្រីធាមានឫសពីរផ្សេងគ្នាគឺ $x_1 = \dfrac{-b + \sqrt{\Delta}}{2a}$ ឬ $x_2 = \dfrac{-b - \sqrt{\Delta}}{2a}$ ។

នាំឱ្យ $ax^2 + bx + c = a\left[\left(x + \dfrac{b}{2a}\right)^2 + \dfrac{4ac - b^2}{4a^2}\right] = a\left[\left(x + \dfrac{b}{2a}\right)^2 - \dfrac{\Delta}{4a^2}\right]$

$$= a(x - x_1)(x - x_2)$$

និងយើងតាង $t = x + \dfrac{b}{2a}$ នាំឱ្យ $dx = dt$ ។

- ប្រសិនបើ $a > 0$ នាំឱ្យ

$$\int \frac{dx}{\sqrt{ax^2 + bx + c}} = \frac{1}{\sqrt{a}} \int \frac{dx}{\sqrt{\left(x + \frac{b}{2a}\right)^2 - \frac{\Delta}{4a^2}}}$$

$$= \frac{1}{\sqrt{a}} \ln\left|x + \frac{b}{2a} + \sqrt{(x + \frac{b}{2a})^2 - \frac{\Delta}{4a^2}}\right| + c_1$$

$$= \frac{1}{\sqrt{a}} \ln\left|x + \frac{b}{2a} + \sqrt{\frac{ax^2 + bx + c}{a}}\right| + c_1$$

$$=\boxed{\frac{1}{\sqrt{a}}\ln\left|2ax+b+2\sqrt{a\left(ax^2+bx+c\right)}\right|+c_2} \quad (3.15)$$

ដែល $c_1$ , $c_2$ ជាចំនួនថេរ និង $a>0$ ។

- ប្រសិនបើ $a<0$ នាំឱ្យ

$$\int\frac{\mathrm{d}x}{\sqrt{\mathrm{a}x^2+bx+c}}=\frac{1}{\sqrt{-a}}\int\frac{dx}{\sqrt{\frac{\Delta}{4a^2}-\left(x+\frac{b}{2a}\right)^2}}$$

$$=\boxed{\frac{1}{\sqrt{-a}}\sin^{-1}\left(\frac{2ax+b}{\sqrt{\Delta}}\right)+c_1} \quad (3.16)$$

ដែល $|2ax+b|<\sqrt{\Delta}$ , $c_1$ ជាចំនួនថេរ និង $a<0$ ។

៣. ប្រសិនបើ $\Delta<0$ នោះត្រីធាគ្មានឫសចំនួនពិតទេ។ នាំឱ្យត្រីធាអាចសរសេរជា

$$\mathrm{a}x^2+bx+c=a\left[\left(x+\frac{b}{2a}\right)^2+\frac{4ac-b^2}{4a^2}\right]=a\left[\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}\right]$$

និងយើងតាង $t=x+\dfrac{b}{2a}$ នាំឱ្យ $dx=dt$ ។

- ប្រសិនបើ $a>0$ នាំឱ្យ

$$\int\frac{\mathrm{d}x}{\sqrt{\mathrm{a}x^2+bx+c}}=\frac{1}{\sqrt{a}}\int\frac{dx}{\sqrt{\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}}}$$

$$=\frac{1}{\sqrt{a}}\ln\left|x+\frac{b}{2a}+\sqrt{(x+\frac{b}{2a})^2-\frac{\Delta}{4a^2}}\right|+c_1$$

$$=\frac{1}{\sqrt{a}}\ln\left|x+\frac{b}{2a}+\sqrt{\frac{ax^2+bx+c}{a}}\right|+c_1$$

$$=\frac{1}{\sqrt{a}}\ln\left|2ax+b+2\sqrt{a\left(ax^2+bx+c\right)}\right|+c_2$$

( ដូចគ្នានឹងរូបមន្ត (3.15) )

ដែល $c_1$ , $c_2$ ជាចំនួនថេរ និង $a>0$ ។

- ប្រសិនបើ $a<0$ នាំឱ្យ $ax^2+bx+c=a\left[\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}\right]<0$ នោះយើងមិនអាចគណនា អាំងតេក្រាលប្រភេទនេះបានទេ។

**ឧទាហរណ៍ទី១២** គណនា $\int\frac{dx}{\sqrt{4x^2+4x+1}}$ , $\int\frac{dx}{\sqrt{4x^2+4x+3}}$ , $\int\frac{dx}{\sqrt{4x^2+4x-8}}$ និង $\int\frac{dx}{\sqrt{-4x^2-4x+4}}$ ។

ដំណោះស្រាយ

ចំពោះអាំងតេក្រាល $\int\frac{dx}{\sqrt{4x^2+4x+1}}$ មាន $\Delta=b^2-4ac=4^2-4(4)(1)=0$ ។

នោះតាមរូបមន្ត $(3.14)$ យើងបាន៖

$$\int\frac{dx}{\sqrt{4x^2+4x+1}}=\frac{1}{\sqrt{4}}\ln|2\cdot4x+4|+c_2=\frac{1}{2}\ln|8x+4|+c_2 \text{ ។}$$

ចំពោះអាំងតេក្រាល $\int\frac{dx}{\sqrt{4x^2+4x+3}}$ មាន $a=4>0,\ \Delta=b^2-4ac=4^2-4(4)(3)$ $=-32<0$ ។

នោះតាមរូបមន្ត $(3.15)$ យើងបាន៖

$$\int\frac{dx}{\sqrt{4x^2+4x+3}}=\frac{1}{\sqrt{4}}\ln\left|2\cdot4x+4+2\sqrt{4\left(4x^2+4x+3\right)}\right|+c_2$$

$$=\frac{1}{2}\ln\left|8x+4+4\sqrt{4x^2+4x+3}\right|+c_2 \text{ ។}$$

ចំពោះអាំងតេក្រាល $\int\frac{dx}{\sqrt{4x^2+4x-8}}$ មាន $a=4>0,\ \Delta=b^2-4ac=4^2-4(4)(-8)$ $=144>0$ ។

នោះតាមរូបមន្ត $(3.15)$ យើងបាន៖

$$\int\frac{dx}{\sqrt{4x^2+4x-8}}=\frac{1}{\sqrt{4}}\ln\left|2\cdot4x+4+2\sqrt{4\left(4x^2+4x-8\right)}\right|+c_2$$

ចំពោះអាំងតេក្រាល $\int\frac{\mathrm{d}x}{\sqrt{-4x^2-4x+4}}$ មាន $a=-4<0, \Delta=(-4)^2-4(-4)(4)$ $=80>0$ ។

នោះតាមរូបមន្ត (3.16) យើងបាន៖

$$\int\frac{\mathrm{d}x}{\sqrt{-4x^2-4x+4}}=\frac{1}{\sqrt{-(-4)}}\sin^{-1}\left(\frac{2(-4)x+(-4)}{\sqrt{80}}\right)+c_1$$

## ៣.១៣ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int\sqrt{ax^2+bx+c}\,dx$

អាំងតេក្រាល $\int\sqrt{ax^2+bx+c}\,dx$ $(a\neq 0)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sqrt{ax^2+bx+c}$ ជាអនុគមន៍អសនិទាន។ អនុគមន៍នេះមានត្រីជា $ax^2+bx+c$ $(a\neq 0)$ ។

យើងនឹងសិក្សាតាម $\Delta=b^2-4ac$ ដើម្បីស្វែងរកឫសនៃត្រីជានេះ។

១. ករណី $\Delta=0$ នោះត្រីជាមានឫសឌុបគឺ $x_1=x_2=-\frac{b}{2a}$ ។

នាំឱ្យ $ax^2+bx+c=a\left(x+\frac{b}{2a}\right)^2$ , $\sqrt{ax^2+bx+c}=\sqrt{a}\left|x+\frac{b}{2a}\right|$ $(a>0)$ និង

$$\int\sqrt{ax^2+bx+c}\,dx=\sqrt{a}\int\left(x+\frac{b}{2a}\right)dx=\sqrt{a}\left(\frac{1}{2}x^2+\frac{b}{2a}x\right)+c_1$$

$$=\boxed{\frac{\sqrt{a}}{2}x^2+\frac{b\sqrt{a}}{2a}x+c_1}\qquad(3.17)$$

ដែល $c_1$ ជាចំនួនថេរ និង $a>0$ ។

២. ករណី $\Delta>0$ នោះត្រីជាមានឫសពីរផ្សេងគ្នាគឺ $x_1=\frac{-b+\sqrt{\Delta}}{2a}$ ឬ $x_2=\frac{-b-\sqrt{\Delta}}{2a}$ ។

នាំឱ្យ $ax^2+bx+c=a\left[\left(x+\frac{b}{2a}\right)^2+\frac{4ac-b^2}{4a^2}\right]=a\left[\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}\right]$

$$= a(x-x_1)(x-x_2)$$

និងយើងតាង $t = x + \frac{b}{2a}$ នាំឱ្យ $dx = dt$ ។

- ប្រសិនបើ $a>0$ នាំឱ្យ

$$\int\sqrt{ax^2+bx+c}\,dx = \sqrt{a}\int\sqrt{\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}}\,dx = \sqrt{a}\int\sqrt{t^2-\frac{\Delta}{4a^2}}\,dt$$

$$= \frac{\sqrt{a}}{2}(x+\frac{b}{2a})\sqrt{(x+\frac{b}{2a})^2-\frac{\Delta}{4a^2}} - \frac{\sqrt{a}}{2}\cdot\frac{\Delta}{4a^2}\ln\left|x+\frac{b}{2a}+\sqrt{(x+\frac{b}{2a})^2-\frac{\Delta}{4a^2}}\right|+c_1$$

$$= \frac{\sqrt{a}}{2}(x+\frac{b}{2a})\sqrt{\frac{ax^2+bx+c}{a}} - \frac{\Delta\sqrt{a}}{8a^2}\ln\left|x+\frac{b}{2a}+\sqrt{\frac{ax^2+bx+c}{a}}\right|+c_1$$

$$= \boxed{\frac{(2ax+b)\sqrt{a}}{4a^2}\sqrt{a\left(ax^2+bx+c\right)} - \frac{\Delta\sqrt{a}}{8a^2}\ln\left|2ax+b+2\sqrt{a\left(ax^2+bx+c\right)}\right|+c_2} \quad (3.18)$$

ដែល $c_1, c_2$ ជាចំនួនថេរ និង $a>0$ ។

- ប្រសិនបើ $a<0$ នាំឱ្យ

$$\int\sqrt{ax^2+bx+c}\,dx = \sqrt{-a}\int\sqrt{\frac{\Delta}{4a^2}-\left(x+\frac{b}{2a}\right)^2}\,dx$$

$$= \frac{\sqrt{-a}}{2}t\sqrt{\frac{\Delta}{4a^2}-t^2} + \frac{\sqrt{-a}}{2}\cdot\frac{\Delta}{4a^2}\sin^{-1}\left(\frac{t}{\sqrt{\Delta}/2a}\right)+c_1 \text{ ( តាម (3.7) )}$$

$$= \frac{\sqrt{-a}}{2}(x+\frac{b}{2a})\sqrt{\frac{\Delta}{4a^2}-(x+\frac{b}{2a})^2} + \frac{\Delta\sqrt{-a}}{8a^2}\sin^{-1}\left(\frac{x+\frac{b}{2a}}{\sqrt{\Delta}/2a}\right)+c_1$$

$$= \frac{(2ax+b)\sqrt{-a}}{4a}\sqrt{\frac{ax^2+bx+c}{-a}} + \frac{\Delta\sqrt{-a}}{8a^2}\sin^{-1}\left(\frac{2ax+b}{\sqrt{\Delta}}\right)+c_1$$

$$= \boxed{\frac{(2ax+b)\sqrt{-a}}{4a^2}\sqrt{-a(ax^2+bx+c)} + \frac{\Delta\sqrt{-a}}{8a^2}\sin^{-1}\left(\frac{2ax+b}{\sqrt{\Delta}}\right)+c_1} \quad (3.19)$$

ដែល $|2ax+b|<\sqrt{\Delta}$, $c_1$ ជាចំនួនថេរ និង $a<0$ ។

៣. ប្រសិនបើ $\Delta<0$ នោះត្រីធាគ្មានឫសចំនួនពិតទេ។ នាំឱ្យត្រីធាអាចសរសេរជា

$$\mathrm{a}x^2+bx+c=a\left[\left(x+\frac{b}{2a}\right)^2+\frac{4ac-b^2}{4a^2}\right]=a\left[\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}\right]$$

និងយើងតាង $t=x+\dfrac{b}{2a}$ នាំឱ្យ $dx=dt$ ។

- ប្រសិនបើ $a>0$ នាំឱ្យ

$$\int\sqrt{\mathrm{a}x^2+bx+c}\,dx=\sqrt{a}\int\sqrt{\left(x+\frac{b}{2a}\right)^2-\frac{\Delta}{4a^2}}\,dx$$

$$=\frac{\sqrt{a}}{2}t\sqrt{t^2-\frac{\Delta}{4a^2}}+\frac{\sqrt{a}}{2}\cdot(-\frac{\Delta}{4a^2})\ln\left|t+\sqrt{t^2-\frac{\Delta}{4a^2}}\right|+c_1$$ ( តាម (3.8) )

$$=\frac{\sqrt{a}}{2}(x+\frac{b}{2a})\sqrt{\frac{ax^2+bx+c}{a}}-\frac{\Delta\sqrt{a}}{8a^2}\ln\left|x+\frac{b}{2a}+\sqrt{\frac{ax^2+bx+c}{a}}\right|+c_1$$

$$=\frac{(2ax+b)\sqrt{a}}{4a^2}\sqrt{a\left(ax^2+bx+c\right)}-\frac{\Delta\sqrt{a}}{8a^2}\ln\left|2ax+b+2\sqrt{a\left(ax^2+bx+c\right)}\right|+c_2$$

ដែល $c_1$ , $c_2$ ជាចំនួនថេរ និង $a>0$ ( ដូចគ្នានឹងរូបមន្ត (3.18) )។

- ប្រសិនបើ $a<0$ នាំឱ្យ $\mathrm{a}x^2+bx+c=a\left[\left(x+\dfrac{b}{2a}\right)^2-\dfrac{\Delta}{4a^2}\right]<0$ នោះយើងមិនអាចគណនាអាំងតេក្រាលប្រភេទនេះបានទេ។

**ឧទាហរណ៍ទី១៣** គណនា $\int\sqrt{4x^2+4x+1}dx$ , $\int\sqrt{4x^2+4x+3}\,dx$ , $\int\sqrt{4x^2+4x-8}\,dx$ និង $\int\sqrt{-4x^2-4x+4}\,dx$ ។

ដំណោះស្រាយ

ចំពោះអាំងតេក្រាល $\int\sqrt{4x^2+4x+1}dx$ មាន $\Delta=b^2-4ac=4^2-4(4)(1)=0$ ។

នោះតាមរូបមន្ត (3.17) យើងបាន៖

$$\int\sqrt{4x^2+4x+1}dx=\frac{\sqrt{4}}{2}x^2+\frac{4\sqrt{4}}{2\cdot4}x+c_1=x^2+x+c_1$$ ។

ចំពោះអាំងតេក្រាល $\int\sqrt{4x^2+4x+3}\,dx$ មាន $a=4>0,\Delta=b^2-4ac=4^2-4(4)(3)$ $=-32<0$ ។

នោះតាមរូបមន្ត (3.18) យើងបាន៖

$$\int\sqrt{4x^2+4x+3}\,dx=\frac{(2\cdot 4x+4)\sqrt{4}}{4\cdot 4^2}\sqrt{4\left(4x^2+4x+3\right)}$$

$$-\frac{\Delta\sqrt{4}}{8\cdot 4^2}\ln\left|2\cdot 4x+4+2\sqrt{4\left(4x^2+4x+3\right)}\right|+c_2$$

$$=\frac{(8x+4)}{16}\sqrt{4x^2+4x+3}+\frac{1}{2}\ln\left|8x+4+4\sqrt{4x^2+4x+3}\right|+c_2$$ ។

ចំពោះអាំងតេក្រាល $\int\sqrt{4x^2+4x-8}\,dx$ មាន $a=4>0,\ \Delta=b^2-4ac=4^2-4(4)(-8)$

$=144>0$ ។

នោះតាមរូបមន្ត (3.18) យើងបាន៖

$$\int\sqrt{4x^2+4x-8}\,dx=\frac{(2\cdot 4x+4)\sqrt{4}}{4\cdot 4^2}\sqrt{4\left(4x^2+4x-8\right)}$$

$$-\frac{\Delta\sqrt{4}}{8\cdot 4^2}\ln\left|2\cdot 4x+4+2\sqrt{4\left(4x^2+4x-8\right)}\right|+c_2$$

$$=\frac{(8x+4)}{16}\sqrt{4x^2+4x-8}-\frac{9}{4}\ln\left|8x+4+4\sqrt{4x^2+4x-8}\right|+c_2$$ ។

ចំពោះអាំងតេក្រាល $\int\sqrt{-4x^2-4x+4}\,dx$ មាន $a=-4<0,\ \Delta=(-4)^2-4(-4)(4)$

$=80>0$ ។

នោះតាមរូបមន្ត (3.19) យើងបាន៖

$$\int\sqrt{-4x^2-4x+4}\,dx=\frac{(2(-4)x-4)\sqrt{4}}{4(-4)^2}\sqrt{4(-4x^2-4x+4)}$$

$$+\frac{80\sqrt{4}}{8(-4)^2}\sin^{-1}\left(\frac{2(-4)x-4}{\sqrt{80}}\right)+c_1$$

$$=\frac{(-8x-4)}{16}\sqrt{-4x^2-4x+4}+\frac{5}{4}\sin^{-1}\left(\frac{-8x-4}{4\sqrt{5}}\right)+c_1$$ ។

## ៣.១៤ អាំងតេក្រាលនៃអនុគមន៍អសនិទានរាង $\int\frac{(\alpha x+\beta)\,dx}{\sqrt{ax^2+bx+c}}$

អាំងតេក្រាល $\int \frac{(\alpha x+\beta)dx}{\sqrt{ax^2+bx+c}}$ $(a\neq 0)$ ជាអាំងតេក្រាលមិនកំណត់ដែលមាន

អនុគមន៍អាំងតេក្រាល $\frac{\alpha x+\beta}{\sqrt{ax^2+bx+c}}$ ជាអនុគមន៍អសនិទាន។

យើងមាន $\frac{\alpha x+\beta}{\sqrt{ax^2+bx+c}} = \frac{A(2ax+b)}{\sqrt{ax^2+bx+c}} + \frac{B}{\sqrt{ax^2+bx+c}}$

នាំឱ្យ $\alpha x+\beta = A(2ax+b)+B = 2aAx+bA+B$

នាំឱ្យ $2aA=\alpha$ , $Ab+B=\beta \Rightarrow A=\frac{\alpha}{2a}$ , $B=\beta-Ab=\frac{2a\beta-\alpha b}{2a}$ ។

នាំឱ្យ $\int \frac{(\alpha x+\beta)dx}{\sqrt{ax^2+bx+c}} = A\int \frac{(2ax+b)dx}{\sqrt{ax^2+bx+c}} + B\int \frac{dx}{\sqrt{ax^2+bx+c}}$

$$= A\int (ax^2+bx+c)^{-\frac{1}{2}} d(ax^2+bx+c) + B\int \frac{dx}{\sqrt{ax^2+bx+c}}$$

$$= \boxed{\frac{\alpha}{a}\sqrt{ax^2+bx+c} + \frac{(2a\beta-\alpha b)}{2a}\int \frac{dx}{\sqrt{ax^2+bx+c}}} \quad (3.20)$$

ដែលអាំងតេក្រាល $\int \frac{dx}{\sqrt{ax^2+bx+c}}$ អាចគណនាបានតាមផ្នែក ៣.១២ (រូបមន្ត (3.14) , (3.15) និង (3.16) )។

**ឧទាហរណ៍ទី១៤** គណនា $\int \frac{3x+5}{\sqrt{x^2+2x+4}}dx$ និង $\int \frac{5x-3}{\sqrt{-4x^2-12x+7}}dx$ ។

ដំណោះស្រាយ

ចំពោះអាំងតេក្រាល $\int \frac{3x+5}{\sqrt{x^2+2x+4}}dx$ មាន $\alpha=3, \beta=5, a=1>0,\ \Delta=b^2-4ac$ $=2^2-4(1)(4)=-12<0$ ។

នោះតាមរូបមន្ត (3.20) និង (3.15) យើងបាន៖

$$\int \frac{3x+5}{\sqrt{x^2+2x+4}}dx = \frac{3}{1}\sqrt{x^2+2x+4} + \frac{(2\cdot 1\cdot 5-3\cdot 2)}{2\cdot 1}\int \frac{dx}{\sqrt{x^2+2x+4}}$$

$$= 3\sqrt{x^2+2x+4} + 2\int \frac{dx}{\sqrt{x^2+2x+4}}$$

$$= 3\sqrt{x^2+2x+4} + \frac{2}{\sqrt{1}}\ln\left|2x+2+2\sqrt{1\cdot\left(x^2+2x+4\right)}\right| + c_2$$

ចំពោះអាំងតេក្រាល $\int \frac{5x-3}{\sqrt{-4x^2-12x+7}}dx$ មាន $\alpha = 5,\ \beta = -3,\ a = -4 < 0,$

$\Delta = b^2 - 4ac = (-12)^2 - 4(-4)(7) = 256 > 0$ ។

នោះតាមរូបមន្ត (3.20) និង (3.16) យើងបាន៖

$$\int \frac{5x-3}{\sqrt{-4x^2-12x+7}}dx = \frac{5}{-4}\sqrt{-4x^2-12x+7} + \frac{(2(-4)(-3)-5(-12))}{2(-4)}\int \frac{dx}{\sqrt{-4x^2-12x+7}}$$

$$= -\frac{5}{4}\sqrt{-4x^2-12x+7} - \frac{21}{2}\int \frac{dx}{\sqrt{-4x^2-12x+7}}$$

$$= -\frac{5}{4}\sqrt{-4x^2-12x+7} - \frac{21}{2}\cdot\frac{1}{\sqrt{4}}\sin^{-1}\left(\frac{2(-4)x-12}{\sqrt{256}}\right) + c_1$$

$$= -\frac{5}{4}\sqrt{-4x^2-12x+7} - \frac{21}{4}\sin^{-1}\left(\frac{-8x-12}{16}\right) + c_1$$ ។

ជាសរុប ជំពូកទី៣នេះបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍អសនិទានមួយចំនួនដូចជា $\int \frac{1}{\sqrt[n]{ax+b}}dx$ , $\int \sqrt[n]{ax+b}\, dx$ , $\int \sqrt[n]{(ax+b)^m}\, dx$ , $\int \frac{1}{\sqrt{k-x^2}}dx$ , $\int \frac{1}{\sqrt{x^2+k}}dx$ , $\int \frac{1}{\sqrt{x^2-k}}dx$ , $\int \sqrt{k-x^2}\, dx$ , $\int \sqrt{x^2+k}\, dx$ , $\int \sqrt{x^2-k}\, dx$ , $\int (\alpha x+\beta)\sqrt{ax+b}\, dx$ , $\int \frac{dx}{(\alpha x+\beta)\sqrt{ax+b}}$ , $\int \frac{dx}{\sqrt{ax^2+bx+c}}$ , $\int \sqrt{ax^2+bx+c}\, dx$ និង $\int \frac{(\alpha x+\beta)dx}{\sqrt{ax^2+bx+c}}$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនៅក្នុងជំពូកទី៤បន្តទៀត។

# ជំពូកទី៤

# ប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល

## ( Types of Integrals Involving Exponential Functions )

នៅក្នុងជំពូកទី៤នេះ យើងនឹងសិក្សាតែអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលដែលមានលក្ខណៈពិសេសមួយចំនួននិងដំណោះស្រាយរបស់វាដូចតទៅ៖

## ៤.១ អាំងតេក្រាលនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int a^{\alpha x+\beta}\,dx$

អាំងតេក្រាល $\int a^{\alpha x+\beta}\,dx$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $a^{\alpha x+\beta}$ $(a>0\,,\,a\neq 1)$ ជាអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល។

ដើម្បីគណនាអាំងតេក្រាល $\int a^{\alpha x+\beta}\,dx$ យើងប្រើវិធីប្តូរអថេរដោយតាង

$t=a^{\alpha x+\beta}$ $(\alpha\neq 0)$ នាំឱ្យ $\ln t=\ln a^{\alpha x+\beta}=(\alpha x+\beta)\ln a$ $(a>0\,,\,a\neq 1)$ នាំឱ្យ $x=\dfrac{1}{\alpha}\left(\dfrac{\ln t}{\ln a}-\beta\right)$ និង $dx=\dfrac{1}{\alpha\ln a}\cdot\dfrac{dt}{t}$ ។

នាំឱ្យ $$\int a^{\alpha x+\beta}\,dx=\int t\frac{1}{\alpha\ln a}\,\frac{dt}{t}=\frac{1}{\alpha\ln a}\int dt$$

$$=\frac{1}{\alpha\ln a}\,t+c=\frac{a^{\alpha x+\beta}}{\alpha\ln a}+c\quad(*)$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $a=e\,,\,\alpha=1\,,\,\beta=0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int e^x\,dx=\boxed{e^x+c}\qquad(4.1)$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $\alpha=1\,,\,\beta=0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int a^x\,dx=\boxed{\frac{a^x}{\ln a}+c}\qquad(4.2)$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $a=e$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int e^{\alpha x+\beta}\,dx = \boxed{\frac{1}{\alpha}e^{\alpha x+\beta}+c} \qquad (4.3)$$

ដែល $c$ ជាចំនួនពិតថេរ។

ចំពោះករណីទូទៅ តាមសមីការ $(*)$ ផ្តល់ឱ្យ

$$\int a^{\alpha x+\beta}\,dx = \boxed{\frac{a^{\alpha x+\beta}}{\alpha\ln a}+c} \qquad (4.4)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0\,,\, a\neq 1$ ។

**ឧទាហរណ៍ទី១** គណនា $\int 3e^{x}\,dx\,,\ \int\sqrt{2}\cdot 3^{x}\,dx\,,\ \int_{0}^{(1/7)\ln 2} 14e^{7x}\,dx\,,\ \int 7^{2x+3}\,dx$ និង $\int\left(3^{4x+5}\right)^{6}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.1) , (4.2) , (4.3) និង (4.4) យើងបាន៖

$$\int 3e^{x}\,dx = 3\int e^{x}\,dx = 3e^{x}+c$$

$$\int\sqrt{2}\cdot 3^{x}\,dx = \sqrt{2}\int 3^{x}\,dx = \sqrt{2}\cdot\frac{3^{x}}{\ln 3}+c$$

$$\int_{0}^{(1/7)\ln 2} 14e^{7x}\,dx = 14\int_{0}^{(1/7)\ln 2} e^{7x}\,dx = 14\cdot\frac{e^{7x}}{7}\Bigg|_{0}^{(1/7)\ln 2}$$

$$= 2\left(e^{7(1/7)\ln 2}-e^{0}\right) = 2(2-1) = 2$$

$$\int 7^{2x+3}\,dx = \frac{7^{2x+3}}{2\ln 7}+c$$

និង $\int\left(3^{4x+5}\right)^{6}dx = \int 3^{6(4x+5)}\,dx = \int 3^{24x+30}\,dx = \dfrac{3^{24x+30}}{24\ln 3}+c$ ។

**ឧទាហរណ៍ទី២** គណនា $\int_{0}^{1} e^{x\cdot\ln a+(1-x)\cdot\ln b}\,dx\ (a>0\,,\, b>0)$ ។

ដំណោះស្រាយ

យើងមាន $e^{x\cdot\ln a+(1-x)\cdot\ln b} = e^{\ln a^{x}+\ln b^{1-x}} = e^{\ln(a^{x}b^{1-x})}$

$$= a^x b^{1-x} = \frac{a^x}{b^x} b = \left(\frac{a}{b}\right)^x b \quad (*)$$ ។

- បើ $a = b$ និងពីសមីការ $(*)$ នាំឱ្យ

$$\int_0^1 e^{x\cdot\ln a + (1-x)\cdot\ln b}\, dx = \int_0^1 \left(\frac{b}{b}\right)^x b\, dx = b\int_0^1 dx = b\,x + c$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $a \neq b$ និងពីសមីការ $(*)$ និងរូបមន្ត $(2)$ យើងបាន៖

$$\int_0^1 e^{x\cdot\ln a + (1-x)\cdot\ln b}\, dx = \int_0^1 \left(\frac{a}{b}\right)^x b\, dx = b\int_0^1 \left(\frac{a}{b}\right)^x dx$$

ដូចនេះ ចំពោះ $a > 0\,, b > 0\,, a \neq b$ យើងបានរូបមន្ត

$$\int_0^1 e^{x\cdot\ln a + (1-x)\cdot\ln b}\, dx = \int_0^1 a^x b^{1-x}\, dx = \int_0^1 \left(\frac{a}{b}\right)^x b\, dx = \boxed{\frac{a-b}{\ln a - \ln b}} \quad (4.5)$$ ។

**ឧទាហរណ៍ទី៣** គណនា $\int_0^{+\infty} e^{a\,x}\, dx$ ។

ដំណោះស្រាយ

តាមរូបមន្ត $(3)$ និង $a \neq 0$ យើងបាន៖

$$\int_0^{+\infty} e^{a\,x}\, dx = \lim_{b\to+\infty}\int_0^b e^{a\,x}\, dx = \lim_{b\to+\infty} \frac{1}{a} e^{a\,x}\Big|_0^b = \lim_{b\to+\infty} \frac{1}{a}\left(e^{ab} - 1\right) \quad (*)$$ ។

ប្រសិនបើ $a = x + i\,y \in \mathbb{C}$ ដែល $\text{Re}(a) = x < 0$ នាំឱ្យ

$$\lim_{b\to+\infty} e^{ab} = \lim_{b\to+\infty} e^{(x+i\,y)b} = \lim_{b\to+\infty} e^{xb + i\,yb}$$

$$= \lim_{b\to+\infty} \frac{\cos yb + i\sin yb}{e^{-xb}}$$

$$= \lim_{b\to+\infty} \frac{\cos yb}{e^{-xb}} + i\lim_{b\to+\infty} \frac{\sin yb}{e^{-xb}} = 0 + i\cdot 0 = 0$$

និងតាមសមីការ $(*)$ យើងបាន៖

$$\int_0^{+\infty} e^{a\,x}\, dx = \lim_{b\to+\infty} \frac{1}{a}\left(e^{ab} - 1\right) = \frac{1}{a}(0-1) = \boxed{-\frac{1}{a}} \quad (4.6)$$

ដែល $\text{Re}(a) < 0$ ។

យើងអាចទាញបាន

$$\int_0^{+\infty} e^{-a\,x}\,dx = \boxed{\frac{1}{a}} \qquad (4.7)$$

ដែល $-\text{Re}(a) = \text{Re}(-a) < 0 \Leftrightarrow \text{Re}(a) > 0$ ។

**ឧទាហរណ៍ទី៤** គណនា $\int_0^1 e^{x\cdot\ln 7 + (1-x)\cdot\ln 9}\,dx$ និង $\int_0^{+\infty} e^{-\sqrt{3}\,x}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.5) និង (4.7) យើងបាន៖

$$\int_0^1 e^{x\cdot\ln 7 + (1-x)\cdot\ln 9}\,dx = \frac{7-9}{\ln 7 - \ln 9} = \frac{-2}{\ln 7 - \ln 9}$$

និង $$\int_0^{+\infty} e^{-\sqrt{3}\,x}\,dx = \frac{1}{\sqrt{3}} = \frac{\sqrt{3}}{3}$$ ។

**ឧទាហរណ៍ទី៥** គណនា $\int e^{5x}\left(\frac{e^{2x}}{7} + \frac{3}{e^{3x}}\right)dx$ , $\int (e^{4x} - e^{-4x})^2\,dx$ និង $\int_0^1 \frac{3^x + 4^x}{5^x}\,dx$ ។

ដំណោះស្រាយ

យើងបាន៖

$$\int e^{5x}\left(\frac{e^{2x}}{7} + \frac{3}{e^{3x}}\right)dx = \int\left(\frac{e^{7x}}{7} + 3e^{2x}\right)dx = \frac{1}{7}\int e^{7x}\,dx + 3\int e^{2x}\,dx$$

$$= \frac{1}{7}\cdot\frac{e^{7x}}{7} + 3\cdot\frac{e^{2x}}{2} + c = \frac{1}{49}e^{7x} + \frac{3}{2}e^{2x} + c$$ ( តាមរូបមន្ត (4.3) )

$$\int (e^{4x} - e^{-4x})^2\,dx = \int [(e^{4x})^2 - 2(e^{4x})(e^{-4x}) + (e^{-4x})^2]\,dx$$

និង $$\int_0^1 \frac{3^x + 4^x}{5^x}\,dx = \int_0^1 [(3/5)^x + (4/5)^x]\,dx$$

$$= \left[\frac{(3/5)^x}{\ln(3/5)} + \frac{(4/5)^x}{\ln(4/5)}\right]_0^1$$ ( តាមរូបមន្ត (4.2) )

$$= \left[\frac{3/5}{\ln(3/5)} + \frac{4/5}{\ln(4/5)}\right] - \left[\frac{1}{\ln(3/5)} + \frac{1}{\ln(4/5)}\right]$$

$$= \frac{(3/5)-1}{\ln(3/5)} + \frac{(4/5)-1}{\ln(4/5)} = -\frac{2}{5\ln(3/5)} - \frac{1}{5\ln(4/5)}$$ ។

## ៤.២ អាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int \frac{dx}{p+a^{\alpha x}}$

អាំងតេក្រាល $\int \frac{dx}{p+a^{\alpha x}}$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{p+a^{\alpha x}}$ ។ អនុគមន៍នេះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល $a^{\alpha x}$ ។

ដើម្បីគណនាអាំងតេក្រាល $\int \frac{dx}{p+a^{\alpha x}}$ យើងប្រើវិធីប្តូរអថេរដោយតាង $t=p+a^{\alpha x}$ $(\alpha \neq 0)$ នាំឱ្យ $x=\frac{\ln(t-p)}{\alpha \ln a}$ និង $dx=\frac{1}{\alpha \ln a}\cdot\frac{dt}{t-p}$ ។

នាំឱ្យ $\int \frac{dx}{p+a^{\alpha x}}=\int \frac{1}{t}\cdot\frac{1}{\alpha \ln a}\cdot\frac{dt}{t-p}=\frac{1}{\alpha \ln a}\int \frac{1}{t(t-p)}dt \quad (*)$ ។

- បើ $p=0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int \frac{dx}{p+a^{\alpha x}}=\int \frac{dx}{a^{\alpha x}}=\frac{1}{\alpha \ln a}\int \frac{1}{t^2}dt=\frac{1}{\alpha \ln a}\int t^{-2}dt$$

$$=\frac{1}{\alpha \ln a}\cdot\frac{t^{-1}}{(-1)}+c=\frac{-1}{\alpha \ln a}\cdot\frac{1}{t}+c=\boxed{\frac{-1}{\alpha \ln a}\cdot\frac{1}{a^{\alpha x}}+c} \quad (4.8)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0\,,\,a\neq 1\,,\,\alpha\neq 0$ ។

- បើ $p\neq 0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int \frac{dx}{p+a^{\alpha x}}=\frac{1}{\alpha \ln a}\int \frac{1}{t(t-p)}dt=\frac{1}{\alpha\, p \ln a}\int \frac{t-(t-p)}{t(t-p)}dt$$

$$=\frac{1}{\alpha\, p \ln a}\int\left(\frac{1}{t-p}-\frac{1}{t}\right)dt=\frac{1}{\alpha\, p \ln a}\left(\ln|t-p|-\ln|t|\right)+c$$

$$=\frac{1}{\alpha\, p \ln a}\left(\alpha x \ln a-\ln\left|p+a^{\alpha x}\right|\right)+c_1$$

$$=\boxed{\frac{x}{p}-\frac{1}{\alpha\, p \ln a}\ln\left|p+a^{\alpha x}\right|+c_1} \quad (4.9)$$

ដែល $c\,,\,c_1$ ជាចំនួនពិតថេរ និង $a>0\,,\,a\neq 1\,,\,\alpha\neq 0$ ។

- ករណីពិសេស បើ $a=e$ នាំឱ្យសមីការ $(4.9)$ ទៅជា

$$\int \frac{dx}{p+e^{\alpha x}}=\boxed{\frac{x}{p}-\frac{1}{\alpha\, p}\ln\left|p+e^{\alpha x}\right|+c_1} \quad (4.10)$$

ដែល $c_1$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៦** គណនា $\int \frac{dx}{3\cdot 7^{2x}}$ , $\int \frac{dx}{3+e^{6x}}$ និង $\int \frac{dx}{7-5^{4x}}$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.8) , (4.10) និង (4.9) យើងបាន៖

$$\int \frac{dx}{3\cdot 7^{2x}} = \frac{1}{3}\int \frac{dx}{7^{2x}} = \frac{1}{3}\cdot\frac{-1}{2\ln 7}\cdot\frac{1}{7^{2x}} + c = \frac{-1}{6\ln 7}\cdot\frac{1}{7^{2x}} + c$$

$$\int \frac{dx}{3+e^{6x}} = \frac{x}{3} - \frac{1}{6\cdot 3}\ln\left|3+e^{6x}\right| + c = \frac{x}{3} - \frac{1}{18}\ln\left|3+e^{6x}\right| + c$$

និង $$\int \frac{dx}{7-5^{4x}} = -\int \frac{dx}{-7+5^{4x}} = -\left[\frac{x}{-7} - \frac{1}{4\cdot(-7)\ln 5}\ln\left|-7+5^{4x}\right|\right] + c$$

$$= \frac{x}{7} - \frac{1}{28\ln 5}\ln\left|7-5^{4x}\right| + c$$ ។

**ឧទាហរណ៍ទី៧** គណនា $\int_0^1 \frac{e^{2x}dx}{8+6^{3e^{2x}}}$ ។

ដំណោះស្រាយ

តាង $t = e^{2x}$ នាំឱ្យ $dt = 2e^{2x}dx \Leftrightarrow e^{2x}dx = \frac{dt}{2}$ ។ ពិនិត្យគោល៖ បើ $x = 0$ នាំឱ្យ $t = 1$ និង បើ $x = 1$ នាំឱ្យ $t = e^2$ ។

នាំឱ្យ $$\int_0^1 \frac{e^{2x}dx}{8+6^{3e^{2x}}} = \int_1^{e^2} \frac{\frac{dt}{2}}{8+6^{3t}} = \frac{1}{2}\int_1^{e^2} \frac{dt}{8+6^{3t}}$$

$$= \frac{1}{2}\left[\frac{t}{8} - \frac{1}{3(8)\ln 6}\ln\left|8+6^{3t}\right|\right]\Bigg|_1^{e^2}$$ ( តាមរូបមន្ត (4.9) )

$$= \left(\frac{e^2}{16} - \frac{1}{48\ln 6}\ln(8+6^{3e^2})\right) - \left(\frac{1}{16} - \frac{1}{48\ln 6}\ln(224)\right)$$

$$= \frac{e^2-1}{16} + \frac{\ln 224 - \ln(8+6^{3e^2})}{48\ln 6}$$ ។

## ៤.៣ អាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int\frac{dx}{(p+a^{\alpha x})^2}$

អាំងតេក្រាល $\int\frac{dx}{(p+a^{\alpha x})^2}$ $(a>0\ ,\ a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{(p+a^{\alpha x})^2}$ ។ អនុគមន៍នេះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល $a^{\alpha x}$ ។

ដើម្បីគណនាអាំងតេក្រាល $\int\frac{dx}{(p+a^{\alpha x})^2}$ យើងតាង $t=p+a^{\alpha x}$ $(\alpha\neq 0)$

នាំឱ្យ $x=\frac{\ln(t-p)}{\alpha\ln a}$ និង $dx=\frac{1}{\alpha\ln a}\cdot\frac{dt}{t-p}$ ។

នាំឱ្យ $\int\frac{dx}{(p+a^{\alpha x})^2}=\int\frac{1}{t^2}\cdot\frac{1}{\alpha\ln a}\cdot\frac{dt}{t-p}=\frac{1}{\alpha\ln a}\int\frac{1}{t^2(t-p)}dt$ $(*)$ ។

- បើ $p=0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int\frac{dx}{(p+a^{\alpha x})^2}=\int\frac{dx}{(a^{\alpha x})^2}=\frac{1}{\alpha\ln a}\int\frac{1}{t^3}dt$$

$$=\frac{1}{\alpha\ln a}\int t^{-3}dt\ =\frac{1}{\alpha\ln a}\cdot\frac{t^{-2}}{(-2)}+c$$

$$=\frac{-1}{2\alpha\ln a}\cdot\frac{1}{t^2}+c=\frac{-1}{2\alpha\ln a}\cdot\frac{1}{(a^{\alpha x})^2}+c$$

$$=\boxed{\frac{-1}{2\alpha\ln a}\cdot\frac{1}{a^{2\alpha x}}+c}\quad(4.11)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0\,,a\neq 1\,,\alpha\neq 0$ ។

- បើ $p\neq 0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int\frac{dx}{(p+a^{\alpha x})^2}=\frac{1}{\alpha\ln a}\int\frac{1}{t^2(t-p)}dt=\frac{1}{\alpha\, p\ln a}\int\frac{t-(t-p)}{t^2(t-p)}dt$$

$$=\frac{1}{\alpha\, p\ln a}\int\frac{1}{t(t-p)}dt-\frac{1}{\alpha\, p\ln a}\int\frac{1}{t^2}dt$$

$$=\frac{1}{\alpha\, p^2\ln a}\int\left(\frac{1}{t-p}-\frac{1}{t}\right)dt-\frac{1}{\alpha\, p\ln a}\int t^{-2}dt$$

$$=\frac{1}{\alpha p^2\ln a}\left(\ln|t-p|-\ln|t|\right)-\frac{1}{\alpha p\ln a}\cdot\frac{t^{-1}}{(-1)}+c$$

$$=\frac{1}{\alpha p^2\ln a}\left(\ln\left|p+a^{\alpha x}-p\right|-\ln\left|p+a^{\alpha x}\right|\right)$$

$$-\frac{1}{\alpha p\ln a}\cdot\frac{1}{(p+a^{\alpha x})}+c$$

$$=\frac{1}{\alpha p^2\ln a}\left(\alpha x\ln a-\ln\left|p+a^{\alpha x}\right|\right)+\frac{1}{\alpha p\ln a(p+a^{\alpha x})}+c_1$$

$$=\boxed{\frac{x}{p^2}-\frac{1}{\alpha p^2\ln a}\ln\left|p+a^{\alpha x}\right|+\frac{1}{\alpha p\ln a(p+a^{\alpha x})}+c_1}\quad(4.12)$$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ និង $a>0$ , $a\neq 1$ , $\alpha\neq 0$ ។

- ករណីពិសេស បើ $a=e$ នាំឱ្យសមីការ (4.12) ទៅជា

$$\int\frac{dx}{(p+e^{\alpha x})^2}=\boxed{\frac{x}{p^2}-\frac{1}{\alpha p^2}\ln\left|p+e^{\alpha x}\right|+\frac{1}{\alpha p(p+e^{\alpha x})}+c_1}\quad(4.13)$$

ដែល $c_1$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៨** គណនា $\int\frac{dx}{(3\cdot 7^{2x})^2}$ និង $\int\frac{dx}{(3+e^{6x})^2}$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.11) និង (4.13) យើងបាន៖

$$\int\frac{dx}{(3\cdot 7^{2x})^2}=\frac{1}{3^2}\int\frac{dx}{(7^{2x})^2}=\frac{1}{9}\left[\frac{-1}{2\cdot 2\ln 7}\cdot\frac{1}{7^{2\cdot 2x}}\right]+c=\frac{-1}{36\ln 7}\cdot\frac{1}{7^{4x}}+c$$

និង $$\int\frac{dx}{(3+e^{6x})^2}=\frac{x}{3^2}-\frac{1}{6\cdot 3^2}\ln\left|3+e^{6x}\right|+\frac{1}{6\cdot 3(3+e^{6x})}+c$$

$$=\frac{x}{9}-\frac{1}{54}\ln\left|3+e^{6x}\right|+\frac{1}{18(3+e^{6x})}+c$$ ។

**ឧទាហរណ៍ទី៩** គណនា $\int_0^2\frac{t^2\,dt}{(2+e^{4t^3})^2}$ ។

ដំណោះស្រាយ

តាង $x=t^3$ នាំឱ្យ $dx=3t^2\,dt \Leftrightarrow t^2\,dt=\dfrac{dx}{3}$ ។ ពិនិត្យគោល៖ បើ $t=0$ នាំឱ្យ $x=0$ និង បើ $t=2$ នាំឱ្យ $x=2^3=8$ ។ នាំឱ្យ

$$\int_0^2\frac{t^2\,dt}{(2+e^{4t^3})^2}=\int_0^8\frac{\frac{dx}{3}}{(2+e^{4x})^2}=\frac{1}{3}\int_0^8\frac{dx}{(2+e^{4x})^2}$$

$$=\frac{1}{3}\left[\frac{x}{2^2}-\frac{1}{4(2^2)}\ln\left|2+e^{4x}\right|+\frac{1}{4(2)(2+e^{4x})}\right]\Bigg|_0^8 \text{ ( តាមរូបមន្ត (4.13) )}$$

$$=(\frac{8}{12}-\frac{1}{48}\ln(2+e^{32})+\frac{1}{24(2+e^{32})})-(0-\frac{1}{48}\ln 3+\frac{1}{72})$$

$$=\frac{47}{72}+\frac{1}{48}\ln(\frac{3}{2+e^{32}})+\frac{1}{24(2+e^{32})}\approx 0.008998 \text{ ។}$$

## ៤.៤ អាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int\frac{a^{2\alpha x}\,dx}{p+q\,a^{\alpha x}}$

អាំងតេក្រាល $\int\frac{a^{2\alpha x}\,dx}{p+q\,a^{\alpha x}}$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\dfrac{a^{2\alpha x}}{p+q\,a^{\alpha x}}$ ។ អនុគមន៍នេះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល $a^{\alpha x}$ និង $a^{2\alpha x}$ ។

ដើម្បីគណនាអាំងតេក្រាល $\int\frac{a^{2\alpha x}\,dx}{p+q\,a^{\alpha x}}$ យើងតាង $t=p+q\,a^{\alpha x}$ $(\alpha\neq 0)$ នាំឱ្យ $a^{\alpha x}=\dfrac{t-p}{q}$ , $x=\dfrac{\ln(t-p)-\ln q}{\alpha\ln a}$ និង $dx=\dfrac{1}{\alpha\ln a}\cdot\dfrac{dt}{t-p}$ ។

នាំឱ្យ $$\int\frac{a^{2\alpha x}\,dx}{p+q\,a^{\alpha x}}=\int\frac{(a^{\alpha x})^2\,dx}{p+q\,a^{\alpha x}}=\int\frac{[(t-p)/q]^2}{t}\cdot\frac{1}{\alpha\ln a}\cdot\frac{dt}{t-p}$$

$$=\frac{1}{\alpha q^2\ln a}\int\frac{(t-p)}{t}dt \quad (*) \text{ ។}$$

- បើ $p=0$ និង $q\neq 0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int\frac{a^{2\alpha x}\,dx}{p+q\,a^{\alpha x}}=\int\frac{a^{2\alpha x}\,dx}{q\,a^{\alpha x}}=\frac{1}{\alpha q^2\ln a}\int\frac{(t-0)}{t}dt$$

$$=\frac{1}{\alpha q^2\ln a}\int dt=\frac{1}{\alpha q^2\ln a}\cdot t+c$$

$$=\frac{1}{\alpha q^2\ln a}\cdot q a^{\alpha x}+c=\boxed{\frac{1}{\alpha q\ln a}\cdot a^{\alpha x}+c}\quad(4.14)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0\,,\,a\neq 1\,,\,\alpha\neq 0$ ។

- បើ $p\neq 0$ និង $q\neq 0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int\frac{a^{2\alpha x}dx}{p+qa^{\alpha x}}=\frac{1}{\alpha q^2\ln a}\int\frac{(t-p)}{t}dt=\frac{1}{\alpha q^2\ln a}\int\left(1-\frac{p}{t}\right)dt$$

$$=\frac{1}{\alpha q^2\ln a}\left(t-p\ln|t|\right)+c$$

$$=\frac{1}{\alpha q^2\ln a}\left(p+qa^{\alpha x}-p\ln\left|p+qa^{\alpha x}\right|\right)+c$$

$$=\boxed{\frac{a^{\alpha x}}{\alpha q\ln a}-\frac{p}{\alpha q^2\ln a}\ln\left|p+qa^{\alpha x}\right|+c_1}\quad(4.15)$$

ដែល $c\,,c_1$ ជាចំនួនពិតថេរ និង $a>0\,,\,a\neq 1\,,\,\alpha\neq 0$ ។

- ករណីពិសេស បើ $a=e$ នាំឱ្យសមីការ (15) ទៅជា

$$\int\frac{a^{2\alpha x}dx}{p+qa^{\alpha x}}=\boxed{\frac{a^{\alpha x}}{\alpha q}-\frac{p}{\alpha q^2}\ln\left|p+qa^{\alpha x}\right|+c_1}\quad(4.16)$$

ដែល $c_1$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១០** គណនា $\int\frac{7^{4x}dx}{3\cdot 7^{2x}}\,,\int\frac{e^{12x}dx}{3+4\cdot e^{6x}}$ និង $\int\frac{5^{8x}dx}{7-6\cdot 5^{4x}}$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.14) , (4.16) និង (4.15) យើងបាន៖

$$\int\frac{7^{4x}dx}{3\cdot 7^{2x}}=\frac{1}{2\cdot 3\ln 7}\cdot 7^{2x}+c=\frac{1}{6\ln 7}\cdot 7^{2x}+c$$

$$\int\frac{e^{12x}dx}{3+4\cdot e^{6x}}=\frac{e^{6x}}{6\cdot 4}-\frac{3}{6\cdot 4^2}\ln\left|3+4\cdot e^{6x}\right|+c_1$$

$$=\frac{e^{6x}}{24}-\frac{1}{32}\ln\left|3+4\cdot e^{6x}\right|+c_1$$

និង $$\int\frac{5^{8x}\,dx}{7-6\cdot 5^{4x}}=\frac{5^{4x}}{4(-6)}-\frac{7}{4(-6)^2}\ln\left|7-6\cdot 5^{4x}\right|+c_1$$

$$=-\frac{5^{4x}}{24}-\frac{7}{144}\ln\left|7-6\cdot 5^{4x}\right|+c_1$$ ។

## ៤.៥ អាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}$

អាំងតេក្រាល $\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{pa^{\alpha x}+qa^{-\alpha x}}$ ។ អនុគមន៍នេះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល $a^{\alpha x}$ និង $a^{-\alpha x}$ ។

ដើម្បីគណនាអាំងតេក្រាល $\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}$ យើងតាង $t=a^{\alpha x}$ $(\alpha\neq 0)$

នាំឱ្យ $dt=\alpha a^{\alpha x}\ln a\,dx$ និង $dx=\frac{1}{\alpha\ln a}\cdot\frac{dt}{t}$ ។

នាំឱ្យ $$\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}=\int\frac{1}{pt+\frac{q}{t}}\cdot\frac{1}{\alpha\ln a}\cdot\frac{dt}{t}=\frac{1}{\alpha\ln a}\int\frac{dt}{pt^2+q}\quad(*)$$ ។

- បើ $pq>0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}=\frac{1}{\alpha p\ln a}\int\frac{dt}{t^2+\frac{q}{p}}$$

$$=\frac{1}{\alpha p\ln a}\cdot\frac{1}{\sqrt{q/p}}\tan^{-1}\left(\frac{t}{\sqrt{q/p}}\right)+c$$

$$=\boxed{\frac{1}{\alpha\sqrt{pq}\ln a}\tan^{-1}\left(\sqrt{p/q}\;a^{\alpha x}\right)+c}\quad(4.17)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0\,,\,a\neq 1\,,\,\alpha\neq 0$ ។

ករណីពិសេស បើ $a=e$ នាំឱ្យសមីការ (4.17) ទៅជា

$$\int \frac{dx}{pe^{\alpha x}+qe^{-\alpha x}} = \boxed{\frac{1}{\alpha\sqrt{pq}}\tan^{-1}\left(\sqrt{p/q}\; e^{\alpha x}\right)+c} \qquad (4.18)$$

ដែល $c_1$ ជាចំនួនពិតថេរ។

- បើ $pq<0 \Leftrightarrow -pq>0$ នាំឱ្យសមីការ $(*)$ ទៅជា

$$\int \frac{dx}{pa^{\alpha x}+qa^{-\alpha x}} = \frac{1}{\alpha p\ln a}\int \frac{dt}{t^2+\frac{q}{p}} = \frac{1}{\alpha p\ln a}\int \frac{dt}{t^2-(\sqrt{-q/p})^2}$$

$$= \frac{1}{\alpha p\ln a}\cdot\frac{1}{2\sqrt{-q/p}}\ln\left|\frac{t-\sqrt{-q/p}}{t+\sqrt{-q/p}}\right|+c$$

$$= \boxed{\frac{1}{2\alpha\sqrt{-pq}\ln a}\ln\left|\frac{a^{\alpha x}-\sqrt{-q/p}}{a^{\alpha x}+\sqrt{-q/p}}\right|+c} \qquad (4.19)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0, a\neq 1, \alpha\neq 0$ ។

ករណីពិសេស បើ $a=e$ នាំឱ្យសមីការ (4.19) ទៅជា

$$\int \frac{dx}{pe^{\alpha x}+qe^{-\alpha x}} = \boxed{\frac{1}{2\alpha\sqrt{-pq}}\ln\left|\frac{e^{\alpha x}-\sqrt{-q/p}}{e^{\alpha x}+\sqrt{-q/p}}\right|+c} \qquad (4.20)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១១** គណនា $\int \frac{dx}{3e^{2x}+4e^{-2x}}$, $\int \frac{dx}{3e^{2x}-4e^{-2x}}$, $\int \frac{dx}{3\cdot 5^{6x}+4\cdot 5^{-6x}}$

និង $\int \frac{dx}{-3\cdot 5^{6x}+4\cdot 5^{-6x}}$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.18), (4.20), (4.17) និង (4.19) យើងបាន៖

$$\int \frac{dx}{3e^{2x}+4e^{-2x}} = \frac{1}{2\sqrt{3\cdot 4}}\tan^{-1}\left(\sqrt{3/4}\; e^{2x}\right)+c$$

$$= \frac{1}{4\sqrt{3}}\tan^{-1}\left(\frac{\sqrt{3}}{2}e^{2x}\right)+c$$

$$\int \frac{dx}{3e^{2x}-4e^{-2x}} = \frac{1}{2\cdot 2\sqrt{-3(-4)}}\ln\left|\frac{e^{2x}-\sqrt{-(-4)/3}}{e^{2x}+\sqrt{-(-4)/3}}\right|+c$$

$$=\frac{1}{8\sqrt{3}}\ln\left|\frac{e^{2x}-2/\sqrt{3}}{e^{2x}+2/\sqrt{3}}\right|+c$$

$$\int\frac{dx}{3\cdot 5^{6x}+4\cdot 5^{-6x}}=\frac{1}{6\sqrt{3\cdot 4}\ln 5}\tan^{-1}\left(\sqrt{3/4}\,5^{6x}\right)+c$$

$$=\frac{1}{12\sqrt{3}\ln 5}\tan^{-1}\left(\frac{\sqrt{3}}{2}5^{6x}\right)+c$$

និង $$\int\frac{dx}{-3\cdot 5^{6x}+4\cdot 5^{-6x}}=\frac{1}{2\cdot 6\sqrt{-(-3)\cdot 4}\ln 5}\ln\left|\frac{5^{6x}-\sqrt{-4/(-3)}}{5^{6x}+\sqrt{-4/(-3)}}\right|+c$$

## ៤.៦ អាំងតេក្រាលនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int_{-\infty}^{+\infty}e^{-ax^2}dx$

អាំងតេក្រាល $\int_{-\infty}^{+\infty}e^{-ax^2}dx\ (a>0)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $e^{-ax^2}$ ជាអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល។ ឥឡូវនេះ យើងតាង

$I(a)=\int_{0}^{+\infty}e^{-ax^2}dx\ (a>0)$ ។

នាំឱ្យ $$(I(a))^2=\int_0^{+\infty}e^{-ax^2}dx\int_0^{+\infty}e^{-ay^2}dy$$

$$=\int_0^{+\infty}\int_0^{+\infty}e^{-ax^2}e^{-ay^2}dxdy=\int_0^{+\infty}\int_0^{+\infty}e^{-a(x^2+y^2)}dxdy\quad(*)$$ ។

តាង $y=xt\,,\,t>0$ នាំឱ្យ $dy=x\,dt\,,\,t>0$ និងតាមសមីការ $(*)$ នាំឱ្យ

$$(I(a))^2=\int_0^{+\infty}\int_0^{+\infty}e^{-a(x^2+x^2t^2)}x\,dxdt=\int_0^{+\infty}\int_0^{+\infty}e^{-a(1+t^2)x^2}x\,dxdt\quad(*_1)$$ ។

តាង $u=-a(1+t^2)x^2$ នាំឱ្យ $du=-2a(1+t^2)x\,dx\Rightarrow x\,dx=-\frac{du}{2a(1+t^2)}$ និងតាមសមីការ $(*_1)$ នាំឱ្យ

$$(I(a))^2=-\int_0^{+\infty}\int_0^{-\infty}e^u\frac{du}{2a(1+t^2)}dt=-\frac{1}{2a}\int_0^{+\infty}\int_0^{-\infty}\frac{e^u}{1+t^2}du\,dt$$

$$= -\frac{1}{2a}\int_0^{+\infty}\frac{e^u}{1+t^2}\Bigg|_0^{-\infty} dt = \frac{1}{2a}\int_0^{+\infty}\frac{dt}{1+t^2}$$

$$= \frac{1}{2a}\tan^{-1}(t)\Big|_0^{+\infty} = \frac{1}{2a}\left(\frac{\pi}{2}-0\right) = \frac{\pi}{4a}$$

នាំឱ្យ $\int_0^{+\infty} e^{-ax^2}dx = I(a) = \sqrt{\frac{\pi}{4a}} = \boxed{\frac{1}{2}\sqrt{\frac{\pi}{a}}}$ (4.21)

និង $\int_{-\infty}^{+\infty} e^{-ax^2}dx = 2\int_0^{+\infty} e^{-ax^2}dx = \boxed{\sqrt{\frac{\pi}{a}}}$ (4.22)

ដែល $a > 0$ ។

ឥឡូវនេះ យើងនឹងគណនាអាំងតេក្រាល $\int_{\mu}^{+\infty}\frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2}dx$ និង $\int_{-\infty}^{+\infty}\frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2}dx$ ។

យើងតាង $t = \frac{x-\mu}{\sigma}$ នាំឱ្យ $dt = \frac{dx}{\sigma} \Leftrightarrow dx = \sigma\, dt$ ។

នាំឱ្យ $\int_{\mu}^{+\infty}\frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2}dx = \frac{1}{\sigma\sqrt{2\pi}}\int_0^{+\infty} e^{-\frac{1}{2}t^2}\sigma\, dt$

$$= \frac{1}{\sqrt{2\pi}}\int_0^{+\infty} e^{-\frac{1}{2}t^2}dt$$

$$= \frac{1}{\sqrt{2\pi}}\cdot\frac{1}{2}\sqrt{\frac{\pi}{1/2}} = \boxed{\frac{1}{2}}$$ (4.23) ( តាមរូបមន្ត (4.21) )

និង $\int_{-\infty}^{+\infty}\frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2}dx = \frac{1}{\sigma\sqrt{2\pi}}\int_{-\infty}^{+\infty} e^{-\frac{1}{2}t^2}\sigma\, dt$

$$= \frac{1}{\sqrt{2\pi}}\int_{-\infty}^{+\infty} e^{-\frac{1}{2}t^2}dt$$

$$=\frac{1}{\sqrt{2\pi}}\sqrt{\frac{\pi}{1/2}}=\boxed{1}\quad (4.24)$$ (តាមរូបមន្ត (4.22) )។

**ឧទាហរណ៍ទី១២** គណនា $\int_{0}^{+\infty} e^{-\sqrt{3}x^2}dx$ , $\int_{-\infty}^{+\infty} e^{-9x^2}dx$ , $\int_{5}^{+\infty} e^{-\frac{1}{2}\left(\frac{x-5}{2}\right)^2}dx$ និង $\int_{-\infty}^{+\infty} e^{-\frac{1}{2}\left(\frac{x-7}{3}\right)^2}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.21) , (4.22) , (4.23) និង (4.24) យើងបាន៖

$$\int_{0}^{+\infty} e^{-\sqrt{3}x^2}dx=\frac{1}{2}\sqrt{\frac{\pi}{\sqrt{3}}}$$

$$\int_{-\infty}^{+\infty} e^{-9x^2}dx=\sqrt{\frac{\pi}{9}}=\frac{\sqrt{\pi}}{3}$$

$$\int_{5}^{+\infty} e^{-\frac{1}{2}\left(\frac{x-5}{2}\right)^2}dx=\frac{1}{2}\cdot 2\sqrt{2\pi}=\sqrt{2\pi}$$

និង $$\int_{-\infty}^{+\infty} e^{-\frac{1}{2}\left(\frac{x-7}{3}\right)^2}dx=3\sqrt{2\pi}$$ ។

## ៤.៧ អាំងតេក្រាលនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលរាង $\int_{-\infty}^{+\infty} e^{-(ax^2+bx+c)}dx$

អាំងតេក្រាល $\int_{-\infty}^{+\infty} e^{-(ax^2+bx+c)}dx$ $(a>0)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $e^{-(ax^2+bx+c)}$ ជាអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល។

យើងមាន

$$-(ax^2+bx+c)=-a(x^2+\frac{bx}{a}+\frac{c}{a})=-a(x^2+2x\frac{b}{2a}+\frac{b^2}{4a^2}-\frac{b^2}{4a^2}+\frac{c}{a})$$

នាំឱ្យ $$\int_{-\infty}^{+\infty} e^{-(ax^2+bx+c)}dx=\int_{-\infty}^{+\infty} e^{-a(x+\frac{b}{2a})^2+\frac{b^2-4ac}{4a}}dx$$

$$= e^{\frac{b^2-4ac}{4a}} \int_{-\infty}^{+\infty} e^{-a(x+\frac{b}{2a})^2} d(x+\frac{b}{2a})$$

$$= \boxed{\sqrt{\frac{\pi}{a}}\, e^{\frac{b^2-4ac}{4a}}} \quad (4.25)$$ ( តាមរូបមន្ត (4.22) )។

ស្រដៀងគ្នាដែរ យើងបាន

$$\int_{-\infty}^{+\infty} e^{-ax^2} e^{-2bx}\, dx = \int_{-\infty}^{+\infty} e^{-ax^2-2bx}\, dx = \int_{-\infty}^{+\infty} e^{-a(x+b/a)^2+b^2/a}\, dx$$

ចំពោះអាំងតេក្រាល $\int_{-b/2a}^{+\infty} e^{-(ax^2+bx+c)}\, dx$ យើងតាង $u = x+\frac{b}{2a}$ នាំឱ្យ $du = dx$ ។

នាំឱ្យ $$\int_{-b/2a}^{+\infty} e^{-(ax^2+bx+c)}\, dx = \int_{-b/2a}^{+\infty} e^{-a(x+\frac{b}{2a})^2+\frac{b^2-4ac}{4a}}\, dx$$

$$= \int_{0}^{+\infty} e^{-au^2+\frac{b^2-4ac}{4a}}\, du = e^{\frac{b^2-4ac}{4a}} \int_{0}^{+\infty} e^{-au^2}\, du$$

$$= \boxed{\frac{1}{2}\sqrt{\frac{\pi}{a}}\, e^{\frac{b^2-4ac}{4a}}} \quad (4.27)$$ ( តាមរូបមន្ត (4.21) )។

**ឧទាហរណ៍ទី១៣** គណនា $\int_{-\infty}^{+\infty} e^{-(2x^2+3x+4)}\, dx$ , $\int_{-\infty}^{+\infty} e^{-16x^2} e^{-6x}\, dx$ និង

$\int_{-5/6}^{+\infty} e^{-(3x^2+5x+7)}\, dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (4.25) , (4.26) និង (4.27) យើងបាន៖

$$\int_{-\infty}^{+\infty} e^{-(2x^2+3x+4)}\, dx = \sqrt{\frac{\pi}{2}}\, e^{\frac{3^2-4\cdot 2\cdot 4}{4\cdot 2}} = \sqrt{\frac{\pi}{2}}\, e^{-\frac{23}{8}}$$

$$\int_{-\infty}^{+\infty} e^{-16x^2} e^{-6x}\, dx = \sqrt{\frac{\pi}{16}}\, e^{3^2/16} = \frac{1}{4}\sqrt{\pi}\, e^{9/16}$$

និង $\int_{-5/6}^{+\infty} e^{-(3x^2+5x+7)}\,dx = \frac{1}{2}\sqrt{\frac{\pi}{3}}\,e^{\frac{5^2-4\cdot3\cdot7}{4\cdot3}} = \frac{1}{6}\sqrt{3\pi}\,e^{-\frac{59}{12}}$ ។

ជាសរុប ជំពូកទី៤នេះបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលមួយចំនួនដូចជា $\int a^{\alpha x+\beta}\,dx$ , $\int e^{\alpha x+\beta}\,dx$ , $\int \frac{dx}{p+qa^{\alpha x}}$ , $\int \frac{dx}{(p+qa^{\alpha x})^2}$ , $\int \frac{a^{2\alpha x}\,dx}{p+qa^{\alpha x}}$ , $\int \frac{dx}{pa^{\alpha x}+qa^{-\alpha x}}$ , $\int_0^{+\infty} e^{-ax^2}dx$ , $\int_{-\infty}^{+\infty} e^{-ax^2}dx$ , $\int_{\mu}^{+\infty} \frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2}dx$ , $\int_{-\infty}^{+\infty} \frac{1}{\sigma\sqrt{2\pi}}e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2}dx$ , $\int_{-\infty}^{+\infty} e^{-(ax^2+bx+c)}\,dx$ , $\int_{-\infty}^{+\infty} e^{-ax^2}e^{-2bx}\,dx$ និង $\int_{-b/2a}^{+\infty} e^{-(ax^2+bx+c)}\,dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍លោការីតនៅក្នុងជំពូកទី៥បន្តទៀត។

# ជំពូកទី៥
# ប្រភេទអាំងតេក្រាលមានអនុគមន៍លោការីត
## ( Types of Integrals Involving Logarithmic Functions )

នៅក្នុងជំពូកទី៥នេះ យើងនឹងសិក្សាតែអំពីប្រភេទអាំងតេក្រាលមានអនុគមន៍លោការីតដែលមានលក្ខណៈពិសេសមួយចំនួននិងដំណោះស្រាយរបស់វាដូចតទៅ៖

## ៥.១ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a(px+q)\,dx$

អាំងតេក្រាល $\int \log_a(px+q)\,dx$ $(a>0\,,\, a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\log_a(px+q)$ $(a>0\,,\, a\neq 1)$ ជាអនុគមន៍លោការីតដែលកំណត់បានកាលណា $px+q>0$ ។

យើងចាប់ផ្តើមគណនាអាំងតេក្រាល $\int \log_a(px+q)\,dx$ ដោយសិក្សាពីរករណីគឺ $p=0$ និង $p\neq 0$ ។

- ករណី $p=0$ នាំឱ្យ $\int \log_a(px+q)\,dx = \int \log_a q\,dx = x\log_a q + c$

ដែល $c$ ជាចំនួនពិតថេរ និង $q>0$ ។

- ករណី $p\neq 0$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក

ដោយយក $u=\log_a(px+q)=\dfrac{\ln(px+q)}{\ln a}$ នាំឱ្យ $du=\dfrac{p\,dx}{(px+q)\ln a}$

និង $dv=dx$ នាំឱ្យ $v=x$ ។

នាំឱ្យ $\int \log_a(px+q)\,dx = \int u\,dv = uv - \int v\,du$

$$= x\log_a(px+q) - \frac{1}{\ln a}\int \frac{px}{(px+q)}dx$$

$$= x\log_a(px+q) - \frac{1}{\ln a}\int \frac{(px+q)-q}{(px+q)}dx$$

$$= x\log_a(px+q) - \frac{1}{\ln a}\int\left(1 - \frac{q}{px+q}\right)dx$$

$$= x\log_a(px+q) - \frac{1}{\ln a}\left(x - \frac{q}{p}\ln|px+q|\right) + c$$

$$= \frac{(px+q)}{p}\log_a(px+q) - \frac{x}{\ln a} + c \quad (px+q>0)$$

$$= \frac{(px+q)\ln(px+q) - px}{p\ln a} + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\int \log_a(px+q)dx = \frac{(px+q)}{p}\log_a(px+q) - \frac{x}{\ln a} + c = \frac{(px+q)\ln(px+q) - px}{p\ln a} + c \quad (5.1)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ , $p=1$ និង $q=0$ នោះតាមរូបមន្ត (5.1) ផ្តល់ឱ្យ

$$\int \ln x\,dx = x\ln x - x + c \quad (5.2)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $p=1$ និង $q=0$ នោះតាមរូបមន្ត (5.1) ផ្តល់ឱ្យ

$$\int \log_a x\,dx = x\log_a x - \frac{x}{\ln a} + c = \frac{x\ln x - x}{\ln a} + c \quad (5.3)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ នោះតាមរូបមន្ត (5.1) ផ្តល់ឱ្យ

$$\int \ln(px+q)dx = \frac{(px+q)\ln(px+q) - px}{p} + c = \frac{1}{p}(px+q)\ln(px+q) - x + c \quad (5.4)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១** គណនា $\int_1^e \ln x\,dx$ , $\int \log_3 x\,dx$ , $\int_3^4 \ln(2x-4)dx$ និង $\int \log_5(7x+9)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.2) , (5.3) , (5.4) និង (5.1) យើងបាន៖

$$\int_1^e \ln x\,dx = (x\ln x - x)\Big|_1^e = (e\ln e - e) - (1\cdot\ln 1 - 1) = 0 + 1 = 1$$

$$\int \log_3 x\,dx = x\log_3 x - \frac{x}{\ln 3} + c$$

$$\int_3^4 \ln(2x-4)\,dx = \frac{(2x-4)\ln(2x-4) - 2x}{2}\Bigg|_3^4$$

$$= \frac{6\ln 2 - 2}{2} = 3\ln 2 - 1 \approx 1.0794$$

និង $\int \log_5(7x+9)\,dx = \frac{(7x+9)}{7}\log_5(7x+9) - \frac{x}{\ln 5} + c$ ។

**ឧទាហរណ៍ទី២** គណនា $I = \int_1^e x\ln x\,dx$ និង $J = \int_1^e x^2\ln x\,dx$ ។

ដំណោះស្រាយ

ជាដំបូង យើងគណនា $I = \int_1^e x\ln x\,dx$ ។

យើងយក $u = x$ នាំឱ្យ $du = dx$

និង $dv = \ln x\,dx$ នាំឱ្យ $v = \int dv = \int \ln x\,dx = x\ln x - x$ ( តាមរូបមន្ត (5.2) )។

នាំឱ្យ $I = \int_1^e x\ln x\,dx = \int u\,dv = uv - \int v\,du$

$$= x(x\ln x - x)\Big|_1^e - \int_1^e (x\ln x - x)\,dx$$

$$= e(e\ln e - e) - 1\cdot(1\cdot\ln 1 - 1) - \int_1^e x\ln x\,dx + \int_1^e x\,dx$$

$$= 1 - I + \frac{x^2}{2}\Bigg|_1^e = 1 - I + \frac{1}{2}(e^2 - 1)$$

នាំឱ្យ $2I = 1 + \frac{1}{2}(e^2 - 1) = \frac{e^2 + 1}{2}$

នាំឱ្យ $I = \frac{e^2 + 1}{4} \approx 2.0972$ ។

បន្ទាប់មក យើងគណនា $J = \int_1^e x^2\ln x\,dx$ ។

យើងយក $u = x^2$ នាំឱ្យ $du = 2x\,dx$

និង $dv = \ln x\,dx$ នាំឱ្យ $v = \int dv = \int \ln x\,dx = x\ln x - x$ ( តាមរូបមន្ត (5.2) ) ។

នាំឱ្យ $\mathrm{J} = \int_1^e x^2 \ln x\,dx = \int u\,dv = uv - \int v\,du$

$$= x^2(x\ln x - x)\Big|_1^e - \int_1^e 2x(x\ln x - x)\,dx$$

$$= e^2(e\ln e - e) - 1^2\cdot(1\cdot\ln 1 - 1) - 2\int_1^e x^2\ln x\,dx + 2\int_1^e x^2\,dx$$

$$= 1 - 2\mathrm{J} + 2\cdot\frac{x^3}{3}\Big|_1^e = 1 - 2\mathrm{J} + \frac{2}{3}(e^3 - 1)$$

នាំឱ្យ $3\mathrm{J} = 1 + \frac{2}{3}(e^3 - 1) = \frac{2e^3 + 1}{3}$

នាំឱ្យ $\mathrm{J} = \frac{2e^3 + 1}{9} \approx 4.5745$ ។

## ៥.២ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a |px + q|\,dx$

អាំងតេក្រាល $\int \log_a |px+q|\,dx$ $(a > 0\,,\, a \neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\log_a |px+q|$ $(a > 0\,,\, a \neq 1)$ ជាអនុគមន៍លោការីតដែលកំណត់បានកាលណា $px + q \neq 0$ ។

យើងចាប់ផ្ដើមគណនាអាំងតេក្រាល $\int \log_a |px+q|\,dx$ ដោយសិក្សាពីរករណីគឺ $p = 0$ និង $p \neq 0$ ។

- ករណី $p = 0$ នាំឱ្យ $\int \log_a |px+q|\,dx = \int \log_a |q|\,dx = x\log_a |q| + c$

ដែល $c$ ជាចំនួនពិតថេរ និង $q \neq 0$ ។

- ករណី $p \neq 0$ និងយើងបន្ថែមលក្ខខណ្ឌ $px + q \neq 0$ ។

+ ចំពោះ $px + q > 0$ នាំឱ្យ $|px+q| = px + q$ និងតាមរូបមន្ត (5.1) ផ្ដល់ឱ្យ

$$\int \log_a|px+q|dx = \int \log_a(px+q)dx = \frac{(px+q)}{p}\log_a(px+q) - \frac{x}{\ln a} + c$$

+ ចំពោះ $px+q<0$ នាំឱ្យ $|px+q| = -(px+q) = (-p)x-q$ និងតាមរូបមន្ត (5.1) ផ្ដល់ឱ្យ

$$\int \log_a|px+q|dx = \int \log_a((-p)x-q)dx = \frac{((-p)x-q)}{(-p)}\log_a((-p)x-q) - \frac{x}{\ln a} + c$$

$$= \frac{(px+q)}{p}\log_a(-(px+q)) - \frac{x}{\ln a} + c$$

$$= \frac{(px+q)\ln(-(px+q)) - px}{p\ln a} + c$$ ។

ដូចនេះ បើ $p \neq 0$ និង $px+q \neq 0$ នាំឱ្យយើងបានរូបមន្ត

$$\int \log_a|px+q|dx = \frac{(px+q)}{p}\log_a|px+q| - \frac{x}{\ln a} + c = \frac{(px+q)\ln|px+q| - px}{p\ln a} + c \quad (5.5)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ , $p=1$ និង $q=0$ នោះតាមរូបមន្ត (5.5) ផ្ដល់ឱ្យ

$$\int \ln|x|dx = x\ln|x| - x + c \quad (5.6)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $p=1$ និង $q=0$ នោះតាមរូបមន្ត (5.5) ផ្ដល់ឱ្យ

$$\int \log_a|x|dx = x\log_a|x| - \frac{x}{\ln a} + c = \frac{x\ln|x| - x}{\ln a} + c \quad (5.7)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ នោះតាមរូបមន្ត (5.5) ផ្ដល់ឱ្យ

$$\int \ln|px+q|dx = \frac{(px+q)\ln|px+q| - px}{p} + c = \frac{1}{p}(px+q)\ln|px+q| - x + c \quad (5.8)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៣** គណនា $\int_{-1}^{-e} \ln|x|dx$ , $\int \log_7|x|dx$ , $\int_{1}^{2} \ln|3x-7|dx$ និង

$\int \log_{11}|3x-7|dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.6) , (5.7) , (5.8) និង (5.5) យើងបាន៖

$$\int_{-1}^{-e} \ln|x|dx = (x\ln|x|-x)\Big|_{-1}^{-e}$$

$$= (-e\ln|-e|-(-e))-((-1)\ln|-1|-(-1)) = -1$$

$$\int \log_7|x|dx = x\log_7|x| - \frac{x}{\ln 7} + c$$

$$\int_1^2 \ln|3x-7|dx = (\frac{1}{3}(3x-7)\ln|3x-7|-x)\Big|_1^2$$

$$= -2+\frac{4}{3}\ln 4+1 = \frac{4}{3}\ln 4 - 1 \approx 0.8483$$

និង $\int \log_{11}|3x-7|dx = \frac{(3x-7)}{3}\log_{11}|3x-7| - \frac{x}{\ln 11} + c$ ។

**ឧទាហរណ៍ទី៤** គណនា $\int \ln\left|3-\frac{7}{x}\right|dx$ និង $\int \ln|x(x+3)(5-x)|dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.8) និង (5.6) យើងបាន៖

$$\int \ln\left|3-\frac{7}{x}\right|dx = \int\big(\ln|3x-7|-\ln|x|\big)dx$$

$$= \left(\frac{1}{3}(3x-7)\ln|3x-7|-x\right)-\big(x\ln|x|-x\big)+c$$

$$= \frac{1}{3}(3x-7)\ln|3x-7| - x\ln|x| + c$$

និង $\int \ln|x(x+3)(5-x)|dx = \int\big(\ln|x|+\ln|x+3|+\ln|x-5|\big)dx$

$$= \big(x\ln|x|-x\big)+\big((x+3)\ln|x+3|-x\big)+\big((x-5)\ln|x-5|-x\big)+c$$

$$= x\ln|x|+(x+3)\ln|x+3|+(x-5)\ln|x-5|-3x+c$$ ។

## ៥.៣ អាំងតេក្រាលមានអនុគមន៍លោការីតរាង $\int \log_a^2(px+q)\,dx$

អាំងតេក្រាល $\int \log_a^2(px+q)\,dx$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\log_a^2(px+q)=[\log_a(px+q)]^2$ $(a>0\,,\,a\neq 1)$ ។ អនុគមន៍នេះមានអនុគមន៍លោការីត $\log_a(px+q)$ និងវាកំណត់បានកាលណា $px+q>0$ ។

យើងចាប់ផ្តើមគណនាអាំងតេក្រាល $\int \log_a^2(px+q)\,dx$ ដោយសិក្សាពីរករណីគឺ $p=0$ និង $p\neq 0$ ។

- ករណី $p=0$ នាំឱ្យ $\int \log_a^2(px+q)\,dx=\int \log_a^2 q\,dx = x\log_a^2 q + c$

ដែល $c$ ជាចំនួនពិតថេរ និង $q>0$ ។

- ករណី $p\neq 0$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក

ដោយយក $u=\log_a^2(px+q)=\dfrac{\ln^2(px+q)}{\ln^2 a}$ នាំឱ្យ $du=\dfrac{2p\ln(px+q)\,dx}{(px+q)\ln^2 a}$

និង $dv=dx$ នាំឱ្យ $v=x$ ។

នាំឱ្យ $\int \log_a^2(px+q)\,dx=\int u\,dv = uv-\int v\,du$

$$= x\log_a^2(px+q)-\frac{2p}{\ln^2 a}\int \frac{x\ln(px+q)}{(px+q)}dx$$

$$= x\log_a^2(px+q)-\frac{2}{\ln^2 a}\int \frac{[(px+q)-q]\ln(px+q)}{(px+q)}dx$$

$$= x\log_a^2(px+q)-\frac{2}{\ln^2 a}\int \ln(px+q)\,dx-\frac{2(-q)}{\ln^2 a}\int \frac{\ln(px+q)}{px+q}dx$$

$$= x\log_a^2(px+q)-\frac{2}{\ln^2 a}\left[\frac{1}{p}(px+q)\ln|px+q|-x\right]+\frac{2q}{p\ln^2 a}\int \ln(px+q)\,d[\ln(px+q)]$$

$$= x\log_a^2(px+q)-\frac{2}{p\ln^2 a}(px+q)\ln|px+q|+\frac{2x}{\ln^2 a}+\frac{q}{p\ln^2 a}\ln^2(px+q)+c$$

$$= x\log_a^2(px+q)-\frac{2}{p\ln a}(px+q)\log_a(px+q)+\frac{2x}{\ln^2 a}+\frac{q}{p}\log_a^2(px+q)+c$$

$$=\frac{(px+q)}{p}\log_a^2(px+q)-\frac{2(px+q)}{p\ln a}\log_a(px+q)+\frac{2x}{\ln^2 a}+c$$

ដែល $c$ ជាចំនួនពិតថេរ និង $px+q>0$ ។

ដូចនេះ បើ $p\neq 0$ និង $px+q>0$ នាំឱ្យយើងបានរូបមន្ត

$$\boxed{\int\log_a^2(px+q)dx=\frac{(px+q)}{p}\log_a^2(px+q)-\frac{2(px+q)}{p\ln a}\log_a(px+q)+\frac{2x}{\ln^2 a}+c}\quad(5.9)$$

ដែល $c$ ជាចំនួនពិតថេរ និង $px+q>0$ ។

- ចំពោះ $a=e$ , $p=1$ និង $q=0$ នោះតាមរូបមន្ត (5.9) ផ្តល់ឱ្យ

$$\boxed{\int\ln^2 x\,dx=x\ln^2 x-2x\ln x+2x+c}\quad(5.10)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $p=1$ និង $q=0$ នោះតាមរូបមន្ត (5.9) ផ្តល់ឱ្យ

$$\boxed{\int\log_a^2 x\,dx=x\log_a^2 x-\frac{2x}{\ln a}\log_a x+\frac{2x}{\ln^2 a}+c}\quad(5.11)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ នោះតាមរូបមន្ត (5.9) ផ្តល់ឱ្យ

$$\boxed{\int\ln^2(px+q)dx=\frac{(px+q)}{p}\ln^2(px+q)-\frac{2(px+q)}{p}\ln(px+q)+2x+c}\quad(5.12)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៥** គណនា $\int_1^e\ln^2 x\,dx$ , $\int\log_3^2 x\,dx$ , $\int_3^4\ln^2(2x-4)dx$ និង

$\int\log_5^2(7x+9)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.10) , (5.11) , (5.12) និង (5.9) យើងបាន៖

$$\int_1^e\ln^2 x\,dx=\left(x\ln^2 x-2x\ln x+2x\right)\Big|_1^e$$

$$=\left(e\ln^2 e-2e\ln e+2e\right)-\left(1\cdot\ln^2 1-2\cdot 1\cdot\ln 1+2\cdot 1\right)$$

$$= e - 2 \approx 0.7182$$

$$\int \log_3^2 x\,dx = x\log_3^2 x - \frac{2x}{\ln 3}\log_3 x + \frac{2x}{\ln^2 3} + c$$

$$\int_3^4 \ln^2(2x-4)\,dx = \left[\frac{(2x-4)}{2}\ln^2(2x-4) - \frac{2(2x-4)}{2}\ln(2x-4) + 2x\right]\Bigg|_3^4$$

$$= 7\ln^2 2 - 6\ln 2 + 2 \approx 1.2042$$

និង $$\int \log_5^2(7x+9)\,dx = \frac{1}{7}(7x+9)\log_5^2(7x+9)$$

$$-\frac{2(7x+9)}{7\ln 5}\log_5(7x+9) + \frac{2x}{\ln^2 5} + c \text{ ។}$$

## ៥.៤ អាំងតេក្រាលមានអនុគមន៍លោការីតរាង $\int \log_a^2 |px+q|\,dx$

អាំងតេក្រាល $\int \log_a^2 |px+q|\,dx$ $(a>0\,,\, a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\log_a^2 |px+q| = \left[\log_a |px+q|\right]^2$ $(a>0\,,\, a\neq 1)$ ។ អនុគមន៍នេះមានអនុគមន៍លោការីត $\log_a |px+q|$ និងវាកំណត់បានកាលណា $px+q\neq 0$ ។

យើងចាប់ផ្តើមគណនាអាំងតេក្រាល $\int \log_a^2 |px+q|\,dx$ ដោយសិក្សាពីរករណីគឺ $p=0$ និង $p\neq 0$ ។

- ករណី $p=0$ នាំឱ្យ $\int \log_a^2 |px+q|\,dx = \int \log_a^2 |q|\,dx = x\log_a^2 |q| + c$ ដែល $c$ ជាចំនួនពិតថេរ និង $q\neq 0$ ។

- ករណី $p\neq 0$ និងយើងបន្ថែមលក្ខខណ្ឌ $px+q\neq 0$ ។

+ ចំពោះ $px+q>0$ នាំឱ្យ $|px+q| = px+q$ និងតាមរូបមន្ត (5.9) ផ្តល់ឱ្យ

$$\int \log_a^2 |px+q|\,dx = \int \log_a^2 (px+q)\,dx$$

$$= \frac{(px+q)}{p}\log_a^2(px+q) - \frac{2(px+q)}{p\ln a}\log_a(px+q) + \frac{2x}{\ln^2 a} + c \text{ ។}$$

+ ចំពោះ $px+q<0$ នាំឱ្យ $|px+q|=-(px+q)=(-p)x-q$ និងតាមរូបមន្ត (5.9) ផ្តល់ឱ្យ

$$\int \log_a^2|px+q|dx = \int \log_a^2((-p)x-q)dx$$

$$= \frac{((-p)x-q)}{(-p)}\log_a^2((-p)x-q) - \frac{2((-p)x-q)}{(-p)\ln a}\log_a((-p)x-q) + \frac{2x}{\ln^2 a} + c$$

$$= \frac{(px+q)}{p}\log_a^2(-(px+q)) - \frac{2(px+q)}{p\ln a}\log_a(-(px+q)) + \frac{2x}{\ln^2 a} + c$$ ។

ដូចនេះ បើ $p\neq 0$ និង $px+q\neq 0$ នាំឱ្យយើងបានរូបមន្ត

$$\boxed{\int \log_a^2|px+q|dx = \frac{(px+q)}{p}\log_a^2|px+q| - \frac{2(px+q)}{p\ln a}\log_a|px+q| + \frac{2x}{\ln^2 a} + c} \quad (5.13)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ , $p=1$ និង $q=0$ នោះតាមរូបមន្ត (5.13) ផ្តល់ឱ្យ

$$\boxed{\int \ln^2|x|dx = x\ln^2|x| - 2x\ln|x| + 2x + c} \quad (5.14)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $p=1$ និង $q=0$ នោះតាមរូបមន្ត (5.13) ផ្តល់ឱ្យ

$$\boxed{\int \log_a^2|x|dx = x\log_a^2|x| - \frac{2x}{\ln a}\log_a|x| + \frac{2x}{\ln^2 a} + c} \quad (5.15)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ នោះតាមរូបមន្ត (5.13) ផ្តល់ឱ្យ

$$\boxed{\int \ln^2|px+q|dx = \frac{(px+q)}{p}\ln^2|px+q| - \frac{2(px+q)}{p}\ln|px+q| + 2x + c} \quad (5.16)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៦** គណនា $\int_{-e}^{-1} \ln^2|x|dx$ , $\int \log_5^2|x|dx$ , $\int_3^4 \ln^2|2-3x|dx$ និង $\int \log_7^2|4x-5|dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.14) , (5.15) , (5.16) និង (5.13) យើងបាន៖

$$\int_{-e}^{-1} \ln^2|x|dx = \left(x\ln^2|x| - 2x\ln|x| + 2x\right)\Big|_{-e}^{-1}$$

$$= \left((-1)\ln^2|-1| - 2(-1)\ln|-1| + 2(-1)\right) - \left((-e)\ln^2|-e| - 2(-e)\ln|-e| + 2(-e)\right)$$

$$= e - 2 \approx 0.7182$$

$$\int \log_5^2|x|dx = x\log_5^2|x| - \frac{2x}{\ln 5}\log_5|x| + \frac{2x}{\ln^2 5} + c$$

$$\int_3^4 \ln^2|2-3x|dx = \int_3^4 \ln^2|3x-2|dx$$

$$= \left[\frac{(3x-2)}{3}\ln^2|3x-2| - \frac{2(3x-2)}{3}\ln|3x-2| + 2x\right]\Big|_3^4$$

$$= \frac{10}{3}\ln^2 10 - \frac{7}{3}\ln^2 7 - \frac{20}{3}\ln 10 + \frac{14}{3}\ln 7 + 2 \approx 4.5680$$

និង $\int \log_7^2|4x-5|dx = \frac{(4x-5)}{4}\log_7^2|4x-5| - \frac{2(4x-5)}{4\ln 7}\log_7|4x-5| + \frac{2x}{\ln^2 7} + c$ ។

## ៥.៥ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a(x^2+b^2)\,dx$

អាំងតេក្រាល $\int \log_a(x^2+b^2)\,dx$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\log_a(x^2+b^2)$ $(a>0\,,\,a\neq 1)$ ។ អនុគមន៍នេះ ជាអនុគមន៍លោការីតដែលកំណត់លើ $\mathbb{R}$ កាលណា $b\neq 0$ ។

យើងចាប់ផ្តើមគណនាអាំងតេក្រាល $\int \log_a(x^2+b^2)\,dx$ ដោយសិក្សាពីរករណីគឺ $b=0$ និង $b\neq 0$ ។

- ករណី $b=0$ នាំឱ្យ

$$\int \log_a(x^2+b^2)\,dx = \int \log_a(x^2)\,dx = 2\int \log_a(x)\,dx$$

$$= 2\left(x\log_a x - \frac{x}{\ln a}\right) + c = 2x\log_a x - \frac{2x}{\ln a} + c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $b \neq 0$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក

ដោយយក $u = \log_a(x^2+b^2) = \dfrac{\ln(x^2+b^2)}{\ln a}$ នាំឱ្យ $du = \dfrac{2x\,dx}{(x^2+b^2)\ln a}$

និង $dv = dx$ នាំឱ្យ $v = x$ ។

នាំឱ្យ $\int \log_a(x^2+b^2)dx = \int u\,dv = uv - \int v\,du$

$$= x\log_a(x^2+b^2) - \frac{2}{\ln a}\int \frac{x^2}{(x^2+b^2)}dx$$

$$= x\log_a(x^2+b^2) - \frac{2}{\ln a}\int \frac{(x^2+b^2)-b^2}{(x^2+b^2)}dx$$

$$= x\log_a(x^2+b^2) - \frac{2}{\ln a}\int \left(1 - \frac{b^2}{x^2+b^2}\right)dx$$

$$= x\log_a(x^2+b^2) - \frac{2}{\ln a}\left[x - b^2\cdot\frac{1}{b}\tan^{-1}\left(\frac{x}{b}\right)\right] + c$$

$$= x\log_a(x^2+b^2) - \frac{2x}{\ln a} + \frac{2b}{\ln a}\tan^{-1}\left(\frac{x}{b}\right) + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ បើ $b \neq 0$ នាំឱ្យយើងបានរូបមន្ត

$$\boxed{\int \log_a(x^2+b^2)dx = x\log_a(x^2+b^2) - \frac{2x}{\ln a} + \frac{2b}{\ln a}\tan^{-1}\left(\frac{x}{b}\right) + c} \quad (5.17)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a = e$ នោះតាមរូបមន្ត (5.17) ផ្ដល់ឱ្យ

$$\boxed{\int \ln(x^2+b^2)dx = x\ln(x^2+b^2) - 2x + 2b\tan^{-1}\left(\frac{x}{b}\right) + c} \quad (5.18)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៧** គណនា $\int_1^3 \ln(x^2+5)\,dx$ , $\int \log_3(x^2+16)\,dx$ និង $\int_0^2 \log_5(6x^2+25)\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.18) និង (5.17) យើងបាន៖

$$\int_1^3 \ln(x^2+5)\,dx = \left( x\ln(x^2+5) - 2x + 2\sqrt{5}\tan^{-1}\left(\frac{x}{\sqrt{5}}\right)\right)\Bigg|_1^3$$

$$= \left(3\ln 14 - 6 + 2\sqrt{5}\tan^{-1}\left(\frac{3}{\sqrt{5}}\right)\right) - \left(\ln 6 - 2 + 2\sqrt{5}\tan^{-1}\left(\frac{1}{\sqrt{5}}\right)\right)$$

$$\int \log_3(x^2+16)\,dx = x\log_3(x^2+16) - \frac{2x}{\ln 3} + \frac{8}{\ln 3}\tan^{-1}\left(\frac{x}{4}\right) + c$$

និង $\int_0^2 \log_5(6x^2+25)\,dx = \int_0^2 \log_5[6(x^2+25/6)]\,dx$

$$= \int_0^2 \left[\log_5 6 + \log_5(x^2+25/6)\right]dx$$

$$= \left( x\log_5 6 + x\log_5(x^2+25/6) - \frac{2x}{\ln 5} + \frac{10}{\sqrt{6}\ln 5}\tan^{-1}\left(\frac{x\sqrt{6}}{5}\right)\right)\Bigg|_0^2$$

$$= 2\log_5 6 + 2\log_5(49/6) - \frac{4}{\ln 5} + \frac{10}{\sqrt{6}\ln 5}\tan^{-1}\left(\frac{2\sqrt{6}}{5}\right) \approx 4.3172$$ ។

## ៥.៦ អាំងតេក្រាលនៃអនុគមន៍លោការីតរាង $\int \log_a(x^2-b^2)\,dx$

អាំងតេក្រាល $\int \log_a(x^2-b^2)\,dx$ $(a>0\,,\,a\neq 1)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\log_a(x^2-b^2)$ $(a>0\,,\,a\neq 1)$ ។ អនុគមន៍នេះ ជាអនុគមន៍លោការីតដែលកំណត់លើ $x^2-b^2>0 \Leftrightarrow x<-|b| \vee x>|b|$ កាលណា $b\neq 0$ ។

យើងចាប់ផ្ដើមគណនាអាំងតេក្រាល $\int \log_a(x^2-b^2)\,dx$ ដោយសិក្សាពីរករណីគឺ $b=0$ និង $b\neq 0$ ។

- ករណី $b=0$ នាំឱ្យ

$$\int \log_a(x^2-b^2)\,dx=\int \log_a(x^2)\,dx=2\int \log_a(x)\,dx$$

$$=2(x\log_a x-\frac{x}{\ln a})+c=2x\log_a x-\frac{2x}{\ln a}+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $b\neq 0$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក

ដោយយក $u=\log_a(x^2-b^2)=\dfrac{\ln(x^2-b^2)}{\ln a}$ នាំឱ្យ $du=\dfrac{2x\,dx}{(x^2-b^2)\ln a}$

និង $dv=dx$ នាំឱ្យ $v=x$ ។

នាំឱ្យ $\int \log_a(x^2-b^2)dx=\int u\,dv=uv-\int v\,du$

$$=x\log_a(x^2-b^2)-\frac{2}{\ln a}\int\frac{x^2}{(x^2-b^2)}dx$$

$$=x\log_a(x^2-b^2)-\frac{2}{\ln a}\int\frac{(x^2-b^2)+b^2}{(x^2-b^2)}dx$$

$$=x\log_a(x^2-b^2)-\frac{2}{\ln a}\int\left(1+\frac{b^2}{x^2-b^2}\right)dx$$

$$=x\log_a(x^2-b^2)-\frac{2}{\ln a}\left[x+b^2\cdot\frac{1}{2b}\ln\left|\frac{x-b}{x+b}\right|\right]+c$$

$$=x\log_a(x^2-b^2)-\frac{2x}{\ln a}+\frac{b}{\ln a}\ln\left|\frac{x+b}{x-b}\right|+c$$

$$=x\log_a(x^2-b^2)-\frac{2x}{\ln a}+b\log_a\left|\frac{x+b}{x-b}\right|+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ បើ $b\neq 0$ នាំឱ្យយើងបានរូបមន្ត

$$\boxed{\int \log_a(x^2-b^2)dx=x\log_a(x^2-b^2)-\frac{2x}{\ln a}+b\log_a\left|\frac{x+b}{x-b}\right|+c}\quad(5.19)$$

ដែល $c$ ជាចំនួនពិតថេរ។

- ចំពោះ $a=e$ នោះតាមរូបមន្ត (5.19) ផ្តល់ឱ្យ

$$\int \ln(x^2-b^2)\,dx = x\ln(x^2-b^2)-2x+b\ln\left|\frac{x+b}{x-b}\right|+c \quad (5.20)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៨** គណនា $\int_3^5 \ln(x^2-4)\,dx$ , $\int \log_3(x^2-9)\,dx$ និង $\int_{-4}^{-2} \log_5(9x^2-16)\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (5.20) និង (5.19) យើងបាន៖

$$\int_3^5 \ln(x^2-4)\,dx = \left( x\ln(x^2-4)-2x+2\ln\left|\frac{x+2}{x-2}\right| \right)\Bigg|_3^5$$

$$= \left( 5\ln 21-10+2\ln\left|\frac{7}{3}\right| \right) - \left( 3\ln 5-6+2\ln\left|\frac{5}{1}\right| \right)$$

$$= 5\ln 21-3\ln 5-4+2\ln\frac{7}{15} \approx 4.8700$$

$$\int \log_3(x^2-9)\,dx = x\log_3(x^2-9)-\frac{2x}{\ln 3}+3\log_3\left|\frac{x+3}{x-3}\right|+c$$

និង

$$\int_{-4}^{-2} \log_5(9x^2-16)\,dx = \int_{-4}^{-2} \log_5[9(x^2-16/9)]\,dx$$

$$= \int_{-4}^{-2} \left[ \log_5 9+\log_5(x^2-16/9) \right] dx$$

$$= \left( x\log_5 9+x\log_5(x^2-16/9)-\frac{2x}{\ln 5}+\frac{4}{3}\log_5\left|\frac{x+4/3}{x-4/3}\right| \right)\Bigg|_{-4}^{-2}$$

$$-\left( -4\log_5 9-4\log_5\frac{128}{9}+\frac{8}{\ln 5}+\frac{4}{3}\log_5\frac{1}{2} \right)$$

$$= 2\log_5 9-2\log_5\frac{20}{9}+4\log_5\frac{128}{9}-\frac{4}{\ln 5}+\frac{4}{3}\log_5\frac{2}{5} \approx 5.0917$$ ។

**ឧទាហរណ៍ទី៩** គណនា $\int \log_2(x^3-1)\,dx$ និង $\int \log_4(x^4-1)\,dx$ ។

ដំណោះស្រាយ

យើងមាន $x^3-1=(x-1)(x^2+x+1)=(x-1)\left[(x+1/2)^2+3/4\right]$

និង $x^4-1=\left(x^2\right)^2-1^2=\left(x^2-1\right)\left(x^2+1\right)$ ។

តាមរូបមន្ត (5.1) , (5.17) និង (5.19) យើងបាន៖

$$\int \log_2(x^3-1)\,dx = \int \log_2[(x-1)(x^2+x+1)]\,dx$$

$$= \int \log_2(x-1)\,dx + \int \log_2(x^2+x+1)\,dx$$

$$= \int \log_2(x-1)\,dx + \int \log_2\left((x+1/2)^2+3/4\right)d(x+1/2)$$

$$= (x-1)\log_2(x-1) - \frac{x}{\ln 2} + (x+1/2)\log_2\left((x+1/2)^2+3/4\right)$$

$$-\frac{2(x+1/2)}{\ln 2} + \frac{2(\sqrt{3}/2)}{\ln 2}\tan^{-1}\left(\frac{x+1/2}{\sqrt{3}/2}\right) + c$$

$$= (x-1)\log_2(x-1) - \frac{3x}{\ln 2} + \frac{1}{2}(2x+1)\log_2\left(x^2+x+1\right) + \frac{\sqrt{3}}{\ln 2}\tan^{-1}\left(\frac{2x+1}{\sqrt{3}}\right) + c_1$$

និង $\int \log_4(x^4-1)\,dx = \int \log_4\left[(x^2-1)(x^2+1)\right]dx$

$$= \int \log_4(x^2-1)\,dx + \int \log_4(x^2+1)\,dx$$

$$= x\log_4(x^2-1) - \frac{2x}{\ln 4} + \log_4\left|\frac{x+1}{x-1}\right|$$

$$+x\log_4(x^2+1) - \frac{2x}{\ln 4} + \frac{2}{\ln 4}\tan^{-1}x + c$$

$$= x\log_4(x^4-1) - \frac{4x}{\ln 4} + \log_4\left|\frac{x+1}{x-1}\right| + \frac{2}{\ln 4}\tan^{-1}x + c$$ ។

**ឧទាហរណ៍ទី១០** គណនា $\int \log_7(x^8-1)dx$ ។

ដំណោះស្រាយ

យើងមាន $x^8-1 = \left(x^4\right)^2 - 1^2 = \left(x^4-1\right)\left(x^4+1\right)$

$$= \left(x^2-1\right)\left(x^2+1\right)\left[(x^4+2x^2+1) - 2x^2\right]$$

$$= \left(x^2-1\right)\left(x^2+1\right)\left[(x^2+1)^2 - (x\sqrt{2})^2\right]$$

$$= \left(x^2-1\right)\left(x^2+1\right)\left(x^2+1-x\sqrt{2}\right)\left(x^2+1+x\sqrt{2}\right)$$

$$= \left(x^2-1\right)\left(x^2+1\right)\left((x-\sqrt{2}/2)^2+1/2\right)\left((x+\sqrt{2}/2)^2+1/2\right)$$ ។

តាមរូបមន្ត (5.17) និង (5.19) យើងបាន៖

$$\int \log_7(x^8-1)dx = \int \log_7\left[\left(x^2-1\right)\left(x^2+1\right)\left((x-\sqrt{2}/2)^2+1/2\right)\left((x+\sqrt{2}/2)^2+1/2\right)\right]dx$$

$$= \int \log_7\left(x^2-1\right)dx + \int \log_7\left(x^2+1\right)dx$$

$$+\int \log_7\left((x-\sqrt{2}/2)^2+1/2\right)dx + \int \log_7\left((x+\sqrt{2}/2)^2+1/2\right)dx$$

$$= x\log_7(x^2-1) - \frac{2x}{\ln 7} + \log_7\left|\frac{x+1}{x-1}\right| + x\log_7(x^2+1) - \frac{2x}{\ln 7} + \frac{2}{\ln 7}\tan^{-1}x$$

$$+(x-\sqrt{2}/2)\log_7\left((x-\sqrt{2}/2)^2+1/2\right) - \frac{2(x-\sqrt{2}/2)}{\ln 7} + \frac{2(\sqrt{2}/2)}{\ln 7}\tan^{-1}\left(\frac{(x-\sqrt{2}/2)}{\sqrt{2}/2}\right)$$

$$+(x+\sqrt{2}/2)\log_7\left((x+\sqrt{2}/2)^2+1/2\right) - \frac{2(x+\sqrt{2}/2)}{\ln 7} + \frac{2(\sqrt{2}/2)}{\ln 7}\tan^{-1}\left(\frac{(x+\sqrt{2}/2)}{\sqrt{2}/2}\right) + c$$

$$= x\log_7(x^4-1) - \frac{4x}{\ln 7} + \log_7\left|\frac{x+1}{x-1}\right| + \frac{2}{\ln 7}\tan^{-1}x$$

$$+\frac{1}{2}(2x-\sqrt{2})\log_7\left(x^2-x\sqrt{2}+1\right) - \frac{4x}{\ln 7} + \frac{\sqrt{2}}{\ln 7}\tan^{-1}\left(\frac{2x-\sqrt{2}}{\sqrt{2}}\right)$$

$$+\frac{1}{2}(2x+\sqrt{2})\log_7\left(x^2+x\sqrt{2}+1\right) + \frac{\sqrt{2}}{\ln 7}\tan^{-1}\left(\frac{2x+\sqrt{2}}{\sqrt{2}}\right) + c$$ ។

ជាសរុប ជំពូកទី៥នេះបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍លោការីតនិងអាំងតេក្រាលមានអនុគមន៍លោការីតមួយចំនួនដូចជា $\int \log_a(px+q)\,dx$ , $\int \log_a|px+q|\,dx$ , $\int \log_a^2(px+q)\,dx$ , $\int \log_a^2|px+q|\,dx$ , $\int \log_a(x^2+b^2)\,dx$ និង $\int \log_a(x^2-b^2)\,dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅ និងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណនៅក្នុងជំពូកទី៦បន្តទៀត។

# ជំពូកទី៦
# ប្រភេទអាំងតេក្រាលមាន
# អនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ
( Types of Integrals Involving Exponential and Power Functions )

នៅក្នុងជំពូកទី៦នេះ យើងនឹងសិក្សាតែអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណដែលមានលក្ខណៈពិសេសមួយចំនួននិងដំណោះស្រាយរបស់វាដូចតទៅ៖

## ៦.១ ប្រភេទអាំងតេក្រាលមានរាង $\int x e^{\alpha x}\,dx$ និង $\int x a^{\alpha x}\,dx$

អាំងតេក្រាល $\int x e^{\alpha x}\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $xe^{\alpha x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងនឹងគណនាអាំងតេក្រាល $\int x e^{\alpha x}\,dx$ តាមការសិក្សាពីរករណីគឺ $\alpha = 0$ និង $\alpha \neq 0$ ។

- ករណី $\alpha = 0$ នាំឱ្យ

$$\int x e^{\alpha x}\,dx = \int x e^{0\cdot x}\,dx = \int x\,dx = \frac{x^2}{2} + c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $\alpha \neq 0$ នោះយើងប្រើវិធីអាំងតេក្រាលដោយផ្នែក ដោយយក $u = x$ នាំឱ្យ $du = dx$ និង $dv = e^{\alpha x}dx$ នាំឱ្យ $v = \frac{1}{\alpha}e^{\alpha x}$ ។

នាំឱ្យ $\int x e^{\alpha x}\,dx = \frac{x}{\alpha}e^{\alpha x} - \frac{1}{\alpha}\int e^{\alpha x}\,dx$

$$=\frac{x}{\alpha}e^{\alpha x}-\frac{1}{\alpha}\cdot\frac{1}{\alpha}e^{\alpha x}+c=\frac{e^{\alpha x}}{\alpha^2}(\alpha x-1)+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x e^{\alpha x}\,dx=\frac{e^{\alpha x}}{\alpha^2}(\alpha x-1)+c} \quad (6.1)$$

ដែល $c$ ជាចំនួនពិតថេរ។

បន្ទាប់មក យើងនឹងគណនាអាំងតេក្រាល $\int x a^{\alpha x}\,dx$ ។

តាមរូបមន្ត (6.1) យើងទាញបាន៖

$$\int x a^{\alpha x}\,dx=\int x\left(e^{\ln a}\right)^{\alpha x}dx=\int x e^{(\alpha\ln a)x}\,dx$$

$$=\frac{e^{(\alpha\ln a)x}}{(\alpha\ln a)^2}\left((\alpha\ln a)x-1\right)+c$$

$$=\frac{a^{\alpha x}}{\alpha^2\ln^2 a}(\alpha x\ln a-1)+c$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0$ , $a\neq 1$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x a^{\alpha x}\,dx=\frac{a^{\alpha x}}{\alpha^2\ln^2 a}(\alpha x\ln a-1)+c} \quad (6.2)$$

ដែល $c$ ជាចំនួនពិតថេរ និង $a>0$ , $a\neq 1$។

**ឧទាហរណ៍ទី១** គណនា $\int x e^{3x}\,dx$ , $\int (2x+5)e^{2x-7}\,dx$ និង $\int x 5^{3x+4}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.1) និង (6.2) យើងបាន៖

$$\int x e^{3x}\,dx=\frac{e^{3x}}{3^2}(3x-1)+c=\frac{e^{3x}}{9}(3x-1)+c$$

$$\int (2x+5)e^{2x-7}\,dx=e^{-7}\int (2x+5)e^{2x}\,dx$$

$$= 2e^{-7}\int xe^{2x}\,dx + 5e^{-7}\int e^{2x}\,dx$$

$$= 2e^{-7}\cdot\frac{e^{2x}}{2^2}(2x-1) + 5e^{-7}\cdot\frac{1}{2}e^{2x} + c$$

$$= \frac{e^{2x-7}}{2}(2x-1) + \frac{5e^{2x-7}}{2} + c$$

$$= \frac{e^{2x-7}}{2}(2x+4) + c$$

និង $\int x5^{3x+4}\,dx = 5^4\int x5^{3x}\,dx = 5^4\cdot\frac{5^{3x}}{3^2\ln^2 5}(3x\ln 5 - 1) + c$

$$= \frac{5^{3x+4}}{9\ln^2 5}(3x\ln 5 - 1) + c$$ ។

**ឧទាហរណ៍ទី២** គណនា $\int_0^1 xe^{2x+3}\,dx$ និង $\int_0^{+\infty} x3^{-4x}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.1) និង (6.2) យើងបាន៖

$$\int_0^1 xe^{2x+3}\,dx = \left.\frac{e^{2x}}{2^2}(2x-1)\right|_0^1$$

$$= \frac{e^{2\cdot 1}}{2^2}(2\cdot 1 - 1) - \frac{e^{2\cdot 0}}{2^2}(2\cdot 0 - 1) = \frac{e^2+1}{4}$$

និង $\int_0^{+\infty} x3^{-4x}\,dx = \left.\frac{3^{-4x}}{(-4)^2\ln^2 3}\left((-4)x\ln 3 - 1\right)\right|_0^{+\infty}$

$$= 0 - \frac{(-4\cdot 0\cdot \ln 3 - 1)}{16\ln^2 3\times 3^0} = \frac{1}{16\ln^2 3}$$ ។

## ៦.២ ប្រភេទអាំងតេក្រាលមានរាង $\int x^2 e^{\alpha x}\,dx$ និង $\int x^2 a^{\alpha x}\,dx$

អាំងតេក្រាល $\int x^2 e^{\alpha x}\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^2 e^{\alpha x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងនឹងគណនាអាំងតេក្រាល $\int x^2 e^{\alpha x} dx$ តាមការសិក្សាពីរករណីគឺ $\alpha = 0$ និង $\alpha \neq 0$ ។

- ករណី $\alpha = 0$ នាំឱ្យ

$$\int x^2 e^{\alpha x} dx = \int x^2 e^{0\cdot x} dx = \int x^2 dx = \frac{x^3}{3} + c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $\alpha \neq 0$ នោះយើងប្រើវិធីអាំងតេក្រាលដោយផ្នែក ដោយយក $u = x^2$ នាំឱ្យ $du = 2x\,dx$ និង $dv = e^{\alpha x}dx$ នាំឱ្យ $v = \frac{1}{\alpha}e^{\alpha x}$ ។

នាំឱ្យ
$$\int x^2 e^{\alpha x} dx = \frac{x^2}{\alpha}e^{\alpha x} - \frac{2}{\alpha}\int x e^{\alpha x} dx$$
$$= \frac{x^2}{\alpha}e^{\alpha x} - \frac{2}{\alpha}\cdot\frac{e^{\alpha x}}{\alpha^2}(\alpha x - 1) + c$$
$$= \frac{\alpha^2 x^2}{\alpha^3}e^{\alpha x} - \frac{2e^{\alpha x}}{\alpha^3}(\alpha x - 1) + c$$
$$= \frac{e^{\alpha x}}{\alpha^3}\left(\alpha^2 x^2 - 2\alpha x + 2\right) + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x^2 e^{\alpha x} dx = \frac{e^{\alpha x}}{\alpha^3}\left(\alpha^2 x^2 - 2\alpha x + 2\right) + c} \quad (6.3)$$

ដែល $c$ ជាចំនួនពិតថេរ។

បន្ទាប់មក យើងនឹងគណនាអាំងតេក្រាល $\int x^2 a^{\alpha x} dx$ ។

តាមរូបមន្ត (6.3) យើងទាញបាន៖

$$\int x^2 a^{\alpha x} dx = \int x^2 \left(e^{\ln a}\right)^{\alpha x} dx = \int x^2 e^{(\alpha \ln a)x} dx$$
$$= \frac{e^{(\alpha \ln a)x}}{(\alpha \ln a)^3}\left((\alpha \ln a)^2 x^2 - 2(\alpha \ln a)x + 2\right) + c$$

$$= \frac{a^{\alpha x}}{\alpha^3 \ln^3 a}\left(\alpha^2 \ln^2 a\, x^2 - 2\alpha x \ln a + 2\right) + c$$

ដែល $c$ ជាចំនួនពិតថេរ និង $a > 0\,,\, a \neq 1$ ។

ដូចនេះ យើងបានរូបមន្ត

$$\int x^2 a^{\alpha x}\, dx = \frac{a^{\alpha x}}{\alpha^3 \ln^3 a}\left(\alpha^2 \ln^2 a\, x^2 - 2\alpha x \ln a + 2\right) + c \quad (6.4)$$

ដែល $c$ ជាចំនួនពិតថេរ និង $a > 0\,,\, a \neq 1$ ។

**ឧទាហរណ៍ទី៣** គណនា $\int x^2 e^{2x}\, dx$ , $\int (3x^2 - 5) e^{4x-3}\, dx$ និង $\int x^2 3^{4x+7}\, dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.3) និង (6.4) យើងបាន៖

$$\int x^2 e^{2x}\, dx = \frac{e^{2x}}{2^3}\left(2^2 x^2 - 2\cdot 2x + 2\right) + c$$

$$= \frac{e^{2x}}{8}\left(4x^2 - 4x + 2\right) + c$$

$$\int (3x^2 - 5) e^{4x-3}\, dx = 3\int x^2 e^{4x-3}\, dx - 5\int e^{4x-3}\, dx$$

$$= 3e^{-3}\int x^2 e^{4x}\, dx - 5e^{-3}\int e^{4x}\, dx$$

$$= 3e^{-3}\cdot \frac{e^{4x}}{4^3}\left(4^2 x^2 - 2\cdot 4x + 2\right) - 5e^{-3}\cdot \frac{1}{4} e^{4x} + c$$

$$= \frac{e^{4x-3}}{64}\left(48x^2 - 24x - 74\right) + c$$

និង $$\int x^2 3^{4x+7}\, dx = 3^7 \int x^2 3^{4x}\, dx$$

$$= 3^7 \cdot \frac{3^{4x}}{4^3 \ln^3 3}\left(4^2 \ln^2 3\, x^2 - 2\cdot 4x \ln 3 + 2\right) + c$$

$$= \frac{3^{4x+7}}{64 \ln^3 3}\left(16 \ln^2 3 \cdot x^2 - 8x \ln 3 + 2\right) + c \text{ ។}$$

## ៦.៣ ប្រភេទអាំងតេក្រាលមានរាង $\int x^n e^{\alpha x}\,dx$

អាំងតេក្រាល $\int x^n e^{\alpha x}\,dx \;(n\in\{0,1,2,...\})$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^n e^{\alpha x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងនឹងគណនាអាំងតេក្រាល $\int x^n e^{\alpha x}\,dx$ តាមការសិក្សាពីរករណីគឺ $\alpha=0$ និង $\alpha\neq 0$ ។

- ករណី $\alpha=0$ នាំឱ្យ

$$\int x^n e^{\alpha x}\,dx=\int x^n e^{0\cdot x}\,dx=\int x^n\,dx=\frac{x^{n+1}}{n+1}+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $\alpha\neq 0$ យើងតាង $\mathrm{I}_n=\int x^n e^{\alpha x}\,dx$ ។

- បើ $n=0$ នាំឱ្យ $\mathrm{I}_0=\int x^0 e^{\alpha x}\,dx=\int e^{\alpha x}\,dx=\frac{1}{\alpha}e^{\alpha x}+c$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $n\geq 1$ នោះយើងប្រើវិធីអាំងតេក្រាលដោយផ្នែកដើម្បីរកទំនាក់ទំនងរវាង $\mathrm{I}_n$ និង $\mathrm{I}_{n-1}$ ដោយ យក $u=x^n$ នាំឱ្យ $du=nx^{n-1}dx$ និង $dv=e^{\alpha x}dx$ នាំឱ្យ $v=\frac{1}{\alpha}e^{\alpha x}$ ។

នាំឱ្យ $\mathrm{I}_n=\int x^n e^{\alpha x}\,dx=\frac{x^n}{\alpha}e^{\alpha x}-\frac{n}{\alpha}\int x^{n-1}e^{\alpha x}\,dx$

$$=\frac{x^n}{\alpha}e^{\alpha x}-\frac{n}{\alpha}\mathrm{I}_{n-1}=\frac{x^n}{\alpha}e^{\alpha x}-\frac{n}{\alpha}\left(\frac{x^{n-1}}{\alpha}e^{\alpha x}-\frac{n-1}{\alpha}\mathrm{I}_{n-2}\right)$$

$$=\frac{x^n}{\alpha}e^{\alpha x}-\frac{n\,x^{n-1}}{\alpha^2}e^{\alpha x}+\frac{n(n-1)}{\alpha^2}\left(\frac{x^{n-2}}{\alpha}e^{\alpha x}-\frac{n-2}{\alpha}\mathrm{I}_{n-3}\right)$$

$$=.....$$

$$=\frac{x^n}{\alpha}e^{\alpha x}-\frac{nx^{n-1}}{\alpha^2}e^{\alpha x}+\frac{n(n-1)x^{n-2}}{\alpha^3}e^{\alpha x}-\ldots+\frac{(-1)^{n-3}n(n-1)\ldots 3\cdot x^3}{\alpha^{n-2}}e^{\alpha x}+$$

$$+\frac{(-1)^{n-2}n!\cdot x^2}{\alpha^{n-1}}e^{\alpha x}+\frac{(-1)^{n-1}n!\cdot x}{\alpha^n}e^{\alpha x}+\frac{(-1)^n n!}{\alpha^{n+1}}e^{\alpha x}+c$$

$$=e^{\alpha x}\sum_{i=0}^{n}\frac{(-1)^i n!\,x^{n-i}}{(n-i)!\,\alpha^{i+1}}+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x^n e^{\alpha x}dx=e^{\alpha x}\sum_{i=0}^{n}\frac{(-1)^i n!\,x^{n-i}}{(n-i)!\,\alpha^{i+1}}+c} \quad (6.5)$$

ដែល $c$ ជាចំនួនពិតថេរ , $n\in\{0,1,2,...\}$ និង $\alpha\neq 0$ ។

**ឧទាហរណ៍ទី៤** គណនា $\int x^3 e^{2x}dx$ និង $\int x^5 3^{4x+3}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.5) យើងបាន៖

$$\int x^3 e^{2x}dx=e^{2x}\sum_{i=0}^{3}\frac{(-1)^i 3!\,x^{3-i}}{(3-i)!\,2^{i+1}}+c$$

និង $$\int x^5 3^{4x+3}dx=3^3\int x^5 3^{4x}dx=3^3\int x^5\left(e^{\ln 3}\right)^{4x}dx$$

$$=3^3\int x^5 e^{(4\ln 3)x}dx$$

$$=3^3 e^{(4\ln 3)x}\sum_{i=0}^{5}\frac{(-1)^i 5!\,x^{5-i}}{(5-i)!\,(4\ln 3)^{i+1}}+c$$

$$=3^{4x+3}\sum_{i=0}^{5}\frac{(-1)^i 5!\,x^{5-i}}{(5-i)!\,(4\ln 3)^{i+1}}+c \text{ ។}$$

## ៦.៤ ប្រភេទអាំងតេក្រាលមានរាង $\int x^{-1}e^{\alpha x}dx$

អាំងតេក្រាល $\int x^{-1}e^{\alpha x}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេ

ក្រាល $x^{-1}e^{\alpha x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិង អនុគមន៍ស្វ័យគុណ។

យើងនឹងគណនាអាំងតេក្រាល $\int x^{-1} e^{\alpha x} dx$ តាមការសិក្សាពីរករណីគឺ $\alpha = 0$ និង $\alpha \neq 0$ ។

- ករណី $\alpha = 0$ នាំឱ្យ

$$\int x^{-1} e^{\alpha x} dx = \int x^{-1} e^{0 \cdot x} dx = \int x^{-1} dx = \int \frac{dx}{x} = \ln|x| + c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $\alpha \neq 0$ យើងគណនា $\int x^{-1} e^{\alpha x} dx = \int \frac{e^{\alpha x}}{x} dx$ ។

យើងមានស៊េរីស្វ័យគុណនៃចំនួនពិតគឺ

$$e^x = 1 + x + \frac{x^2}{2!} + ... + \frac{x^n}{n!} + ... = \sum_{k=0}^{+\infty} \frac{x^k}{k!}$$ ចំពោះ $\forall x \in \mathbb{R}$

នាំឱ្យ $\frac{e^{\alpha x}}{x} = \frac{1}{x} + \alpha + \frac{\alpha^2}{2!} x + \frac{\alpha^3}{3!} x^2 + ... + \frac{\alpha^n}{n!} x^{n-1} + ...$ ។

នាំឱ្យ $\int x^{-1} e^{\alpha x} dx = \int \frac{e^{\alpha x}}{x} dx$

$$= \int \left( \frac{1}{x} + \alpha + \frac{\alpha^2}{2!} x + \frac{\alpha^3}{3!} x^2 + ... + \frac{\alpha^n}{n!} x^{n-1} + ... \right) dx$$

$$= \ln|x| + \alpha x + \frac{\alpha^2}{2!} \cdot \frac{x^2}{2} + \frac{\alpha^3}{3!} \cdot \frac{x^3}{3} + ... + \frac{\alpha^n}{n!} \cdot \frac{x^n}{n} + ...$$

$$= \ln|x| + \sum_{n=1}^{+\infty} \frac{(\alpha x)^n}{n \cdot n!}$$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x^{-1} e^{\alpha x} dx = \int \frac{e^{\alpha x}}{x} dx = \ln|x| + \sum_{n=1}^{+\infty} \frac{(\alpha x)^n}{n \cdot n!}} \quad (6.6)$$

ចំពោះគ្រប់ $\alpha \in \mathbb{R}$ ។

**ឧទាហរណ៍ទី៥** គណនា $\int x^{-1} e^{2x} dx$ និង $\int_1^2 \frac{e^{3x}}{x} dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.6) យើងបាន៖

$$\int x^{-1}e^{2x}\,dx=\ln|x|+\sum_{n=1}^{+\infty}\frac{(2x)^n}{n\cdot n!}$$

និង
$$\int_1^2\frac{e^{3x}}{x}dx=\ln|x|+\sum_{n=1}^{+\infty}\frac{(3x)^n}{n\cdot n!}\Bigg|_1^2$$

$$=\left(\ln|2|+\sum_{n=1}^{+\infty}\frac{6^n}{n\cdot n!}\right)-\left(\ln|1|+\sum_{n=1}^{+\infty}\frac{3^n}{n\cdot n!}\right)$$

$$=\ln 2+\sum_{n=1}^{+\infty}\frac{6^n-3^n}{n\cdot n!}\approx 76.0559$$ (ប្រើម៉ាស៊ីនគិតលេខ)។

**ឧទាហរណ៍ទី៦** គណនាអាំងតេក្រាល $\int\frac{\left(3x^2+2x+1\right)e^{4x}}{x}dx$ ។

ដំណោះស្រាយ

តាមលក្ខណៈអាំងតេក្រាល រូបមន្ត(6.1) និង (6.6) យើងបាន៖

$$\int\frac{\left(3x^2+2x+1\right)e^{4x}}{x}dx=\int\left(3x+2+\frac{1}{x}\right)e^{4x}\,dx$$

$$=3\int xe^{4x}\,dx+2\int e^{4x}\,dx+\int\frac{e^{4x}}{x}dx$$

$$=3\cdot\frac{e^{4x}}{4^2}(4x-1)+2\cdot\frac{1}{4}e^{4x}+\ln|x|+\sum_{n=1}^{+\infty}\frac{(4x)^n}{n\cdot n!}$$

$$=\frac{3e^{4x}}{16}(4x-1)+\frac{1}{2}e^{4x}+\ln|x|+\sum_{n=1}^{+\infty}\frac{(4x)^n}{n\cdot n!}$$ ។

**ឧទាហរណ៍ទី៧** គណនាអាំងតេក្រាល $\int\frac{(3t-2)^3e^{5t}}{t}dt$ ។

ដំណោះស្រាយ

តាមលក្ខណៈអាំងតេក្រាល រូបមន្ត (6.3) , (6.1) និង (6.6) យើងបាន៖

$$\int\frac{(3t-2)^3e^{5t}}{t}dt=\int\frac{\left[(3t)^3+3(3t)^2(-2)+3(3t)(-2)^2+(-2)^3\right]e^{5t}}{t}dt$$

$$=\int\frac{\left(27t^3-54t^2+36t-8\right)e^{5t}}{t}dt$$

$$=\int\left(27t^2-54t+36-\frac{8}{t}\right)e^{5t}\,dt$$

$$=27\int t^2e^{5t}\,dt-54\int t\,e^{5t}\,dt+36\int e^{5t}\,dt-8\int\frac{e^{5t}}{t}\,dt$$

$$=27\cdot\frac{e^{5t}}{5^3}\left(5^2x^2-2\cdot5x+2\right)-54\cdot\frac{e^{5t}}{5^2}(5x-1)+36\cdot\frac{e^{5t}}{5}-8\left[\ln|x|+\sum_{n=1}^{+\infty}\frac{(5x)^n}{n\cdot n!}\right]$$

$$=\frac{e^{5t}}{125}\left(675x^2-270x+54\right)-\frac{e^{5t}}{125}(1350x-270)+900\cdot\frac{e^{5t}}{125}-8\ln|x|-8\sum_{n=1}^{+\infty}\frac{(5x)^n}{n\cdot n!}$$

$$=\frac{e^{5t}}{125}\left(675x^2-1620x+1224\right)-8\ln|x|-8\sum_{n=1}^{+\infty}\frac{(5x)^n}{n\cdot n!}$$ ។

## ៦.៥ ប្រភេទអាំងតេក្រាលមានរាង $\int xe^{\alpha x^2}dx$ និង $\int xa^{\alpha x^2}dx$

អាំងតេក្រាល $\int xe^{\alpha x^2}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $xe^{\alpha x^2}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងនឹងគណនាអាំងតេក្រាល $\int xe^{\alpha x^2}dx$ តាមការសិក្សាពីរករណីគឺ $\alpha=0$ និង $\alpha\neq0$ ។

- ករណី $\alpha=0$ នាំឱ្យ

$$\int xe^{\alpha x^2}dx=\int xe^{0\cdot x^2}dx=\int x\,dx=\frac{x^2}{2}+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $\alpha\neq0$ នោះយើងប្រើវិធីប្តូរអថេរ ដោយតាង $u=\alpha x^2$ នាំឱ្យ $du=2\alpha x\,dx$ សមមូល $x\,dx=\frac{du}{2\alpha}$ ។

នាំឱ្យ $\int xe^{\alpha x^2}dx=\int e^u\frac{du}{2\alpha}=\frac{1}{2\alpha}\int e^u du$

$$= \frac{1}{2\alpha} e^{u} + c = \frac{1}{2\alpha} e^{\alpha x^2} + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x e^{\alpha x^2}\, dx = \frac{1}{2\alpha} e^{\alpha x^2} + c} \quad (6.7)$$

ដែល $c$ ជាចំនួនពិតថេរ។

បន្ទាប់មក យើងនឹងគណនាអាំងតេក្រាល $\int x a^{\alpha x^2}\, dx$ , $a > 0$ , $a \neq 1$ ។

តាមរូបមន្ត (6.7) យើងទាញបាន៖

$$\int x a^{\alpha x^2}\, dx = \int x \left(e^{\ln a}\right)^{\alpha x^2} dx = \int x e^{(\alpha \ln a) x^2}\, dx$$

$$= \frac{1}{2(\alpha \ln a)} e^{(\alpha \ln a) x^2} + c = \frac{1}{2\alpha \ln a} a^{\alpha x^2} + c$$

ដែល $c$ ជាចំនួនពិតថេរ និង $a > 0$ , $a \neq 1$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x a^{\alpha x^2}\, dx = \frac{1}{2\alpha \ln a} a^{\alpha x^2} + c} \quad (6.8)$$

ដែល $c$ ជាចំនួនពិតថេរ និង $a > 0$ , $a \neq 1$ ។

ចំពោះ $\alpha < 0$ និងតាមរូបមន្ត (6.7) យើងបាន៖

$$\int_{-\infty}^{+\infty} x e^{\alpha x^2}\, dx = \frac{1}{2\alpha} e^{\alpha x^2} \Bigg|_{-\infty}^{+\infty} = \frac{1}{2\alpha e^{-\alpha x^2}} \Bigg|_{-\infty}^{+\infty} = 0 - 0 = 0$$

និង $$\int_{0}^{+\infty} x e^{\alpha x^2}\, dx = \frac{1}{2\alpha} e^{\alpha x^2} \Bigg|_{0}^{+\infty} = \frac{1}{2\alpha e^{-\alpha x^2}} \Bigg|_{0}^{+\infty} = 0 - \frac{1}{2\alpha} = -\frac{1}{2\alpha}$$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int_{-\infty}^{+\infty} x e^{\alpha x^2}\, dx = 0} \quad (6.9) \text{ និង } \boxed{\int_{0}^{+\infty} x e^{\alpha x^2}\, dx = -\frac{1}{2\alpha}} \quad (6.10)$$

ដែល $\alpha < 0$ ។

**ឧទាហរណ៍ទី៨** គណនា $\int x e^{2x^2}\,dx$ , $\int x e^{-3x^2}\,dx$ និង $\int_0^1 x 5^{3x^2+4}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.7) និង (6.8) យើងបាន៖

$$\int x e^{2x^2}\,dx = \frac{1}{2\cdot 2}e^{2x^2} + c = \frac{1}{4}e^{2x^2} + c$$

$$\int x e^{-3x^2}\,dx = \frac{1}{2(-3)}e^{-3x^2} + c = -\frac{1}{6}e^{-3x^2} + c$$

និង $$\int_0^1 x 5^{3x^2+4}\,dx = 5^4\int_0^1 x 5^{3x^2}\,dx = 5^4\cdot\frac{1}{2\cdot 3\ln 5}5^{3x^2}\Big|_0^1$$

$$= 5^4\left(\frac{1}{2\cdot 3\ln 5}5^{3\cdot 1^2} - \frac{1}{2\cdot 3\ln 5}5^{3\cdot 0^2}\right)$$

$$= \frac{5^4\left(5^3-1\right)}{6\ln 5} = \frac{77500}{6\ln 5}$$ ។

## ៦.៦ ប្រភេទអាំងតេក្រាលមានរាង $\int x^{-2}e^{-\alpha x^2}dx$

អាំងតេក្រាល $\int x^{-2}e^{-\alpha x^2}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^{-2}e^{-\alpha x^2}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងមានស៊េរីស្វ័យគុណនៃអនុគមន៍ $e^x$ គឺ

$$e^x = 1 + x + \frac{x^2}{2!} + \ldots + \frac{x^n}{n!} + \ldots = \sum_{k=0}^{+\infty}\frac{x^k}{k!}$$ ចំពោះ $\forall x \in \mathbb{R}$

នាំឱ្យ $$e^{-\alpha x^2} = \sum_{k=0}^{+\infty}\frac{\left(-\alpha x^2\right)^k}{k!} = \sum_{k=0}^{+\infty}\frac{(-1)^k\alpha^k x^{2k}}{k!}$$

និង $$x^{-2}e^{-\alpha x^2} = \frac{e^{-\alpha x^2}}{x^2} = \sum_{k=0}^{+\infty}\frac{(-1)^k\alpha^k x^{2k}}{x^2\,k!}$$

$$= \frac{1}{x^2} + \sum_{k=1}^{+\infty}\frac{(-1)^k\alpha^k x^{2k}}{x^2\,k!}$$

$$= \frac{1}{x^2} + \sum_{k=1}^{+\infty} \frac{(-1)^k \alpha^k x^{2k-2}}{k!} \text{ ។}$$

នាំឱ្យ $\int x^{-2} e^{-\alpha x^2} dx = \int \frac{e^{-\alpha x^2}}{x^2} dx = \int \left( \frac{1}{x^2} + \sum_{k=1}^{+\infty} \frac{(-1)^k \alpha^k x^{2k-2}}{k!} \right) dx$

$$= \int x^{-2} dx + \sum_{k=1}^{+\infty} \frac{(-1)^k \alpha^k}{k!} \int x^{2k-2} dx$$

$$= -\frac{1}{x} + \sum_{k=1}^{+\infty} \frac{(-1)^k \alpha^k x^{2k-1}}{k!(2k-1)} \text{ ។}$$

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int x^{-2} e^{-\alpha x^2} dx = \int \frac{e^{-\alpha x^2}}{x^2} dx = -\frac{1}{x} + \sum_{k=1}^{+\infty} \frac{(-1)^k \alpha^k x^{2k-1}}{k!(2k-1)}} \quad (6.11)$$

ចំពោះគ្រប់ $\alpha \in \mathbb{R}$ ។

**ឧទាហរណ៍ទី៩** គណនា $\int x^{-2} e^{-3x^2} dx$ និង $\int_1^2 \frac{e^{-2x^2}}{x^2} dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.11) យើងបាន៖

$$\int x^{-2} e^{-3x^2} dx = -\frac{1}{x} + \sum_{k=1}^{+\infty} \frac{(-1)^k 3^k x^{2k-1}}{k!(2k-1)}$$

និង $\int_1^2 \frac{e^{-2x^2}}{x^2} dx = -\frac{1}{x} + \sum_{k=1}^{+\infty} \frac{(-1)^k 2^k x^{2k-1}}{k!(2k-1)} \Bigg|_1^2$

$$= \left( -\frac{1}{2} + \sum_{k=1}^{+\infty} \frac{(-1)^k 2^k \cdot 2^{2k-1}}{k!(2k-1)} \right) - \left( -\frac{1}{1} + \sum_{k=1}^{+\infty} \frac{(-1)^k 2^k \cdot 1^{2k-1}}{k!(2k-1)} \right)$$

$$= \frac{1}{2} + \sum_{k=1}^{+\infty} \frac{(-1)^k \left(2^{3k-1} - 2^k\right)}{k!(2k-1)} \text{ ។}$$

## ៦.៧ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x e^{-a(x-b)^2} dx$

អាំងតេក្រាល $\int_{-\infty}^{+\infty} x e^{-a(x-b)^2} dx$ $(a > 0)$ ជាអាំងតេក្រាលមិនកំណត់ដែលមាន

អនុគមន៍អាំងតេក្រាល $xe^{-a(x-b)^2}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

ជាដំបូង យើងគណនា $I(a)=\int_0^{+\infty} e^{-ax^2}dx \ (a>0)$ ។

នាំឱ្យ $(I(a))^2=\int_0^{+\infty} e^{-ax^2}dx\int_0^{+\infty} e^{-ay^2}dy$

$$=\int_0^{+\infty}\int_0^{+\infty} e^{-ax^2}e^{-ay^2}dxdy=\int_0^{+\infty}\int_0^{+\infty} e^{-a(x^2+y^2)}dxdy \ (*)$$ ។

តាង $y=xt$ , $t>0$ នាំឱ្យ $dy=xdt$ , $t>0$ និងតាមសមីការ $(*)$ នាំឱ្យ

$$(I(a))^2=\int_0^{+\infty}\int_0^{+\infty} e^{-a(x^2+x^2t^2)}x\,dxdt=\int_0^{+\infty}\int_0^{+\infty} e^{-a(1+t^2)x^2}x\,dxdt \ (*_1)$$ ។

តាង $u=-a(1+t^2)\,x^2$ នាំឱ្យ $du=-2a(1+t^2)\,xdx\Rightarrow xdx=-\dfrac{du}{2a(1+t^2)}$ និងតាមសមីការ $(*_1)$ នាំឱ្យ

$$(I(a))^2=-\int_0^{+\infty}\int_0^{-\infty} e^u\frac{du}{2a(1+t^2)}dt=-\frac{1}{2a}\int_0^{+\infty}\int_0^{-\infty}\frac{e^u}{1+t^2}du\,dt$$

$$=-\frac{1}{2a}\int_0^{+\infty}\frac{e^u}{1+t^2}\Bigg|_0^{-\infty}dt=\frac{1}{2a}\int_0^{+\infty}\frac{dt}{1+t^2}$$

$$=\frac{1}{2a}\tan^{-1}(t)\Big|_0^{+\infty}=\frac{1}{2a}\left(\frac{\pi}{2}-0\right)=\frac{\pi}{4a}$$

នាំឱ្យ $\int_0^{+\infty} e^{-ax^2}dx=I(a)=\sqrt{\dfrac{\pi}{4a}}=\dfrac{1}{2}\sqrt{\dfrac{\pi}{a}}$

និង $\int_{-\infty}^{+\infty} e^{-ax^2}dx=2\int_0^{+\infty} e^{-ax^2}dx=\sqrt{\dfrac{\pi}{a}}$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int_0^{+\infty} e^{-ax^2}dx=\frac{1}{2}\sqrt{\frac{\pi}{a}}} \ (6.12) \text{ និង } \boxed{\int_{-\infty}^{+\infty} e^{-ax^2}dx=\sqrt{\frac{\pi}{a}}} \ (6.13)$$

ដែល $a>0$ ។

បន្ទាប់មក យើងអាចគណនាអាំងតេក្រាល $\int_{-\infty}^{+\infty} xe^{-a(x-b)^2}dx$ នេះបានដោយតាង

$t=x-b$ នាំឱ្យ $dt=dx$ និង $x=t+b$ ។

នាំឱ្យ $\int_{-\infty}^{+\infty} xe^{-a(x-b)^2}dx=\int_{-\infty}^{+\infty}(t+b)e^{-at^2}dt$

$$=\int_{-\infty}^{+\infty} te^{-at^2}dt+b\int_{-\infty}^{+\infty} e^{-at^2}dt$$

$$=0+b\sqrt{\frac{\pi}{a}}=b\sqrt{\frac{\pi}{a}}$$ (តាមរូបមន្ត (6.9) និង (6.13) )។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int_{-\infty}^{+\infty} xe^{-a(x-b)^2}dx=b\sqrt{\frac{\pi}{a}}} \quad (6.14)$$

ដែល $a>0$ ។

**ឧទាហរណ៍ទី១០** គណនា $\int_{0}^{+\infty} e^{-2x^2}dx$ , $\int_{-\infty}^{+\infty} e^{-3x^2}dx$ និង $\int_{-\infty}^{+\infty} xe^{-3(x-2)^2}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.12) , (6.13) និង (6.14) យើងបាន៖

$$\int_{0}^{+\infty} e^{-2x^2}dx=\frac{1}{2}\sqrt{\frac{\pi}{2}}$$

$$\int_{-\infty}^{+\infty} e^{-3x^2}dx=\sqrt{\frac{\pi}{3}}$$

និង $\int_{-\infty}^{+\infty} xe^{-3(x-2)^2}dx=2\sqrt{\frac{\pi}{3}}$ ។

## ៦.៨ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} xe^{-ax^2+bx}dx$

អាំងតេក្រាល $\int_{-\infty}^{+\infty} xe^{-ax^2+bx}dx$ $(a>0)$ ជាអាំងតេក្រាលមិនកំណត់ដែលមាន

អនុគមន៍អាំងតេក្រាល $xe^{-ax^2+bx}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងមាន $-ax^2+bx=-a\left(x^2-2\cdot\frac{b}{2a}\cdot x+\frac{b^2}{4a^2}-\frac{b^2}{4a^2}\right)$

$$=-a\left(x-\frac{b}{2a}\right)^2+\frac{b^2}{4a}\text{ ។}$$

នាំឱ្យ $\int_{-\infty}^{+\infty} xe^{-ax^2+bx}dx=\int_{-\infty}^{+\infty} xe^{-a\left(x-\frac{b}{2a}\right)^2+\frac{b^2}{4a}}dx$

$$=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty} xe^{-a\left(x-\frac{b}{2a}\right)^2}dx$$

$$=e^{\frac{b^2}{4a}}\cdot\frac{b}{2a}\sqrt{\frac{\pi}{a}}=\frac{\sqrt{\pi}\,b}{2a^{3/2}}e^{\frac{b^2}{4a}}$$ (តាមរូបមន្ត (6.14) )។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int_{-\infty}^{+\infty} xe^{-ax^2+bx}dx=\frac{\sqrt{\pi}\,b}{2a^{3/2}}e^{\frac{b^2}{4a}}}\quad(6.15)$$

ដែល $a>0$ ។

**ឧទាហរណ៍ទី១១** គណនា $\int_{-\infty}^{+\infty} xe^{-x^2+2x}dx$ និង $\int_{-\infty}^{+\infty} xe^{-4x^2+3x+2}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.15) យើងបាន៖

$$\int_{-\infty}^{+\infty} xe^{-x^2+2x}dx=\frac{\sqrt{\pi}\cdot 2}{2\cdot 1^{3/2}}e^{\frac{2^2}{4\cdot 1}}=e\sqrt{\pi}$$

និង $\int_{-\infty}^{+\infty} xe^{-4x^2+3x+2}dx=e^2\int_{-\infty}^{+\infty} xe^{-4x^2+3x}dx$

$$=e^2\cdot\frac{\sqrt{\pi}\cdot 3}{2\cdot 4^{3/2}}e^{\frac{3^2}{4\cdot 4}}=\frac{3\sqrt{\pi}}{16}e^{\frac{41}{16}}\text{ ។}$$

## ៦.៩ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x^2e^{-ax^2}dx$

អាំងតេក្រាល $\int_{-\infty}^{+\infty} x^2e^{-ax^2}dx$ $(a>0)$ ជាអាំងតេក្រាលមិនកំណត់ដែលមាន

អនុគមន៍អាំងតេក្រាល $x^2 e^{-ax^2}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងមានរូបមន្ត (6.13) គឺ $\int_{-\infty}^{+\infty} e^{-ax^2}dx = \sqrt{\frac{\pi}{a}}$ ដែល $a>0$ ។

យើងធ្វើដេរីវេលើអង្គទាំងពីរនៃសមីការ (6.13) ធៀបនឹងអថេរ $a$ ផ្តល់ឱ្យ

$$\frac{d}{da}\int_{-\infty}^{+\infty} e^{-ax^2}dx = \frac{d}{da}\sqrt{\frac{\pi}{a}} = \frac{d}{da}\left(\sqrt{\pi}\,a^{-1/2}\right)$$

សមមូល $$-\int_{-\infty}^{+\infty} x^2 e^{-ax^2}dx = \sqrt{\pi}\left(-\frac{1}{2}\right)a^{-\frac{1}{2}-1} = -\frac{1}{2a}\sqrt{\frac{\pi}{a}}$$

ដូចនេះ $$\boxed{\int_{-\infty}^{+\infty} x^2 e^{-ax^2}dx = \frac{1}{2a}\sqrt{\frac{\pi}{a}} = \frac{1}{2}\sqrt{\frac{\pi}{a^3}}} \quad (6.16)$$

ដែល $a>0$ ។

**ឧទាហរណ៍ទី១២** គណនា $\int_{-\infty}^{+\infty} x^2 e^{-x^2}dx$ និង $\int_{-\infty}^{+\infty} (3x-2)^2 e^{-2x^2}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.16) នាំឱ្យ

$$\int_{-\infty}^{+\infty} x^2 e^{-x^2}dx = \frac{1}{2}\sqrt{\frac{\pi}{1^3}} = \frac{1}{2}\sqrt{\pi}$$

និងតាមរូបមន្ត (6.16) , (6.9) និង (6.13) នាំឱ្យ

$$\begin{aligned}\int_{-\infty}^{+\infty} (3x-2)^2 e^{-2x^2}dx &= \int_{-\infty}^{+\infty}\left((3x)^2 - 2(3x)(2) + 2^2\right)e^{-2x^2}dx \\ &= \int_{-\infty}^{+\infty}\left(9x^2 - 12x + 4\right)e^{-2x^2}dx \\ &= 9\int_{-\infty}^{+\infty} x^2 e^{-2x^2}dx - 12\int_{-\infty}^{+\infty} xe^{-2x^2}dx + 4\int_{-\infty}^{+\infty} e^{-2x^2}dx \\ &= 9\cdot\frac{1}{2}\sqrt{\frac{\pi}{2^3}} - 12\times 0 + 4\sqrt{\frac{\pi}{2}} \\ &= \left(\frac{9}{4}+4\right)\sqrt{\frac{\pi}{2}} = \frac{25}{4}\sqrt{\frac{\pi}{2}}\end{aligned}$$ ។

## ៦.១០ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x^2 e^{-ax^2-bx}\,dx$

អាំងតេក្រាល $\int_{-\infty}^{+\infty} x^2 e^{-ax^2-bx}\,dx$ $(a>0)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^2 e^{-ax^2-bx}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងមាន $-ax^2-bx=-a\left(x^2+\frac{bx}{a}\right)=-a\left(x^2+2\cdot\frac{b}{2a}\cdot x+\frac{b^2}{4a^2}-\frac{b^2}{4a^2}\right)$

$$=-a\left(x+\frac{b}{2a}\right)^2+\frac{b^2}{4a}\text{ ។}$$

នាំឱ្យ $\int_{-\infty}^{+\infty} x^2 e^{-ax^2-bx}\,dx=\int_{-\infty}^{+\infty} x^2 e^{-a\left(x+\frac{b}{2a}\right)^2+\frac{b^2}{4a}}\,dx$

$$=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty} x^2 e^{-a\left(x+\frac{b}{2a}\right)^2}\,dx\quad(*)\text{ ។}$$

តាង $t=x+\frac{b}{2a}$ នាំឱ្យ $dt=dx$ និង $x=t-\frac{b}{2a}$ ហើយ

$x^2=\left(t-\frac{b}{2a}\right)^2=t^2-2\cdot t\cdot\frac{b}{2a}+\left(\frac{b}{2a}\right)^2=t^2-\frac{b}{a}t+\frac{b^2}{4a^2}$ ។

បើ $x\to+\infty$ នោះ $t\to+\infty$ ហើយបើ $x\to-\infty$ នោះ $t\to-\infty$ ។

តាមសមីការ $(*)$ ហើយរូបមន្ត $(6.16)$ , $(6.9)$ និង $(6.13)$ នាំឱ្យ

$$\int_{-\infty}^{+\infty} x^2 e^{-ax^2-bx}\,dx=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty} x^2 e^{-a\left(x+\frac{b}{2a}\right)^2}\,dx$$

$$=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty}\left(t^2-\frac{b}{a}t+\frac{b^2}{4a^2}\right)e^{-at^2}\,dt$$

$$=e^{\frac{b^2}{4a}}\left[\int_{-\infty}^{+\infty} t^2 e^{-at^2}\,dt-\frac{b}{a}\int_{-\infty}^{+\infty} t e^{-at^2}\,dt+\frac{b^2}{4a^2}\int_{-\infty}^{+\infty} e^{-at^2}\,dt\right]$$

$$=e^{\frac{b^2}{4a}}\left(\frac{\sqrt{\pi}}{2a^{3/2}}+\frac{b^2\sqrt{\pi}}{4a^{5/2}}\right)$$

$$=\frac{\sqrt{\pi}\left(2a+b^2\right)}{4a^{5/2}}e^{\frac{b^2}{4a}}$$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int_{-\infty}^{+\infty} x^2 e^{-ax^2-bx}\,dx=\frac{\sqrt{\pi}\left(2a+b^2\right)}{4a^{5/2}}e^{\frac{b^2}{4a}}} \quad (6.17)$$

ដែល $a>0$ ។

**ឧទាហរណ៍ទី១៣** គណនា $\int_{-\infty}^{+\infty} x^2 e^{-x^2-x}\,dx$ និង $\int_{-\infty}^{+\infty} x^2 e^{-2x^2-3x}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.17) នាំឱ្យ

$$\int_{-\infty}^{+\infty} x^2 e^{-x^2-x}\,dx=\frac{\sqrt{\pi}\left(2\cdot 1+1^2\right)}{4\cdot 1^{5/2}}e^{\frac{1^2}{4\cdot 1}}=\frac{3\sqrt{\pi}}{4}e^{\frac{1}{4}}$$

និង $$\int_{-\infty}^{+\infty} x^2 e^{-2x^2-3x}\,dx=\frac{\sqrt{\pi}\left(2\cdot 2+3^2\right)}{4\cdot 2^{5/2}}e^{\frac{3^2}{4\cdot 2}}=\frac{13\sqrt{\pi}}{16\sqrt{2}}e^{\frac{9}{8}}$$ ។

**ឧទាហរណ៍ទី១៤** គណនា $\int_{-\infty}^{+\infty} (2x+5)^2 e^{-4x^2-3x}\,dx$ ។

ដំណោះស្រាយ

យើងមាន $(2x+5)^2=(2x)^2+2(2x)(5)+5^2=4x^2+20x+25$ ។

នាំឱ្យ

$$\int_{-\infty}^{+\infty} (2x+5)^2 e^{-4x^2-3x}\,dx=\int_{-\infty}^{+\infty}\left(4x^2+20x+25\right)e^{-4x^2-3x}\,dx$$

តាមរូបមន្ត (6.17) នាំឱ្យ

$$\int_{-\infty}^{+\infty} x^2 e^{-4x^2-3x}\,dx=\frac{\sqrt{\pi}\left(2\cdot 4+3^2\right)}{4\cdot 4^{5/2}}e^{\frac{3^2}{4\cdot 4}}=\frac{17\sqrt{\pi}}{4\cdot 32}e^{\frac{9}{16}} \quad (*_2)$$ ។

តាមរូបមន្ត (6.15) នាំឱ្យ

$$\int_{-\infty}^{+\infty} x e^{-4x^2-3x}\,dx=\frac{\sqrt{\pi}(-3)}{2\cdot 4^{3/2}}e^{\frac{(-3)^2}{4\cdot 4}}=-\frac{3\sqrt{\pi}}{16}e^{\frac{9}{16}} \quad (*_3)$$ ។

ឥឡូវនេះ យើងគណនាអាំងតេក្រាល $\int_{-\infty}^{+\infty} e^{-4x^2-3x}\,dx$ ។

យើងមាន $-4x^2-3x=-4\left(x+\frac{3}{8}\right)^2+\frac{9}{16}$ ។

តាង $t=x+\frac{3}{8}$ នាំឱ្យ $dt=dx$ ។

បើ $x\to+\infty$ នោះ $t\to+\infty$ ហើយបើ $x\to-\infty$ នោះ $t\to-\infty$ ។

នាំឱ្យ $\int_{-\infty}^{+\infty} e^{-4x^2-3x}\,dx=\int_{-\infty}^{+\infty} e^{-4\left(x+\frac{3}{8}\right)^2+\frac{9}{16}}\,dx$

$$=e^{\frac{9}{16}}\int_{-\infty}^{+\infty} e^{-4\left(x+\frac{3}{8}\right)^2}\,dx$$

$$=e^{\frac{9}{16}}\int_{-\infty}^{+\infty} e^{-4t^2}\,dx$$

$$=e^{\frac{9}{16}}\sqrt{\frac{\pi}{4}}=\frac{\sqrt{\pi}}{2}e^{\frac{9}{16}}\ (*_4)$$ ។

តាម $(*_1)$, $(*_2)$, $(*_3)$ និង $(*_4)$ នាំឱ្យ

$$\int_{-\infty}^{+\infty}(2x+5)^2e^{-4x^2-3x}\,dx=4\cdot\frac{17\sqrt{\pi}}{4\cdot 32}e^{\frac{9}{16}}+20\cdot\left(-\frac{3\sqrt{\pi}}{16}e^{\frac{9}{16}}\right)+25\cdot\frac{\sqrt{\pi}}{2}e^{\frac{9}{16}}$$

$$=\frac{297\sqrt{\pi}}{32}e^{\frac{9}{16}}$$ ។

## ៦.១១ ប្រភេទអាំងតេក្រាលមានរាង $\int_{-\infty}^{+\infty} x^3e^{-ax^2+bx}\,dx$

អាំងតេក្រាល $\int_{-\infty}^{+\infty} x^3e^{-ax^2+bx}\,dx$ $(a>0)$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^3e^{-ax^2+bx}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណ។

យើងមាន $-ax^2+bx=-a\left(x^2-2\cdot\frac{b}{2a}\cdot x+\frac{b^2}{4a^2}-\frac{b^2}{4a^2}\right)$

$$=-a\left(x-\frac{b}{2a}\right)^2+\frac{b^2}{4a} \text{ ។}$$

នាំឱ្យ $\int_{-\infty}^{+\infty} x^3 e^{-ax^2+bx}dx=\int_{-\infty}^{+\infty} x^3 e^{-a\left(x-\frac{b}{2a}\right)^2+\frac{b^2}{4a}}dx$

$$=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty} x^3 e^{-a\left(x-\frac{b}{2a}\right)^2}dx \quad (*) \text{ ។}$$

តាង $t=x-\frac{b}{2a}$ នាំឱ្យ $dt=dx$ និង $x=t+\frac{b}{2a}$ ហើយ

$$x^3=\left(t+\frac{b}{2a}\right)^3=t^3+3\cdot t^2\cdot\frac{b}{2a}+3t\left(\frac{b}{2a}\right)^2+\left(\frac{b}{2a}\right)^3$$

$$=t^3+\frac{3b}{2a}t^2+\frac{3b^2}{4a^2}t+\frac{b^3}{8a^3} \text{ ។}$$

បើ $x\to+\infty$ នោះ $t\to+\infty$ ហើយបើ $x\to-\infty$ នោះ $t\to-\infty$ ។

តាមសមីការ $(*)$ នាំឱ្យ

$$\int_{-\infty}^{+\infty} x^3 e^{-ax^2+bx}dx=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty} x^3 e^{-a\left(x-\frac{b}{2a}\right)^2}dx$$

$$=e^{\frac{b^2}{4a}}\int_{-\infty}^{+\infty}\left(t^3+\frac{3b}{2a}t^2+\frac{3b^2}{4a^2}t+\frac{b^3}{8a^3}\right)e^{-at^2}dt$$

$$=e^{\frac{b^2}{4a}}\left[\int_{-\infty}^{+\infty}t^3e^{-at^2}dt+\frac{3b}{2a}\int_{-\infty}^{+\infty}t^2e^{-at^2}dt+\frac{3b^2}{4a^2}\int_{-\infty}^{+\infty}te^{-at^2}dt+\frac{b^3}{8a^3}\int_{-\infty}^{+\infty}e^{-at^2}dt\right]$$

$$=e^{\frac{b^2}{4a}}\left[0+\frac{3b}{2a}\cdot\frac{1}{2}\sqrt{\frac{\pi}{a^3}}+\frac{3b^2}{4a^2}\cdot 0+\frac{b^3}{8a^3}\cdot\sqrt{\frac{\pi}{a}}\right]$$

$$=\sqrt{\pi}\,e^{\frac{b^2}{4a}}\left[\frac{3b}{4a^{5/2}}+\frac{b^3}{8a^{7/2}}\right]=\frac{\sqrt{\pi}\left(6ab+b^3\right)}{8a^{7/2}}e^{\frac{b^2}{4a}} \text{ ។}$$

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int_{-\infty}^{+\infty} x^3 e^{-ax^2+bx}dx=\frac{\sqrt{\pi}\left(6ab+b^3\right)}{8a^{7/2}}e^{\frac{b^2}{4a}}} \quad (6.18)$$

ដែល $a>0$ ។

**ឧទាហរណ៍ទី១៥** គណនា $\int_{-\infty}^{+\infty} x^3 e^{-x^2+x}\,dx$ និង $\int_{-\infty}^{+\infty} x^3 e^{-9x^2-2x}\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (6.18) នាំឱ្យ

$$\int_{-\infty}^{+\infty} x^3 e^{-x^2+x}\,dx = \frac{\sqrt{\pi}\left(6(1)(1)+1^3\right)}{8\cdot 1^{7/2}} e^{\frac{1^2}{4(1)}} = \frac{7\sqrt{\pi}}{8} e^{\frac{1}{4}}$$

និង $$\int_{-\infty}^{+\infty} x^3 e^{-9x^2-2x}\,dx = \frac{\sqrt{\pi}\left(6(9)(-2)+(-2)^3\right)}{8\cdot 9^{7/2}} e^{\frac{(-2)^2}{4(9)}}$$

$$= \frac{-116\sqrt{\pi}}{17496} e^{\frac{1}{9}} = \frac{-29\sqrt{\pi}}{4374} e^{\frac{1}{9}} \text{ ។}$$

ជាសរុប ជំពូកទី៦នេះបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណដែលមានទម្រង់ពិសេសមួយចំនួនដូចជា $\int x e^{\alpha x}\,dx$, $\int x a^{\alpha x}\,dx$, $\int x^2 e^{\alpha x}\,dx$, $\int x^2 a^{\alpha x}\,dx$, $\int x^n e^{\alpha x}\,dx$, $\int x^{-1} e^{\alpha x}\,dx$, $\int x e^{\alpha x^2}\,dx$, $\int x a^{\alpha x^2}\,dx$, $\int_{-\infty}^{+\infty} x e^{\alpha x^2}\,dx$, $\int_{0}^{+\infty} x e^{\alpha x^2}\,dx$, $\int x^{-2} e^{-\alpha x^2}\,dx$, $\int_{-\infty}^{+\infty} x e^{-a(x-b)^2}\,dx$, $\int_{-\infty}^{+\infty} x e^{-ax^2+bx}\,dx$, $\int_{-\infty}^{+\infty} x^2 e^{-ax^2}\,dx$, $\int_{-\infty}^{+\infty} x^2 e^{-ax^2-bx}\,dx$ និង $\int_{-\infty}^{+\infty} x^3 e^{-ax^2+bx}\,dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណនៅក្នុងជំពូកទី៧បន្តទៀត។

# ជំពូកទី៧

# ប្រភេទអាំងតេក្រាលមាន អនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណ

( Types of Integrals Involving Logarithmic and Power Functions )

នៅក្នុងជំពូកទី៧នេះ យើងនឹងសិក្សាតែអំពីប្រភេទអាំងតេក្រាលមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែលមានលក្ខណៈពិសេសមួយចំនួននិងដំណោះស្រាយរបស់វាដូចតទៅ៖

## ៧.១ ប្រភេទអាំងតេក្រាលមានរាង $\int x^m \ln x\,dx$

អាំងតេក្រាល $\int x^m \ln x\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^m \ln x$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណ។

យើងនឹងគណនាអាំងតេក្រាល $\int x^m \ln x\,dx$ តាមវិធីអាំងតេក្រាលដោយផ្នែក

ដោយយក $u = \ln x$ , $x > 0$ នាំឱ្យ $du = \dfrac{dx}{x}$ និង $dv = x^m\,dx$ នាំឱ្យ

$v = \dfrac{x^{m+1}}{m+1}$ , $m \neq -1$ ។

នាំឱ្យ $\int x^m \ln x\,dx = \int u\,dv = uv - \int v\,du$

$$= \frac{x^{m+1}}{m+1}\ln x - \frac{1}{m+1}\int x^{m+1}\cdot\frac{dx}{x}$$

$$= \frac{x^{m+1}}{m+1}\ln x - \frac{1}{m+1}\int x^m\,dx$$

$$= \frac{x^{m+1}}{m+1}\ln x - \frac{1}{m+1}\cdot\frac{x^{m+1}}{m+1} + c$$

$$= x^{m+1}\left[\frac{\ln x}{m+1} - \frac{1}{(m+1)^2}\right] + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\int x^m \ln x\,dx = x^{m+1}\left[\frac{\ln x}{m+1} - \frac{1}{(m+1)^2}\right] + c \quad (7.1)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១** គណនា $\int \ln x\,dx$ , $\int x\ln x\,dx$ និង $\int x^2 \ln x\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.1) យើងបាន៖

$$\int \ln x\,dx = \int x^0 \ln x\,dx = x^{0+1}\left[\frac{\ln x}{0+1} - \frac{1}{(0+1)^2}\right] + c = x(\ln x - 1) + c$$

$$\int x\ln x\,dx = x^{1+1}\left[\frac{\ln x}{1+1} - \frac{1}{(1+1)^2}\right] + c = x^2\left(\frac{\ln x}{2} - \frac{1}{4}\right) + c$$

និង $$\int x^2 \ln x\,dx = x^{2+1}\left[\frac{\ln x}{2+1} - \frac{1}{(2+1)^2}\right] + c = x^3\left(\frac{\ln x}{3} - \frac{1}{9}\right) + c$$ ។

**ឧទាហរណ៍ទី២** គណនា $\int_1^e x^3 \ln x\,dx$ និង $\int_1^{+\infty} x^{-3} \ln x\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.1) យើងបាន៖

$$\int_1^e x^3 \ln x\,dx = x^{3+1}\left[\frac{\ln x}{3+1} - \frac{1}{(3+1)^2}\right]\Bigg|_1^e = x^4\left[\frac{\ln x}{4} - \frac{1}{16}\right]\Bigg|_1^e$$

$$= e^4\left[\frac{\ln e}{4} - \frac{1}{16}\right] - 1^4\left[\frac{\ln 1}{4} - \frac{1}{16}\right] = \frac{3e^4 + 1}{16} \approx 10.2996$$

និង $\int_{1}^{+\infty} x^{-3}\ln x\,dx = \lim_{N\to+\infty}\int_{1}^{N} x^{-3}\ln x\,dx$

$$= \lim_{N\to+\infty} x^{-3+1}\left[\frac{\ln x}{-3+1}-\frac{1}{(-3+1)^2}\right]\Bigg|_1^N$$

$$= \lim_{N\to+\infty}\left[\frac{-\ln x}{2x^2}-\frac{1}{4x^2}\right]\Bigg|_1^N$$

$$= \lim_{N\to+\infty}\left[\frac{-\ln N}{2N^2}-\frac{1}{4N^2}+\frac{\ln 1}{2}+\frac{1}{4}\right]=\frac{1}{4} \text{ ។}$$

## ៧.២ ប្រភេទអាំងតេក្រាលមានរាង $\int \frac{(\ln(ax))^n}{x}dx$

អាំងតេក្រាល $\int \frac{(\ln(ax))^n}{x}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{(\ln(ax))^n}{x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែល $a\neq 0$ ។ អនុគមន៍នេះកំណត់បានចំពោះ $x>0$ បើ $a>0$ និងវាកំណត់បានចំពោះ $x<0$ បើ $a<0$។

យើងនឹងគណនាអាំងតេក្រាល $\int \frac{(\ln(ax))^n}{x}dx$ ដែល $a\neq 0$ ។ យើងតាង $u=ax$

នាំឱ្យ $x=\frac{u}{a}$ និង $dx=\frac{du}{a}$ ។

នាំឱ្យ $\int \frac{(\ln(ax))^n}{x}dx = \int \frac{(\ln(u))^n}{(u/a)}\cdot\frac{du}{a}$

$$= \int \frac{(\ln(u))^n}{u}du = \int (\ln(u))^n d(\ln(u)) \quad (*) \text{ ។}$$

- បើ $n=-1$ នោះពីសមីការ $(*)$ នាំឱ្យ

$$\int \frac{(\ln(ax))^n}{x}dx = \int (\ln u)^{-1}d(\ln u) = \int \frac{d(\ln u)}{\ln u}$$

$$= \ln|\ln u| + c = \ln|\ln(ax)| + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\int \frac{\left(\ln(ax)\right)^{-1}}{x}dx = \int \frac{dx}{x\ln(ax)} = \ln\left|\ln(ax)\right| + c \quad (7.2)$$

ដែល $c$ ជាចំនួនពិតថេរ និង $a \neq 0$ ។

- បើ $n \neq -1$ នោះពីសមីការ $(*)$ នាំឱ្យ

$$\int \frac{\left(\ln(ax)\right)^{n}}{x}dx = \int \left(\ln(u)\right)^{n} d\left(\ln(u)\right)$$

$$= \frac{\left(\ln(u)\right)^{n+1}}{n+1} + c = \frac{\left(\ln(ax)\right)^{n+1}}{n+1} + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\int \frac{\left(\ln(ax)\right)^{n}}{x}dx = \frac{\left(\ln(ax)\right)^{n+1}}{n+1} + c \quad (7.3)$$

ដែល $c$ ជាចំនួនពិតថេរ និង $a \neq 0\,, n \neq -1$ ។

**ឧទាហរណ៍ទី៣** គណនា $\int \frac{dx}{x\ln x}$ និង $\int \frac{(\ln x)^2}{x}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.2) និង (7.3) យើងបាន៖

$$\int \frac{dx}{x\ln x} = \ln\left|\ln x\right| + c$$

និង $$\int \frac{(\ln x)^2}{x}dx = \frac{(\ln x)^3}{3} + c$$ ។

**ឧទាហរណ៍ទី៤** គណនា $\int_e^{3e} \frac{dx}{x\ln(2x)}$ និង $\int_1^{e} \frac{(\ln 3 + \ln x)^5}{x}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.2) និង (7.3) យើងបាន៖

$$\int_e^{3e} \frac{dx}{x\ln(2x)} = \ln\left|\ln(2x)\right|\Big|_e^{3e} = \ln\left|\ln(6e)\right| - \ln\left|\ln(2e)\right|$$

$$=\ln\left(\frac{\ln 6e}{\ln 2e}\right)\approx 0.5000$$

និង $$\int_1^e \frac{(\ln 3+\ln x)^5}{x}dx=\int_1^e\frac{(\ln 3x)^5}{x}dx=\frac{(\ln(3x))^6}{6}\Bigg|_1^e$$

$$=\frac{(\ln(3e))^6}{6}-\frac{(\ln(3))^6}{6}$$

$$=\frac{(\ln 3e)^6-(\ln 3)^6}{6}\approx 13.9447$$ ។

## ៧.៣ ប្រភេទអាំងតេក្រាលមានរាង $\int\frac{\ln(ax)^n}{x}dx$

អាំងតេក្រាល $\int\frac{\ln(ax)^n}{x}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{\ln(ax)^n}{x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែល $a\neq 0$ ។ អនុគមន៍នេះកំណត់បានចំពោះ $x>0$ បើ $a>0$ និងវាកំណត់បានចំពោះ $x<0$ បើ $a<0$ ។

យើងនឹងគណនាអាំងតេក្រាល $\int\frac{\ln(ax)^n}{x}dx$ ដែល $a\neq 0$ ។

- បើ $n=0$ នាំឱ្យ

$$\int\frac{\ln(ax)^n}{x}dx=\int\frac{\ln(ax)^0}{x}dx=\int\frac{\ln 1}{x}dx=\int 0\,dx=c$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $n\neq 0$ និង យើងតាង $t=\ln(ax)$ នាំឱ្យ $ax=e^t$ , $x=\frac{1}{a}e^t$ និង $dx=\frac{1}{a}e^t\,dt$ ។

នាំឱ្យ $$\int\frac{\ln(ax)^n}{x}dx=n\int\frac{\ln(ax)}{x}dx$$

$$=n\int\frac{t}{(e^t/a)}\cdot\frac{e^t\,dt}{a}$$

$$= n\int t\,dt = n\cdot\frac{t^2}{2}+c$$

$$= \frac{n\left(\ln(ax)\right)^2}{2}+c = \frac{\left(\ln(ax)^n\right)^2}{2n}+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\int\frac{\ln(ax)^n}{x}dx = \frac{n\left(\ln(ax)\right)^2}{2}+c = \frac{\left(\ln(ax)^n\right)^2}{2n}+c \qquad (7.4)$$

ដែល $c$ ជាចំនួនពិតថេរ និង $a\neq 0$ ។

**ឧទាហរណ៍ទី៥** គណនា $\int\frac{\ln x}{x}dx$ និង $\int\frac{\ln x^3}{x}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.4) យើងបាន៖

$$\int\frac{\ln x}{x}dx = \frac{(\ln x)^2}{2}+c$$

និង $$\int\frac{\ln x^3}{x}dx = \frac{3(\ln x)^2}{2}+c \text{ ។}$$

**ឧទាហរណ៍ទី៦** គណនា $\int_1^e\frac{\ln x^7}{x}dx$ និង $\int_1^e\frac{\ln 625+\ln x^4}{x}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត(7.4) យើងបាន៖

$$\int_1^e\frac{\ln x^7}{x}dx = \frac{7(\ln x)^2}{2}\Bigg|_1^e = \frac{7(\ln e)^2}{2}-\frac{7(\ln 1)^2}{2} = \frac{7}{2}$$

និង $$\int_1^e\frac{\ln 625+\ln x^4}{x}dx = \int_1^e\frac{\ln 5^4+\ln x^4}{x}dx = \int_1^e\frac{\ln(5x)^4}{x}dx$$

$$= \frac{4\left(\ln(5x)\right)^2}{2}\Bigg|_1^e = 2\left(\ln(5e)\right)^2-2\left(\ln 5\right)^2 \approx 8.4377\text{។}$$

## ៧.៤ ប្រភេទអាំងតេក្រាលមានរាង $\int \frac{\ln(ax)}{x^m}dx$

អាំងតេក្រាល $\int \frac{\ln(ax)}{x^m}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{\ln(ax)}{x^m}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែល $a \neq 0$។ អនុគមន៍នេះកំណត់បានចំពោះ $x>0$ បើ $a>0$ និងវាកំណត់បានចំពោះ $x<0$ បើ $a<0$ ។

យើងនឹងគណនាអាំងតេក្រាល $\int \frac{\ln(ax)}{x^m}dx$ ដែល $a \neq 0$ ។

យើងតាង $t=\ln(ax)$ នាំឱ្យ $ax=e^t$ , $x=\frac{1}{a}e^t$ និង $dx=\frac{1}{a}e^t\,dt$ ។

នាំឱ្យ $\int \frac{\ln(ax)}{x^m}dx = \int \frac{t}{\left(e^t/a\right)^m}\cdot\frac{e^t}{a}dt = a^{m-1}\int t\,e^{(1-m)t}\,dt \quad (*)$ ។

- បើ $m=1$ នោះតាមសមីការ $(*)$ នាំឱ្យ

$$\int \frac{\ln(ax)}{x^m}dx = \int \frac{\ln(ax)}{x}dx = \int t\,dt$$

$$= \frac{t^2}{2}+c = \frac{\left(\ln(ax)\right)^2}{2}+c$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $m \neq 1$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក ដោយយក $u=t$ នាំឱ្យ $du=dt$ និង $dv=e^{(1-m)t}\,dt$ នាំឱ្យ $v=-\frac{e^{-(m-1)t}}{m-1}$ , $m\neq 1$ ។

នោះតាមសមីការ $(*)$ នាំឱ្យ

$$\int \frac{\ln(ax)}{x^m}dx = a^{m-1}\int t\,e^{(1-m)t}\,dt$$

$$= a^{m-1}\int u\,dv = a^{m-1}\left(uv - \int v\,du\right)$$

$$= a^{m-1}\left(-\frac{t\,e^{-(m-1)t}}{m-1}+\frac{1}{m-1}\int e^{-(m-1)t}\,dt\right)$$

$$=-\frac{a^{m-1}te^{-(m-1)t}}{m-1}+\frac{a^{m-1}}{m-1}\left(-\frac{e^{-(m-1)t}}{m-1}\right)$$

$$=-\frac{a^{m-1}\ln(ax)(ax)^{-(m-1)}}{m-1}-\frac{a^{m-1}}{(m-1)^2}(ax)^{-(m-1)}+c$$

$$=-\frac{\ln(ax)}{(m-1)x^{m-1}}-\frac{1}{(m-1)^2x^{m-1}}+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int\frac{\ln(ax)}{x^m}dx=-\frac{\ln(ax)}{(m-1)x^{m-1}}-\frac{1}{(m-1)^2x^{m-1}}+c} \quad (7.5)$$

ដែល $c$ ជាចំនួនពិតថេរ, $m\neq1$ និង $a\neq0$ ។

**ឧទាហរណ៍ទី៧** គណនា $\int\frac{\ln x}{x^2}dx$ និង $\int\frac{\ln(2x)}{x^3}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.5) យើងបាន៖

$$\int\frac{\ln x}{x^2}dx=-\frac{\ln x}{(2-1)x^{2-1}}-\frac{1}{(2-1)^2x^{2-1}}+c$$

$$=-\frac{\ln x}{x}-\frac{1}{x}+c$$

និង $$\int\frac{\ln(2x)}{x^3}dx=-\frac{\ln(2x)}{(3-1)x^{3-1}}-\frac{1}{(3-1)^2x^{3-1}}+c$$

$$=-\frac{\ln(2x)}{2x^2}-\frac{1}{4x^2}+c \text{ ។}$$

**ឧទាហរណ៍ទី៨** គណនា $\int_1^e\frac{\ln(5x)}{x^5}dx$ និង $\int_1^{+\infty}\frac{\ln(7x)}{x^7}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.5) យើងបាន៖

$$\int_1^e \frac{\ln(5x)}{x^5}dx = -\frac{\ln(5x)}{(5-1)x^{5-1}} - \frac{1}{(5-1)^2 x^{5-1}}\Bigg|_1^e$$

$$= -\frac{\ln(5x)}{4x^4} - \frac{1}{16x^4}\Bigg|_1^e$$

$$= \left(-\frac{\ln(5e)}{4e^4} - \frac{1}{16e^4}\right) - \left(-\frac{\ln(5)}{4} - \frac{1}{16}\right)$$

$$= -\frac{\ln(5e)}{4e^4} - \frac{1}{16e^4} + \frac{\ln(5)}{4} + \frac{1}{16} \approx 0.4517$$

និង $$\int_1^{+\infty} \frac{\ln(7x)}{x^7}dx = \lim_{N\to+\infty}\int_1^N \frac{\ln(7x)}{x^7}dx$$

$$= \lim_{N\to+\infty} -\frac{\ln(7x)}{(7-1)x^{7-1}} - \frac{1}{(7-1)^2 x^{7-1}}\Bigg|_1^N$$

$$= \lim_{N\to+\infty} -\frac{\ln(7x)}{6x^6} - \frac{1}{36x^6}\Bigg|_1^N$$

$$= 0 + \frac{\ln(7)}{6} + \frac{1}{36} = \frac{\ln(7)}{6} + \frac{1}{36} \text{ ។}$$

## ៧.៥ ប្រភេទអាំងតេក្រាលមានរាង $\int \frac{dx}{x\left[\ln(ax)\right]^n}$

អាំងតេក្រាល $\int \frac{dx}{x\left[\ln(ax)\right]^n}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{x\left[\ln(ax)\right]^n}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែល $a \neq 0$ ។ អនុគមន៍នេះកំណត់បានចំពោះ $x > 0$ បើ $a > 0$ និងវាកំណត់បានចំពោះ $x < 0$ បើ $a < 0$ ។

យើងនឹងគណនាអាំងតេក្រាល $\int \frac{dx}{x\left[\ln(ax)\right]^n}$ ដែល $a \neq 0$ ។

យើងតាង $t = \ln(ax)$ នាំឱ្យ $ax = e^t$ , $x = \frac{1}{a}e^t$ និង $dx = \frac{1}{a}e^t\,dt$ ។

នាំឱ្យ $\int \frac{dx}{x\left[\ln(ax)\right]^n} = \int \frac{1}{\left(e^t/a\right)t^n}\cdot\frac{e^t}{a}dt = \int t^{-n}\,dt \quad (*)$ ។

- បើ $n=1$ នោះតាមសមីការ $(*)$ នាំឱ្យ

$$\int \frac{dx}{x\left[\ln(ax)\right]^n} = \int t^{-1}\,dt = \int \frac{dt}{t}$$

$$= \ln|t| + c = \ln\left|\ln(ax)\right| + c$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $n\neq 1$ នោះតាមសមីការ $(*)$ នាំឱ្យ

$$\int \frac{dx}{x\left[\ln(ax)\right]^n} = \int t^{-n}\,dt = \frac{t^{-n+1}}{-n+1} + c$$

$$= -\frac{1}{(n-1)t^{n-1}} + c = -\frac{1}{(n-1)\left[\ln(ax)\right]^{n-1}} + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int \frac{dx}{x\left[\ln(ax)\right]^n} = -\frac{1}{(n-1)\left[\ln(ax)\right]^{n-1}} + c} \quad (7.6)$$

ដែល $c$ ជាចំនួនពិតថេរ, $n\neq 1$ និង $a\neq 0$ ។

**ឧទាហរណ៍ទី៩** គណនា $\int \frac{dx}{x(\ln x)^2}$ និង $\int \frac{dx}{x(\ln 2x)^3}$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.6) យើងបាន៖

$$\int \frac{dx}{x(\ln x)^2} = -\frac{1}{(2-1)(\ln x)^{2-1}} + c = -\frac{1}{\ln x} + c$$

និង $$\int \frac{dx}{x(\ln 2x)^3} = -\frac{1}{(3-1)\left[\ln(2x)\right]^{3-1}} + c$$

$$= -\frac{1}{2\left[\ln(2x)\right]^2} + c \text{ ។}$$

**ឧទាហរណ៍ទី១០** គណនា $\int_e^{2e}\frac{dx}{x(\ln 3x)^4}$ និង $\int_1^{+\infty}\frac{dx}{x(\ln ex)^9}$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.6) យើងបាន៖

$$\int_e^{2e}\frac{dx}{x(\ln 3x)^4}=-\frac{1}{(4-1)\left[\ln(3x)\right]^{4-1}}\Bigg|_e^{2e}=-\frac{1}{3\left[\ln(3x)\right]^3}\Bigg|_e^{2e}$$

និង
$$\int_1^{+\infty}\frac{dx}{x(\ln ex)^9}=\lim_{N\to+\infty}\int_1^N\frac{dx}{x(\ln ex)^9}$$

$$=\lim_{N\to+\infty}-\frac{1}{(9-1)\left[\ln(ex)\right]^{9-1}}\Bigg|_1^N$$

$$=\lim_{N\to+\infty}-\frac{1}{8\left[\ln(ex)\right]^8}\Bigg|_1^N$$

$$=\lim_{N\to+\infty}-\frac{1}{8\left[\ln(eN)\right]^8}+\frac{1}{8\left[\ln(e)\right]^8}=0+\frac{1}{8}=\frac{1}{8}$$ ។

## ៧.៦ ប្រភេទអាំងតេក្រាលមានរាង $\int\frac{dx}{x^m\ln x}$

អាំងតេក្រាល $\int\frac{dx}{x^m\ln x}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{x^m\ln x}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណ។ អនុគមន៍នេះកំណត់បានចំពោះ $x>0$ ។

យើងនឹងគណនាអាំងតេក្រាល $\int\frac{dx}{x^m\ln x}$ ដែល $m\in\mathbb{N}=\{1,2,3,...\}$ ។

យើងតាង $t=\ln x$ នាំឱ្យ $x=e^t$ និង $dx=e^t\,dt$ ។

នាំឱ្យ $\int\frac{dx}{x^m\ln x}=\int\frac{1}{\left(e^t\right)^m t}\cdot e^t dt=\int\frac{e^{(1-m)t}}{t}dt \quad (*)$ ។

- បើ $m=1$ នោះតាមសមីការ $(*)$ នាំឱ្យ

$$\int \frac{dx}{x^m \ln x} = \int \frac{e^{(1-1)t}}{t} dt = \int \frac{dt}{t}$$

$$= \ln|t| + c = \ln|\ln x| + c$$

ដែល $c$ ជាចំនួនពិតថេរ។

- បើ $m \geq 2$ និងយើងមាន

$$e^x = 1 + x + \frac{x^2}{2!} + ... + \frac{x^n}{n!} + ... , \forall x \in \mathbb{R}$$ ។

នាំឱ្យ $$\frac{e^{(1-m)t}}{t} = \frac{1}{t}\left(1 + (1-m)t + \frac{\left[(1-m)t\right]^2}{2!} + ... + \frac{\left[(1-m)t\right]^n}{n!} + ...\right)$$

នោះតាមសមីការ $(*)$ និង $(*_1)$ នាំឱ្យ

$$\int \frac{dx}{x^m \ln x} = \int \frac{e^{(1-m)t}}{t} dt = \int [\frac{1}{t} + (1-m) + \frac{(1-m)^2}{2!} t + ... + \frac{(1-m)^n}{n!} t^{n-1} + ...] dt$$

$$= \ln|t| + (1-m)t + \frac{(1-m)^2}{2!} \cdot \frac{t^2}{2} + ... + \frac{(1-m)^n}{n!} \cdot \frac{t^n}{n} + ...$$

$$= \ln|t| + \sum_{k=1}^{+\infty} \frac{(1-m)^k}{k!} \cdot \frac{t^k}{k}$$

$$= \ln|\ln x| + \sum_{k=1}^{+\infty} \frac{(-1)^k (m-1)^k}{k \cdot k!} (\ln x)^k$$ ។

ដូចនេះ យើងបានរូបមន្ត

$$\boxed{\int \frac{dx}{x^m \ln x} = \ln|\ln x| + \sum_{k=1}^{+\infty} \frac{(-1)^k (m-1)^k}{k \cdot k!} (\ln x)^k} \quad (7.7)$$

ដែល $m \in \mathbb{N}$ ។

**ឧទាហរណ៍ទី១១** គណនា $\int \frac{dx}{x^2 \ln x}$ និង $\int \frac{dx}{x^5 \ln x}$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.7) យើងបាន៖

$$\int \frac{dx}{x^2 \ln x} = \ln|\ln x| + \sum_{k=1}^{+\infty} \frac{(-1)^k}{k \cdot k!} (\ln x)^k$$

និង $$\int \frac{dx}{x^5 \ln x} = \ln|\ln x| + \sum_{k=1}^{+\infty} \frac{(-1)^k 4^k}{k \cdot k!} (\ln x)^k$$ ។

**ឧទាហរណ៍ទី១២** គណនា $\int \frac{dx}{x^3 \ln(3x)}$ ។

ដំណោះស្រាយ

តាង $t = 3x$ នាំឱ្យ $x = \frac{t}{3}$ និង $dx = \frac{dt}{3}$ ។

នាំឱ្យ $$\int \frac{dx}{x^3 \ln(3x)} = \int \frac{dt/3}{(t/3)^3 \ln t}$$

$$= \frac{3^3}{3} \int \frac{dt}{t^3 \ln t} = 9 \int \frac{dt}{t^3 \ln t}$$

$$= 9 \left[\ln|\ln t| + \sum_{k=1}^{+\infty} \frac{(-1)^k 2^k}{k \cdot k!} (\ln t)^k\right]$$ ( តាមរូបមន្ត (7.7) )

$$= 9 \ln|\ln(3x)| + 9 \sum_{k=1}^{+\infty} \frac{(-1)^k 2^k}{k \cdot k!} (\ln(3x))^k$$ ។

## ៧.៧ ប្រភេទអាំងតេក្រាលមានរាង $\int x^m (\ln x)^n dx$

អាំងតេក្រាល $\int x^m (\ln x)^n dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $x^m (\ln x)^n$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណ។ អនុគមន៍នេះកំណត់បានចំពោះ $x > 0$ ។

យើងនឹងគណនាអាំងតេក្រាល $\int x^m (\ln x)^n dx$ ដែល $n \in \{0,1,2,3,...\}$ ។

- ករណី $m = -1$ នាំឱ្យ

$$\int x^m (\ln x)^n dx = \int x^{-1} (\ln x)^n dx = \int (\ln x)^n \frac{dx}{x}$$

$$=\int(\ln x)^n d(\ln x)=\frac{(\ln x)^{n+1}}{n+1}+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $m\neq -1$ និង $n=0$ នាំឱ្យ

$$\int x^m(\ln x)^n dx=\int x^m(\ln x)^0 dx$$

$$=\int x^m dx=\frac{x^{m+1}}{m+1}+c$$

ដែល $c$ ជាចំនួនពិតថេរ និង $m\neq -1$ ។

- ករណី $m\neq -1$ និង $n\in\{1,2,3,...\}=\mathbb{N}$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក

ដោយយក $u=(\ln x)^n$ , $x>0$ នាំឱ្យ $du=\frac{n(\ln x)^{n-1}}{x}dx$ និង $dv=x^m dx$ នាំឱ្យ $v=\frac{x^{m+1}}{m+1}$ , $m\neq -1$ ។

នាំឱ្យ $\int x^m(\ln x)^n dx=\int u\,dv=uv-\int v\,du$

$$=\frac{x^{m+1}(\ln x)^n}{m+1}-\frac{n}{m+1}\int x^{m+1}\frac{(\ln x)^{n-1}}{x}dx$$

$$=\frac{x^{m+1}(\ln x)^n}{m+1}-\frac{n}{m+1}\int x^m(\ln x)^{n-1}dx \text{ ។}$$

ដូចនេះ ចំពោះ $m\neq -1$ និង $n\in\{1,2,3,...\}$ យើងបានរូបមន្តខាងក្រោម៖

$$\boxed{\int x^m(\ln x)^n dx=\frac{x^{m+1}(\ln x)^n}{m+1}-\frac{n}{m+1}\int x^m(\ln x)^{n-1}dx} \quad (7.8) \text{ ។}$$

**ឧទាហរណ៍ទី១៣** គណនា $\int x\ln x\,dx$ និង $\int x^{-5}\ln x\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.8) យើងបាន៖

$$\int x\ln x\,dx=\frac{x^{1+1}(\ln x)^1}{1+1}-\frac{1}{1+1}\int x^1(\ln x)^{1-1}dx$$

$$=\frac{x^2\ln x}{2}-\frac{1}{2}\int x^1\,dx$$

$$=\frac{x^2\ln x}{2}-\frac{1}{2}\cdot\frac{x^2}{2}+c$$

$$=\frac{x^2\ln x}{2}-\frac{x^2}{4}+c$$

និង $\int x^{-5}\ln x\,dx=\frac{x^{-5+1}(\ln x)^1}{-5+1}-\frac{1}{-5+1}\int x^{-5}(\ln x)^{1-1}\,dx$

$$=\frac{x^{-4}\ln x}{-4}+\frac{1}{4}\int x^{-5}\,dx$$

$$=\frac{x^{-4}\ln x}{-4}+\frac{1}{4}\cdot\frac{x^{-5+1}}{-5+1}+c$$

$$=-\frac{\ln x}{4x^4}-\frac{1}{16x^4}+c$$ ។

**ឧទាហរណ៍ទី១៤** គណនា $\int_1^e x(\ln x)^2\,dx$ និង $\int_1^e x^2(\ln x)^3\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.8) យើងបាន៖

$$\int_1^e x(\ln x)^2\,dx=\left.\frac{x^{1+1}(\ln x)^2}{1+1}\right|_1^e-\frac{2}{1+1}\int_1^e x^1(\ln x)^{2-1}\,dx$$

$$=\frac{e^2(\ln e)^2}{2}-\frac{1^2(\ln 1)^2}{2}-\int_1^e x^1(\ln x)^1\,dx$$

$$=\frac{e^2}{2}-\left.\frac{x^{1+1}(\ln x)^1}{1+1}\right|_1^e+\frac{1}{1+1}\int_1^e x^1(\ln x)^{1-1}\,dx$$

$$=\frac{e^2}{2}-\frac{e^2(\ln e)^1}{2}+\frac{1^2(\ln 1)^1}{2}+\frac{1}{2}\int_1^e x^1\,dx$$

$$=0+\frac{1}{2}\cdot\left.\frac{x^2}{2}\right|_1^e=\frac{e^2}{4}-\frac{1^2}{4}=\frac{e^2-1}{4}\approx 1.5972$$

និង $\int_1^e x^2(\ln x)^3\,dx = \left.\frac{x^{2+1}(\ln x)^3}{2+1}\right|_1^e - \frac{3}{2+1}\int_1^e x^2(\ln x)^{3-1}\,dx$

$$= \frac{e^3}{3} - \left.\frac{x^{2+1}(\ln x)^2}{2+1}\right|_1^e + \frac{2}{2+1}\int_1^e x^2(\ln x)^{2-1}\,dx$$

$$= \frac{e^3}{3} - \frac{e^3(\ln e)^2}{3} + \frac{1^3(\ln 1)^2}{3} + \frac{2}{3}\int_1^e x^2 \ln x\,dx$$

$$= 0 + \frac{2}{3}\int_1^e x^2 \ln x\,dx$$

$$= \frac{2}{3}\cdot\left.\frac{x^{2+1}(\ln x)^1}{2+1}\right|_1^e - \frac{2}{3}\cdot\frac{1}{2+1}\int_1^e x^2(\ln x)^{1-1}\,dx$$

$$= \frac{2}{3}\cdot\frac{e^3(\ln e)^1}{3} - \frac{2}{3}\cdot\frac{1^3(\ln 1)^1}{3} - \frac{2}{9}\int_1^e x^2\,dx$$

$$= \frac{4e^3+2}{27} \approx 3.0497 \text{ ។}$$

**ឧទាហរណ៍ទី១៥** គណនា $\int_1^{+\infty} x^{-6}(\ln x)^3\,dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.8) យើងបាន៖

$$\int_1^{+\infty} x^{-6}(\ln x)^3\,dx = \lim_{N\to+\infty}\int_1^N x^{-6}(\ln x)^3\,dx$$

$$= 0 + \frac{3}{5}\lim_{N\to+\infty}\int_1^N x^{-6}(\ln x)^2\,dx$$

$$= \frac{3}{5}\lim_{N\to+\infty}\frac{N^{-5}(\ln N)^2}{-5} - \frac{1^{-5}(\ln 1)^2}{-5} + \frac{6}{25}\lim_{N\to+\infty}\int_1^N x^{-6}(\ln x)^1\,dx$$

$$= 0 + \frac{6}{25}\lim_{N\to+\infty}\int_1^N x^{-6}(\ln x)^1\,dx$$

$$=\frac{6}{25}\lim_{N\to+\infty}\frac{x^{-6+1}(\ln x)^{1}}{-6+1}\Bigg|_{1}^{N}-\frac{6}{25}\lim_{N\to+\infty}\frac{1}{-6+1}\int_{1}^{N}x^{-6}(\ln x)^{1-1}dx$$

$$=\frac{6}{25}\lim_{N\to+\infty}\frac{N^{-5}\ln N}{-5}-\frac{1^{-5}\ln 1}{-5}+\frac{6}{125}\lim_{N\to+\infty}\int_{1}^{N}x^{-6}dx$$

$$=\frac{6}{25}\cdot 0+\frac{6}{125}\lim_{N\to+\infty}\frac{x^{-5}}{-5}\Bigg|_{1}^{N}$$

$$=\frac{6}{125}\lim_{N\to+\infty}\frac{N^{-5}}{-5}-\frac{1^{-5}}{-5}=\frac{6}{125}\left(0+\frac{1}{5}\right)=\frac{6}{625}$$ ។

## ៧.៨ ប្រភេទអាំងតេក្រាលមានរាង $\int\frac{x^m}{(\ln x)^n}dx$

អាំងតេក្រាល $\int\frac{x^m}{(\ln x)^n}dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{x^m}{(\ln x)^n}$ ជាអនុគមន៍ចម្រុះដែលក្នុងនោះមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណ។ អនុគមន៍នេះកំណត់បានចំពោះ $x>0$ ។

យើងនឹងគណនាអាំងតេក្រាល $\int\frac{x^m}{(\ln x)^n}dx$ ដែល $n\in\{0,1,2,3,...\}$ ។

- ករណី $n=0$ និង $m=-1$ នាំឱ្យ

$$\int\frac{x^m}{(\ln x)^n}dx=\int\frac{x^{-1}}{(\ln x)^0}dx$$

$$=\int x^{-1}dx=\int\frac{dx}{x}=\ln|x|+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $n=0$ និង $m\neq-1$ នាំឱ្យ

$$\int\frac{x^m}{(\ln x)^n}dx=\int\frac{x^m}{(\ln x)^0}dx$$

$$=\int x^m dx=\frac{x^{m+1}}{m+1}+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $n=1$ និង $m=-1$ នាំឱ្យ

$$\int \frac{x^m}{(\ln x)^n}dx=\int \frac{x^{-1}}{\ln x}dx=\int \frac{d(\ln x)}{\ln x}=\ln\left|\ln x\right|+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $n=1$ និង $m\neq -1$ នាំឱ្យ

$$\int \frac{x^m}{(\ln x)^n}dx=\int \frac{x^m}{\ln x}dx$$

(ករណីនេះ យើងខ្ញុំមិនអាចគណនាវាបាន ហេតុនេះយើងខ្ញុំនឹងស្រាវជ្រាវវាបន្ត)។

- ករណី $n\in\{2,3,4,...\}$ យើងប្រើវិធីអាំងតេក្រាលដោយផ្នែក ដោយយក

$u=x^{m+1}$ នាំឱ្យ $du=(m+1)x^m\,dx$ និង $dv=\dfrac{dx}{x(\ln x)^n}$ នាំឱ្យ $v=\dfrac{(\ln x)^{-n+1}}{-n+1}$

$=-\dfrac{1}{(n-1)(\ln x)^{n-1}}$ ។

នាំឱ្យ $\displaystyle\int \frac{x^m}{(\ln x)^n}dx=\int u\,dv=uv-\int v\,du$

$$=-\frac{x^{m+1}}{(n-1)(\ln x)^{n-1}}+\frac{(m+1)}{n-1}\int \frac{x^m}{(\ln x)^{n-1}}dx \text{ ។}$$

ដូចនេះ ចំពោះ $n\in\{2,3,4,...\}$ យើងបានរូបមន្តខាងក្រោម៖

$$\boxed{\int \frac{x^m}{(\ln x)^n}dx=-\frac{x^{m+1}}{(n-1)(\ln x)^{n-1}}+\frac{(m+1)}{n-1}\int \frac{x^m}{(\ln x)^{n-1}}dx} \quad (7.9) \text{ ។}$$

**ឧទាហរណ៍ទី១៦** គណនា $\displaystyle\int \frac{x}{(\ln x)^2}dx$ និង $\displaystyle\int \frac{x}{(\ln x)^3}dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (7.9) យើងបាន៖

$$\int \frac{x}{(\ln x)^2}dx=-\frac{x^{1+1}}{(2-1)(\ln x)^{2-1}}+\frac{(1+1)}{2-1}\int \frac{x^1}{(\ln x)^{2-1}}dx$$

$$=-\frac{x^2}{\ln x}+2\int\frac{x}{\ln x}dx \quad (*)$$ ។

បន្ទាប់មក យើងតាង $u=\ln x$ នាំឱ្យ $x=e^u$ និង $dx=e^u\,du$ ។

ពីសមីការ $(*)$ នាំឱ្យ

$$\int\frac{x}{\ln x}dx=\int\frac{e^u}{u}\cdot e^u\,du=\int\frac{e^{2u}}{u}du$$

$$=\int\frac{1}{u}\sum_{k=0}^{+\infty}\frac{(2u)^k}{k!}du=\int[\frac{1}{u}+\sum_{k=1}^{+\infty}\frac{2^k u^{k-1}}{k!}]du$$

$$=\ln|u|+\sum_{k=1}^{+\infty}\frac{2^k u^k}{k\cdot k!}$$

$$=\ln|\ln x|+\sum_{k=1}^{+\infty}\frac{2^k(\ln x)^k}{k\cdot k!}$$

និង $$\int\frac{x}{(\ln x)^2}dx=-\frac{x^2}{\ln x}+2\int\frac{x}{\ln x}dx$$

$$=-\frac{x^2}{\ln x}+2[\ln|\ln x|+\sum_{k=1}^{+\infty}\frac{2^k(\ln x)^k}{k\cdot k!}]$$

$$=-\frac{x^2}{\ln x}+2\ln|\ln x|+\sum_{k=1}^{+\infty}\frac{2^{k+1}(\ln x)^k}{k\cdot k!} \quad (*_1)$$ ។

តាមរូបមន្ត (7.9) យើងបាន៖

$$\int\frac{x}{(\ln x)^3}dx=-\frac{x^{1+1}}{(3-1)(\ln x)^{3-1}}+\frac{(1+1)}{3-1}\int\frac{x}{(\ln x)^{3-1}}dx$$

$$=-\frac{x^2}{2(\ln x)^2}+\int\frac{x}{(\ln x)^2}dx$$

$$=-\frac{x^2}{2(\ln x)^2}-\frac{x^2}{\ln x}+2\ln|\ln x|+\sum_{k=1}^{+\infty}\frac{2^{k+1}(\ln x)^k}{k\cdot k!}$$ ( តាម $(*_1)$ )។

ជាសរុប ជំពូកទី៧នេះបានផ្តល់នូវវិធីសាស្រ្តគណនាអាំងតេក្រាលមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែលមានទម្រង់ពិសេសមួយចំនួនដូចជា $\int x^m \ln x\,dx$ , $\int \frac{(\ln(ax))^n}{x}dx$ , $\int \frac{\ln(ax)^n}{x}dx$ , $\int \frac{\ln(ax)}{x^m}dx$ , $\int \frac{dx}{x[\ln(ax)]^n}$ , $\int \frac{dx}{x^m \ln x}$ , $\int x^m (\ln x)^n\,dx$ និង $\int \frac{x^m}{(\ln x)^n}dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។ បន្ទាប់មក យើងនឹងបង្ហាញនិងសិក្សាអំពីប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីកនៅក្នុងជំពូកទី៨បន្តទៀត។

# ជំពូកទី៨
# ប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីក
# ( Types of Integrals Involving Hyperbolic Functions )

នៅក្នុងជំពូកទី៨នេះ យើងនឹងសិក្សាអំពីអនុគមន៍អ៊ីពែបូលីកនិងប្រភេទអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីកដែលមានលក្ខណៈពិសេសមួយចំនួននិងដំណោះស្រាយរបស់វាដូចតទៅ៖

## ៨.១ អនុគមន៍អ៊ីពែបូលីក

### ៨.១.១ និយមន័យ

អនុគមន៍អ៊ីពែបូលីកមានដូចជា $\cosh$ , $\sinh$ , $\tanh$ , $\coth$ , $\operatorname{sec}h$ និង $\operatorname{cos}ech$ ហើយកំណត់ដោយ៖

$$\cosh x = \frac{e^x + e^{-x}}{2} \qquad \sinh x = \frac{e^x - e^{-x}}{2}$$

$$\tanh x = \frac{\sinh x}{\cosh x} \qquad \coth x = \frac{\cosh x}{\sinh x}$$

$$\operatorname{sec}h\, x = \frac{1}{\cosh x} \quad \text{និង} \quad \operatorname{cos}ech\, x = \frac{1}{\sinh x}$$ ។

រូបខាងក្រោម ជាក្រាហ្វនៃអនុគមន៍អ៊ីពែបូលីក $y = \cosh x$ , $y = \sinh x$ និង $y = \tanh x$ ។




រូបទី១




រូបទី២




**រូបទី៣**

## ៨.១.២ លក្ខណៈ

យើងមានរូបមន្តសំខាន់នៃអនុគមន៍អ៊ីពែបូលីកមួយចំនួនខាងក្រោម៖

១. $\cosh^2 x - \sinh^2 x = 1$

២. $1 - \tanh^2 x = \sec h^2 x$

៣. $1 - \coth^2 x = -\ \cos ech^2 x$

៤. $\frac{d}{dx}(\sinh x) = (\sinh x)'_x = \cosh x$

៥. $\frac{d}{dx}(\cosh x) = (\cosh x)'_x = \sinh x$

៦. $\frac{d}{dx}(\tanh x) = (\tanh x)'_x = \text{sech}^2 x$

៧. $\frac{d}{dx}(\coth x) = (\coth x)'_x = -\ co\text{sech}^2 x$

ឥឡូវនេះ យើងនឹងស្រាយបញ្ជាក់រូបមន្តទី១ ទី២ និង ទី៤ដូចតទៅ៖

១. បង្ហាញថា $\cosh^2 x - \sinh^2 x = 1$ ។

យើងមាន $\cosh^2 x - \sinh^2 x = \left(\frac{e^x + e^{-x}}{2}\right)^2 - \left(\frac{e^x - e^{-x}}{2}\right)^2$

$$= \frac{1}{4}\left(e^x + e^{-x}\right)^2 - \frac{1}{4}\left(e^x - e^{-x}\right)^2$$

$$= \frac{1}{4}\left(e^{2x} + 2e^x e^{-x} + e^{-2x}\right) - \frac{1}{4}\left(e^{2x} - 2e^x e^{-x} + e^{-2x}\right)$$

$$=\frac{1}{4}e^{2x}+\frac{1}{2}+\frac{1}{4}e^{-2x}-\frac{1}{4}e^{2x}+\frac{1}{2}-\frac{1}{4}e^{-2x}=1 \text{ (ពិត)។}$$

៣. បង្ហាញថា $1-\tanh^2 x=\sec h^2 x$ ។

យើងមាន $1-\tanh^2 x=1-\left(\frac{\sinh x}{\cosh x}\right)^2=1-\left(\frac{\left(e^x-e^{-x}\right)/2}{\left(e^x+e^{-x}\right)/2}\right)^2$

$$=\frac{\left(e^x+e^{-x}\right)^2-\left(e^x-e^{-x}\right)^2}{\left(e^x+e^{-x}\right)^2}$$

$$=\frac{e^{2x}+2e^x e^{-x}+e^{-2x}-e^{2x}+2e^x e^{-x}-e^{-2x}}{\left(e^x+e^{-x}\right)^2}$$

$$=\frac{4}{\left(e^x+e^{-x}\right)^2}=\frac{1}{\left(\frac{e^x+e^{-x}}{2}\right)^2}$$

$$=\frac{1}{\cosh^2 x}=\sec h^2 x \text{ (ពិត) ។}$$

៤. បង្ហាញថា $\frac{d}{dx}\left(\sinh x\right)=\cosh x$ ។

យើងមាន $\frac{d}{dx}\left(\sinh x\right)=\frac{d}{dx}\left(\frac{e^x-e^{-x}}{2}\right)=\frac{e^x+e^{-x}}{2}=\cosh x$ (ពិត) ។

**ឧទាហរណ៍ទី១** គេឱ្យ $\sinh x_0=4$ ។ ចូររកតម្លៃនៃអនុគមន៍អ៊ីពែបូលីកប្រាំផ្សេងទៀតត្រង់ចំណុច $x_0$ ។

## ដំណោះស្រាយ

យើងមាន $\sinh x_0=4$ និងរូបមន្ត $\cosh^2 x_0-\sinh^2 x_0=1$ នាំឱ្យ

$\cosh^2 x_0=1+\sinh^2 x_0=1+4^2=17$ ។

ដោយ $\cosh x_0=\frac{e^{x_0}+e^{-x_0}}{2}>0$, $\forall x_0\in\mathbb{R}$ នាំឱ្យ $\cosh x_0=\sqrt{17}$ ។

ពីរូបមន្តនៃអនុគមន៍អ៊ីពែបូលីក យើងទាញបាន៖

$$\tanh x_0=\frac{\sinh x_0}{\cosh x_0}=\frac{4}{\sqrt{17}}$$

$$\coth x_0 = \frac{\cosh x_0}{\sinh x_0} = \frac{\sqrt{17}}{4}$$

$$\sec h\, x_0 = \frac{1}{\cosh x_0} = \frac{1}{\sqrt{17}}$$

និង $\cos ech\, x_0 = \dfrac{1}{\sinh x_0} = \dfrac{1}{4}$ ។

**ឧទាហរណ៍ទី២** ដោះស្រាយសមីការ $5\cosh x + 3\sinh x = 4$ ។

ដំណោះស្រាយ

យើងមាន $5\cosh x + 3\sinh x = 4$

សមមូល $5\left(\dfrac{e^x + e^{-x}}{2}\right) + 3\left(\dfrac{e^x - e^{-x}}{2}\right) = 4$

សមមូល $5e^x + 5e^{-x} + 3e^x - 3e^{-x} = 8$

សមមូល $8e^x + 2e^{-x} = 8$

សមមូល $4e^x + e^{-x} = 4$

សមមូល $4\left(e^x\right)^2 + 1 = 4e^x$

សមមូល $4\left(e^x\right)^2 - 4e^x + 1 = 0$

សមមូល $\left(2e^x - 1\right)^2 = 0$ សមមូល $2e^x - 1 = 0$

សមមូល $e^x = \dfrac{1}{2}$ សមមូល $x = \ln\dfrac{1}{2} = -\ln 2$ ជាឬសសមីការ។

**ឧទាហរណ៍ទី៣** គណនាដេរីវេ $\dfrac{d}{dx}\left(\sinh(a\,x)\right)$ និង $\dfrac{d}{dx}\left(\cosh(a\,x)\right)$ ដែល $a$ ជាចំនួនពិតថេរ។

ដំណោះស្រាយ

យើងមាន $\dfrac{d}{dx}\left(\sinh(a\,x)\right) = \dfrac{d}{dx}\left(\dfrac{e^{a\,x} - e^{-a\,x}}{2}\right) = \dfrac{a\,e^{a\,x} + a\,e^{-a\,x}}{2}$

$$= a\left(\frac{e^{a\,x} + e^{-a\,x}}{2}\right) = a\,\cosh(a\,x)$$

និង $\dfrac{d}{dx}\left(\cosh(a\,x)\right) = \dfrac{d}{dx}\left(\dfrac{e^{a\,x} + e^{-a\,x}}{2}\right) = \dfrac{a\,e^{a\,x} - a\,e^{-a\,x}}{2}$

$$= a\left(\frac{e^{ax}-e^{-ax}}{2}\right) = a\sinh(ax)$$ ។

ដូចនេះ $\frac{d}{dx}(\sinh(ax)) = a\cosh(ax)$ និង $\frac{d}{dx}(\cosh(ax)) = a\sinh(ax)$ ។

## ៨.២ ប្រភេទអាំងតេក្រាលមានរាង $\int \sinh(ax)dx$

អាំងតេក្រាល $\int \sinh(ax)dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sinh(ax)$ ជាអនុគមន៍ស៊ីនុសអ៊ីពែបូលីកកំណត់លើ $\mathbb{R}$ ។

យើងនឹងគណនាអាំងតេក្រាល $\int \sinh(ax)dx$ តាមករណីពីរគឺ $a=0$ និង $a\neq 0$ ។

- ករណី $a=0$ នាំឱ្យ

$$\int \sinh(ax)dx = \int \sinh(0)dx = \int \frac{e^0-e^{-0}}{2}dx = \int 0\,dx = c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a\neq 0$ នាំឱ្យ

$$\int \sinh(ax)dx = \int \frac{e^{ax}-e^{-ax}}{2}dx$$

$$= \frac{1}{2}\left[\frac{1}{a}e^{ax} - \frac{1}{(-a)}e^{-ax}\right] + c$$

$$= \frac{1}{a}\cdot\frac{e^{ax}+e^{-ax}}{2} + c = \frac{1}{a}\cosh(ax) + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int \sinh(ax)dx = \frac{1}{a}\cosh(ax) + c} \quad (8.1)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៤** គណនា $\int \sinh(2x)dx$ និង $\int_0^1 \sinh\left(\frac{3}{2}x\right)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.1) យើងបាន៖

$$\int \sinh(2x)\,dx = \frac{1}{2}\cosh(2x) + c$$

និង $$\int_0^1 \sinh\left(\frac{3}{2}x\right)dx = \frac{1}{(3/2)}\cosh\left(\frac{3}{2}x\right)\Big|_0^1$$

$$= \frac{2}{3}\cosh\left(\frac{3}{2}\right) - \frac{2}{3}\cosh(0)$$

$$= \frac{2}{3}\cosh\left(\frac{3}{2}\right) - \frac{2}{3} \approx 0.9016$$ ។

**ឧទាហរណ៍ទី៥** គណនា $\int \sinh(2x+3)\,dx$ និង $\int_0^2 x\sinh\left(\frac{3}{2}x^2+4\right)dx$ ។

ដំណោះស្រាយ

តាង $u = 2x+3$ នាំឱ្យ $du = 2dx$ និង $dx = \frac{du}{2}$ ។

នាំឱ្យ $$\int \sinh(2x+3)\,dx = \int \sinh u \frac{du}{2} = \frac{1}{2}\int \sinh u\,du$$

$$= \frac{1}{2}\cosh u + c = \frac{1}{2}\cosh(2x+3) + c$$ ( តាមរូបមន្ត (8.1) )។

ចំពោះ $\int_0^2 x\sinh\left(\frac{3}{2}x^2+4\right)dx$ យើងតាង $u = \frac{3}{2}x^2+4$ នាំឱ្យ $du = 3x\,dx$ និង $x\,dx = \frac{du}{3}$ ។

ពេល $x=0$ នោះ $u = \frac{3}{2}x^2+4 = 4$ និងពេល $x=2$ នោះ $u = \frac{3}{2}x^2+4 = 10$ ។

នាំឱ្យ $$\int_0^2 x\sinh\left(\frac{3}{2}x^2+4\right)dx = \int_4^{10} \sinh u \frac{du}{3} = \frac{1}{3}\int_4^{10} \sinh u\,du$$

$$= \frac{1}{3}\cosh u\Big|_4^{10}$$ ( តាមរូបមន្ត (8.1) )

$$= \frac{1}{3}(\cosh 10 - \cosh 4) \approx 3661.9748$$ ។

## ៨.៣ ប្រភេទអាំងតេក្រាលមានរាង $\int \cosh(ax)dx$

អាំងតេក្រាល $\int \cosh(ax)dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\cosh(ax)$ ជាអនុគមន៍កូស៊ីនុសអ៊ីពែបូលីកកំណត់លើ $\mathbb{R}$។

យើងនឹងគណនាអាំងតេក្រាល $\int \cosh(ax)dx$ តាមករណីពីរគឺ $a=0$ និង $a\neq 0$។

- ករណី $a=0$ នាំឱ្យ

$$\int \cosh(ax)dx=\int \cosh(0)dx=\int \frac{e^{0}+e^{-0}}{2}dx=\int 1dx=x+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a\neq 0$ នាំឱ្យ

$$\int \cosh(ax)dx=\int \frac{e^{ax}+e^{-ax}}{2}dx$$

$$=\frac{1}{2}\left[\frac{1}{a}e^{ax}+\frac{1}{(-a)}e^{-ax}\right]+c$$

$$=\frac{1}{a}\cdot\frac{e^{ax}-e^{-ax}}{2}+c=\frac{1}{a}\sinh(ax)+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int \cosh(ax)dx=\frac{1}{a}\sinh(ax)+c} \quad (8.2)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី៦** គណនា $\int \cosh(3x)dx$ និង $\int_0^1 \cosh\left(\frac{4}{5}x\right)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.2) យើងបាន៖

$$\int \cosh(3x)dx=\frac{1}{3}\sinh(3x)+c$$

និង $\int_0^1 \cosh\left(\frac{4}{5}x\right)dx = \frac{1}{(4/5)}\sinh\left(\frac{4}{5}x\right)\Big|_0^1$

$$= \frac{5}{4}\sinh\left(\frac{4}{5}\right) - \frac{5}{4}\sinh(0)$$

$$= \frac{5}{4}\sinh\left(\frac{4}{5}\right) \approx 1.1101 \text{ ។}$$

**ឧទាហរណ៍ទី៧** គណនា $\int \cosh(3v-2)dv$ និង $\int_0^1 t^2\cosh\left(-t^3+3\right)dt$ ។

ដំណោះស្រាយ

តាង $u = 3v-2$ នាំឱ្យ $du = 3dv$ និង $dv = \frac{du}{3}$ ។

នាំឱ្យ $\int \cosh(3v-2)dv = \int \cosh u\frac{du}{3} = \frac{1}{3}\int \cosh u\, du$

$= \frac{1}{3}\sinh u + c = \frac{1}{3}\sinh(3v-2) + c$ (តាមរូបមន្ត (8.2) )។

ចំពោះ $\int_0^1 t^2\cosh\left(-t^3+3\right)dt$ យើងតាង $u = -t^3+3$ នាំឱ្យ $du = -3t^2\,dt$ និង $t^2\,dt = -\frac{du}{3}$ ។ ពេល $t=0$ នោះ $u=-t^3+3=3$ និងពេល $t=1$ នោះ $u=-t^3+3=2$ ។

នាំឱ្យ $\int_0^1 t^2\cosh\left(-t^3+3\right)dt = \int_3^2 \cosh u\left(-\frac{du}{3}\right) = -\frac{1}{3}\int_3^2 \cosh u\, du$

$= -\frac{1}{3}\sinh u\Big|_3^2$ (តាមរូបមន្ត (8.2) )

$$= -\frac{1}{3}(\sinh 2 - \sinh 3) \approx 2.1303 \text{ ។}$$

## ៨.៤ ប្រភេទអាំងតេក្រាលមានរាង $\int \sinh^2(ax)dx$

អាំងតេក្រាល $\int \sinh^2(ax)dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\sinh^2(ax)$ ជាអនុគមន៍អ៊ីពែបូលីកកំណត់លើ $\mathbb{R}$ ។

យើងនឹងគណនាអាំងតេក្រាល $\int \sinh^2(ax)dx$ តាមករណីពីរគឺ $a=0$ និង $a\neq 0$។

- ករណី $a=0$ នាំឱ្យ

$$\int \sinh^2(ax)dx = \int \sinh^2(0)dx = \int\left(\frac{e^0-e^{-0}}{2}\right)^2 dx = \int 0\,dx = c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a\neq 0$ នាំឱ្យ

$$\int \sinh^2(ax)dx = \int\left(\frac{e^{ax}-e^{-ax}}{2}\right)^2 dx$$

$$=\frac{1}{4}\int\left((e^{ax})^2-2e^{ax}e^{-ax}+(e^{-ax})^2\right)dx$$

$$=\frac{1}{4}\int\left(e^{2ax}-2+e^{-2ax}\right)dx$$

$$=\frac{1}{4}\left[\frac{1}{2a}e^{2ax}-2x+\frac{1}{(-2a)}e^{-2ax}\right]+c$$

$$=\frac{1}{4a}\sinh(2ax)-\frac{x}{2}+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int \sinh^2(ax)dx = \frac{1}{4a}\sinh(2ax)-\frac{x}{2}+c} \quad (8.3)$$

ដែល $c$ ជាចំនួនពិតថេរ

**ឧទាហរណ៍ទី៨** គណនា $\int \sinh^2(2x)dx$ និង $\int \sinh^2\left(\frac{3x}{2}\right)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.3) យើងបាន៖

$$\int \sinh^2(2x)dx = \frac{1}{4\cdot 2}\sinh(2\cdot 2x)-\frac{x}{2}+c$$

$$=\frac{1}{8}\sinh(4x)-\frac{x}{2}+c$$

និង $$\int \sinh^2\left(\frac{3x}{2}\right)dx=\frac{1}{4(3/2)}\sinh\left(2(3/2)x\right)-\frac{x}{2}+c$$

$$=\frac{1}{6}\sinh(3x)-\frac{x}{2}+c$$ ។

**ឧទាហរណ៍ទី៩** គណនា $\int \sinh^2(3y-5)dy$ និង $\int_0^2 t\sinh^2\left(\frac{5t^2+4}{2}\right)dt$ ។

ដំណោះស្រាយ

តាង $u=3y-5$ នាំឱ្យ $du=3dy$ និង $dy=\frac{du}{3}$ ។

នាំឱ្យ $$\int \sinh^2(3y-5)dy=\int \sinh^2 u\frac{du}{3}=\frac{1}{3}\int \sinh^2 u\,du$$

$$=\frac{1}{3}\left[\frac{1}{4}\sinh(2u)-\frac{u}{2}\right]+c_1$$ ( តាមរូបមន្ត (8.3) )

$$=\frac{1}{12}\sinh\left(2(3y-5)\right)-\frac{(3y-5)}{6}+c_1$$

$$=\frac{1}{12}\sinh(6y-10)-\frac{y}{2}+c$$ ។

ចំពោះ $\int_0^2 t\sinh^2\left(\frac{5t^2+4}{2}\right)dt$ យើងតាង $u=\frac{5t^2+4}{2}$ នាំឱ្យ $du=5t\,dt$ និង $t\,dt=\frac{du}{5}$ ។

ពេល $t=0$ នោះ $u=\frac{5t^2+4}{2}=2$ និងពេល $t=2$ នោះ $u=\frac{5t^2+4}{2}=12$ ។

នាំឱ្យ $$\int_0^2 t\sinh^2\left(\frac{5t^2+4}{2}\right)dt=\int_2^{12}\sinh^2 u\left(\frac{du}{5}\right)=\frac{1}{5}\int_2^{12}\sinh^2 u\,du$$

$$=\frac{1}{5}\left(\frac{1}{4}\sinh(2u)-\frac{u}{2}\right)\Bigg|_2^{12}$$ ( តាមរូបមន្ត (8.3) )

$$=\frac{1}{5}\left(\frac{1}{4}\sinh(2\cdot 12)-\frac{12}{2}\right)-\frac{1}{5}\left(\frac{1}{4}\sinh(2\cdot 2)-\frac{2}{2}\right)$$

$$=\frac{1}{20}\sinh 24-\frac{1}{20}\sinh 4-1\approx 662228050.9$$ ។

## ៨.៥ ប្រភេទអាំងតេក្រាលមានរាង $\int \cosh^2(ax)dx$

អាំងតេក្រាល $\int \cosh^2(ax)dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\cosh^2(ax)$ ជាអនុគមន៍អ៊ីពែបូលីកកំណត់លើ $\mathbb{R}$។

យើងនឹងគណនាអាំងតេក្រាល $\int \cosh^2(ax)dx$ តាមករណីពីរគឺ $a=0$ និង $a\neq 0$។

- ករណី $a=0$ នាំឱ្យ

$$\int \cosh^2(ax)dx = \int \cosh^2(0)dx = \int \left(\frac{e^0+e^{-0}}{2}\right)^2 dx = \int 1dx = x+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a\neq 0$ នាំឱ្យ

$$\int \cosh^2(ax)dx = \int \left(\frac{e^{ax}+e^{-ax}}{2}\right)^2 dx$$

$$= \frac{1}{4}\int \left((e^{ax})^2 + 2e^{ax}e^{-ax} + (e^{-ax})^2\right)dx$$

$$= \frac{1}{4}\int \left(e^{2ax} + 2 + e^{-2ax}\right)dx$$

$$= \frac{1}{4}\left[\frac{1}{2a}e^{2ax} + 2x + \frac{1}{(-2a)}e^{-2ax}\right] + c$$

$$= \frac{1}{4a}\sinh(2ax) + \frac{x}{2} + c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int \cosh^2(ax)dx = \frac{1}{4a}\sinh(2ax) + \frac{x}{2} + c} \quad (8.4)$$

ដែល $c$ ជាចំនួនពិតថេរ

**ឧទាហរណ៍ទី១០** គណនា $\int \cosh^2(7x)dx$ និង $\int \cosh^2\left(-\frac{9x}{4}\right)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.4) យើងបាន៖

$$\int \cosh^2(7x)dx = \frac{1}{4\cdot 7}\sinh(2\cdot 7x) + \frac{x}{2} + c$$

$$= \frac{1}{28}\sinh(14x) + \frac{x}{2} + c$$

និង $$\int \cosh^2\left(-\frac{9x}{4}\right)dx = \frac{1}{4(-9/4)}\sinh(2(-9/4)x) + \frac{x}{2} + c$$

$$= -\frac{1}{9}\sinh\left(\frac{-9x}{2}\right) + \frac{x}{2} + c \text{ ។}$$

**ឧទាហរណ៍ទី១១** គណនា $\int_0^1 \cosh^2(4y-7)\,dy$ និង $\int_0^2 (2t-3)\cosh^2(2t^2-6t+5)dt$ ។

ដំណោះស្រាយ

តាង $u = 4y-7$ នាំឱ្យ $du = 4dy$ និង $dy = \frac{du}{4}$ ។

ពេល $y=0$ នោះ $u = 4y-7 = -7$ និងពេល $y=1$ នោះ $u = 4y-7 = -3$ ។

នាំឱ្យ $$\int_0^1 \cosh^2(4y-7)\,dy = \int_{-7}^{-3} \cosh^2 u \frac{du}{4} = \frac{1}{4}\int_{-7}^{-3} \cosh^2 u\,du$$

$$= \frac{1}{4}\left[\frac{1}{4}\sinh(2u) + \frac{u}{2}\right]\Bigg|_{-7}^{-3} \text{ (តាមរូបមន្ត (8.4) )}$$

$$= \frac{1}{4}\left[\frac{1}{4}\sinh(-6) + \frac{-3}{2}\right] - \frac{1}{4}\left[\frac{1}{4}\sinh(-14) + \frac{-7}{2}\right]$$

$$= \frac{1}{16}\sinh(-6) - \frac{1}{16}\sinh(-14) + \frac{1}{2} \approx 37569.2768 \text{ ។}$$

ចំពោះ $\int_0^2 (2t-3)\cosh^2(2t^2-6t+5)dt$ យើងតាង $u = 2t^2-6t+5$ នាំឱ្យ

$du = (4t-6)dt = 2(2t-3)dt$ និង $(2t-3)dt = \frac{du}{2}$ ។ ពេល $t=0$ នោះ

$u = 2t^2-6t+5 = 5$ និងពេល $t=2$ នោះ $u = 2t^2-6t+5 = 1$ ។ នាំឱ្យ

$$\int_0^2 (2t-3)\cosh^2\left(2t^2-6t+5\right)dt = \int_5^1 \cosh^2 u \left(\frac{du}{2}\right) = \frac{1}{2}\int_5^1 \cosh^2 u\ du$$

$$= \frac{1}{2}\left(\frac{1}{4}\sinh(2u) + \frac{u}{2}\right)\Bigg|_5^1 \text{ (តាមរូបមន្ត (8.4) )}$$

$$= \frac{1}{2}\left(\frac{1}{4}\sinh(2) + \frac{1}{2}\right) - \frac{1}{2}\left(\frac{1}{4}\sinh(10) + \frac{5}{2}\right)$$

$$= \frac{1}{8}\sinh 2 - \frac{1}{8}\sinh 10 - 1 \approx -1377.2007 \text{ ។}$$

## ៨.៦ ប្រភេទអាំងតេក្រាលមានរាង $\int \tanh(ax)\,dx$

អាំងតេក្រាល $\int \tanh(ax)\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\tanh(ax)$ ជាអនុគមន៍តង់ហ្សង់អ៊ីពែបូលីកកំណត់លើ $\mathbb{R}$ ។

យើងនឹងគណនាអាំងតេក្រាល $\int \tanh(ax)\,dx$ តាមករណីពីរគឺ $a=0$ និង $a \neq 0$ ។

- ករណី $a=0$ នាំឱ្យ

$$\int \tanh(ax)\,dx = \int \tanh(0)\,dx = \int \frac{\sinh(0)}{\cosh(0)}dx = \int 0\,dx = c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a \neq 0$ នាំឱ្យ

$$\int \tanh(ax)\,dx = \int \frac{\sinh(ax)}{\cosh(ax)}dx \quad (*) \text{ ។}$$

តាង $u = \cosh(ax) = \dfrac{e^{ax}+e^{-ax}}{2}$ នាំឱ្យ $du = \dfrac{ae^{ax}+(-a)e^{-ax}}{2}dx = a\left(\dfrac{e^{ax}-e^{-ax}}{2}\right)dx$ $= a\sinh(ax)dx$ និង $\sinh(ax)dx = \dfrac{du}{a}$ ។

តាមសមីការ $(*)$ យើងបាន៖

$$\int \tanh(ax)\,dx = \int \frac{1}{u}\cdot\frac{du}{a} = \frac{1}{a}\int \frac{du}{u}$$

$$= \frac{1}{a}\ln|u| + c = \frac{1}{a}\ln|\cosh(ax)| + c$$

$$=\frac{1}{a}\ln\left(\cosh\left(a\,x\right)\right)+c$$

( ពីព្រោះ $\cosh\left(a\,x\right)=\dfrac{e^{a\,x}+e^{-a\,x}}{2}>0\,,\forall x\in\mathbb{R}$ ) ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int\tanh\left(a\,x\right)\,dx=\frac{1}{a}\ln\left(\cosh\left(a\,x\right)\right)+c}\quad (8.5)$$

ដែល $c$ ជាចំនួនពិតថេរ

**ឧទាហរណ៍ទី១២** គណនា $\int\tanh\left(3x\right)\,dx$ និង $\int_0^1\tanh\left(\dfrac{5x}{3}\right)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.5) យើងបាន៖

$$\int\tanh\left(3x\right)\,dx=\frac{1}{3}\ln\left(\cosh\left(3x\right)\right)+c$$

និង $$\int_0^1\tanh\left(\frac{5x}{3}\right)dx=\frac{1}{(5/3)}\ln\left(\cosh\left(\frac{5x}{3}\right)\right)\Bigg|_0^1$$

$$=\frac{3}{5}\ln\left(\cosh\left(\frac{5}{3}\right)\right)-\frac{3}{5}\ln\left(\cosh\left(0\right)\right)$$

$$=\frac{3}{5}\ln\left(\cosh\left(\frac{5}{3}\right)\right)\approx 0.6051 \text{ ។}$$

**ឧទាហរណ៍ទី១៣** គណនា $\int\tanh\left(3t-5\right)\,dt$ និង $\int_{-1}^1 u^2\tanh\left(4u^3+7\right)\,du$ ។

ដំណោះស្រាយ

តាង $u=3t-5$ នាំឱ្យ $du=3dt$ និង $dt=\dfrac{du}{3}$ ។

នាំឱ្យ $$\int\tanh\left(3t-5\right)\,dt=\int\tanh u\,\frac{du}{3}=\frac{1}{3}\int\tanh u\,du$$

$$=\frac{1}{3}\ln\left(\cosh u\right)+c \quad \text{( តាមរូបមន្ត (8.5) )}$$

$$=\frac{1}{3}\ln\left(\cosh\left(3t-5\right)\right)+c \text{ ។}$$

ចំពោះ $\int_{-1}^{1} u^2 \tanh\left(4u^3+7\right) du$ យើងតាង $t=4u^3+7$ នាំឱ្យ $dt=12u^2\,du$ និង $u^2\,du=\dfrac{dt}{12}$ ។ ពេល $u=-1$ នោះ $t=4u^3+7=3$ និងពេល $u=1$ នោះ $t=4u^3+7=11$ ។

នាំឱ្យ $$\int_{-1}^{1} u^2 \tanh\left(4u^3+7\right) du=\int_{3}^{11}\tanh t\,\frac{dt}{12}=\frac{1}{12}\int_{3}^{11}\tanh t\,dt$$

$$=\frac{1}{12}\ln\left(\cosh t\right)\Big|_{3}^{11}$$ ( តាមរូបមន្ត (8.5) )

$$=\frac{1}{12}\ln\left(\cosh 11\right)-\frac{1}{12}\ln\left(\cosh 3\right)\approx 0.6664$$ ។

# ៨.៧ ប្រភេទអាំងតេក្រាលមានរាង $\int \coth(ax)\,dx$

អាំងតេក្រាល $\int \coth(ax)\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\coth(ax)$ ជាអនុគមន៍កូតង់ហ្សង់អ៊ីពែបូលីកកំណត់ចំពោះ $x\neq 0$ ។

យើងនឹងគណនាអាំងតេក្រាល $\int \coth(ax)\,dx$ ចំពោះ $a\neq 0$ ។

យើងមាន $\int \coth(ax)\,dx=\int \dfrac{\cosh(ax)}{\sinh(ax)}dx \quad (*)$ ។

តាង $u=\sinh(ax)=\dfrac{e^{ax}-e^{-ax}}{2}$ នាំឱ្យ $du=\dfrac{ae^{ax}-(-a)e^{-ax}}{2}dx=a\left(\dfrac{e^{ax}+e^{-ax}}{2}\right)dx$ $=a\cosh(ax)\,dx$ និង $\cosh(ax)\,dx=\dfrac{du}{a}$ ។

តាមសមីការ $(*)$ យើងបាន៖

$$\int \coth(ax)\,dx=\int \frac{1}{u}\cdot\frac{du}{a}=\frac{1}{a}\int\frac{du}{u}$$

$$=\frac{1}{a}\ln|u|+c=\frac{1}{a}\ln\left|\sinh(ax)\right|+c$$

ដែល $c$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\int \coth(ax)\,dx = \frac{1}{a}\ln\left|\sinh(ax)\right| + c \quad (8.6)$$

ដែល $c$ ជាចំនួនពិតថេរ

**ឧទាហរណ៍ទី១៤** គណនា $\int \coth(-5x)\,dx$ និង $\int_1^2 \coth\left(\frac{8x}{5}\right)dx$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.6) យើងបាន៖

$$\int \coth(-5x)\,dx = -\frac{1}{5}\ln\left|\sinh(-5x)\right| + c$$

និង $$\int_1^2 \coth\left(\frac{8x}{5}\right)dx = \frac{1}{(8/5)}\ln\left|\sinh\left(\frac{8x}{5}\right)\right|\Bigg|_1^2$$

$$= \frac{5}{8}\ln\left(\sinh\left(\frac{16}{5}\right)\right) - \frac{5}{8}\ln\left(\sinh\left(\frac{8}{5}\right)\right) \approx 1.0249 \text{ ។}$$

**ឧទាហរណ៍ទី១៥** គណនា $\int \coth(12x+123)\,dx$ និង $\int_0^1 t^4\coth\left(2t^5+7\right)dt$ ។

ដំណោះស្រាយ

តាង $u = 12x + 123$ នាំឱ្យ $du = 12dx$ និង $dx = \frac{du}{12}$ ។

នាំឱ្យ $$\int \coth(12x+123)\,dx = \int \coth u\,\frac{du}{12} = \frac{1}{12}\int \coth u\,du$$

$$= \frac{1}{12}\ln\left|\sinh u\right| + c \quad (\text{តាមរូបមន្ត } (8.6))$$

$$= \frac{1}{12}\ln\left|\sinh(12x+123)\right| + c \text{ ។}$$

ចំពោះ $\int_0^1 t^4\coth\left(2t^5+7\right)dt$ យើងតាង $u = 2t^5+7$ នាំឱ្យ $du = 10t^4\,dt$ និង $\frac{du}{10} = t^4\,dt$ ។ ពេល $t=0$ នោះ $u = 2t^5+7 = 7$ និងពេល $t=1$ នោះ $u = 2t^5+7 = 9$ ។

នាំឱ្យ $$\int_0^1 t^4\coth\left(2t^5+7\right)dt = \int_7^9 \coth u\,\frac{du}{10} = \frac{1}{10}\int_7^9 \coth u\,du$$

$$=\frac{1}{10}\ln\left|\sinh u\right|\Big|_7^9$$ (តាមរូបមន្ត (8.6) )

$$=\frac{1}{10}\ln\left|\sinh 9\right|-\frac{1}{10}\ln\left|\sinh 7\right|$$

$$=\frac{1}{10}\ln\left|\frac{\sinh 9}{\sinh 7}\right|\approx 0.2000$$ ។

## ៨.៨ ប្រភេទអាំងតេក្រាលមានរាង $\int \operatorname{sech}(ax)\,dx$

អាំងតេក្រាល $\int \operatorname{sech}(ax)\,dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\operatorname{sech}(ax)$ ជាអនុគមន៍សេកង់អ៊ីពែបូលីកកំណត់លើ $\mathbb{R}$ ។

យើងនឹងគណនាអាំងតេក្រាល $\int \operatorname{sech}(ax)\,dx$ តាមករណីពីរគឺ $a=0$ និង $a\neq 0$ ។

យើងមាន $\operatorname{sech}(ax)=\dfrac{1}{\cosh(ax)}=\dfrac{2}{e^{ax}+e^{-ax}}=\dfrac{2e^{ax}}{\left(e^{ax}\right)^2+1}$ ។

- ករណី $a=0$ នាំឱ្យ

$$\int \operatorname{sech}(ax)\,dx=\int \operatorname{sech}(0)\,dx=\int \frac{2}{e^0+e^0}dx=\int 1dx=x+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a\neq 0$ យើងតាង $t=e^{ax}$ នាំឱ្យ $dt=ae^{ax}\,dx$ និង $e^{ax}\,dx=\dfrac{dt}{a}$ ។

នាំឱ្យ $\displaystyle\int \operatorname{sech}(ax)\,dx=\int \frac{2e^{ax}\,dx}{\left(e^{ax}\right)^2+1}=\int \frac{2}{t^2+1}\cdot\frac{dt}{a}$

$$=\frac{2}{a}\int\frac{dt}{t^2+1}=\frac{2}{a}\arctan t+c$$

$$=\frac{2}{a}\arctan e^{ax}+c$$

ដែល $c$ ជាចំនួនពិតថេរ។

ម្យ៉ាងទៀត យើងមាន $\cosh^2(ax)-\sinh^2(ax)=1$ នាំឱ្យ $\cosh^2(ax)=\sinh^2(ax)+1$ ។

នាំឱ្យ $\displaystyle\int \operatorname{sech}(ax)\,dx=\int\frac{1}{\cosh(ax)}\,dx=\int\frac{\cosh(ax)}{\cosh^2(ax)}\,dx$

$$=\int \frac{\cosh(ax)}{\sinh^2(ax)+1}\,dx \quad (*)$$ ។

បន្ទាប់មក យើងតាង $t=\sinh(ax)=\frac{e^{ax}-e^{-ax}}{2}$ នាំឱ្យ $dt=\frac{ae^{ax}-(-a)e^{-ax}}{2}dx$
$=a\left(\frac{e^{ax}+e^{-ax}}{2}\right)dx=a\cosh(ax)dx$ និង $\cosh(ax)dx=\frac{dt}{a}$ ។

តាមសមីការ $(*)$ យើងបាន៖

$$\int \operatorname{sech}(ax)\,dx=\int \frac{\cosh(ax)}{\sinh^2(ax)+1}\,dx=\int \frac{1}{t^2+1}\,\frac{dt}{a}$$

$$=\frac{1}{a}\int \frac{dt}{t^2+1}=\frac{1}{a}\arctan t+c_1$$

$$=\frac{1}{a}\arctan\left(\sinh(ax)\right)+c_1$$

ដែល $c_1$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int \operatorname{sech}(ax)\,dx=\frac{2}{a}\arctan e^{ax}+c=\frac{1}{a}\arctan\left(\sinh(ax)\right)+c_1} \quad (8.7)$$

ដែល $c\,,c_1$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១៦** គណនា $\int \operatorname{sech}(6x)\,dx$ និង $\int_0^1 \operatorname{sech}\left(\frac{-3t}{2}\right)dt$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.7) យើងបាន៖

$$\int \operatorname{sech}(6x)\,dx=\frac{2}{6}\arctan e^{6x}+c=\frac{1}{3}\arctan e^{6x}+c$$

និង $$\int_0^1 \operatorname{sech}\left(\frac{-3t}{2}\right)dt=\frac{2}{(-3/2)}\arctan e^{-\frac{3t}{2}}\Bigg|_0^1$$

$$=-\frac{4}{3}\arctan e^{-\frac{3}{2}}+\frac{4}{3}\arctan e^{0}$$

$$= -\frac{4}{3}\arctan e^{-\frac{3}{2}} + \frac{4}{3}\cdot\frac{\pi}{4}$$

$$= -\frac{4}{3}\arctan e^{-\frac{3}{2}} + \frac{\pi}{3} \approx 0.7544$$ ។

**ឧទាហរណ៍ទី១៧** គណនា $\int_{-\infty}^{+\infty} \operatorname{sech}(9x-15)\,dx$ និង $\int_{0}^{+\infty} t^2 \operatorname{sech}\left(-2t^3+17\right) dt$ ។

ដំណោះស្រាយ

តាង $u = 9x - 15$ នាំឱ្យ $du = 9dx$ និង $dx = \frac{du}{9}$ ។ ពេល $x \to +\infty$ នោះ $u \to +\infty$ និងពេល $x \to -\infty$ នោះ $u \to -\infty$ ។ នាំឱ្យ

$$\int_{-\infty}^{+\infty} \operatorname{sech}(9x-15)\,dx = \int_{-\infty}^{+\infty} \operatorname{sech} u\,\frac{du}{9} = \frac{1}{9}\int_{-\infty}^{+\infty} \operatorname{sech} u\,du$$

$$= \frac{1}{9}\lim_{N\to-\infty}\int_{N}^{0} \operatorname{sech} u\,du + \frac{1}{9}\lim_{M\to+\infty}\int_{0}^{M} \operatorname{sech} u\,du$$

$$= \frac{2}{9}\lim_{N\to-\infty} \arctan e^{u}\Big|_{N}^{0} + \frac{2}{9}\lim_{M\to+\infty} \arctan e^{u}\Big|_{0}^{M}$$ ( រូបមន្ត (8.7) )

$$= \frac{2}{9}\lim_{N\to-\infty}\left(\arctan e^{0} - \arctan e^{N}\right) + \frac{2}{9}\lim_{M\to+\infty}\left(\arctan e^{M} - \arctan e^{0}\right)$$

$$= \frac{2}{9}\left(\frac{\pi}{4} - \arctan 0\right) + \frac{2}{9}\left(\arctan(+\infty) - \frac{\pi}{4}\right)$$

$$= \frac{\pi}{18} + \frac{2}{9}\cdot\frac{\pi}{2} - \frac{\pi}{18} = \frac{\pi}{9}$$ ។

ចំពោះ $\int_{0}^{+\infty} t^2 \operatorname{sech}\left(-2t^3+17\right) dt$ យើងតាង $u = -2t^3 + 17$ នាំឱ្យ $du = -6t^2 dt$ និង $t^2 dt = -\frac{du}{6}$ ។ ពេល $t = 0$ នោះ $u = -2t^3 + 17 = 17$ និងពេល $t \to +\infty$ នោះ $u \to -\infty$ ។

នាំឱ្យ $\int_{0}^{+\infty} t^2 \operatorname{sech}\left(-2t^3+17\right) dt = \int_{17}^{+\infty} \operatorname{sech} u \left(-\frac{du}{6}\right)$

$$= -\frac{1}{6}\int_{17}^{+\infty} \operatorname{sech} u\,du = -\frac{1}{6}\lim_{M\to+\infty}\int_{17}^{M} \operatorname{sech} u\,du$$

$$= -\frac{1}{6}\lim_{M\to+\infty} \arctan e^{u}\Big|_{17}^{M}$$ ( តាមរូបមន្ត (8.7) )

$$= -\frac{1}{6}\lim_{M\to+\infty}\left(\arctan e^{M} - \arctan 17\right)$$

$$= -\frac{1}{6}\left(\frac{\pi}{2} - \arctan e^{17}\right) \approx 0 \text{ ។}$$

## ៨.៩ ប្រភេទអាំងតេក្រាលមានរាង $\int \cos ech(ax)\, dx$

អាំងតេក្រាល $\int \cos ech(ax)\, dx$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\cos ech(ax)$ ជាអនុគមន៍កូសេកង់អ៊ីពែបូលីកកំណត់លើ $\mathbb{R}^*$ ដែល $a \neq 0$។

យើងនឹងគណនាអាំងតេក្រាល $\int \cos ech(ax)\, dx$ ដែល $a \neq 0$ ។

យើងមាន $\cos ech(ax) = \dfrac{1}{\sinh(ax)} = \dfrac{2}{e^{ax} - e^{-ax}} = \dfrac{2e^{ax}}{\left(e^{ax}\right)^2 - 1}$ ។

យើងតាង $t = e^{ax}$ នាំឱ្យ $dt = ae^{ax}dx$ និង $e^{ax}dx = \dfrac{dt}{a}$ ។

នាំឱ្យ $\int \cos ech(ax)\, dx = \int \dfrac{dx}{\sinh(ax)} = \int \dfrac{2e^{ax}dx}{\left(e^{ax}\right)^2 - 1}$

$$= \int \frac{2}{t^2-1}\cdot\frac{dt}{a} = \frac{2}{a}\int\frac{dt}{t^2-1}$$

$$= \frac{2}{a}\cdot\frac{1}{2}\ln\left|\frac{t-1}{t+1}\right| + c = \frac{1}{a}\ln\left|\frac{e^{ax}-1}{e^{ax}+1}\right| + c \quad (*) \text{ ។}$$

ម៉្យាងទៀត យើងមាន

$$\tanh\frac{ax}{2} = \frac{e^{ax/2} - e^{-ax/2}}{e^{ax/2} + e^{-ax/2}} = \frac{e^{ax}-1}{e^{ax}+1}$$

$$\frac{\cosh(ax)-1}{\sinh(ax)} = \frac{\dfrac{e^{ax}+e^{-ax}}{2} - 1}{\dfrac{e^{ax}-e^{-ax}}{2}} = \frac{e^{ax}+e^{-ax}-2}{e^{ax}-e^{-ax}}$$

ហើយ $\sqrt{\dfrac{\cosh(ax)-1}{\cosh(ax)+1}}=\sqrt{\dfrac{\dfrac{e^{ax}+e^{-ax}}{2}-1}{\dfrac{e^{ax}+e^{-ax}}{2}+1}}=\sqrt{\dfrac{e^{ax}+e^{-ax}-2}{e^{ax}+e^{-ax}+2}}$

$$=\sqrt{\frac{e^{2ax}+1-2e^{ax}}{e^{2ax}+1+2e^{ax}}}=\sqrt{\frac{\left(e^{ax}-1\right)^2}{\left(e^{ax}+1\right)^2}}=\frac{e^{ax}-1}{e^{ax}+1}$$ ។

ដូចនេះ តាមសមីការ $(*)$ និងចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\int \cos ech(ax)\,dx=\int\frac{dx}{\sinh(ax)}=\frac{1}{a}\ln\left|\frac{e^{ax}-1}{e^{ax}+1}\right|+c=\frac{1}{a}\ln\left|\tanh\frac{ax}{2}\right|+c$$
$$=\frac{1}{a}\ln\left|\frac{\cosh(ax)-1}{\sinh(ax)}\right|+c=\frac{1}{2a}\ln\left|\frac{\cosh(ax)-1}{\cosh(ax)+1}\right|+c \qquad (8.8)$$

ដែល $c$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី១៨** គណនា $\int \cos ech(7x)\,dx$ និង $\int_1^2 \dfrac{dx}{\sinh\left(\dfrac{5x}{2}\right)}$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.8) យើងបាន៖

$$\int \cos ech(7x)\,dx=\frac{1}{7}\ln\left|\tanh\frac{7x}{2}\right|+c$$

និង $\displaystyle\int_1^2 \frac{dx}{\sinh\left(\frac{5x}{2}\right)}=\frac{1}{(5/2)}\ln\left|\frac{e^{5x/2}-1}{e^{5x/2}+1}\right|\Bigg|_1^2$

$$=\frac{2}{5}\ln\left|\frac{e^5-1}{e^5+1}\right|-\frac{2}{5}\ln\left|\frac{e^{5/2}-1}{e^{5/2}+1}\right|$$

$$=\frac{2}{5}\ln\frac{\left(e^5-1\right)\left(e^{5/2}+1\right)}{\left(e^5+1\right)\left(e^{5/2}-1\right)}\approx 0.0604$$ ។

**ឧទាហរណ៍ទី១៩** គណនា $\int_0^{+\infty} \cos ech(8x+5)\,dx$ និង $\int_0^{+\infty} t^3\cos ech\left(-2t^4-3\right)dt$ ។

## ដំណោះស្រាយ

តាង $u=8x+5$ នាំឱ្យ $du=8dx$ និង $dx=\dfrac{du}{8}$ ។ ពេល $x\to+\infty$ នោះ $u\to+\infty$ និង ពេល $x=0$ នោះ $u=5$ ។

នាំឱ្យ $\displaystyle\int_0^{+\infty}\cos ech(8x+5)\,dx=\int_5^{+\infty}\cos echu\,\frac{du}{8}=\frac{1}{8}\int_5^{+\infty}\cos echu\,du$

$$=\frac{1}{8}\lim_{N\to+\infty}\int_5^{N}\cos ech\,u\,du$$

$$=\frac{1}{8}\lim_{N\to+\infty}\ln\left|\frac{e^u-1}{e^u+1}\right|\Bigg|_5^{N}\ (\text{តាមរូបមន្ត}\,(8.8)\,)$$

$$=\frac{1}{8}\lim_{N\to+\infty}\ln\left|\frac{e^N-1}{e^N+1}\right|-\ln\left|\frac{e^5-1}{e^5+1}\right|$$

$$=\frac{1}{8}\lim_{N\to+\infty}\ln\left|\frac{1-1/e^N}{1+1/e^N}\right|-\ln\left|\frac{e^5-1}{e^5+1}\right|$$

$$=-\frac{1}{8}\ln\frac{e^5-1}{e^5+1}\approx0.0016\ \text{។}$$

ចំពោះ $\displaystyle\int_0^{+\infty}t^3\cos ech\left(-2t^4-3\right)dt$ យើងតាង $u=-2t^4-3$ នាំឱ្យ $du=-8t^3\,dt$ និង $t^3\,dt=-\dfrac{du}{8}$ ។ ពេល $t=0$ នោះ $u=-2t^4-3=-3$ និងពេល $t\to+\infty$ នោះ $u\to-\infty$ ។

នាំឱ្យ $\displaystyle\int_0^{+\infty}t^3\cos ech\left(-2t^4-3\right)dt=\int_{-3}^{-\infty}\cos echu\left(-\frac{du}{8}\right)$

$$=\frac{1}{8}\int_{-\infty}^{-3}\cos echu\,du=\frac{1}{8}\lim_{M\to-\infty}\int_M^{-3}\cos echu\,du$$

$$=\frac{1}{8}\lim_{M\to-\infty}\ln\left|\frac{e^u-1}{e^u+1}\right|\Bigg|_M^{-3}\ (\text{តាមរូបមន្ត}\,(8.8)\,)$$

$$=\frac{1}{8}\lim_{M\to-\infty}\left[\ln\left|\frac{e^{-3}-1}{e^{-3}+1}\right|-\ln\left|\frac{e^M-1}{e^M+1}\right|\right]$$

$$=\frac{1}{8}\ln\left|\frac{e^{-3}-1}{e^{-3}+1}\right|=\frac{1}{8}\ln\left(\frac{1-e^{-3}}{1+e^{-3}}\right)\approx -0.0124$$ ។

## ៨.១០ ប្រភេទអាំងតេក្រាលមានរាង $\int\frac{dx}{\cosh^2(ax)}$

អាំងតេក្រាល $\int\frac{dx}{\cosh^2(ax)}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\cosh^2(ax)}$ ជាអនុគមន៍អ៊ីពែបូលីកកំណត់លើ $\mathbb{R}$ ។

យើងនឹងគណនាអាំងតេក្រាល $\int\frac{dx}{\cosh^2(ax)}$ តាមករណីពីរគឺ $a=0$ និង $a\neq 0$។

យើងមាន $\cosh^2(ax)=\left(\frac{e^{ax}+e^{-ax}}{2}\right)^2=\frac{1}{4}\left(e^{2ax}+2e^{ax}e^{-ax}+e^{-2ax}\right)$

$$=\frac{1}{4}\left(e^{2ax}+2+e^{-2ax}\right)$$

និង $\frac{1}{\cosh^2(ax)}=\frac{4}{e^{2ax}+2+e^{-2ax}}$ ។

- ករណី $a=0$ នាំឱ្យ

$$\int\frac{dx}{\cosh^2(ax)}=\int\frac{4}{e^{2ax}+2+e^{-2ax}}\,dx=\int dx=x+c$$

ដែល $c$ ជាចំនួនពិតថេរ។

- ករណី $a\neq 0$ យើងតាង $t=e^{2ax}$ នាំឱ្យ $2ax=\ln t$ , $x=\frac{\ln t}{2a}$ និង $dx=\frac{dt}{2at}$ ។

នាំឱ្យ $\int\frac{dx}{\cosh^2(ax)}=\int\frac{4}{e^{2ax}+2+e^{-2ax}}\,dx=\int\frac{4}{t+2+t^{-1}}\cdot\frac{dt}{2at}$

$$=\frac{2}{a}\int\frac{dt}{t^2+2t+1}=\frac{2}{a}\int\frac{dt}{(t+1)^2}$$

$$=\frac{2}{a}\int(t+1)^{-2}\,dt=\frac{2}{a}\cdot\frac{(t+1)^{-1}}{(-1)}+c$$

$$=-\frac{2}{a}\cdot\frac{1}{t+1}+c=\frac{1}{a}\left(-\frac{2}{e^{2ax}+1}\right)+c$$

$$=\frac{1}{a}\left[\tanh(ax)-1\right]+c=\frac{1}{a}\tanh(ax)+c_1$$

ពីព្រោះ $\tanh(ax)=\frac{e^{ax}-e^{-ax}}{e^{ax}+e^{-ax}}=\frac{e^{2ax}-1}{e^{2ax}+1}$

$$=\frac{\left(e^{2ax}+1\right)-2}{e^{2ax}+1}=1-\frac{2}{e^{2ax}+1}$$

នាំឱ្យ $-\frac{2}{e^{2ax}+1}=\tanh(ax)-1$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int\frac{dx}{\cosh^2(ax)}=-\frac{2}{a\left(e^{2ax}+1\right)}+c=\frac{1}{a}\tanh(ax)+c_1}\quad (8.9)$$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី២០** គណនា $\int\frac{dx}{\cosh^2(3x)}$ និង $\int_0^1\frac{dx}{\cosh^2(5x)}$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.9) យើងបាន៖

$$\int\frac{dx}{\cosh^2(3x)}=\frac{1}{3}\tanh(3x)+c_1$$

និង $\int_0^1\frac{dx}{\cosh^2(5x)}=-\frac{2}{5\left(e^{10x}+1\right)}\Bigg|_0^1=-\frac{2}{5\left(e^{10}+1\right)}+\frac{1}{5}\approx 0.1999$ ។

**ឧទាហរណ៍ទី២១** គណនា $\int_{-\infty}^{+\infty}\frac{dx}{\cosh^2(12x-123)}$ និង $\int_0^{+\infty}\frac{(t-1)\,dt}{\cosh^2\left(12t^2-24t\right)}$ ។

ដំណោះស្រាយ

តាង $u=12x-123$ នាំឱ្យ $du=12dx$ និង $dx=\frac{du}{12}$ ។ ពេល $x\to+\infty$ នោះ $u\to+\infty$ និងពេល $x\to-\infty$ នោះ $u\to-\infty$ ។

នាំឱ្យ $\int_{-\infty}^{+\infty}\frac{dx}{\cosh^2(12x-123)}=\int_{-\infty}^{+\infty}\frac{1}{\cosh^2 u}\cdot\frac{du}{12}=\frac{1}{12}\int_{-\infty}^{+\infty}\frac{du}{\cosh^2 u}$

$$=\frac{1}{12}\lim_{N\to-\infty}\int_N^0\frac{du}{\cosh^2 u}+\frac{1}{12}\lim_{M\to+\infty}\int_0^M\frac{du}{\cosh^2 u}$$

$$=\frac{1}{12}\lim_{N\to-\infty}\left.\frac{-2}{e^{2x}+1}\right|_N^0+\frac{1}{12}\lim_{M\to+\infty}\left.\frac{-2}{e^{2x}+1}\right|_0^M$$ ( រូបមន្ត (8.9) )

$$=\frac{1}{12}\lim_{N\to-\infty}\left(\frac{-2}{e^0+1}+\frac{2}{e^{2N}+1}\right)+\frac{1}{12}\lim_{M\to+\infty}\left(\frac{-2}{e^{2M}+1}+\frac{2}{e^0+1}\right)$$

$$=\frac{1}{12}(-1+2)+\frac{1}{12}(0+1)=\frac{1}{6}\approx 0.1666$$ ។

ចំពោះ $\int_0^{+\infty}\frac{(t-1)\,dt}{\cosh^2(12t^2-24t)}$ យើងតាង $u=12t^2-24t$ នាំឱ្យ $du=(24t-24)dt$ $=24(t-1)dt$ និង $(t-1)dt=\frac{du}{24}$ ។ ពេល $t=0$ នោះ $u=12t^2-24t=0$ និងពេល $t\to+\infty$ នោះ $u\to+\infty$ ។

នាំឱ្យ $\int_0^{+\infty}\frac{(t-1)\,dt}{\cosh^2(12t^2-24t)}=\int_0^{+\infty}\frac{1}{\cosh^2 u}\cdot\frac{du}{24}=\frac{1}{24}\int_0^{+\infty}\frac{du}{\cosh^2 u}$

$$=\frac{1}{24}\lim_{M\to+\infty}\int_0^M\frac{du}{\cosh^2 u}$$

$$=\frac{1}{24}\lim_{M\to+\infty}\left.\frac{-2}{e^{2x}+1}\right|_0^M$$ ( តាមរូបមន្ត (8.9) )

$$=\frac{1}{24}\lim_{M\to+\infty}\left(\frac{-2}{e^{2M}+1}-\frac{(-2)}{e^0+1}\right)$$

$$=\frac{1}{24}(0+1)=\frac{1}{24}\approx 0.0416$$ ។

## ៨.១១ ប្រភេទអាំងតេក្រាលមានរាង $\int\frac{dx}{\sinh^2(ax)}$

អាំងតេក្រាល $\int\frac{dx}{\sinh^2(ax)}$ ជាអាំងតេក្រាលមិនកំណត់ដែលមានអនុគមន៍អាំងតេក្រាល $\frac{1}{\sinh^2(ax)}$ ជាអនុគមន៍អ៊ីពែបូលីកកំណត់លើ $\mathbb{R}^*$ ដែល $a\neq 0$ ។

យើងនឹងគណនាអាំងតេក្រាល $\int\frac{dx}{\sinh^2(ax)}$ ដែល $a\neq 0$ ។

យើងមាន $\sinh^2(ax)=\left(\frac{e^{ax}-e^{-ax}}{2}\right)^2=\frac{1}{4}\left(e^{2ax}-2e^{ax}e^{-ax}+e^{-2ax}\right)$

$$=\frac{1}{4}\left(e^{2ax}-2+e^{-2ax}\right)$$

និង $\frac{1}{\sinh^2(ax)}=\frac{4}{e^{2ax}-2+e^{-2ax}}$ ។

យើងតាង $t=e^{2ax}$ នាំឱ្យ $2ax=\ln t$ , $x=\frac{\ln t}{2a}$ និង $dx=\frac{dt}{2at}$ ។

នាំឱ្យ $\int\frac{dx}{\sinh^2(ax)}=\int\frac{4}{e^{2ax}-2+e^{-2ax}}\,dx=\int\frac{4}{t-2+t^{-1}}\cdot\frac{dt}{2at}$

$$=\frac{2}{a}\int\frac{dt}{t^2-2t+1}=\frac{2}{a}\int\frac{dt}{(t-1)^2}$$

$$=\frac{2}{a}\int(t-1)^{-2}\,dt=\frac{2}{a}\cdot\frac{(t-1)^{-1}}{(-1)}+c$$

$$=-\frac{2}{a}\cdot\frac{1}{t-1}+c=-\frac{1}{a}\cdot\frac{2}{e^{2ax}-1}+c$$

$$=-\frac{1}{a}\left[\coth(ax)-1\right]+c=-\frac{1}{a}\coth(ax)+c_1$$

ពីព្រោះ $\coth(ax)=\frac{e^{ax}+e^{-ax}}{e^{ax}-e^{-ax}}=\frac{e^{2ax}+1}{e^{2ax}-1}$

$$=\frac{\left(e^{2ax}-1\right)+2}{e^{2ax}-1}=1+\frac{2}{e^{2ax}-1}$$

នាំឱ្យ $\frac{2}{e^{2ax}-1}=\coth(ax)-1$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ។

ដូចនេះ ចំពោះ $a\neq 0$ យើងបានរូបមន្ត

$$\boxed{\int\frac{dx}{\sinh^2(ax)}=-\frac{2}{a\left(e^{2ax}-1\right)}+c=-\frac{1}{a}\coth(ax)+c_1} \quad (8.10)$$

ដែល $c$ , $c_1$ ជាចំនួនពិតថេរ។

**ឧទាហរណ៍ទី២២** គណនា $\int \frac{dx}{\sinh^2(2x)}$ និង $\int_{0.5}^{1} \frac{dx}{\sinh^2(1.5x)}$ ។

ដំណោះស្រាយ

តាមរូបមន្ត (8.10) យើងបាន៖

$$\int \frac{dx}{\sinh^2(2x)} = -\frac{1}{2}\coth(2x) + c_1$$

និង $$\int_{0.5}^{1} \frac{dx}{\sinh^2(1.5x)} = -\frac{2}{1.5(e^{3x}-1)}\Bigg|_{0.5}^{1}$$

$$= -\frac{2}{1.5(e^3-1)} + \frac{2}{1.5(e^{1.5}-1)} \approx 0.3130 \text{ ។}$$

**ឧទាហរណ៍ទី២៣** គណនា $\int_0^{+\infty} \frac{dx}{\sinh^2(-8x-12)}$ និង $\int_0^{+\infty} \frac{(3e^t-5)\,dt}{\sinh^2(6e^t-10t+7)}$ ។

ដំណោះស្រាយ

តាង $u=-8x-12$ នាំឱ្យ $du=-8dx$ និង $dx=-\frac{du}{8}$ ។ ពេល $x \to +\infty$ នោះ $u \to -\infty$ និងពេល $x \to 0$ នោះ $u \to -12$ ។

នាំឱ្យ $$\int_0^{+\infty} \frac{dx}{\sinh^2(-8x-12)} = \int_{-12}^{-\infty} \frac{1}{\sinh^2 u}\cdot\left(-\frac{du}{8}\right) = -\frac{1}{8}\int_{-12}^{-\infty}\frac{du}{\sinh^2 u}$$

$$= \frac{1}{8}\int_{-\infty}^{-12}\frac{du}{\sinh^2 u} = \frac{1}{8}\lim_{N\to-\infty}\int_N^{-12}\frac{du}{\sinh^2 u}$$

$$= \frac{1}{8}\lim_{N\to-\infty}\frac{-2}{e^{2x}-1}\Bigg|_N^{-12} \text{ (តាមរូបមន្ត (8.10) )}$$

$$= \frac{1}{8}\lim_{N\to-\infty}\left(\frac{-2}{e^{-24}-1} + \frac{2}{e^{2N}-1}\right)$$

$$= \frac{1}{8}\left(\frac{-2}{e^{-24}-1} - 2\right) \text{ ។}$$

ចំពោះ $\int_0^{+\infty} \frac{(3e^t-5)\,dt}{\sinh^2(6e^t-10t+7)}$ យើងតាង $u=6e^t-10t+7$ នាំឱ្យ $du=(6e^t-10)dt$

$= 2\left(3e^t - 5\right)dt$ និង $\left(3e^t - 5\right)dt = \dfrac{du}{2}$ ។ ពេល $t = 0$ នោះ $u = 13$ និងពេល $t \to +\infty$ នោះ $u \to +\infty$ ។

នាំឱ្យ $\displaystyle\int_0^{+\infty} \frac{\left(3e^t - 5\right)dt}{\sinh^2\left(6e^t - 10t + 7\right)} = \int_{13}^{+\infty} \frac{1}{\sinh^2 u}\cdot\frac{du}{2} = \frac{1}{2}\int_{13}^{+\infty} \frac{du}{\sinh^2 u}$

$$= \frac{1}{2}\lim_{M\to+\infty}\int_{13}^{M}\frac{du}{\sinh^2 u}$$

$$= \frac{1}{2}\lim_{N\to+\infty}\left.\frac{-2}{e^{2x}-1}\right|_{13}^{N} \text{ (តាមរូបមន្ត (8.10) )}$$

$$= \frac{1}{2}\lim_{N\to+\infty}\left(\frac{-2}{e^{2N}-1} + \frac{2}{e^{26}-1}\right)$$

$$= \frac{1}{2}\left(0 + \frac{2}{e^{26}-1}\right) = \frac{1}{e^{26}-1} \text{ ។}$$

ជាសរុប ជំពូកទី៨នេះបានផ្តល់នូវនិយមន័យនិងលក្ខណៈនៃអនុគមន៍អ៊ីពែបូលីក ហើយនិងវិធីសាស្ត្រគណនាអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីកដែលមានទម្រង់ពិសេសមួយចំនួនដូចជា $\int \sinh(ax)\,dx$ , $\int \cosh(ax)\,dx$ , $\int \sinh^2(ax)\,dx$ , $\int \cosh^2(ax)\,dx$ , $\int \tanh(ax)\,dx$ , $\int \coth(ax)\,dx$ , $\int \mathrm{sec}h(ax)\,dx$ , $\int \mathrm{cos}ech(ax)\,dx$ , $\int \dfrac{dx}{\cosh^2(ax)}$ និង $\int \dfrac{dx}{\sinh^2(ax)}$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

# ការសន្និដ្ឋាន

ជារួមមកវិញ យើងឃើញថា ជំពូកទី១បានបង្ហាញនូវនិយមន័យនៃព្រីមីទីវនិងអាំងតេក្រាល ទ្រឹស្តីបទ រូបមន្តគ្រឹះ ហើយលក្ខណៈជាច្រើននៃអាំងតេក្រាលមិនកំណត់និងអាំងតេក្រាលកំណត់។ ជាងនេះទៅទៀត ជំពូកទី១នេះបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលមិនកំណត់ អាំងតេក្រាលកំណត់ និង អាំងតេក្រាល Improper តាមនិយមន័យ រូបមន្តងាយ វិធីប្តូរអថេរ និង វិធីអាំងតេក្រាលដោយផ្នែកដោយអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំណែកឯជំពូកទី២បានផ្តល់នូវវិធីសាស្ត្រនៃការបំបែកអនុគមន៍សនិទានក្នុង $\mathbb{R}$ និងវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍សនិទានមួយចំនួនដូចជា $\int \frac{1}{(ax+b)^n}dx$, $\int \frac{dx}{x^2 \pm a^2}$, $\int \frac{dx}{ax^2+bx+c}$, $\int \frac{(a_1x+b_1)\,dx}{ax^2+bx+c}$, $\int \frac{dx}{(x^2+a^2)^m}$ និង $\int \frac{dx}{(x^2-a^2)^m}$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំពោះជំពូកទី៣បានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍អសនិទានមួយចំនួនដូចជា $\int\frac{1}{\sqrt[n]{ax+b}}dx$, $\int\sqrt[n]{ax+b}\,dx$, $\int\sqrt[n]{(ax+b)^m}\,dx$, $\int\frac{1}{\sqrt{k-x^2}}dx$, $\int\frac{1}{\sqrt{x^2+k}}dx$, $\int\frac{1}{\sqrt{x^2-k}}dx$, $\int\sqrt{k-x^2}\,dx$, $\int\sqrt{x^2+k}\,dx$, $\int\sqrt{x^2-k}\,dx$, $\int(\alpha x+\beta)\sqrt{ax+b}\,dx$, $\int\frac{dx}{(\alpha x+\beta)\sqrt{ax+b}}$, $\int\frac{dx}{\sqrt{ax^2+bx+c}}$, $\int\sqrt{ax^2+bx+c}\,dx$ និង $\int\frac{(\alpha x+\beta)dx}{\sqrt{ax^2+bx+c}}$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំពោះជំពូកទី៤បានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលមួយចំនួនដូចជា $\int a^{\alpha x+\beta}dx$, $\int e^{\alpha x+\beta}dx$, $\int\frac{dx}{p+qa^{\alpha x}}$, $\int\frac{dx}{(p+qa^{\alpha x})^2}$, $\int\frac{a^{2\alpha x}dx}{p+qa^{\alpha x}}$, $\int\frac{dx}{pa^{\alpha x}+qa^{-\alpha x}}$,

$\int_{0}^{+\infty} e^{-ax^2}dx$ , $\int_{-\infty}^{+\infty} e^{-ax^2}dx$ , $\int_{\mu}^{+\infty} \frac{1}{\sigma\sqrt{2\pi}} e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2} dx$ , $\int_{-\infty}^{+\infty} \frac{1}{\sigma\sqrt{2\pi}} e^{-\frac{1}{2}\left(\frac{x-\mu}{\sigma}\right)^2} dx$ , $\int_{-\infty}^{+\infty} e^{-(ax^2+bx+c)}dx$ , $\int_{-\infty}^{+\infty} e^{-ax^2}e^{-2bx}dx$ និង $\int_{-b/2a}^{+\infty} e^{-(ax^2+bx+c)}dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំណែកឯជំពូកទី៥បានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលនៃអនុគមន៍លោការីត និងអាំងតេក្រាលមានអនុគមន៍លោការីតមួយចំនួនដូចជា $\int \log_a(px+q)dx$ , $\int \log_a|px+q|dx$ , $\int \log_a^2(px+q)dx$ , $\int \log_a^2|px+q|dx$ , $\int \log_a(x^2+b^2)dx$ និង $\int \log_a(x^2-b^2)dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំពោះជំពូកទី៦បានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលមានអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលនិងអនុគមន៍ស្វ័យគុណដែលមានទម្រង់ពិសេសមួយចំនួនដូចជា $\int xe^{\alpha x}dx$ , $\int xa^{\alpha x}dx$ , $\int x^2e^{\alpha x}dx$ , $\int x^2a^{\alpha x}dx$ , $\int x^n e^{\alpha x}dx$ , $\int x^{-1}e^{\alpha x}dx$ , $\int xe^{\alpha x^2}dx$ , $\int xa^{\alpha x^2}dx$ , $\int_{-\infty}^{+\infty} xe^{\alpha x^2}dx$ , $\int_{0}^{+\infty} xe^{\alpha x^2}dx$ , $\int x^{-2}e^{-\alpha x^2}dx$ , $\int_{-\infty}^{+\infty} xe^{-a(x-b)^2}dx$ , $\int_{-\infty}^{+\infty} xe^{-ax^2+bx}dx$ , $\int_{-\infty}^{+\infty} x^2e^{-ax^2}dx$ , $\int_{-\infty}^{+\infty} x^2e^{-ax^2-bx}dx$ និង $\int_{-\infty}^{+\infty} x^3e^{-ax^2+bx}dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំពោះជំពូកទី៧វិញបានផ្តល់នូវវិធីសាស្ត្រគណនាអាំងតេក្រាលមានអនុគមន៍លោការីតនិងអនុគមន៍ស្វ័យគុណដែលមានទម្រង់ពិសេសមួយចំនួនដូចជា $\int x^m \ln x\,dx$ ,

$\int\frac{(\ln(ax))^n}{x}dx$, $\int\frac{\ln(ax)^n}{x}dx$, $\int\frac{\ln(ax)}{x^m}dx$, $\int\frac{dx}{x[\ln(ax)]^n}$, $\int\frac{dx}{x^m\ln x}$, $\int x^m(\ln x)^n\,dx$ និង $\int\frac{x^m}{(\ln x)^n}dx$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ចំពោះជំពូកទី៨បានផ្តល់នូវនិយមន័យនិងលក្ខណៈនៃអនុគមន៍អ៊ីពែបូលីកហើយនិងវិធីសាស្ត្រគណនាអាំងតេក្រាលមានអនុគមន៍អ៊ីពែបូលីកដែលមានទម្រង់ពិសេសមួយចំនួន ដូចជា $\int\sinh(ax)\,dx$, $\int\cosh(ax)\,dx$, $\int\sinh^2(ax)\,dx$, $\int\cosh^2(ax)\,dx$, $\int\tanh(ax)\,dx$, $\int\coth(ax)\,dx$, $\int\operatorname{sec}h(ax)\,dx$, $\int\operatorname{cos}ech(ax)\,dx$, $\int\frac{dx}{\cosh^2(ax)}$ និង $\int\frac{dx}{\sinh^2(ax)}$ ដោយបង្កើតជារូបមន្តដើម្បីយកមកប្រើប្រាស់ជាលក្ខណៈទូទៅនិងបានអនុវត្តន៍លើឧទាហរណ៍មួយចំនួន។

ជាទីបញ្ចប់នេះ យើងខ្ញុំយល់ឃើញថាការសិក្សាស្រាវជ្រាវទៅលើប្រធានបទអំពី << **សិក្សាប្រភេទអាំងតេក្រាលមួយចំនួនក្នុងវិស័យគណិតវិទ្យានិងវិទ្យាសាស្ត្រ** >> បានផ្តល់នូវផលប្រយោជន៍ជាច្រើនទាំងខាងទ្រឹស្តីនិងការអនុវត្តគណនាវា។ ជាងនេះទៅទៀត យើងខ្ញុំបានទទួលនូវគំនិតថ្មីនិងចំណេះដឹងថ្មីដែលកើតចេញអំពីប្រធានបទនៃអត្ថបទស្រាវជ្រាវនេះ និងយើងខ្ញុំសង្ឃឹមថា សៀវភៅស្រាវជ្រាវនេះជាឯកសារដ៏សំខាន់មួយសម្រាប់ជួយដល់សិស្សនិស្សិត លោកគ្រូ និង អ្នកគ្រូដែលមានបញ្ហាខ្លះៗទាក់ទងនឹងការគណនាអាំងតេក្រាលទាំងកម្រិតមធ្យមសិក្សានិងឧត្តមសិក្សា។

# ឯកសារយោង


១. យឹម អាយុវឌ្ឍនៈវិជ្ជា "*អាំងតេក្រាលមិនកំណត់*" ភ្នំពេញ ឆ្នាំ១៩៩៧។

២. យឹម អាយុវឌ្ឍនៈវិជ្ជា "*អាំងតេក្រាលកំណត់*" ភ្នំពេញ ឆ្នាំ១៩៩៩។

៣. សួន សូវ៉ាន់ "*វិភាគចំនួនពិត ភាគ១*" ដេប៉ាតឺម៉ង់គណិតវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ភ្នំពេញ ឆ្នាំ២០០៧។

៤. ក្រុមអ្នកនិពន្ធ "*គណិតវិទ្យា ថ្នាក់ទី១២*" បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និងកីឡា ភ្នំពេញ ឆ្នាំ២០១០។

៥. http://en.wikipedia.org/wiki/List_of_integrals_of_hyperbolic_functions

៦. http://archives.math.utk.edu/visual.calculus/4/improper.2/

៧. Herbert Bristol Dwight, *Tables of Integrals and Other Mathematical Data*, New York, Macmillan Company, Third Edition, 1957.

៨. Karl Smith, *Student Mathematics Handbook and Integral Table for Calculus*, United States of America, Prentice-Hall, Inc., Third Edition, 2002.

